

# ពង្រឹងការចូលរួម
# ដើម្បីសម្រេចនូវលទ្ធផលនៃការអភិវឌ្ឍ

## មគ្គុទេសក៍ស្តីពីការចូលរួមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

Asian Development Bank

ADB

# ពង្រឹងការចូលរួមដើម្បីសម្រេច នូវលទ្ធផលនៃការអភិវឌ្ឍ

## មគ្គុទេសក៍ស្តីពីការចូលរួមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

Asian Development Bank

© 2012 ធនាគារអភិវឌ្ឍន៍អាស៊ី

រក្សាសិទ្ធិគ្រប់បែបយ៉ាង ចេញផ្សាយនៅក្នុងឆ្នាំ ២០១២

បោះពុម្ពនៅក្នុងប្រទេសហ្វីលីពីន

ISBN 978-92-9092-818-8 (Print)
ISBN 978-92-9092-819-5 (PDF)

សន្និធិបោះពុម្ពលេខ TIM124919

លីបិក្រមក្នុងទិន្នន័យបោះពុម្ពផ្សាយ

ធនាគារអភិវឌ្ឍន៍អាស៊ី
ពង្រឹងការចូលរួមដើម្បីសម្រេចនូវលទ្ធផលនៃការអភិវឌ្ឍ : មគ្គុទេសក៍ស្តីពីការចូលរួមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ មគ្គុទេសក៍ស្តីពីការចូលរួមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទីក្រុងម៉ានដាលូយ៉ុង ប្រទេសហ្វីលីពីន : ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ ២០១២

១. ការចូលរួម ២. សង្គមស៊ីវិល ៣. ធនាគារអភិវឌ្ឍន៍អាស៊ី
I. ធនាគារអភិវឌ្ឍន៍អាស៊ី

ទស្សនៈ ដែលបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងពីទស្សនៈ និងគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ឬក្រុមប្រឹក្សាភិបាលរបស់ធនាគារ ឬរដ្ឋាភិបាល ដែលតំណាងដោយសមាជិកក្រុមប្រឹក្សាភិបាលធនាគារឡើយ ។

ធនាគារអភិវឌ្ឍន៍អាស៊ី មិនធានាសុក្រឹតភាពនៃទិន្នន័យ ដែលត្រូវបានដាក់បញ្ចូលក្នុងឯកសារបោះពុម្ពផ្សាយ ហើយមិនទទួលយកការទទួលខុសត្រូវចំពោះផលវិបាកនៃការប្រើប្រាស់ទិន្នន័យទាំងនេះឡើយ ។

ដោយមានការលើកឡើង ឬយោងលើអធិបតេយ្យភាពដែនដី ឬភូមិសាស្ត្រណាមួយ ឬការប្រើប្រាស់វាក្យស័ព្ទ "ប្រទេស" ក្នុងឯកសារនេះ ADB មិនមានចេតនាធ្វើការវិនិច្ឆ័យណាមួយទាក់ទងទៅនឹងស្ថានភាពច្បាប់ ឬស្ថានភាព ផ្សេងៗទៀត របស់ដែនដី ឬតំបន់នោះឡើយ ។

ADB លើកទឹកចិត្តឱ្យមានការបោះពុម្ព ឬថតចំលងព័ត៌មានសម្រាប់ប្រើប្រាស់ជាលក្ខណៈបុគ្គល និងលក្ខណៈ មិនមែនពាណិជ្ជកម្ម តែត្រូវមានការថ្លែងអំណរគុណចំពោះ ADB ។ អ្នកប្រើប្រាស់ទាំងឡាយត្រូវបានហាមឃាត់មិន ឱ្យលក់បន្ត ចែកចាយបន្ត ឬដកស្រង់ខ្លឹមសារពីច្បាប់ដើមសម្រាប់គោលបំណងពាណិជ្ជកម្ម ដោយពុំមានការយល់ព្រមជា លាយល័ក្ខណ៍អក្សរពី ADB នោះឡើយ ។

កំណត់ចំណាំ :
ក្នុងការបោះពុម្ពផ្សាយនេះ (i) “$” មានន័យថា ជាដុល្លារសហរដ្ឋអាមេរិច ។ និង (ii) ដរាបណាមានការលើកឡើងផ្សេងពាក្យថា "គម្រោង" សំដៅលើកម្ចី និងជំនួយឥតសំណងសម្រាប់ការវិនិយោគ កម្ចី និងជំនួយឥតសំណង ផ្អែកតាមគោលនយោបាយ និងជំនួយបច្ចេកទេស ។

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានខិតខំប្រឹងប្រែងដើម្បីផ្ទៀងផ្ទាត់ទៅលើភាពជាក់លាក់នៃការបកប្រែនេះ ។ ភាសាអង់គ្លេសគឺជាភាសាការងាររបស់ADB ហើយឯកសារច្បាប់ដើមជាភាសាអង់គ្លេសគឺជាឯកសារដែលត្រឹមត្រូវ និងផ្លូវការតែមួយគត់របស់ខ្លួន ។ សេចក្តីដកស្រង់ណាមួយចេញពីឯកសារនេះត្រូវតែយោងទៅលើឯកសារច្បាប់ដើមក្នុងភាសាអង់គ្លេស ។

6 ADB Avenue, Mandaluyong City
1550 Metro Manila, Philippines

♻ បោះពុម្ពដោយប្រើប្រាស់ក្រដាសកែច្នៃ

# មាតិកា


សារ់តារ iv

ការកោតសរសើរ iv

អារម្ភកថា v

ពាក្យកាត់ vii

សេចក្ដីផ្ដើម ១

ការចូលរួមនៅក្នុងការពិនិត្យឡើងវិញលើគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសរបស់ ADB ១១

ការចូលរួមនៅក្នុងវដ្តគម្រោងរបស់ ADB ការណែនាំ និងឧបករណ៍នានា ១៧

ឧបករណ៍ទី ១ : ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ ៣២

ឧបករណ៍ទី ២ : បង្កើនការចូលរួមជាអតិបរមា នៅក្នុងក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដាន ៤៣

ឧបករណ៍ទី ៣ : ការវាយតម្លៃដោយមានការចូលរួម ៤៨

ឧបករណ៍ទី ៤ : ការបង្កើតផែនការស្ដីពីការចូលរួម ៥៤

ឧបករណ៍ទី ៥ : ការបង្កើតយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ ៦១

ឧបករណ៍ទី ៦ : ការធ្វើការងារជាមួយនឹងអង្គការសង្គមស៊ីវិល ៦៦

ឧបករណ៍ទី ៧ : ការពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួម ៧៤

ការចូលរួម នៅក្នុងប្រតិបត្តិការការងាររបស់ ADB បទពិសោធន៍ និងធនធាន ៧៩

១.( Safeguards ) ការការពារផលប៉ះពាល់សង្គម និងបរិស្ថាន ៨១

២. សមធមិយេនឌ័រ ៨៨

៣. អភិបាលកិច្ចល្អ និងការអភិវឌ្ឍសមត្ថភាព ៩២

៤. ហេដ្ឋារចនាសម្ព័ន្ធ-ការបង្ការមេរោគ និងជំងឺអេដស៍ ៩៧

៥. ហេដ្ឋារចនាសម្ព័ន្ធ-ទឹក និងអនាម័យ ១០២

ឧបសម្ព័ន ១០៩

១. ភារកិច្ចរបស់ ADB ពាក់ព័ន្ធនឹងការចូលរួម ១០៩

២. សៀវភៅណែនាំអំពីការចូលរួមនៅក្នុងប្រតិបត្តិការរបស់ ADB ១១៣

៣. សំណួរដែលគេតែងសួរញឹកញាប់ ១២១

៤. បញ្ជីធនធាន ១២៥

លេខយោងចុងក្រោយ ១៣៨

## សារតារ

មគ្គុទេសក៍នេះជំនួសឱ្យ *ការពង្រឹងការចូលរួមដើម្បីសម្រេចលទ្ធផលនៃការអភិវឌ្ឍ : មគ្គុទេសក៍អំពីកិច្ចពិគ្រោះយោបល់ និងការចូលរួមរបស់បុគ្គលិក* (២០០៦)។ ការកែសម្រួលមគ្គុទេសក៍នេះ ដែលធ្វើឡើងដោយ មជ្ឈមណ្ឌលអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល (NGOC) របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ផ្ដល់នូវព័ត៌មាន និងឧបករណ៍បន្ថែមទៀតសំដៅផ្ដល់លទ្ធភាពឱ្យមានការចូលរួមប្រកបដោយអត្ថន័យ នៅក្នុងប្រតិបត្តិការនានារបស់ ADB ក្រោមយុទ្ធសាស្ត្រ ២០២០។ ខ្លឹមសារដែលត្រូវបានធ្វើបច្ចុប្បន្នកម្មនេះឆ្លុះបញ្ចាំងពីដំណើរការធុរកិច្ចថ្មីរបស់ ADB។ ការពង្រីកក្រុមគោលដៅបន្ថែមពីលើបុគ្គលិកដូចជា ដៃគូជាប្រទេសកំពុងអភិវឌ្ឍជាសមាជិក (DMC) អតិថិជននៃវិស័យឯកជនអ្នកពិគ្រោះការ និងអង្គការសង្គមស៊ីវិលទទួលស្គាល់តួនាទីដ៏សំខាន់របស់ក្រុមគោលដៅ ទាំងនេះ នៅក្នុងការអនុវត្តគម្រោងនានា ដែលទទួលបានហិរញ្ញប្បទានពី ADB។

## ការកោតសរសើរ

មគ្គុទេសក៍នេះត្រូវបានបញ្ចប់ក្រោមការត្រួតពិនិត្យ និងការណែនាំជារួមរបស់ Sandra Nicoll ប្រធានផ្នែកគ្រប់គ្រងសាធារណៈ អភិបាលកិច្ច និងការចូលរួមនៃនាយកដ្ឋានអភិវឌ្ឍន៍តំបន់ប្រកបដោយនិរន្តរភាព។ ការងារនេះត្រូវបានធ្វើឡើងដោយក្រុមការងារមួយ ក្រោមការដឹកនាំរបស់ Lainie Thomas អ្នកឯកទេសផ្នែកអភិវឌ្ឍន៍សង្គម (សង្គម ស៊ីវិល និងការចូលរួម) និងដោយមានការចូលរួមពីអ្នកពិគ្រោះការ។ ក្រុមការងារអន្តរនាយកដ្ឋានមួយ ដែលដឹកនាំដោយ Chris Morris អ្នកឯកទេសជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍សង្គម (NGOC) បានជួយដឹកនាំដំណើរការនេះ។ ក្រុមការងារនេះរួមមានបុគ្គលិករបស់ដូចជា Madhumita Gupta, Sri Wening Handayani, Parvez Imdad, Jocelyn Munsayac, Suzanne Nazal, Makoto Ojiro, Jayantha Perera, Nogendra Sapkota, Indira Simbolan និងតំណាងសង្គមស៊ីវិលចំនួន៣នាក់ រួមមាន Kathy Mulville, Fely Rixhon និង Malou Sevilla។ មន្ត្រីរដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍជាសមាជិក មកពីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងប្រទេសហ្វីលីពីន ក៏បានផ្ដល់នូវដំបូន្មាន និងព័ត៌មានយ៉ាងមានតម្លៃផងដែរ។ មានមនុស្សជាង១០០នាក់ បានផ្ដល់នូវធាតុចូលតាមរយៈក្រុមការងារនេះ កិច្ចប្រជុំតាមដានបន្តការផ្ដល់ព័ត៌មានត្រឡប់ក្រៅផ្លូវការ ការអង្កេតតាមអនឡាញ និងការពិនិត្យឡើងវិញជាលក្ខណៈអន្តរនាយកដ្ឋានលើសេចក្ដី ព្រាងនេះ។

# អារម្ភកថា

គោលបំណងជារួមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) គឺត្រូវសម្រេចឱ្យបាននូវលទ្ធផលប្រកបដោយ និរន្តរភាពនៅក្នុងការកាត់បន្ថយភាពក្រីក្រនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិច។ ដើម្បីមានប្រសិទ្ធភាព ប្រតិបត្តិការដែលពាក់ព័ន្ធនឹងការអភិវឌ្ឍត្រូវឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋក្រីក្រ។ ហើយការចូលរួមជាមួយអ្នកពាក់ព័ន្ធត្រូវមាននៅគ្រប់ដំណាក់កាលទាំងអស់នៃវដ្តប្រតិបត្តិការ ជាអាទិ៍ការបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រការអភិវឌ្ឍគម្រោងការអនុវត្តការពិនិត្យតាមដាន និងការវាយតម្លៃ។

នៅក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ ADB បានខិតខំឱ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធបែបនេះ។ ជាការពិតក្របខ័ណ្ឌយុទ្ធសាស្ត្ររយៈពេលវែងរបស់ ADB ឆ្នាំ២០២០ គូសបញ្ជាក់ពីសារៈសំខាន់នៃការចូលរួមនៅក្នុងប្រតិបត្តិការរបស់ ADB និងគូសបញ្ជាក់ថាភាពជាដៃគូជាទូទៅ គឺជាកម្លាំងជម្រុញដ៏សំខាន់ ដែលធ្វើឱ្យមានការផ្លាស់ប្តូរក្នុងការអភិវឌ្ឍ។ ការចូលរួមមានសារៈសំខាន់យ៉ាងខ្លាំងចំពោះការកសាងទំនាក់ទំនងយ៉ាងរឹងមាំរវាងរដ្ឋ និងប្រជាពលរដ្ឋដើម្បីជម្រុញឱ្យមានគណនេយ្យភាពទ្វេទិសការផ្តល់សេវាសាធារណៈដែលមានការឆ្លើយតប និងការដាក់បញ្ចូលក្រុមដែលគ្មានឱកាសនៅក្នុងសកម្មភាពសង្គម និងសេដ្ឋកិច្ចនានា។ នៅក្នុងប្រតិបត្តិការរបស់ ADB ការចូលរួមផ្តល់លទ្ធភាពឱ្យមានការគាំទ្រ និងភាពជាម្ចាស់របស់អ្នកពាក់ព័ន្ធនានា, កែលំអដំណើរការរបស់គម្រោង និងបង្កើន គុណភាពសម្រាប់ការចាប់ផ្តើមគម្រោង, បង្កើនគុណភាពក្នុងពេលអនុវត្ត និងពង្រឹងនិរន្តរភាពនៃលទ្ធផលនៃការអភិវឌ្ឍ។ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀតបំពេញតួនាទីយ៉ាងសំខាន់តាមរយៈឯកទេស និងចំណេះដឹងរបស់ពួកគេអំពីដំណើរការដែលមានការចូលរួម ដើម្បីបង្កើនគុណភាពនៃការចូលរួមក្នុងប្រតិបត្តិការនានា របស់ ADB ។

ការចូលរួមពាក់ព័ន្ធនឹងចំណាយប្រតិបត្តិការ។ ប៉ុន្តែយើងមានជំនឿយ៉ាងមុតមាំថាប្រយោជន៍ដែលទទួលបានពីការចូលរួមប្រកបដោយប្រសិទ្ធភាព មានទម្ងន់ធ្ងន់ជាងការចំណាយ។ ខណៈពេលដែលប្រតិបត្តិការរបស់ ADB បន្តមានការកើនឡើង និងពង្រីកបន្ថែមជាការសំខាន់ណាស់ដែលបុគ្គលិករបស់ ADB និងរដ្ឋាភិបាលនៃប្រទេសកំពុង អភិវឌ្ឍជាសមាជិក (DMC) និងអ្នកពាក់ព័ន្ធមកពីវិស័យឯកជន និងសង្គមស៊ីវិល ដែលចូលរួមក្នុងប្រតិបត្តិការនេះ មាន គោលវិធី និងឧបករណ៍ជាច្រើន ដើម្បីយកមកកែសម្រួល និងប្រើប្រាស់ ដើម្បីធានាឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាព។

កំណែទីពីរនៃមគ្គុទេសក៍នេះ ផ្តល់នូវព័ត៌មានបច្ចុប្បន្នកម្ម និងឧបករណ៍ពង្រីកបន្ថែមជាច្រើន ដើម្បីផ្តល់ការ គាំទ្រដល់បុគ្គលិកនិងអ្នកពាក់ព័ន្ធរបស់ ADB នៅក្នុងការអនុវត្តគោលវិធីដោយមានការចូលរួមប្រកបដោយប្រសិទ្ធភាព។ មគ្គុទេសក៍នេះរំលេចនូវឱកាសសំខាន់ៗ សម្រាប់ការចូលរួមនៅក្នុងការតាក់តែងគោលនយោបាយក្នុងការអនុវត្តកម្មវិធីនៅថ្នាក់តំបន់ និងថ្នាក់ប្រទេសនិងក្នុងវដ្តគម្រោងទាំងមូល និងផ្តល់ដំបូន្មានដល់វិធីសាស្ត្រ និងគោលវិធី និងចំណុចខ្វះខាតនានា ដែលត្រូវចៀសវាង។

នៅក្នុងកំណែនៃមគ្គុទេសក៍នេះមានការយកចិត្តទុកដាក់ជាពិសេស ដល់ការការពារផលប៉ះពាល់សង្គម និង បរិស្ថាន យេនឌ័រ អភិបាលកិច្ច មេរោគ/ជំងឺអេដស៍ និងហេដ្ឋារចនាសម្ព័ន្ធនិងទឹក និងអនាម័យ។ ធនធានពាក់ព័ន្ធនឹងការចូលរួមជាច្រើនដែលបង្កើតឡើងដោយអង្គការស្ថាប័នផ្សេងៗ អាចរកបានអនឡាញ ហើយមគ្គុទេសក៍នេះមានបង្ហាញពីឯកសារយោង សម្រាប់អ្នកដែលចង់បានព័ត៌មានបន្ថែមទៀត។

លើសពីនេះកំណែថ្មីនៃមគ្គុទេសក៏នេះ ត្រូវបានរៀបចំឡើងសម្រាប់ក្រុមគោលដៅដែលមានលក្ខណៈទូលំទូលាយសម្រាប់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ដែលចូលរួមនៅក្នុងគម្រោងដែលទទួលបានការគាំទ្រពី ADB ។ ADB ទទួលស្គាល់ថាការចូលរួមប្រកបដោយអត្ថន័យរបស់គ្រប់អ្នកពាក់ព័ន្ធទាំងអស់លើកកម្ពស់សមធម៌ និងការចូលរួមដែលជាគោលវិធីអភិវឌ្ឍន៍មួយដែលមានចែងនៅក្នុងយុទ្ធសាស្ត្រ ២០២០ ។

មគ្គុទេសក៏នេះបំពេញបន្ថែមគំនិតផ្តួចផ្តើមដទៃទៀតសម្រាប់បង្កើនការចូលរួមរបស់អ្នកពាក់ព័ន្ធរបស់ ADB និងកែលំអលទ្ធផលការងារជារួមរបស់ធនាគារ ។ គំនិតផ្តួចផ្តើមទាំងនេះរួមមានគំនិតផ្តួចផ្តើមគ្រប់គ្រង ដើម្បីសម្រេចលទ្ធផលនៃការអភិវឌ្ឍ, ការបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីកែលំអក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដាន, ការបង្ហាញព័ត៌មាន និងការប្រាស្រ័យទាក់ទងតាមរយៈគោលនយោបាយប្រាស្រ័យទាក់ទងសាធារណៈ និងការងារវិភាគសង្គមដែលមានលក្ខណៈទូលំទូលាយ ។ មគ្គុទេសក៏នេះគឺជាធនធានបន្ថែមរបស់ ADB សម្រាប់បង្កើនគុណភាពសេវាកម្ម សម្រាប់ប្រទេសកំពុងអភិវឌ្ឍ ដែលជាសមាជិករបស់យើង ។

Ursula Schaefer-Preuss

អនុប្រធានធនាគារ ទទួលបន្ទុកការគ្រប់គ្រងចំណេះដឹង និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព

# ពាក្យកាត់

| | | | |
|---|---|---|---|
| ADB | – | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| BA | – | beneficiary assessment | ការវាយតម្លៃអ្នកទទួលផល |
| CBM | – | community-based monitoring | ការពិនិត្យតាមដាននៅតាមសហគមន៍ |
| CBO | – | community-based organization | អង្គការសហគមន៍ |
| CDD | – | community-driven development | ការអភិវឌ្ឍ ដោយមានការជម្រុញពី សហគមន៍ |
| COSO | – | Central operations Services office | ការិយាល័យផ្តល់សេវាប្រតិបត្តិការនៅថ្នាក់កណ្តាល |
| CPS | – | country partnership strategy | យុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស |
| CRC | – | citizens report card | ប័ណ្ណរាយការណ៍របស់ប្រជាពលរដ្ឋ |
| CSO | – | civil society organization | អង្គការសង្គមស៊ីវិល |
| DAG | – | disadvantaged group | ក្រុមប្រជាពលរដ្ឋដែលជួបប្រទះការលំបាក |
| DDC | – | district development committee | គណៈកម្មាធិការអភិវឌ្ឍន៍ស្រុក |
| DMC | – | developing member country | ប្រទេសកំពុងអភិវឌ្ឍជាសមាជិក |
| DMF | – | design and monitoring framework | ក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដាន |
| EA | – | executing agency | ទីភ្នាក់ប្រតិបត្តិ |
| FI | – | financial intermediary | អន្តរការីហិរញ្ញវត្ថុ |
| GACAP II | – | Second Governance and Anticorruption Action Plan | ផែនការសកម្មភាពស្តីពីអភិបាលកិច្ច និងការប្រឆាំងអំពើពុករលួយលើកទី ២ |
| GAP | – | gender action plan | ផែនការសកម្មភាពយេនឌ័រ |
| IED | – | Independent Evaluation Department | នាយកដ្ឋានវាយតម្លៃឯករាជ្យ |
| IFC | – | International Finance Corporation | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| INGO | – | international nongovernment organization | អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ |
| IP | – | indigenous people | ជនជាតិដើមភាគតិច |
| IPSA | – | initial poverty and social analysis | ការវិភាគភាពក្រីក្រ និងសង្គមបឋម |
| LNGO | – | local nongovernment organization | អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក |
| M&E | – | monitoring and evaluation | ការពិនិត្យតាមដាន និងវាយតម្លៃ |
| MFF | – | multitranche financing facility | កម្មវិធីផ្តល់ហិរញ្ញប្បទានពហុផ្នែក |
| MPA | – | methodology for participatory assessment | វិធីសាស្ត្រវាយតម្លៃ ដោយមានការចូលរួម |
| MSC | – | most significant change | ការផ្លាស់ប្តូរសំខាន់បំផុត |
| NGO | – | nongovernment organization | អង្គការក្រៅរដ្ឋាភិបាល |
| NGOC | – | Nongovernment organization | មជ្ឈមណ្ឌលអង្គការក្រៅរដ្ឋាភិបាល និង |

| | | | |
|---|---|---|---|
| | | and Civil Society Center | សង្គមស៊ីវិល |
| OCRP | – | Office of the Compliance Review Panel | ការិយាល័យគណៈកម្មាធិការពិនិត្យឡើងវិញលើភាពអនុលោម |
| PAM | – | project administration manual | សៀវភៅណែនាំអំពីការចាត់ចែងគម្រោង |
| PCP | – | Public Communications Policy | គោលនយោបាយស្ដីពីការប្រាស្រ័យទាក់ទងសាធារណៈ |
| PHAST | – | participatory hygiene and sanitation transformation | ការផ្លាស់ប្ដូរអនាម័យដោយមានការចូលរួម |
| PIPA | – | participatory impact pathway analysis | ការវិភាគគន្លងផ្លូវនៃផលប៉ះពាល់ដោយមានការចូលរួម |
| PM&E | – | participatory monitoring and evaluation | ការពិនិត្យតាមដាន និងការវាយតម្លៃដោយមានការចូលរួម |
| PPA | – | participatory poverty assessment | ការវាយតម្លៃលើភាពក្រីក្រដោយមានការចូលរួម |
| PPMS | – | project performance management system | ប្រព័ន្ធគ្រប់គ្រងលទ្ធផលការងាររបស់ គម្រោង |
| PPTA | – | project preparatory technical assistance | ជំនួយបច្ចេកទេសសម្រាប់ការរៀបចំ គម្រោង |
| PRA | – | participatory rapid assessment | ការវាយតម្លៃតម្លៃតាមបែបរហ័សដោយមានការចូលរួម |
| RRP | – | report and recommendation of the President | របាយការណ៍និងអនុសាសន៍របស់ប្រធានធនាគារ |
| SC | – | significant change | ការផ្លាស់ប្ដូរសំខាន់ |
| SCS | – | stakeholder communications strategy | យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយអ្នក ពាក់ព័ន្ធ |
| SPRSS | – | summary poverty reduction and social strategy | យុទ្ធសាស្ត្រសង្ខេបស្ដីពីការកាត់បន្ថយភាពក្រីក្រ និងសង្គម |
| SPWN | – | small piped water network | បណ្ដាញចែកចាយទឹកខ្នាតតូច |
| SPF | – | Special Project Facilitator | អ្នកសម្របសម្រួលគម្រោងពិសេស |
| SPS | – | Safeguard Policy Statement | គោលនយោបាយស្ដីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាន |
| TA | – | technical assistance | ជំនួយបច្ចេកទេស |
| TOR | – | terms of reference | លក្ខខណ្ឌប្រតិបត្តិ |
| VBFT | – | village-based field team | ក្រុមការងារចុះមូលដ្ឋានតាមភូមិ |
| VDC | – | village development committee | គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ |
| WUA | – | water users association | សមាគមអ្នកប្រើប្រាស់ទឹក |
| WUG | – | water user group | ក្រុមអ្នកប្រើប្រាស់ទឹក |

# ១ សេចក្តីផ្តើម

ការចូលរួមរបស់អ្នកពាក់ព័ន្ធ គាំទ្រដល់អភិបាលកិច្ចល្អការបំពេញកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ និងគណនេយ្យភាព និងលើកកម្ពស់ការច្នៃប្រឌិតថ្មី ភាពឆ្លើយតប និងនិរន្តរភាពដោយភ្ជាប់ទំនាក់ទំនងដោយផ្ទាល់ជាមួយ នឹងប្រសិទ្ធភាពនៃការអភិវឌ្ឍ។ ភាពជាដៃគូដោយរាប់បញ្ចូលទាំងភាពជាដៃគូជាមួយនឹងសង្គមស៊ីវិលផង គឺជាកម្លាំងចលករនៃការផ្លាស់ប្តូរនៅក្នុងយុទ្ធសាស្ត្រ ២០២០ របស់ ADB ។ យុទ្ធសាស្ត្រនេះធ្វើការកំណត់ពីរបៀបដែល ADB នឹងធ្វើការដោះស្រាយបញ្ហាប្រឈមនានា ដែលតំបន់នេះកំពុងជួបប្រទះ ក៏ដូចជាបំពេញទៅតាមតម្រូវការផ្សេងៗ ដើម្បីសម្រេចឱ្យបាននូវកំណើនដែលមានការចូលរួមកំណើនដែលធានានិរន្តរភាពដល់បរិស្ថាន និងសមាហរណកម្មតំបន់។ ភាពជាដៃគូជាមួយនឹងស្ថាប័ននានា ជាអាទិ៍អង្គការក្រៅ រដ្ឋាភិបាល អង្គការតាមសហគមន៍ និងមូលនិធិផ្សេងៗ នឹងមានសារៈសំខាន់យ៉ាងខ្លាំង ចំពោះការរៀបចំផែនការ ការផ្តល់ ហិរញ្ញប្បទាន និងការអនុវត្តប្រតិបត្តិការនានារបស់ ADB ។

ប្រភព : ADB. 2008. *Strategy 2020: The Long-Term Strategic Framework of the Asian Development Bank 2008–2020*. Manila.

## គោលបំណងរបស់មគ្គុទេសក៍នេះ

កំណែទីពីរនេះផ្តល់នូវព័តិមាន និងឧបករណ៍នានា ដើម្បីធ្វើការកសាងសមត្ថភាពអំពីគោលវិធីដោយមានការចូលរួម និងលើកកម្ពស់ការអនុវត្តគោលវិធីទាំងនោះ នៅក្នុងប្រតិបត្តិការរបស់ ADB ប្រទេសកំពុងអភិវឌ្ឍជាសមាជិក (DMCs) និងអតិថិជនវិស័យឯកជន។[១] មគ្គុទេសក៍នេះផ្តល់ការគាំទ្រដល់ការសម្រេចនូវគោលដៅជាយុទ្ធសាស្ត្រនានា សំដៅជម្រុញឱ្យមានការចូលរួមនៅក្នុងយុទ្ធសាស្ត្រ ២០២០ ដែលជាក្របខ័ណ្ឌយុទ្ធសាស្ត្ររយៈពេលវែងរបស់ ADB ។[២] មគ្គុទេសក៍នេះមានដាក់បញ្ចូលនូវឧបករណ៍នានា ដែលសម្រិតសម្រាំងឡើងឱ្យស្របទៅនឹងដំណើរការធុរកិច្ចរបស់ ADB និងមានរំលេចផងដែរពីធនធានរបស់ស្ថាប័នផ្សេងទៀត។

មគ្គុទេសក៍នេះពង្រឹងបន្ថែម និងផ្តល់នូវការណែនាំដើម្បីគាំទ្រដល់ការបំពេញទៅតាមលក្ខខណ្ឌតម្រូវ ឱ្យមានការចូលរួមដូចដែលមានចែងនៅក្នុងគោលនយោបាយយុទ្ធសាស្ត្រ និងឯកសារផ្សេងទៀតរបស់ ADB ។ មគ្គុទេសក៍នេះប្រើប្រាស់ធនធានដែលមានស្រាប់ដទៃទៀតដូចជា *សៀវភៅណែនាំស្តីពីការវិភាគសង្គមគោលការណ៍ណែនាំស្តីពីការរៀបចំក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដាន* (គោលការណ៍ណែនាំអំពី DMF) និង*សៀវភៅធនធានសម្រាប់អង្គការ សង្គមស៊ីវិល* ។[៣]

## រចនាសម្ព័ន្ធនៃមគ្គុទេសក៍នេះ

មគ្គុទេសក៍នេះចែកចេញជា ៤ ផ្នែកធំៗ អមជាមួយនឹងឧបសម្ព័ន្ធ។ ផ្នែកទីមួយបង្ហាញពីការចូលរួមអ្វីទៅជា ារចូលរួម និងហេតុអ្វីបានជាការចូលរួមមានសារៈសំខាន់។ ផ្នែកទី ២ និងទី ៣ ធ្វើការកំណត់ពីសារៈសំខាន់នៃការចូល រួម នៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ ការពិនិត្យឡើងវិញលើកម្មវិធីរបស់ប្រទេស និងតាមរយៈវដ្តប្រតិបត្តិការរបស់គម្រោង។ ផ្នែកទី ៣ មានដាក់បញ្ចូលនូវឧបករណ៍វដ្តគម្រោងចំនួន៧ ដែលគ្រប់ដណ្តប់លើបច្ចេកទេសផ្សេងៗ ដូចជាការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់, ការវាយតម្លៃដោយមានការចូលរួម និងការបង្កើតផែនការស្តីពីការចូលរួម។ ផ្នែកទី៤ ផ្តោតជាក់លាក់លើការចូលរួមនៅក្នុងការការពារផលប៉ះពាល់សង្គម និងបរិស្ថាន និងការងារប្រតិបត្តិការសំខាន់ៗចំនួន៤ ដែលត្រូវបានកំណត់ជាអាទិភាពនៅក្នុងយុទ្ធសាស្ត្រ ២០២០ ជាអាទិ៍ សមធមិយេនឌ័រ, អភិបាលកិច្ចល្អ និងការអភិវឌ្ឍសមត្ថភាព, ការបង្ការមេរោគ និងជំងឺអេដស៍ និងទឹក និងអនាម័យ។

ឧបសម្ព័ន្ធមានរៀបរាប់ពីសាវតារ នៃការកំណត់លក្ខខណ្ឌតម្រូវឱ្យមានការចូលរួម ដូចដែលបានដាក់ចេញ នៅក្នុងឯកសារណែនាំរបស់ ADB, ឧទាហរណ៍អំពីការចូលរួមដែលមាននៅក្នុងសៀវភៅណែនាំអំពីប្រតិបត្តិការរបស់ ADB, បញ្ជីសំណួរដែលគេតែងសួរញឹកញាប់, សន្ទិធិអំពីធនធានសម្រាប់ការចូលរួម និងលេខយោងចុងក្រោយ ក៏ដូចជា ព័ត៌មានបន្ថែមទៀត។

## តើអ្នកណាខ្លះ ដែលជាក្រុមគោលដៅ?

មគ្គុទេសក៍នេះផ្តោតលើអ្នកដែលទទួលខុសត្រូវធានាឱ្យមានការចូលរួមនៅក្នុងការរៀបចំ និងអនុវត្តគម្រោង នានា និងនៅក្នុងការតាក់តែង និងពិនិត្យឡើងវិញលើគោលនយោបាយ និងកម្មវិធីប្រចាំប្រទេស។ អ្នកទទួលខុសត្រូវទាំងនេះរួមមានបុគ្គលិករបស់ ADB, មន្ត្រីរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក, អតិថិជនមកពីវិស័យឯកជន, អ្នក ពិគ្រោះការ និងអង្គការសង្គមស៊ីវិល (CSOs)។ មគ្គុទេសក៍នេះផ្តោតលើប្រតិបត្តិការដែលទទួលបានជំនួយពី ADB ប៉ុន្តែឧបករណ៍ទាំងនេះក៏គាំទ្រដល់សកម្មភាពអភិវឌ្ឍន៍ ដែលមានការចូលរួមយ៉ាងទូលំទូលាយផងដែរ។

ADB ឬអ្នកទទួលជំនួយ និង/ឬអតិថិជន តែងតែជួលអ្នកពិគ្រោះការ និងអង្គការសង្គមស៊ីវិលជាទៀងទាត់ដើម្បីជួយរៀបចំអនុវត្ត និងវាយតម្លៃគម្រោង។ ការទទួលខុសត្រូវលើការអនុវត្តសកម្មភាពដែលបានឯកភាពគ្នា និងលើការរាយការណ៍ទៅកាន់ ADB គឺជាការទទួលខុសត្រូវរបស់អ្នកទទួលជំនួយ និង/ឬអតិថិជន។[៤] តាមរយៈ ការផ្តោតគោលដៅលើបុគ្គលិក ADB និងអ្នកដទៃទៀតដែលចូលរួមនៅក្នុងការអនុវត្តប្រតិបត្តិការដែលទទួលបានជំនួយពី ADB មគ្គុទេសក៍នេះផ្តល់ការគាំទ្រដល់ការអនុវត្តល្អៗ ក្នុងការងារអភិវឌ្ឍន៍របស់អ្នកដែលមានតួនាទីនានា។

## អ្វីទៅជាការចូលរួម?

នៅក្នុងមគ្គុទេសក៍នេះ ការចូលរួម នៅក្នុងប្រតិបត្តិការដែលទទួលបានជំនួយពី ADB សំដៅលើប្រតិបត្តិការ នានា ដែលអ្នកពាក់ព័ន្ធមានឥទ្ធិពល ឬអាចចូលរួមចំណែក នៅក្នុងការរៀបចំ អនុវត្ត និងពិនិត្យតាមដានសកម្មភាព អភិវឌ្ឍន៍ណាមួយ។

ការចូលរួមដែលមិនមែនត្រឹមតែជាគោលបំណងប៉ុណ្ណោះទេ ជួយសម្រេចនូវលទ្ធផលអភិវឌ្ឍន៍ដែលមានភាពប្រសើរជាងមុន។ តាមរយៈការធានាយ៉ាងណាឱ្យអ្នកពាក់ព័ន្ធយល់ និងអាចចូលរួមនៅក្នុងការសម្រេចចិត្តការវិភាជន៍ធនធាន និងសកម្មភាពនានា ដែលមានផលប៉ះពាល់មកលើជីវិតរបស់ពួកគេ ការចូលរួមធានាឱ្យមានការសម្រេចនូវប្រយោជន៍ពីការចូលរួមនេះ។

## គោលវិធីផ្សេងៗ និងភាពស៊ីជម្រៅនៃការចូលរួម

| គោលវិធី | និយមន័យ | ដំណើរការ | ការអនុវត្ត |
|---|---|---|---|
| ការបង្កើត និងការ ចែករំលែកព័តិមាន | ព័តិមាន (i) ត្រូវបានបង្កើតឡើងដោយ ADB/ អ្នកទទួលជំនួយ ឬកម្ចី / អតិថិជន និងចែករំលែកជាមួយអ្នកពាក់ព័ន្ធនានា, (ii) ត្រូវបានបង្កើតឡើងដោយឯករាជ្យ ដោយអ្នកពាក់ព័ន្ធហើយចែករំលែកជាមួយ ADB / អ្នកទទួលជំនួយ ឬកម្ចី / អតិថិជន ឬ (iii) ត្រូវបានបង្កើត ឡើងរួមគ្នា | **ទាប :** ADB/ អ្នកទទួលជំនួយ ឬកម្ចី / អតិថិជនចែករំលែកព័តិមានជាមួយអ្នកពាក់ព័ន្ធនានា<br>**មធ្យម :** ឱកាសសម្រាប់ឱ្យអ្នកពាក់ព័ន្ធចែករំលែកព័តិមានជាមួយ ADB/អ្នកទទួលជំនួយ ឬកម្ចី / អតិថិជន<br>**ខ្ពស់ :** បង្កើត និងចែករំលែកព័តិមានរួមគ្នាដើម្បីសម្រេចគោលដៅរួម (ដូចជាបង្កើនការយល់ដឹងជាដើម) | **ទាប :** ADB/អ្នកទទួលជំនួយ ឬកម្ចី / អតិថិជនចែករំលែកព័តិមានជាមួយអ្នកពាក់ព័ន្ធនានា<br>**មធ្យម :** ឱកាសសម្រាប់ឱ្យសង្គមស៊ីវិលចែករំលែកព័តិមានជាមួយ ADB/អ្នកទទួលជំនួយ ឬកម្ចី / អតិថិជន<br>**ខ្ពស់ :** បង្កើត និងចែករំលែកព័តិមានរួមគ្នាដើម្បីសម្រេចគោលដៅរួម (ដូចជាបង្កើនការយល់ដឹងជាដើម) |
| កិច្ចពិគ្រោះយោបល់ | ធាតុចូលរបស់អ្នកពាក់ព័ន្ធត្រូវបានស្នើ និងយកមកធ្វើការពិចារណាជាផ្នែកមួយនៃ ដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់គោលនយោបាយកម្មវិធី ឬគម្រោង | **ទាប :** កិច្ចពិគ្រោះយោបល់លើគេហទំព័រ / លាយលក្ខណ៍អក្សរតែប៉ុណ្ណោះ<br>**មធ្យម :** ឱកាសធ្វើការប្រាស្រ័យទាក់ទងដោយផ្ទាល់ទ្វេទិស (ដូចជាសិក្ខាសាលាការពិភាក្សាក្រុមគោលដៅ)<br>**ខ្ពស់ :** ទស្សនៈរបស់ក្រុមដែលគ្មានឱកាសត្រូវបានដាក់បញ្ចូលក្នុងការរៀបចំ (ដូចជាដោយប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួម) | **ទាប :** កិច្ចពិគ្រោះយោបល់លើគេហទំព័រ / លាយលក្ខណ៍អក្សរតែប៉ុណ្ណោះ<br>**មធ្យម :** ឱកាសធ្វើការប្រាស្រ័យទាក់ទងដោយផ្ទាល់ទ្វេទិស (ដូចជាសិក្ខាសាលា)<br>**ខ្ពស់ :** ទទួលព័តិមានត្រឡប់ជាប្រចាំពីក្រុមដែលបាត់បង់ឱកាស ក្នុងកំឡុងពេលអនុវត្ត (ដូចជាដោយប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួម) |
| កិច្ចសហប្រតិបត្តិការ | អ្នកពាក់ព័ន្ធ និង ADB/អ្នកទទួលជំនួយ ឬកម្ចី/អតិថិជនធ្វើការងាររួមគ្នា ប៉ុន្តែអ្នកពាក់ព័ន្ធមានការគ្រប់គ្រងមានកំណត់លើការសម្រេចចិត្ត និងធនធាននានា | ទាប : ធាតុចូលពីអ្នកពាក់ព័ន្ធជាក់លាក់ត្រូវបានប្រមូលសម្រាប់ការរៀបចំគម្រោង<br>មធ្យម : ភាពជាតំណាងរបស់អ្នកពាក់ព័ន្ធសំខាន់ៗ នៅក្នុងស្ថាប័នរៀបចំគម្រោង<br>**ខ្ពស់ :** អ្នកពាក់ព័ន្ធមានឥទ្ធិពលលើស្ថាប័នរៀបចំគម្រោង និងលើការព្រមព្រៀងគ្នាលើតួនាទីរបស់អ្នកពាក់ព័ន្ធនៅក្នុងការអនុវត្តគម្រោង | **ទាប :** ធាតុចូលពីអ្នកពាក់ព័ន្ធនៅក្នុងការពិនិត្យតាមដាន និងការវាយតម្លៃ<br>**មធ្យម :** ការអនុវត្តសមាសភាគណាមួយរបស់គម្រោង ដោយស្ថាប័នរបស់អ្នកពាក់ព័ន្ធ (ដូចជាអង្គការសង្គមស៊ីវិលជាដើម)<br>**ខ្ពស់ :** អ្នកពាក់ព័ន្ធមានតំណាងនៅក្នុងស្ថាប័នអនុវត្តគម្រោង និងចូលរួមនៅក្នុងសកម្មភាពអនុវត្តនានា |
| **ភាពជាដៃគូ** | អ្នកពាក់ព័ន្ធ ចូលរួមនៅក្នុងដំណើរការនៃការសម្រេចចិត្តនិង/ឬធ្វើការគ្រប់គ្រងលើធនធាននានា តាមរយៈកិច្ចព្រមព្រៀងផ្លូវការ និងមិនផ្លូវការដើម្បីធ្វើការងាររួមគ្នាឆ្ពោះទៅសម្រេចគោលដៅរួម | **ទាប :** ឯកភាពគ្នាថា ស្ថាប័នរបស់អ្នកពាក់ព័ន្ធនឹងធ្វើការងារជាដៃគូជាមួយនឹងគម្រោងដែលទទួលបានមូលនិធិពីADB<br>**មធ្យម :** អនុស្សរណៈនៃការយោគយល់គ្នា (MoU)/ភាពជាដៃគូបានទទួលការឯកភាព ឬអ្នកពាក់ព័ន្ធទទួលយកការទទួលខុសត្រូវដោយផ្ទាល់មួយចំនួន<br>**ខ្ពស់ :** MoU/កិច្ចព្រមព្រៀងអំពីភាពជាដៃគូត្រូវបានចរចារាប់មានរាប់បញ្ចូលនូវការផ្តល់ហិរញ្ញប្បទានរួមគ្នា និងការគ្រប់គ្រង ឬអ្នកពាក់ព័ន្ធទទួលយកភាពជាម្ចាស់/ការទទួលខុសត្រូវក្នុងកម្រិតខ្ពស់ | **ទាប :** ស្ថាប័នរបស់អ្នកពាក់ព័ន្ធផ្តល់នូវធាតុចូលជាប្រចាំហើយត្រូវបានទទួលស្គាល់ថាជាដៃគូមួយនៅក្នុងគម្រោងដែលទទួលបានមូលនិធិពី ADB<br>**មធ្យម :** MoU/កិច្ចព្រមព្រៀងអំពីភាពជាដៃគូត្រូវបានអនុវត្ត ឬអ្នកពាក់ព័ន្ធទទួលយកភាពជាម្ចាស់ / ការទទួលខុសត្រូវក្នុងកម្រិតមួយ<br>**ខ្ពស់ :** MoU/កិច្ចព្រមព្រៀងអំពីភាពជាដៃគូត្រូវបានអនុវត្ត រាប់មានរាប់បញ្ចូលនូវការផ្តល់ហិរញ្ញប្បទានរួមគ្នា និងការគ្រប់គ្រង ឬអ្នកពាក់ព័ន្ធទទួលយកភាពជាម្ចាស់/ការទទួលខុសត្រូវក្នុងកម្រិតខ្ពស់ |

សម្គាល់ : និយមន័យទូទៅទាំងនេះអាចបង្កើតឡើង សម្រាប់ប្រភេទគម្រោងពិសេសដូចជាគម្រោងផ្គត់ផ្គង់ទឹកជនបទ និងសម្រាប់ប្រតិបត្តិការជាអាទិភាពដូចជា យេនឌ័រ ឬគម្រោងនីមួយៗជាដើម ។

នៅក្នុងប្រតិបត្តិការដែលជួយដោយ ADB អ្នកពាក់ព័ន្ធត្រូវបានបែងចែកជា ៣ក្រុមធំៗ ៖ រដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិល (រាប់បញ្ចូលទាំងអ្នកដែលទទួលរងផលប៉ះពាល់)។ សង្គមស៊ីវិល គឺជាបណ្តុំសកម្មភាពសាធារណៈខាងក្រៅរដ្ឋាភិបាល និងវិស័យឯកជន។ ខណៈពេលដែលជារឿយៗ អង្គការសង្គមស៊ីវិលតំណាងឱ្យអ្នកពាក់ព័ន្ធនានាជាច្រើននៅក្នុងវិស័យសាធារណៈ សំខាន់ត្រូវទទួលស្គាល់ថា អាចមានមនុស្សផ្សេងទៀតដែលមិនទាន់តំណាងដោយអង្គការសង្គមស៊ីវិល ដែលមានស្រាប់ ឬនៅក្នុងដំណើការអភិបាលកិច្ចនៅមូលដ្ឋាន។ ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីជម្រុញឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធនានា សំដៅបង្កើនការចូលរួមក្នុងដំណើរការ អភិបាលកិច្ចផ្លូវការ និងក្រៅផ្លូវការដែលមានទំនាក់ទំនងជាមួយនឹងគម្រោងរបស់ ADB ។

ចុងក្រោយអ្នកទទួលជំនួយ និង/ឬអតិថិជនមិនថារដ្ឋាភិបាល ឬវិស័យឯកជននោះទេ គឺជាអ្នកដែលត្រូវធានាឱ្យមានការចូលរួមឱ្យបានសមស្របពីក្រុមពីរទៀត។ ឧបករណ៍ទី ១ ៖ ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់នៅទំព័រទី ២៥ ចែងលំអិតអំពីអ្នកពាក់ព័ន្ធសំខាន់ៗ។ នៅក្នុងធនាគារអភិវឌ្ឍន៍អាស៊ី ការចូលរួមគ្របដណ្តប់លើគោលវិធី ៤ យ៉ាងធំៗ ដូចជាការបង្កើត និងការចែករំលែកព័ត៌មានការពិគ្រោះយោបល់ការសហការ និងភាពជាដៃគូ។ គោលវិធីទាំងនេះគ្របដណ្តប់ លើការបន្តទំនាក់ទំនងរវាងអ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកពាក់ព័ន្ធនានា ដែលកម្រិតនៃគំនិតផ្តួចផ្តើម និងសកម្មភាពរបស់ភាគីនីមួយៗមានលក្ខណៈផ្សេងៗគ្នា។ ការអនុវត្តគោលវិធីនីមួយៗ អាចកើតឡើងក្នុងកម្រិតស៊ីជម្រៅផ្សេងៗពីគ្នា។ នៅក្នុងមគ្គុទេសក៍នេះ "ការចូលរួម" សំដៅលើការប្រើប្រាស់គោលវិធីទាំង ៤ នេះរួមគ្នា។

## តើការចូលរួមមានគោលការណ៍ស្នូលអ្វីខ្លះ?

គោលវិធី និងភាពស៊ីជម្រៅនៃការចូលរួម មានលក្ខណៈផ្សេងៗពីគ្នា អាស្រ័យទៅតាមបរិបទ និងសកម្មភាព អភិវឌ្ឍន៍ ប៉ុន្តែមានគោលការណ៍ជាច្រើន ដែលនៅតែមានលក្ខណៈដូចគ្នា ៖

- **លើកកម្ពស់គណនេយ្យភាព និងតម្លាភាព ៖** យន្តការដែលមានការចូលរួម ធ្វើឱ្យអ្នកធ្វើសេចក្តីសម្រេចចិត្តមានការទទួលខុសត្រូវចំពោះអ្នកពាក់ព័ន្ធរបស់ខ្លួន។ យន្តការទាំងនេះលើកកម្ពស់ការប្រាស្រ័យទាក់ទង និងការបើកចំហអំពីសកម្មភាពនានា និងតម្លាភាពក្នុងគោលដៅនៃការចូលរួម និងកម្រិតនៃឥទ្ធិពលរបស់អ្នកពាក់ព័ន្ធ។
- **ផ្តល់លទ្ធភាពឱ្យមានការចូលរួមនៅគ្រប់កម្រិតទាំងអស់ ៖** មនុស្សចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត នៅគ្រប់កម្រិតទាំងអស់ (ដូចជាកម្រិតគោលនយោបាយកម្មវិធី និងគម្រោង) តាមរយៈសកម្មភាពទាន់ពេលវេលា មានភាពបត់បែនដែលសមស្របទៅនឹងជំនាញសមត្ថភាព និងផលប្រយោជន៍របស់ពួកគេ។
- **ធ្វើឱ្យមានការចូលរួមសម្រាប់មនុស្សគ្រប់រូប ៖** គ្រប់មនុស្សទាំងអស់ទទួលបានតម្លៃស្មើគ្នា ឱកាសដើម្បីចូលរួមត្រូវបានផ្សព្វផ្សាយយ៉ាងគ្រប់គ្រាន់ និងត្រូវបានផ្តល់ដោយស្មើភាពគ្នាហើយឧបសគ្គនានាដែលបញ្ឈប់ក្រុមណាមួយមិនឱ្យចូលរួមត្រូវបានដោះស្រាយ។
- **គុណតម្លៃចម្រុះ ៖** ភាពចម្រុះនៃបទពិសោធន៍សាវតារជំនឿ និងជំនាញរបស់មនុស្សគឺជាធនធានដ៏វិសេសវិសាលមួយសម្រាប់សង្គម។ ការអបអរសាទរ និងប្រើប្រាស់ភាពចម្រុះនេះ គឺជាកូនសោរសម្រាប់ការចូលរួម។
- **ធានាថាការចូលរួមត្រូវបានធ្វើឡើង ដោយស្ម័គ្រចិត្ត ៖** មនុស្សចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដោយខ្លួនឯងដោយសារតែពួកគេជឿលើសារៈសំខាន់នៃបញ្ហាហើយការចូលរួមរបស់ពួកគេ នឹងធ្វើឱ្យមានភាពខុសប្លែកគ្នាមួយ។ សូមចៀសវាងការបង្ខិតបង្ខំ។
- **លើកទឹកចិត្តអ្នកពាក់ព័ន្ធនានាឱ្យបង្កើតនូវគំនិត និងដំណោះស្រាយរបស់ពួកគេដោយផ្ទាល់ ៖** នៅក្នុងគោលវិធីដែលមានការចូលរួម និងដឹកនាំដោយសហគមន៍មនុស្សធ្វើសកម្មភាពដោយខ្លួនឯង ទៅតាមវិធីដែលពួកគេជ្រើសរើស។

## អ្វីទៅជាការចូលរួមរបស់សង្គមស៊ីវិល?

សង្គមស៊ីវិលគឺជាអ្នកពាក់ព័ន្ធដ៏សំខាន់មួយនៅក្នុងប្រតិបត្តិការរបស់ ADB និងអ្នកទទួលជំនួយឬកម្ចី និង/ឬអតិថិជន។ សង្គមស៊ីវិលមានលក្ខណៈផ្សេងពីរដ្ឋាភិបាល និងវិស័យឯកជន និងមានបុគ្គលក្រុម និងអង្គការមិនរកប្រាក់ចំណេញចម្រុះ។ អង្គការទាំងនេះប្រតិបត្តិការការងាររបស់ខ្លួនជុំវិញប្រយោជន៍គោលបំណង និងគុណតម្លៃរួមដោយមានភាពផ្លូវការក្នុងកម្រិតផ្សេងៗពីគ្នា។ សង្គមស៊ីវិល មានចាប់ពីក្រុមសហគមន៍ដែលមិនផ្លូវការ និងមិនត្រូវបានចងក្រងឱ្យបានត្រឹមត្រូវរហូតដល់សហជីពអន្តរជាតិធំៗ។

ការមានស្ថានភាពជាអង្គការមួយតម្រូវឱ្យមានភាពផ្លូវការក្នុងកម្រិតជាក់លាក់ (ការចុះបញ្ជីការរាយការណ៍ ផ្នែកហិរញ្ញវត្ថុ។ល។) ប៉ុន្តែអង្គការសង្គមស៊ីវិលនៅតែមានទំហំផ្សេងៗ ពីគ្នាមានគោលដៅ និងមុខងារខុសៗគ្នា។ សង្គមស៊ីវិលដែលពាក់ព័ន្ធជាពិសេសជាមួយនឹង ADB រួមមានអង្គការក្រៅរដ្ឋាភិបាល (NGOs) អង្គការតាមសហគមន៍ (CBOs) និងអង្គការរបស់ប្រជាពលរដ្ឋ មូលនិធិសមាគមវិជ្ជាជីវៈ វិទ្យាស្ថានស្រាវជ្រាវ និងសកលវិទ្យាល័យ សហជីព អង្គការមហាជន ចលនាសង្គម និងសម្ព័ន្ធភាព និង/ឬបណ្ដាញអង្គការសង្គមស៊ីវិល និងអង្គការសមាជិកភាព។ សូមមើល ព័ត៌មានបន្ថែមអំពីអង្គការសង្គមស៊ីវិល នៅក្នុងឧបករណ៍ទី ៦ : ធ្វើការងារជាមួយអង្គការសង្គមស៊ីវិល។

ការចូលរួមរបស់សង្គមស៊ីវិល ជម្រុញឱ្យអ្នកពាក់ព័ន្ធទាំងនេះចូលរួម នៅក្នុងសកម្មភាពអភិវឌ្ឍន៍នានា។ ជាពិសេសវាផ្ដល់លទ្ធភាពឱ្យមានការចូលរួមពីជនក្រីក្រស្ត្រី និងក្រុមដែលអាចបាត់បង់ឱកាសផ្សេងទៀត ដែលមិនបានចូលរួមនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ដែលប៉ះពាល់ជីវិតរបស់ពួកគេ។ ការចូលរួមរបស់សង្គមស៊ីវិលក៏មានសារៈសំខាន់ផងដែរ ចំពោះការពង្រឹងទំនាក់ទំនងរវាងរដ្ឋ និងប្រជាពលរដ្ឋ និងការកសាងនូវគណនេយ្យភាពរបស់ ស្ថាប័ន។

## ហេតុអ្វីបានជាការចូលរួមមានសារៈសំខាន់?

ការចូលរួមគាំទ្រដល់អភិបាលកិច្ចល្អការបំពេញកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ និងគណនេយ្យភាពរបស់រដ្ឋ។ ការចូលរួមលើកកម្ពស់ឱ្យមានការចូលរួមពីក្រុមដែលបាត់បង់ឱកាសនៅក្នុងសង្គម និងកំណើនសេដ្ឋកិច្ចប្រកបដោយ សមធម៌។

### គណនេយ្យភាពរបស់ស្ថាប័ន : ធ្វើឱ្យសេវាកម្មមានប្រសិទ្ធភាពសម្រាប់ប្រជាពលរដ្ឋក្រីក្រ

របាយការណ៍អភិវឌ្ឍន៍ពិភពលោកឆ្នាំ ២００៤ ផ្ដោតជាក់លាក់លើការយកចិត្តទុកដាក់ ចំពោះប្រជាពលរដ្ឋនៅក្នុងការផ្ដល់សេវាសាធារណៈ តាមរយៈការផ្ដល់លទ្ធភាពឱ្យពួកគេធ្វើការពិនិត្យតាមដានការផ្ដល់សេវា និងបញ្ចេញសម្លេង នៅក្នុងការតាក់តែងគោល នយោបាយ។[ក] ចំពោះសេវាដែលរដ្ឋជាអ្នកទទួលខុសត្រូវផ្ដល់ និងតាមរយៈការផ្ដល់ប្រាក់ដោយប្រយោលដូចជាតាមរយៈការយកពន្ធជាដើម ប្រជាពលរដ្ឋ ឬអតិថិជនមិនអាចប្រើប្រាស់ការបង់ថ្លៃសេវា ដើម្បីទាមទារឱ្យអ្នកផ្ដល់សេវាមានការទទួលខុសត្រូវបានឡើយ។ យន្តការដែលមានការចូលរួមផ្ដល់លទ្ធភាពឱ្យពួកគេមានឥទ្ធិពលលើអ្នកតាក់តែងគោលនយោបាយ និងអ្នកផ្ដល់សេវា។ ADB លើកទឹកចិត្តឱ្យមានការដាក់បញ្ចូលការវិភាគល្អិតល្អន់លើអ្នកពាក់ព័ន្ធ និងលើគណនេយ្យភាព ទៅក្នុងការវិភាគសេដ្ឋកិច្ចដើម្បីផ្ដល់ជាព័ត៌មានដល់ការរៀបចំគម្រោងសេវាសាធារណៈ, ការប្រើប្រាស់ប័ណ្ណរាយការណ៍របស់ប្រជាជន និងឧបករណ៍ដទៃទៀតដើម្បីទាមទារឱ្យអ្នកផ្ដល់សេវាមានគណនេយ្យភាពដោយផ្ទាល់ និងប្រើប្រាស់អភិក្រមនានាដើម្បីមានឥទ្ធិពលលើការសម្រេចចិត្តរបស់ រដ្ឋាភិបាល ដូចជា ការអង្កេតតាមដានចំណាយ ដោយមានការចូលរួម ជាដើម។[ខ] អភិក្រមដើម្បីពង្រឹងទំនាក់ទំនងរវាងស្ថាប័នរដ្ឋ និងប្រជាពលរដ្ឋមានគោលបំណងលើកកម្ពស់គណនេយ្យភាព និងកែលំអការផ្ដល់សេវាសាធារណៈ។ អង្គការសង្គមស៊ីវិលអាចជួយដល់ដំណើរការនេះតាមរយៈការធ្វើជាតំណាងឱ្យសម្លេងផ្នែកផ្សេងៗរបស់សង្គម និងតាមរយៈការបង្កើតនូវស្ថានមួយដើម្បីរៀបចំឱ្យមានការចូលរួមពីប្រជាពលរដ្ឋឱ្យបានកាន់តែច្រើននាក់បន្ថែមទៀត។

[ក] World Bank. 2004. *World Development Report. Making Services Work for Poor People.* Washington, DC.

[ខ] ADB. 2004. *Sector Diagnosis in Education.* Manila; ADB. 2005. *Improving the Relevance and Feasibility of Agriculture and Rural Development Operations: How Economic Analyses Can Help.* Manila.

សារៈសំខាន់នៃការចូលរួមមានភាពពាក់ព័ន្ធជាមួយនឹងប្រធានបទទាំង ៥ នៃសេចក្តីប្រកាសទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ៖ ភាពជាម្ចាស់សុខុដុមនីយកម្ម ការតម្រឹមការគ្រប់គ្រងដើម្បីសម្រេច លទ្ធផល និងគណនេយ្យភាពចំពោះគ្នាទៅវិញទៅមក។ នេះត្រូវបានគាំទ្របន្ថែមទៀត ដោយផែនការសកម្មភាពទីក្រុង អាក្រា ដែលសង្គមស៊ីវិលបំពេញតួនាទីធំជាងមុន នៅក្នុងការបង្កើតផែនការសកម្មភាពនេះ។[៥] ADB ធ្វើការងារជាមួយ នឹងរដ្ឋាភិបាលរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ក្នុងនាមជាសមភាគីចម្បង ប៉ុន្តែក៏ធ្វើការងារជាមួយនឹងអតិថិជនវិស័យឯកជនផងដែរ ការចូលរួមត្រូវការពេលវេលា ប៉ុន្តែការចូលរួមនៅកម្រិតគោលនយោបាយកម្មវិធីប្រចាំប្រទេស និងគម្រោងអាចកែលំអការកំណត់បញ្ហា និងការស្វែងយល់ពីបញ្ហា ចេញពីទស្សនវិស័យផ្សេងៗ បង្កើនកម្រិតនៃការគាំទ្រពីអ្នកពាក់ព័ន្ធជាច្រើន និងបង្កើនភាពជាម្ចាស់ ភាពស័ក្តិសិទ្ធិ និងនិរន្តរភាព នៅក្នុងការអនុវត្ត។

នៅកម្រិតគម្រោង ការចូលរួមកាត់បន្ថយបញ្ហាប្រឈមក្នុងកំឡុងពេលអនុវត្ត។ ការចូលរួមអាចលើកកម្ពស់ ការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀត។ ជាពិសេសការចូលរួមរបស់សង្គមស៊ីវិលលើកទឹកចិត្តឱ្យមានគំនិតច្នៃប្រឌិតថ្មី និងភាពឆ្លើយតបហើយមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងប្រសិទ្ធភាពនៃការអភិវឌ្ឍ ដែលមានលក្ខណៈវិជ្ជមាន។[៦] ការចូលរួមប្រើប្រាស់ជំនាញ និងចំណេះដឹងរបស់សង្គមស៊ីវិល ហើយជួយសម្រិតសម្រាំងសកម្មភាពនានា ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែជិតស្និទ្ធថែមទៀត។
ADB ត្រូវបានគេផ្តល់តម្លៃលើសមត្ថភាព ក្នុងការអនុវត្តគម្រោងប្រកបដោយគុណភាព ដែលជួយកាត់បន្ថយភាពក្រីក្រ។ ចុងក្រោយការចូលរួមអាចធ្វើឱ្យលទ្ធផលការងារកាន់តែមានភាពល្អប្រសើរ និងបង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍ។ ការវាយតម្លៃជាច្រើនដែលធ្វើឡើងដោយនាយកដ្ឋានវាយតម្លៃឯករាជ្យ (IED) បានរំលេចឱ្យឃើញពី វឌ្ឍនភាពនៅក្នុងការបញ្ជ្រាបអភិក្រមដែលមានការចូលរួម និងការជម្រុញឱ្យមានការចូលរួមពីសំណាក់សង្គមស៊ីវិល និងជនដែលរងផលប៉ះពាល់ទៅក្នុងប្រតិបត្តិការការងាររបស់ ADB។[៧] ការវាយតម្លៃរបស់ IED បង្ហាញដូចៗ គ្នាពីគុណតម្លៃខ្ពស់នៃការចូលរួម និងការបន្តភាពចាំបាច់ដើម្បីពង្រឹង និងកែលំអការអនុវត្តនានា នៅក្នុងប្រតិបត្តិការការងាររបស់ ADB។

---

"អភិក្រមដែលមានការចូលរួម អាចបន្ថែមគុណតម្លៃចំពោះការរៀបចំការអនុវត្ត និងប្រតិបត្តិការគម្រោង គ្រប់គ្រងធនធានធម្មជាតិ ហើយនៅពេលដែលមានការអនុវត្តបានត្រឹមត្រូវ ការចូលរួមអាចបង្កើនភាពជាម្ចាស់ និងនិរន្តរភាព និងផ្តល់នូវផលប្រយោជន៍ធំៗ ដូចជាចំណូលនៅតំបន់ជនបទ និងការកាត់បន្ថយភាពក្រីក្រជាដើម"។

ប្រភព : ADB. 2003. *Special Evaluation Study: Participatory Approaches in Forest and Water Resource Operations in Selected Developing Member Countries.* Manila.

## អ្វីទៅដែលហៅថាការចូលរួមប្រកបដោយភាពគ្រប់គ្រាន់?

ប្រតិបត្តិការភាគច្រើនរបស់ ADB តែងទទួលបានប្រយោជន៍ពីការចូលរួម ប៉ុន្តែគោលវិធីតែមួយសម្រាប់គ្រប់ សកម្មភាពទាំងអស់មិនមែនជាគោលវិធីដែលសមស្របនោះទេ។ ឧបសម្ព័ន្ធស្ដីពីអណត្តិការងារ ដែលតម្រូវឱ្យមានការចូលរួមរៀបរាប់ពីលក្ខខណ្ឌតម្រូវឱ្យមានការចូលរួមក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រនានារបស់ ADB ។ មគ្គុទេសក៍នេះផ្ដល់នូវឧបករណ៍សម្រាប់គាំទ្រដល់ដំណើរការការងារទាំងនេះ។

គោលវិធី និងភាពស៊ីជម្រៅនៃការចូលរួមមានការប្រែប្រួលទៅតាមវិស័យ ស្ថានភាពនៅមូលដ្ឋាន និងគោលដៅនៃការចូលរួម។ ដោយសារតែ ADB ផ្ដោតសំខាន់លើការសម្រេចនូវលទ្ធផល ដែលអាចវាស់វែងបានជាការសំខាន់ ដែលត្រូវបញ្ជាក់ពីលទ្ធផលដែលចង់បាននៃដំណើរការចូលរួម និងសូចនាករគោលដៅនានា។ តែទោះជាយ៉ាងណាក៏ដោយនៅក្នុងគ្រប់ករណីទាំងអស់ការចូលរួមដែលគ្រប់គ្រាន់រួមមាន :

- **ការវិភាគលើអ្នកពាក់ព័ន្ធ** ដើម្បីស្វែងយល់ថាតើអ្នកណា ដែលចាប់អារម្មណ៍ចំពោះសកម្មភាពដែលជួយដោយ ADB និងអំពីទំនាក់ទំនងរបស់ពួកគេ (ឧបករណ៍ទី ១ : ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់)
- **ការពិគ្រោះយោបល់ជាមួយក្រុមអ្នកពាក់ព័ន្ធ** ក្នុងការពិនិត្យឡើងវិញលើគោលនយោបាយ ឬយុទ្ធសាស្ត្រណាមួយ ឬនៅក្នុងការរៀបចំគម្រោងដើម្បីស្វែងយល់ពីការយល់ឃើញរបស់ពួកគេ (ឧបករណ៍ទី ១ : ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់, ឧបករណ៍ទី ២ : ការបង្កើនការចូលរួមឱ្យដល់កម្រិតអតិបរមា នៅក្នុង DMF និង ឧបករណ៍ទី ៣ : ការវាយតម្លៃ ដោយមានការចូលរួម)
- **ការជម្រុញឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ** ក្នុងលក្ខណៈជាប្រព័ន្ធដោយប្រើប្រាស់ផែនការស្ដីពីការចូលរួម ដែលត្រូវបានឯកភាពគ្នា (ឧបករណ៍ទី ៤ : បង្កើតផែនការស្ដីពីការចូលរួម) និងយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ (ឧបករណ៍ទី ៥ : បង្កើតយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ)។ ការចូលរួមមានការប្រែប្រួលហើយអាចរាប់បញ្ចូលការផ្ដល់សេវា ឬការចូលរួមនៅក្នុងការពិនិត្យតាមដាន និងការវាយតម្លៃ (ឧបករណ៍ទី ៦ : ការធ្វើការងារជាមួយអង្គការសង្គមស៊ីវិល និងឧបករណ៍ទី ៧ : ការពិនិត្យតាមដាន និងការវាយតម្លៃ ដោយមានការចូលរួម) និង
- **ការផ្ដល់ព័ត៌មានដល់អ្នកពាក់ព័ន** អំពីយន្តការគណនេយ្យភាព។ ប្រភេទគម្រោងមួយចំនួនទទួលបានប្រយោជន៍ពីការចូលរួមក្នុងកម្រិតខ្ពស់ : ជាពិសេសគម្រោងដែលមានគោលបំណងកាត់បន្ថយភាពក្រីក្រ តាមរយៈការអភិវឌ្ឍជនបទ និងមុខរបរចិញ្ចឹមជីវិត ការផ្ដល់ភាពអង់អាចដល់ស្ត្រី ការលើកកម្ពស់អភិបាលកិច្ចមូលដ្ឋាន និងការលើកកម្ពស់លទ្ធផល នៃការអប់រំ និងសុខភាព។ ការចូលរួមរបស់សង្គមស៊ីវិល អាចធ្វើឱ្យការផ្ដល់សេវាសាធារណៈកាន់តែមានភាពប្រសើរឡើង។ ឧទាហរណ៍គម្រោងមួយដែល បង្កើតក្រុមអ្នកប្រើប្រាស់ទឹក (ជាអង្គការតាមសហគមន៍) ដែលទទួលខុសត្រូវលើការកំណត់តម្លៃប្រើប្រាស់ ឬការចែកចាយទឹកបានផ្ដល់លទ្ធភាពឱ្យសង្គមស៊ីវិលចូលរួមនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្ត។

គម្រោងដែលមានហានិភ័យសង្គមខ្ពស់ ដូចជាគម្រោងដែលពាក់ព័ន្ធនឹងការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត របស់មនុស្សជាច្រើនឬរបស់សកម្មភាពជាច្រើននៅក្នុងតំបន់មួយ ដែលមានជនជាតិដើមរស់នៅច្រើន តម្រូវឱ្យមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យដើម្បីបញ្ចៀសមិនឱ្យមានផលប៉ះពាល់ជាអវិជ្ជមាន ដូចដែលបានកំណត់នៅក្នុង គោលនយោបាយស្ដីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថានរបស់ ADB ។[៨] សូមមើល

ទំព័រទី ៦៥ អំពីនិយមន័យរបស់ ADB ស្ដីពី "កិច្ចពិគ្រោះយោបល់ប្រកបដោយអត្ថន័យ"។ បទពិសោធន៍របស់ ADB ផ្នែកហេដ្ឋារចនាសម្ព័ន្ធ បង្ហាញ ឱ្យឃើញពីសារៈសំខាន់នៃការពិគ្រោះយោបល់នេះ ដោយបង្ហាញឱ្យឃើញថា ការផ្ដល់លទ្ធភាពឱ្យមានការចូលរួមពី សំណាក់សហគមន៍ អាចបញ្ជៀសបញ្ហា និងធ្វើឱ្យការរៀបចំកាន់តែល្អប្រសើរ និងបង្កើនប្រសិទ្ធភាពនៃការអនុវត្ត។ សហគមន៍ក៏គួរដឹងពីរបៀបប្រើប្រាស់យន្តការគណនេយ្យភាពផងដែរ ប្រសិនបើមានបញ្ហាកើតមានឡើង។

ផែនការស្ដីពីការចូលរួម គឺជាឧបករណ៍រៀបចំផែនការ និងដំណើរការដ៏មានសារៈសំខាន់មួយ សម្រាប់ផ្ដល់ការ ណែនាំដល់ការងារគ្រប់បែបយ៉ាង ចាប់ពីសកម្មភាពក្នុងទ្រង់ទ្រាយតូចរហូតដល់សមាសភាគគម្រោងធំៗ ដែលមានច្រើនផ្នែក។ ផែនការនេះអាចមានភាពបត់បែន និងអាចជាផែនការតែឯង ឬអាចត្រូវបានដាក់បញ្ចូលជាផ្លូវការទៅក្នុង ផែនការស្ដីពីការតាំងទីលំនៅ ផែនការយេនឌ័រ ឬផែនការដទៃទៀត។ មគ្គុទេសក៍ត្រូវបានគេប្រើប្រាស់ នៅក្នុងពេលធ្វើ ការពិនិត្យឡើងវិញលើគម្រោងនានា ដើម្បីធ្វើការសម្រេចចិត្តថាផែនការសម្រាប់ការចូលរួម នៅក្នុងការអនុវត្តគម្រោង មានភាពសមស្របដែរឬទេ និងដើម្បីពិនិត្យលើភាពគ្រប់គ្រាន់នៃការចូលរួម នៅក្នុងការរៀបចំ។

## តើការចូលរួមជួយប្រទះបញ្ហាប្រឈមអ្វីខ្លះ?

ការចូលរួមដែលទទួលបានជោគជ័យទាមទារឱ្យមានការប្ដេជ្ញាចិត្តចំពោះដំណើរការនេះ សមត្ថភាព និងធនធានគ្រប់គ្រាន់ និងភាពបត់បែនក្នុងការបំពេញការងារជាមួយអ្នកពាក់ព័ន្ធ និងដាក់បញ្ចូលនូវគំនិតយោបល់របស់ពួកគេ។ អវត្តមាននៃបរិយាកាសអំណោយផល (ច្បាប់នយោបាយ ឬវប្បធម៌) អាចធ្វើឱ្យការចូលរួមមានការលំបាក។ ប្រសិនបើមិនមានតម្លាភាពនោះទេការចូលរួមអាចធ្វើឱ្យមានការរំពឹងទុកខុស ហើយអ្នកពាក់ព័ន្ធអាចនឿយណាយនឹង ការចូលរួម ប្រសិនបើពួកគេមិនឃើញមានការឆ្លុះបញ្ចាំងពីការព្រួយបារម្ភរបស់ពួកគេ នៅក្នុងសកម្មភាពរបស់ ADB ឬរបស់រដ្ឋាភិបាល។ វាក៏អាចធ្វើទំនាស់សង្គមដែលមានស្រាប់កាន់តែធ្ងន់ធ្ងរផងដែរ ប្រសិនបើការចូលរួមនេះមិនយុត្តិធម៌ ហើយអាចរក្សា និងផ្ដល់ភាពស្របច្បាប់ដល់ទំនាក់ទំនងអំណាចដែលមានស្រាប់ប្រសិនបើក្រុមអ្នកពាក់ព័ន្ធមិនបានយល់ឱ្យបានគ្រប់គ្រាន់ ហើយមានទំនាក់ទំនងបែបនេះ។ នេះគឺជាការពិតក្នុងស្ថានភាពរសើបនៅតាមរដ្ឋដែលមានភាពផុយស្រួយ និងដែលរងផលប៉ះពាល់ដោយសារទំនាស់ (FCAS)។ ADB និងអ្នកខ្ចី និង/ឬអតិថិជនអាចមានការព្រួយបារម្ភថា តម្រូវការរបស់អ្នកពាក់ព័ន្ធនឹងគំរាមកំហែងដល់ដំណើរការការងារ ឬអាចធ្វើឱ្យមានទំនាស់កើតមានឡើង ប្រសិនបើអ្នកពាក់ព័ន្ធជំទាស់នឹងផែនការ។ នៅក្នុងការដោះស្រាយវិវាទនានា ជាការសំខាន់ណាស់ដែលត្រូវស្ដាប់ ការព្រួយបារម្ភនានា និងធ្វើការវាយតម្លៃលើភាពស្របច្បាប់ប្រកបដោយភាពយុត្តិធម៌ និងធ្វើឱ្យបានឆាប់។ ជារឿយៗ ការធ្វើបែបនេះត្រូវមានការចូលរួមពីភាគីទី ៣ ដែលអព្យាក្រឹត។

ជាទូទៅគោលវិធីដែលបត់បែន និងមានលក្ខណៈច្នៃប្រឌិតថ្មី ដែលសម្រិតសម្រាំងឡើងឱ្យស្របទៅនឹងបរិបទ ជួយគ្រប់គ្រងបញ្ហាប្រឈមនានា ដូចដែលបង្ហាញនៅក្នុងឧទាហរណ៍ក្នុងមគ្គុទេសក៍នេះ។ ប្រសិនបើធ្វើបានល្អការចូលរួមអាចនាំឱ្យការរៀបចំគោលនយោបាយកម្មវិធី និងគម្រោងកាន់តែមានភាពសមស្រប ហើយការអនុវត្តកាន់តែមាន ភាពរលូន។

## តើអ្នកណាខ្លះ ដែលចូលរួម?

មូលហេតុមួយក្នុងចំណោមមូលហេតុនានា ដែលធ្វើឱ្យមនុស្សមួយចំនួនមានមន្ទិលសង្ស័យចំពោះការអភិវឌ្ឍ ដោយមានការចូលរួមគឺគេគិតថា ការអភិវឌ្ឍបែបនេះ គឺជាដំណើរការប្រជាធិបតេយ្យពេញលេញ ដែលគ្រប់អ្នកពាក់ព័ន្ធទាំងអស់គួរមានឥទ្ធិពល និងអាចត្រួតត្រាលើការអភិវឌ្ឍ និងការគ្រប់គ្រងក្នុងកម្រិតមួយបាន។ ប៉ុន្តែការអភិវឌ្ឍដោយមានការចូលរួមមិនមែនមានន័យថាជាលទ្ធិប្រជាធិបតេយ្យពេញលេញ និងដោយផ្ទាល់នោះទេ។ ឧទាហរណ៍ការពិគ្រោះយោបល់ជាមួយកសិករចំនួន ២០០០០០ នាក់ នៅក្នុងតំបន់មួយអំពីគម្រោងធារាសាស្ត្រដែលស្នើឡើងជាមួយនឹងការផ្ដល់មូលនិធិពី ADB គឺជាការពិគ្រោះយោបល់ដែលមិនមានប្រយោជន៍ និងមិនអាចធ្វើទៅរួចឡើយ ដោយសារតែកត្តាចំណាយ។ ឧទាហរណ៍មួយទៀត ការផ្ដល់លទ្ធភាពឱ្យមានការចូលរួមតែពី មេភូមិ នឹងមិនអាចការពារសិទ្ធិរបស់ប្រជាពលរដ្ឋដែលជួបប្រទះការលំបាកទាំងអស់បានឡើយ។ រវាងអភិក្រមទាំងពីរនេះ មាន ជម្រើសជាច្រើន ដែលផ្ដល់នូវសក្ដានុពលសម្រាប់ការចូលរួមក្នុងកម្រិតសមស្របសម្រាប់គោលបំណងផ្សេងពីគ្នា និងដែលមានបំណងផ្ដល់នូវឱកាសស្មើភាពគ្នា។ មគ្គុទេសក៍នេះធ្វើការស្វែងយល់ពីជម្រើសទាំងនេះយ៉ាងស៊ីជម្រៅដូចជាការប្រើប្រាស់ការអង្កេតតំណាង វិធីសាស្ត្រវាយតម្លៃដោយមានការចូលរួម (ដូចជា ការពិភាក្សាក្រុមគោលដៅ ការដើរមើលក្នុងសហគមន៍) និងកិច្ចប្រជុំពិគ្រោះយោបល់ជាដើម។ វិស័យ និងគម្រោងនីមួយៗ ចាំបាច់ត្រូវកំណត់ពីគោលវិធីដែលល្អបំផុត និងភាពស៊ីជម្រៅនៃការចូលរួមដែលនឹងផ្ដល់លទ្ធភាពឱ្យមានតំណាងគ្រប់គ្រាន់របស់អ្នកពាក់ព័ន្ធ រួមទាំងប្រជាពលរដ្ឋក្រីក្រ និងអ្នកដែលជួបប្រទះការលំបាកផងដែរ ដោយចាំបាច់ឱ្យអស់ចំណាយខ្លាំងពេក។ អ្នកអនុវត្តត្រូវវិធានាយ៉ាងណាឱ្យការចូលរួមនៅក្នុងសកម្មភាពគម្រោងពីសំណាក់អ្នកដែលជួបប្រទះការលំបាក គឺជាការចូលរួមប្រកបដោយប្រសិទ្ធភាព និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។

ប្រភព៖ ADB. 2003. *Special Evaluation Study: Participatory Approaches in Forest and Water Resource Operations in Selected Developing Member Countries.* Manila.

## តើការចូលរួមអស់ចំណាយប៉ុន្មាន?

ការចូលរួមឱ្យបានគ្រប់គ្រាន់នៅកម្រិតគោលនយោបាយកម្មវិធីប្រចាំប្រទេស និងគម្រោងតម្រូវឱ្យមានការចំណាយពេលវេលា និងធនធានហិរញ្ញវត្ថុបន្ថែមនៅពេលចាប់ផ្ដើមដំបូង។ ប៉ុន្តែនៅក្នុងវដ្ដរបស់គម្រោងទាំងមូល គេមិនរំពឹងថានឹងមានការចំណាយធនធានបន្ថែមនោះទេ។ ការប្រើប្រាស់ដំណើរការដោយមានការចូលរួមគួរពន្លឿនការអនុវត្តគម្រោង ដោយមានការផ្លាស់ប្ដូរតិចតួចជាងមុនចំពោះវិសាលភាពរបស់គម្រោង និងមានការពន្យារពេលតិចតួចជាងមុន។[៥] ការខាតបង់ដោយសារការមិនចូលរួម រួមមានការខាតបង់ផ្នែកហិរញ្ញវត្ថុ (ឧ. ដោយសារមានការផ្ដល់ជាសំណង និងការពន្យារពេល) និងការខូចខាតកេរ្តិ៍ឈ្មោះ។

ការវាយតម្លៃជាអន្តរជាតិលើចំណាយ និងប្រយោជន៍ដែលទទួលបានពីការចូលរួមក្នុងគម្រោងអភិវឌ្ឍន៍គាំទ្រដល់ការលើកឡើងខាងលើនេះ។ការវាយតម្លៃទាំងនេះបង្ហាញថាការចំណាយខ្ពស់របស់គម្រោងដែលមានការចូលរួមនៅដំណាក់កាលដំបូងៗ អាចផ្ដល់នូវផលតបស្នងមកវិញតាមរយៈ

ការពន្យារពេលតិចតួចជាងមុន និងការបង្កើនប្រសិទ្ធភាព និងនិរន្តរភាពច្រើនជាងមុន នៅដំណាក់កាលក្រោយៗ។[១០] សំណួរទី ២ នៅក្នុងផ្នែកសំណួរដែលគេតែងសួរញឹកញាប់ មានបង្ហាញពីឧទាហរណ៍អំពីការសិក្សាទាំងនេះ។ ពុំមានរូបមន្តស្តង់ដាណាមួយ អាចកំណត់ពីការចំណាយលើការចូលរួមបាននោះទេ។ ការពិនិត្យឡើងវិញលើគោលនយោបាយ ឬយុទ្ធសាស្ត្រតាមវិស័យមួយចំនួនរបស់ ADB អាចតម្រូវឱ្យមានការចំណាយថវិកាជាច្រើនសម្រាប់កិច្ចពិគ្រោះយោបល់ និងការប្រាស្រ័យទាក់ទងជាអន្តរជាតិ។ ការចំណាយនឹងមានចំនួនតិចតួចជាង សម្រាប់យុទ្ធសាស្ត្រស្តីពីភាពជាដៃគូប្រចាំប្រទេស ដែលផ្តោតលើប្រទេសតែមួយៗ។

នៅកម្រិតគម្រោង ការចំណាយមានការប្រែប្រួលទៅតាមប្រភេទគម្រោង។ ការចំណាយនានា រួមមានចំណាយដែលត្រូវយកចេញពីថវិកាជំនួយបច្ចេកទេសរៀបចំគម្រោង (PPTA) ដែលចាំបាច់ ដើម្បីផ្តល់លទ្ធភាពឱ្យមាន ការចូលរួមពីអ្នកពាក់ព័ន្ធ ក្នុងការរៀបចំគម្រោង និងដើម្បីបង្កើតផែនការស្តីពីការចូលរួម (ដូចជាសិក្ខាសាលារបស់អ្នកពាក់ព័ន្ធជាដើម)។ ចំណាយទាំងនេះ ក៏រាប់បញ្ចូលផងដែរនូវចំណាយសម្រាប់បេសកកម្មពិនិត្យឡើងវិញ និង សកម្មភាពតាមដានបន្តផ្សេងទៀត លើការអនុវត្ត និងការពិនិត្យតាមដាន។ គម្រោង ដែលមានផែនការស្តីពីការចូលរួមក្នុងកម្រិតល្មមនឹងមិនត្រូវការពេលវេលា ឬចំណាយបន្ថែមច្រើនឡើយ។ ប៉ុន្តែគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ ឬគម្រោងអភិវឌ្ឍន៍សង្គមដែលមានការចូលរួមក្នុងកម្រិតខ្ពស់ ដែលព្យាយាមធ្វើឱ្យមានការចូលរួមជាផ្លូវការ តម្រូវ ឱ្យមានការវិនិយោគជាជំនួយឥតសំណង ឬកម្ចីយ៉ាងច្រើន។

ជារឿយៗ ក្រុមការងារបេសកកម្មតែងលើកឡើងថាកាលបរិច្ឆេទកំណត់ដែលមានភាពតឹងរ៉ឹង និងការថយចុះ នូវថវិកាសម្រាប់ជំនួយបច្ចេកទេសថាជាឧបសគ្គ ដែលរារាំងមិនឱ្យមានការចូលរួមយ៉ាងសកម្មរបស់អ្នកពាក់ព័ន្ធនៅក្នុងប្រតិបត្តិការកម្ចី។ មគ្គុទេសក៍នេះឆ្លើយតបទៅនឹងសំណួរជាមូលដ្ឋានអំពីការចូលរួម និងកំណត់នូវឧបករណ៍ និងដំបូន្មានដើម្បីធានាឱ្យមានការប្រើប្រាស់ធនធានដែលមានកម្រិតឱ្យបានល្អ។ ឧទាហរណ៍ជាច្រើន ដែលបង្ហាញពីការអនុវត្តល្អផ្នែកការចូលរួមនៅក្នុងសកម្មភាពដែលទទួលបានជំនួយពី ADB បង្ហាញឱ្យឃើញពីវិធីល្អៗជាច្រើន ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ។

ការសិក្សារបស់មជ្ឈមណ្ឌលអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល (NGOC) ឆ្នាំ ២០០៧ ដែលមិនត្រូវបានបោះពុម្ពផ្សាយមួយលើចំណាយនៃការដាក់បញ្ចូលការចូលរួម បានធ្វើការស្រាវជ្រាវអំពីគម្រោងរបស់ ADB ដែលមានការចូលរួមច្រើននៅក្នុងការរៀបចំ។ ទៅតាមការរំពឹងទុកការសិក្សានេះបានរកឃើញថា ចំណាយប្រែប្រួលទៅតាមគោលវិធីដែលប្រើប្រាស់។ ឧទាហរណ៍ចំណាយលើការចែករំលែកព័ត៌មាន និងការពិគ្រោះយោបល់ដែលជាផ្នែកមួយរបស់ PPTAs មានចាប់ពី ១៦% ទៅ ៥៥% នៃថវិការបស់ PPTA។ កិច្ចសហប្រតិបត្តិការអាចរួមមានការជួលអ្នកពាក់ព័ន្ធខាងក្រៅឱ្យចូលរួម នៅក្នុងការរៀបចំគម្រោង ជាដើម។[១១]

# ២ ការចូលរួមនៅក្នុងការពិនិត្យឡើងវិញលើ គោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេស របស់ ADB

កិច្ចពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធចម្រុះក្នុងពេលតាក់តែង និងពិនិត្យឡើងវិញលើគោលនយោបាយ និងយុទ្ធសាស្ត្រនានា មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីធានាយ៉ាងណាឱ្យគោលនយោបាយនានាឆ្លុះបញ្ចាំងពីការអនុវត្ត ល្អបំផុតជាអន្តរជាតិ និងដាក់បញ្ចូលនូវគំនិតយោបល់ និងតម្រូវការរបស់អ្នកដែលគោលនយោបាយទាំងនោះមានគោលបំណងគាំទ្រ។ ដំណើរការនៃការចូលរួមនេះបង្កើនការយល់ដឹង និងភាពជាម្ចាស់របស់គោលនយោបាយ និង សម្រួលដល់ការអនុវត្ត។

ប្រភព៖ ADB. 2006. *Staff Instructions on Definition of Directional Documents and Processing of Policy and Strategy Papers.* Manila.

## សេចក្តីផ្តើម

ADB តែងស្នើសុំគំនិតយោបល់ពីអ្នកជំនាញ និងអ្នកពាក់ព័ន្ធខាងក្រៅនៅពេលធ្វើការបង្កើត និងពិនិត្យឡើងវិញលើគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសរបស់ខ្លួន (ផ្អែកទៅតាមយុទ្ធសាស្ត្រស្តីពីភាពជាដៃគូប្រចាំប្រទេស [CPS])។ គោលនយោបាយទាំងនេះរួមមានគោលនយោបាយស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាន (SPS) ២០០៩ និងគោលនយោបាយស្តីពីការប្រាស្រ័យទាក់ទងសាធារណៈ (PCP) ២០១១។

## ហេតុអ្វីបានជាការចូលរួមមានសារៈសំខាន់ ចំពោះការពិនិត្យឡើងវិញលើគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំ ប្រទេសរបស់ ADB?

ការចូលរួមតាមរយៈការពិគ្រោះយោបល់អាចទទួលបាននូវធាតុចូល និងដំបូន្មានពីអ្នកពាក់ព័ន្ធជាច្រើន ដែលអាចរកផលប៉ះពាល់ដោយសារឯកសារនេះ ក៏ដូចជាពីអ្នកជំនាញនៅក្នុងផ្នែកនេះ។ គោលវិធីដែលមានការចូលរួមបង្កើតនូវលទ្ធផលដែល

- មានទំនាក់ទំនងប្រសើរជាងមុនជាមួយនឹងបរិបទមូលដ្ឋាន
- មានលក្ខណៈល្អប្រសើរជាងគេផ្នែកបច្ចេកទេស
- អនុវត្តទៅតាមការអនុវត្តល្អជាអន្តរជាតិ

- មានសុខដុមនីយកម្មជាមួយនឹងដៃគូអភិវឌ្ឍន៍ដទៃទៀត (លេខយោងចុងក្រោយទី ៥) និង
- ឆ្លុះបញ្ចាំងពីព័ត៌មាន និងទស្សនវិស័យជាច្រើន

សរុបដោយខ្លួន ឯកសារនេះទទួលបានប្រយោជន៍ពីចំណេះដឹង និងបទពិសោធន៍របស់អ្នកដែលរួមចំណែក ចំពោះការពិគ្រោះយោបល់ ។[១២]

ការពិគ្រោះយោបល់ក៏បង្កើនការយល់ដឹង របស់ភាគីពាក់ព័ន្ធអំពីគោលដៅ និងប្រតិបត្តិការការងាររបស់ ADB និងរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិកផងដែរ ហើយធានាថាឯកសារនានា នឹងទទួលបានប្រយោជន៍ពីការកើនឡើងនូវភាពជាម្ចាស់ និងការគាំទ្រពីអ្នកពាក់ព័ន្ធជាច្រើន។ ចុងក្រោយការពិគ្រោះយោបល់សម្រួល និងធ្វើឱ្យការអនុវត្តមានភាពល្អប្រសើរជាងមុន និងបង្កើនផលរយៈពេលវែងរបស់គោលនយោបាយ ដល់កម្រិតអតិបរមា ។[១៣]

## របៀបអនុវត្តដំណើរការបង្កើត ឬពិនិត្យឡើងវិញ ដោយមានការចូលរួម

ដំបូន្មានអំពីការវិភាគ និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធប្រកបដោយជោគជ័យ នៅក្នុងឧបករណ៍ទី ១ ទំព័រទី ២៦ អាចយកមកអនុវត្តតាមដើម្បីធានាយ៉ាងណាឱ្យដំណើរការបង្កើត ឬពិនិត្យឡើងវិញលើគោលនយោបាយយុទ្ធសាស្ត្រ ឬកម្មវិធីមួយដែលអាចធ្វើឡើងប្រកបដោយប្រសិទ្ធភាពដោយមានការចូលរួម ។ ផ្នែកខាងក្រោមនេះពន្យល់ពីរបៀបដែលការចូលរួមមានភាពសមស្របទៅនឹងដំណើរការពិនិត្យឡើងវិញ ។

### គោលនយោបាយ និងយុទ្ធសាស្ត្រ

ជាធម្មតាឱកាសល្អបំផុតសម្រាប់ឱ្យមានការចូលរួម គឺនៅពេលចាប់ផ្តើម និងពេលបញ្ចប់រយៈពេលរបស់គោលនយោបាយ : នៅពេលបង្កើតគោលនយោបាយថ្មី ឬនៅពេលពិនិត្យឡើងវិញ ឬធ្វើបច្ចុប្បន្នកម្មគោលនយោបាយដែលមានស្រាប់ ។

ឯកសារនានា អាចទទួលបានប្រយោជន៍ពីការបំពេញបន្ថែមយោបល់ផ្ទៃក្នុងរបស់ ADB ជាមួយនឹងគំនិតយោបល់របស់អ្នកពាក់ព័ន្ធខាងក្រៅ ។ ប៉ុន្តែតម្រូវការពិតប្រាកដ និងលក្ខណៈរបស់ការពិនិត្យឡើងវិញខាងក្រៅ គឺប្រែប្រួលទៅតាមប្រធានបទ និងគោលដៅនៃការពិគ្រោះយោបល់ ។ ជារឿយៗអង្គការសង្គមស៊ីវិលធ្វើការពិនិត្យតាមដានការអនុវត្តដោយស្ម័គ្រចិត្ត ។ ពួកគេអាចទាក់ទង ADB ឬមន្ត្រីរដ្ឋាភិបាលហើយគួរមានការពិគ្រោះយោបល់ជាមួយនឹងពួកគេនៅក្នុងកំឡុងពេលមានការពិនិត្យឡើងវិញខាងក្រៅ ។

ការណែនាំរបស់បុគ្គលិក ADB ស្ដីពីនិយមន័យឯកសារណែនាំ និងការវិភាគលើឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រផ្ដល់ជាអនុសាសន៍ឱ្យមានការស្នើសុំការណែនាំពីអ្នកពាក់ព័ន្ធសំខាន់ៗ ទាំងខាងក្នុងទាំងខាងក្រៅ នៅពេលធ្វើការវិភាគ លើឯកសារគោលនយោបាយ ឬយុទ្ធសាស្ត្រ។

ការអនុវត្តល្អផ្នែកការពិគ្រោះយោបល់ខាងក្រៅ ត្រូវរួមផ្សំជាមួយនឹងការពិគ្រោះយោបល់តាមរយៈមធ្យោបាយអេឡិចត្រូនិក និងលាយលក្ខណ៍អក្សរ និងវិធីសាស្ត្រជួបផ្ទាល់ក្នុងប្រទេសជាសមាជិករបស់ ADB ទាំងប្រទេសផ្ដល់ជំនួយ ទាំងប្រទេសកំពុងអភិវឌ្ឍជាសមាជិក។ យ៉ាងហោចណាស់ សេចក្ដីព្រាងចំនួនពីរគួរផ្សព្វផ្សាយ ដើម្បី បានយោបល់ជាការអនុវត្តល្អផ្នែកការពិគ្រោះយោបល់ខាងក្រៅ ត្រូវរួមផ្សំជាមួយនឹងការពិគ្រោះយោបល់តាមរយៈមធ្យោបាយអេឡិចត្រូនិក និងលាយ

លក្ខណ៍អក្សរ និងវិធីសាស្ត្រជួបផ្ទាល់ក្នុងប្រទេសជាសមាជិករបស់ ADB ទាំងប្រទេសផ្ដល់ជំនួយ ទាំងប្រទេសកំពុងអភិវឌ្ឍជាសមាជិក។ យ៉ាងហោចណាស់ សេចក្ដីព្រាងចំនួនពីរគួរផ្សព្វផ្សាយ ដើម្បី បានយោបល់ជាសាធារណៈនៅក្នុងកំឡុងពេលពិនិត្យឡើងវិញនេះ ដែលការធ្វើបែបនេះផ្ដល់នូវពេលវេលាគ្រប់ គ្រាន់ ដើម្បីឱ្យអ្នកពាក់ព័ន្ធអាចផ្ដល់ជាយោបល់។ វិធីសាស្ត្រដែលមានការចូលរួមជាច្រើន ផ្ដល់លទ្ធភាពឱ្យអ្នកដែលគ្មាន ឱកាសអាចផ្ដល់នូវទស្សនៈរបស់ពួកគេហើយអាចបញ្ចៀសការផាត់ចេញអ្នកដែលមិនមានជំនាញភាសាអង់គ្លេស ឬ ដែលមិនអាចប្រើប្រាស់អ៊ីនធឺណិតបាន។

បទពិសោធន៍របស់ ADB រួមមានគំរូថ្មីៗជាច្រើនដូចជាការបង្កើតជា "វេទិកាសរសេរ" ដែលមានការចូលរួម ការជម្រុញឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធខាងក្នុង និងខាងក្រៅនៅក្នុងការពង្រាងផែនការសកម្មភាព និងការរៀបចំការពិគ្រោះយោបល់ដោយផ្ទាល់តាមបែបប្រពៃណី និងការពិគ្រោះយោបល់តាមប្រព័ន្ធអេឡិចត្រូនិច។[១៤]

ឧបករណ៍ទី ១ : ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ផ្ដល់ការណែនាំអំពីវិធីសាស្ត្រវិភាគ និងពិគ្រោះយោបល់ដើម្បីជួយកំណត់អ្នកពាក់ព័ន្ធសំខាន់ៗ និងជ្រើសរើសគោលវិធីឱ្យបានសមស្រប ដើម្បីអាចផ្ដល់សេវា ដល់ក្រុមផ្សេងៗ។

វិធីសាស្ត្រទាំងនេះ មានភាពពាក់ព័ន្ធជាមួយនឹងការពិនិត្យឡើងវិញលើគោលនយោបាយ និងការអភិវឌ្ឍគម្រោង។ លើសពីនេះ *សៀវភៅធនធានសម្រាប់អង្គការសង្គមស៊ីវិល* របស់ ADB បង្ហាញព័ត៌មានលំអិតអំពីការអនុវត្តល្អ ដែលពាក់ព័ន្ធជាមួយនឹងការជម្រុញឱ្យមានការចូលរួមពីសំណាក់អង្គការសង្គមស៊ីវិល ក្នុងការតាក់តែងគោលនយោបាយ។[១៥] នៅពេលដែលការពិគ្រោះយោបល់ខាងក្នុង និងខាងក្រៅត្រូវបានបញ្ចប់រួចរាល់ហើយ អ្នកគ្រប់គ្រងធ្វើការពិភាក្សាអំពីសេចក្ដីព្រាងនេះ ផ្អែកទៅតាមព័ត៌មានត្រឡប់ទទួលបានពីការពិគ្រោះយោបល់ មុនពេលធ្វើការកែសម្រួលកែប្រែ និងដាក់ជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័ត។[១៦]

ការពិនិត្យឡើងវិញដែលធ្វើឡើងនៅក្នុងឆ្នាំ ២០១០ លើគោលនយោបាយស្តីពីការប្រាស្រ័យទាក់ទងសាធារណៈរបស់ ADB និងការពិនិត្យឡើងវិញលើគោលនយោបាយទឹកនៅឆ្នាំ ២០០៥ ផ្តល់នូវឧទាហរណ៍អំពីរបៀបធ្វើ ការពិគ្រោះយោបល់ខាងក្រៅ។

## ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ នៅក្នុងពេលពិនិត្យឡើងវិញលើគោលនយោបាយស្តីពីការប្រាស្រ័យទាក់ទងសាធារណៈ (PCP)

- **សាវតារ :** ADB ត្រូវពិនិត្យឡើងវិញលើ PCP ដែលត្រូវបានអនុម័ត នៅក្នុងខែ កញ្ញា ឆ្នាំ ២០០៥ មិនឱ្យហួស ៥ ឆ្នាំ។
- **គោលដៅ :** ការពិគ្រោះយោបល់នេះផ្តល់លទ្ធភាពឱ្យអ្នកពាក់ព័ន្ធខាងក្នុង និងខាងក្រៅ ផ្តល់នូវគំនិតយោបល់របស់ពួកគេដល់ការពិនិត្យឡើងវិញលើគោលនយោបាយនេះ និងធានាយ៉ាងណាឱ្យគោលនយោបាយថ្មីនេះ អាចបំពេញបានទៅតាមការអនុវត្តល្អៗជាអន្តរជាតិ។
- **វិធីសាស្ត្រ :** ការវិភាគអ្នកពាក់ព័ន្ធ នាំឱ្យមានការបង្កើតផែនការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយមួយ ដែលរួមបញ្ចូលការពិគ្រោះយោបល់តាមរយៈគេហទំព័រ ជាមួយនឹងការពិគ្រោះយោបល់ដោយផ្ទាល់ធ្វើឡើងក្នុងរយៈពេល ៩ ខែ។
  - PCP ២០០៥ និងសេចក្តីព្រាងថ្មីចំនួន ២ ត្រូវបានអាប់ឡូតចូលទៅក្នុងគេហទំព័រ adb.org/PCP-Review ដើម្បីសុំយោបល់ពីសាធារណជនទូទៅ
  - សិក្ខាសាលាពិគ្រោះយោបល់ នៅក្នុងរដ្ឋធានី/រាជធានីរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិកចំនួន ៧ និងប្រទេសសមាជិកមិនមែនជាប្រទេសកំពុងអភិវឌ្ឍចំនួន ៦ ជាមួយនឹងតំណាងមកពីរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ ស្ថាប័នហិរញ្ញវត្ថុពហុភាគីដទៃទៀតអង្គការសង្គមស៊ីវិល វិស័យឯកជន ក្រុមបញ្ញវ័ន្ត ប្រព័ន្ធផ្សព្វផ្សាយ និងស្ថាប័នផ្សេងទៀត។ សំដៅបកប្រែនៃសេចក្តីព្រាងដំបូង ត្រូវបានផ្ញើទៅឱ្យអ្នកចូលរួមជាមុន
  - ការពិគ្រោះយោបល់ជាមួយអ្នកដែលទទួលរងផលប៉ះពាល់ នៅតាមទីតាំងគម្រោងរបស់ ADB នៅក្នុងប្រទេសកំពុងអភិវឌ្ឍជាសមាជិកចំនួន៤ ដោយប្រើប្រាស់ការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងការពិភាក្សាក្រុម ហើយអ្នកសម្របសម្រួលគឺជាអ្នកមកពីអង្គការក្រៅរដ្ឋាភិបាលអត្ថបទនៃការពិគ្រោះយោបល់នេះ ត្រូវបានអាប់ឡូតចូលទៅក្នុងគេហទំព័រ ដោយមានបង្កើតជាតារាងបង្ហាញពីការឆ្លើយតបចំពោះ យោបល់នានា។

**ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ នៅក្នុងការពិនិត្យឡើងវិញលើការអនុវត្តគោលនយោបាយទឹករបស់ ADB នៅក្នុងឆ្នាំ ២០០៥**

- **សាវតារ :** ADB តម្រូវឱ្យមានការពិនិត្យឡើងវិញគ្រប់ជ្រុងជ្រោយលើការអនុវត្តគោលនយោបាយនេះ ៥ ឆ្នាំ ក្រោយទទួលបានការអនុម័ត ។
- **គោលដៅ :** ការពិនិត្យឡើងវិញនេះផ្តល់ឱ្យ ADB និងអ្នកពាក់ព័ន្ធនូវការវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្ត និងអនុសាសន៍ដើម្បីកែលំអប្រតិបត្តិការទឹករបស់ ADB
- **វិធីសាស្ត្រ :** ផែនការពិគ្រោះយោបល់ រៀបរាប់ពីសមាសភាគសំខាន់ៗ ខាងក្រោមដើម្បីអាចផ្តល់ព័ត៌មាន ដល់គ្រប់អ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់ :
- គណៈកម្មាធិការពិនិត្យឡើងវិញមួយ ដើម្បីត្រួតពិនិត្យដំណើរការនេះ ដែលក្នុងនោះមានតំណាងជាមន្ត្រីមកពីប្រទេសកំពុងអភិវឌ្ឍ ជាសមាជិកសង្គមស៊ីវិល អ្នកផ្តល់ជំនួយ និងអ្នកជំនាញមកពីវិស័យឯកជន
- កិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា ដូចជាសង្គមស៊ីវិលនៅតាមតំបន់នីមួយៗក្នុងចំណោមតំបន់ទាំង ៥ របស់ ADB និងការពិគ្រោះយោបល់ដោយឡែកជាមួយសង្គមស៊ីវិល និងវិស័យឯកជន នៅទីក្រុងម៉ានីល
- ព័ត៌មានត្រឡប់ពីអ្នកពាក់ព័ន្ធនានា តាមរយៈការអង្កេត ដែលចែកនៅក្នុងសន្និសីទនានា
- សិក្ខាសាលាសម្រាប់បុគ្គលិក និងអ្នកពិគ្រោះការរបស់ ADB

## សិក្ខាសាលាសម្រាប់បុគ្គលិក និងអ្នកពិគ្រោះការរបស់ ADB

ការរៀបចំ CPS ចាប់ផ្តើមជាមួយនឹងការពិនិត្យលើផែនការអភិវឌ្ឍន៍ជាតិ និងការធ្វើការវិភាគបុរេ CPS ការវាយតម្លៃវិស័យឬផែនទីបង្ហាញផ្លូវ (ឧ. យេនឌ័រភាពក្រីក្រ ហេដ្ឋារចនាសម្ព័ន្ធ អប់រំ ។ល ។) ។ ផែនទីបង្ហាញផ្លូវទាំងនេះ គឺជាកាលនុវត្តភាពដំបូង ដើម្បីធ្វើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងប្រើប្រាស់វិធីសាស្ត្រវាយតម្លៃ ដោយមានការចូលរួម (សូមមើលឧបករណ៍ទី ៣) ។ ការធ្វើសុខដុមនីយកម្មជាមួយនឹងវដ្តគាក់តែងគោលនយោបាយ និងរៀបចំផែនការរបស់រដ្ឋាភិបាល និងរបស់ដៃគូអភិវឌ្ឍន៍ដទៃទៀត មានប្រយោជន៍យ៉ាងខ្លាំង ។

---

គោលការណ៍ណែនាំស្តីពីយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស (CPS) លើកឡើងថាដំណើរការ CPS នឹងមានការចូលរួមយ៉ាងពេញលេញពីអ្នកពាក់ព័ន្ធក្នុងជួររដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលដើម្បីធានាឱ្យមានការប្តេជ្ញាចិត្ត និងភាពជាម្ចាស់យ៉ាងទូលំទូលាយលើ CPS ។

ជាធម្មតាជំហានបន្ទាប់គឺអង្គវិបស្សនារបស់ក្រុមការងារក្នុងប្រទេស ដែលនឹងផ្តល់លទ្ធភាពឱ្យមានការ ពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធផងដែរ ។

គោលការណ៍ណែនាំស្តីពី CPS ផ្តល់អនុសាសន៍ឱ្យមានការកំណត់ពីអ្នកពាក់ព័ន្ធសំខាន់ៗជាមុនសិន ហើយបន្ទាប់មករៀបចំការពិគ្រោះយោបល់ជាក្រោយ ។[១៧] ឧបករណ៍ទី ១ : ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ ចែងលំអិតអំពីដំណើរការនេះ ។ កិច្ចប្រជុំជាមួយអង្គការក្រៅរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ និងអ្នកពាក់ព័ន្ធដទៃទៀត ជុំវិញឯកសារពង្រឹងត្រូវបានស្តែងចេញថាកិច្ចប្រជុំដ៏មានតម្លៃ ។ សិក្ខាសាលាក្រៅផ្លូវការរបស់ក្រុមប្រឹក្សាភិបាលពិភាក្សាពីឯកសារបឋម និងពីលទ្ធផលនៃកិច្ចពិគ្រោះយោបល់ ។ បន្ទាប់មកឯកសារនេះត្រូវបានកែសម្រួលឡើងវិញ ហើយមានការធ្វើវិសោធនកម្មចុងក្រោយ មុនពេលមានការបញ្ជាក់ជាមួយរដ្ឋាភិបាល និងមុនពេលមានការឯកភាព (លេខយោងចុងក្រោយលេខ ១៧) ។ CPS ចាប់ផ្តើមវដ្តរបស់គម្រោង (សូមមើលផ្នែកទី ៣ : ការចូលរួមនៅក្នុងវដ្តគម្រោងរបស់ ADB ទំព័រទី ១៥) ។ ឧទាហរណ៍បង្ហាញពី CPS ឆ្នាំ ២០១១ របស់ប្រទេសកម្ពុជាខាងក្រោម បង្ហាញពីគោលវិធីដែលធ្វើឱ្យមានការចូលរួមពីសង្គមស៊ីវិល ។

## កិច្ចពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល នៅក្នុងការបង្កើតយុទ្ធសាស្ត្រស្តីពីភាពជាដៃគូប្រចាំប្រទេស (CPS)

- **សារពត៌ : ** យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសរបស់ប្រទេសកម្ពុជា (២០០៥-២០០៩) ត្រូវបានធ្វើបច្ចុប្បន្នកម្ម ដើម្បីក្លាយជា CPS សម្រាប់ប្រទេសកម្ពុជា (២០១១-២០១៤) ដែលឆ្លុះបញ្ចាំងពីដំណើរការធុរកិច្ចថ្មីៗរបស់ ADBនិងឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាលកម្ពុជា ។
- **គោលដៅ : ** អង្គការសង្គមស៊ីវិល (CSOs) នៅក្នុងប្រទេសកម្ពុជា បង្ហាញថា ADB ចាំបាច់ត្រូវផ្តោតគោលដៅការពិគ្រោះយោបល់របស់ខ្លួនឱ្យបានប្រសើរជាងមុន និងផ្តោតការយកចិត្តទុកដាក់ លើឱកាសពិចារណាប្រកបដោយអត្ថន័យលើធាតុចូលនានា ។ដូច្នេះហើយ ADB បានសម្រេចចិត្តផ្តោតការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល នៅកម្រិតការវាយតម្លៃលើវិស័យ ដែលផ្តល់នូវព័ត៌មានសម្រាប់បង្កើត CPS ។ ADB ទទួលបានប្រយោជន៍ជំនាញរបស់សង្គមស៊ីវិល ហើយអង្គការសង្គមស៊ីវិលអាចមានឥទ្ធិពលលើយុទ្ធសាស្ត្ររបស់ ADB និងរៀនសូត្រពីឱកាសសហការគ្នាដទៃទៀត ។
- **វិធីសាស្ត្រ : ** សិក្ខាសាលាពិគ្រោះយោបល់ស៊ីជម្រៅ ផ្តោតសំខាន់លើការវាយតម្លៃលើការធ្វើវិមជ្ឈការ និងវិសហមជ្ឈការ វិស័យអប់រំ បរិស្ថាន និងកសិកម្ម ដែលជាវិស័យ ដែលសង្គមស៊ីវិលមានជំនាញជាច្រើន ។ បណ្តាញអង្គការក្រៅរដ្ឋាភិបាល នៅតាមវិស័យនីមួយៗ បានផ្តល់ជាអនុសាសន៍ឱ្យមានការចូលរួមពីអង្គការសង្គមស៊ីវិល ហើយវិស័យទាំងនេះត្រូវបានជ្រើសរើសឡើង ដោយសារតែការបំពេញបន្ថែម និងចំណុចខ្លាំង ដែលពួកគេមានសម្រាប់ ADB និងសង្គមស៊ីវិល ។ អ្នកចូលរួមបានទទួលព័ត៌មានត្រឡប់អំពីផែនការអនុម័តលើធាតុចូលនានា ក្រោយពីកិច្ចប្រជុំរួច ។ ការអាប់ឡូតសេចក្តីព្រាង CPS សង្ខេ ជាភាសាខ្មែរ លើគេហទំព័ររបស់និវាសនដ្ឋានប្រចាំប្រទេសកម្ពុជាបានផ្តល់នូវលទ្ធភាព ឱ្យមានការផ្តល់យោបល់ជាលាយល័ក្ខណ៍អក្សរ ។

# ៣ ការចូលរួមនៅក្នុងវដ្តគម្រោងរបស់ ADB – ការណែនាំ និងឧបករណ៍នានា

ADB ចាត់ទុកការលើកទឹកចិត្តឱ្យមានការចូលរួមរបស់សាធារណជនទូទៅ វិស័យឯកជន និងសង្គមស៊ីវិលនៅក្នុងគ្រប់ប្រតិបត្តិការការងារទាំងអស់ ថាមានសារៈសំខាន់យ៉ាងខ្លាំង ចំពោះការកាត់បន្ថយភាពក្រីក្រ។ ការដាក់បញ្ចូលការចូលរួមនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃវដ្តគម្រោង បង្កើនផលរយៈពេលវែងដល់កម្រិតអតិបរមា និងធានាឱ្យមាននិរន្តរភាព តាមរយៈការទទួលធាតុចូល និងភាពជាម្ចាស់។

ប្រភព៖ *ADB. 2004. Enhancing the Fight against Poverty in Asia and the Pacific. The Poverty Reduction Strategy of the Asian Development Bank. Manila; ADB. 2004. Disaster and Emergency Assistance. Operations Manual. OM D7/BP. Manila.*

## សេចក្តីផ្តើម

នៅក្នុងមគ្គុទេសក៍នេះ "គម្រោង" សំដៅលើកម្ចី (ជាកម្ចីវិនិយោគ និងកម្ចីផ្អែកតាមគោលនយោបាយ) ជំនួយឥតសំណង និងជំនួយបច្ចេកទេសខណៈពេលដែលអង្គភាពរដ្ឋ គឺជាអតិថិជនចម្បងរបស់ ADB ហើយប្រតិបត្តិការមិនមែនរដ្ឋ (រាប់បញ្ចូលទាំងវិស័យឯកជនផង) បន្តមានការរីកចម្រើន បន្ទាប់ពីយុទ្ធសាស្ត្រ ២០២០ បានផ្តល់អាទិភាពលើប្រតិបត្តិការទាំងនោះរួចមក។

> "នៅក្នុងសកម្មភាពកម្ចី និងជំនួយបច្ចេកទេស ADB អាចទទួលបានប្រយោជន៍ពីចំណេះដឹង ដែលអង្គការក្រៅរដ្ឋាភិបាលនានាមាន និងជំនាញ ដែលពួកគេបានអភិវឌ្ឍកន្លងមក។"
>
> ប្រភព៖ ADB. 1996. *Policy: Cooperation between ADB and NGOs:* Manila.

ការដាក់បញ្ចូលការចូលរួមក្នុងកម្រិតខ្ពស់ ទៅក្នុងវដ្តគម្រោងរបស់ADB នាំឱ្យមានការបង្កើនគុណភាព និងធ្វើឱ្យលទ្ធផលការងារកាន់តែមានប្រសើរឡើង។ ការចូលរួមគួរចាប់ផ្តើមក្នុងដំណើរការបង្កើតCPSហើយ បន្តក្នុងពេលបង្កើតឯកសារទស្សនាទានសម្រាប់គម្រោងនីមួយៗ ពេលរៀបចំពេលផ្តល់ការអនុម័ត និងពេលអនុវត្តគម្រោង។ ដោយសារតែរដ្ឋាភិបាលបំពេញតួនាទីជាម្ចាស់គម្រោងភាគច្រើន ដែលទទួលបានហិរញ្ញប្បទានពី ADB ជាការសំខាន់ណាស់ដែល ADB និងប្រទេសកំពុងអភិវឌ្ឍជាសមាជិក ធ្វើការងាររួមគ្នា ដើម្បីធានាឱ្យមានការចូលរួមនៅក្នុងវដ្តគម្រោងទាំងមូល។ តារាងបង្ហាញពីការទទួលខុសត្រូវលើការចូលរួមក្នុងគម្រោងរដ្ឋបង្ហាញពីការទទួលខុសត្រូវរបស់ស្ថាប័នទាំងនោះ។ ស្រដៀងគ្នានេះដែរនៅក្នុងប្រតិបត្តិការវិស័យឯកជន ADB ត្រូវធ្វើការងារឱ្យបានជិតស្និទ្ធជាមួយនឹងអតិថិជនមិនមែនរដ្ឋរបស់ខ្លួន (សូមមើលទំព័រទី ២២)។ ការចូលរួមមានការប្រែប្រួលទៅតាមប្រភេទគម្រោងទម្រង់ការនៃការផ្តល់ហិរញ្ញប្បទាន ឬប្រភេទប្រតិបត្តិការ (រដ្ឋឬមិនមែនរដ្ឋ) និងបរិយាកាសស្ថាប័ន។ ឧទាហរណ៍នៅក្នុងរដ្ឋដែលមានភាពផុយស្រួល និងដែលរងផលប៉ះពាល់ ដោយសារទំនាស់ការចូលរួមរបស់ជនជាតិដើមភាគតិចមានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីពង្រឹងភាពជាម្ចាស់នៃជំនួយ និងកាត់បន្ថយហានិភ័យនៃភាពតានតឹងក្នុងសង្គម ឬទំនាស់ឱ្យនៅទាបជាអប្បបរមា។

## ការទទួលខុសត្រូវលើការចូលរួម ក្នុងគម្រោងរដ្ឋ

| ប្រទេសកំពុងអភិវឌ្ឍជាសមាជិកដែលជាអ្នកទទួល/អតិថិជន | ADB |
|---|---|
| **ការរៀបចំកម្មវិធីប្រចាំប្រទេស** | |
| - ចរចានិងឯកភាពលើគោលដៅ និងផែនការស្តីពីការចូលរួមនៅក្នុងយុទ្ធសាស្ត្រស្តីពីភាពជាដៃគូប្រចាំប្រទេស (CPS) ជាមួយ នឹង ADB | - ពិភាក្សាពីការចូលរួមជាមួយនឹងមន្ត្រីរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក និងធានាថាគោលដៅរួម និងផែនការធំៗ ត្រូវបានដាក់បញ្ចូលក្នុង CPS |
| **ការដំណើរការគម្រោង** | |
| - ពិភាក្សា និងឯកភាពលើការចូលរួម នៅក្នុងការរៀបចំគម្រោងរួមជាមួយនឹងសមាជិកក្រុមការងាររបស់ ADB រួមចំណែកក្នុងការរៀបចំការវិភាគគោលនយោបាយ និងសង្គមបឋម (IPSA)<br>- គាំទ្រដល់ការពិគ្រោះយោបល់ នៅក្នុងការរៀបចំគម្រោង និងការបង្កើតផែនការស្តីពីការចូលរួនៅក្នុងការអនុវត្ត, ផ្តល់ព័ត៌មានអំពីការបញ្ចប់យុទ្ធសាស្ត្រសង្ខេបអំពីការកាត់បន្ថយភាពក្រីក្រ និងសង្គម (SPRSS)<br>- ចូលរួមចំណែក និងឯកភាពលើឯកសារនានា ដែលត្រូវទទួលបានការឯកភាពរាប់បញ្ចូលទាំងឯកសារអំពីការចូលរួមផងដែរ (ឧ. យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ នៅក្នុងសៀវភៅណែនាំអំពីការចាត់ចែងគម្រោងជាដើម) | - ធ្វើការងារជាមួយមន្ត្រីរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ដើម្បីបញ្ចប់ IPSA<br>- ដាក់បញ្ចូលការទទួលខុសត្រូវលើការចូលរួមទៅក្នុងលក្ខខណ្ឌប្រតិបត្តិសម្រាប់អ្នកពិគ្រោះការសម្រាប់ជំនួយបច្ចេកទេស រៀបចំគម្រោង<br>- បង្កើតផែនការស្តីពីការចូលរួម (សម្រាប់ការរៀបចំ និងការ អនុវត្ត) ធ្វើការពិគ្រោះយោបល់ នៅក្នុងការរៀបចំគម្រោង និងបញ្ចប់ SPRSS<br>- ដាក់បញ្ចូលការចូលរួម នៅក្នុងការរៀបចំគម្រោង និង ផែនការស្តីពីការចូលរួម ក្នុងឯកសារនានា ដើម្បីទទួលបានការ ឯកភាព (សូមមើលតារាងបង្ហាញពីការចូលរួម នៅក្នុងវដ្ត គម្រោងរដ្ឋរបស់ ADB សម្រាប់ព័ត៌មានលំអិតបន្ថែម) |
| **ការរៀបចំផែនការប្រតិបត្តិ** | |
| - ទីភ្នាក់ងារប្រតិបត្តិ និងទីភ្នាក់ងារអនុវត្ត ធ្វើការសម្របសម្រួលជាមួយនឹងក្រុមការងារគម្រោងរបស់ ADB និងជាមួយអ្នកពាក់ព័ន្ធដទៃទៀតរបស់គម្រោង | - ធានាយ៉ាងណាឱ្យអ្នកទទួល/អតិថិជន ត្រៀមខ្លួនរួចជាស្រេចសម្រាប់ការអនុវត្ត, ជនបង្គោលត្រូវបានបង្កើតឡើង សម្រាប់ រៀបចំផែនការស្តីពីការចូលរួម និងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ |
| **ការអនុវត្ត ការពិនិត្យតាមដាន និងការរាយការណ៍** | |
| - ដឹកនាំការអនុវត្តគម្រោង រាប់បញ្ចូលទាំងសមាសភាគនានា របស់គម្រោងដែលមានការចូលរួម, ផ្ញើរបាយការណ៍វឌ្ឍនភាព របស់គម្រោងទៅឱ្យ ADB | - ពិនិត្យឡើងវិញលើការអនុវត្តគម្រោង និងវឌ្ឍនភាពពាក់ព័ន្ធនឹង ការចូលរួមដោយប្រៀបធៀបជាមួយនឹងផែនការចូលរួម តាម រយៈរបាយការណ៍របស់ទីភ្នាក់ងារប្រតិបត្តិរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក, បេសកកម្មពិនិត្យឡើងវិញ និងការពិនិត្យតាមដានដោយឯករាជ្យ, ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងគម្រោង |
| **ស្វ័យវាយតម្លៃ និងការវាយតម្លៃក្រោយពេលបញ្ចប់គម្រោង** | |
| - ផ្ញើរបាយការណ៍បញ្ចប់គម្រោងរបស់ខ្លួន ដោយមានដាក់បញ្ចូល ស្ថានភាពនៃការចូលរួម, រួមចំណែកក្នុងការរៀបចំរបាយការណ៍ បញ្ចប់គម្រោងរបស់ ADB នៅពេលចុះទៅទីតាំងគម្រោង បន្ទាប់ ពីការបញ្ចប់គម្រោង និងការវាយតម្លៃឯករាជ្យនៅពេលក្រោយ | - ពិនិត្យឡើងវិញ និងវាយតម្លៃលើការអនុវត្តសកម្មភាពដែលមានការចូលរួម, សរសេររបាយការណ៍បញ្ចប់គម្រោង និង របាយការណ៍របស់នាយកដ្ឋានវាយតម្លៃឯករាជ្យ |

សម្គាល់ : សូមមើលទំព័រទី ៦៤ សម្រាប់ព័ត៌មានលំអិតអំពីការទទួលខុសត្រូវលើការចូលរួម ក្នុងការការពារផលប៉ះពាល់សង្គម និងបរិស្ថានជនដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង អាចចូលរួមនៅក្នុងយន្តការគណនេយ្យភាព នៅដំណាក់កាលណាមួយក៏បាន នៅក្នុងវដ្តគម្រោង (រហូតដល់ពេលដែលមានការផ្ញើរបាយការណ៍បញ្ចប់គម្រោង)។ (យន្តការគណនេយ្យភាពរបស់ ADB ផ្តល់លទ្ធភាពឱ្យអ្នកដែលរងផលប៉ះពាល់ជា អវិជ្ជមាន ដោយសារគម្រោងដែលជួយដោយ ADB បញ្ចេញសម្លេង និងស្វែងរកដំណោះស្រាយចំពោះបញ្ហារបស់ពួកគេ និងរាយការណ៍ពីភាពមិនអនុលោមនានា ជាមួយនឹងគោលនយោបាយ និងនីតិវិធីប្រតិបត្តិការរបស់ ADB)។

## ការចូលរួម នៅក្នុងវដ្តគម្រោង

ផ្នែកនេះ គឺផ្អែកទៅតាមវដ្តគម្រោងស្តង់ដារបស់ ADB សម្រាប់កម្ចីរដ្ឋ ដែលជាឧបករណ៍ផ្តល់ហិរញ្ញប្បទានញឹកញាប់ជាងគេ។[១៨] ជាធម្មតាដំណើរការកម្ចីសម្រាប់ជំនួយបច្ចេកទេសត្រូវធ្វើតាមនីតិវិធីដូចគ្នានឹងកម្ចីគម្រោងដែរ ហើយជំនួយឥតសំណងសម្រាប់ជំនួយបច្ចេកទេស ដែលដំណើរការជាមួយនឹងកម្ចី ត្រូវបានដំណើរការក្រោមនីតិវិធី សម្រាប់សំណើកម្ចី។[១៩] ប៉ុន្តែ មានកម្ចីជាច្រើនប្រភេទ និងមានទម្រង់ការផ្តល់ហិរញ្ញប្បទានដទៃទៀតផងដែរហើយ

### ការចូលរួមក្នុងវដ្តគម្រោងរដ្ឋរបស់ ADB

| វដ្តគម្រោង | ការចូលរួម | ឧបករណ៍ | វិធីសាស្ត្រ/ឧទាហរណ៍ | អ្នកដែលមានតួនាទីសំខាន់ៗ |
|---|---|---|---|---|
| **១. ការរៀបចំកម្មវិធីប្រចាំប្រទេស (យុទ្ធសាស្ត្រស្តីពីភាពជាដៃគូប្រចាំប្រទេសឱ្យ CPS ខ)** | ការវិភាគអ្នកពាក់ព័ន្ធ ការពិគ្រោះយោបល់ និងផែនទីបង្ហាញផ្លូវរបស់វិស័យ ឬការវាយតម្លៃដែលបង្កើតឡើងដោយប្រើប្រាស់វិធីសាស្ត្រ ដែលមានការចូលរួមសម្រាប់ផ្តល់ព័ត៌មានដល់ **CPS** | **- ឧបករណ៍ទី ១ : ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ (ទំព័រទី ២៥)**<br>**- ឧបករណ៍ទី៣ : ការវាយតម្លៃដោយមាន ការចូលរួម (ទំព័រទី ៣៧)** | **ការបង្កើត/ចែករំលែកព័ត៌មាន និងការពិគ្រោះយោបល់ ADB/រដ្ឋាភិបាល ចែករំលែកគំនិតនិងធ្វើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ** | ក្រុមការងារពិនិត្យឡើងវិញរបស់ **ADB**, មន្ត្រីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធសំខាន់ៗក្នុងប្រទេស |
| **២. ដំណើរការគម្រោង** (ឯកសារទស្សនទានគម្រោង ជំនួយបច្ចេកទេសរៀបចំគម្រោងឱ្យ **PPTA**ខ) និងការស្វែងរកការពិតពាក់ព័ន្ធជាមួយនឹងកម្ចី/ជំនួយឥតសំណង) | - ពិភាក្សាអំពីការចូលរួម ជាមួយនឹងរដ្ឋាភិបាល<br>- ការវិភាគអ្នកពាក់ព័ន្ធបឋម និងការពិគ្រោះយោបល់ដែលជាផ្នែកមួយនៃបេសកកម្មរៀបចំឯកសារទស្សនាទាន និងការរៀបចំការវិភាគភាពក្រីក្រ និងសង្គមបឋម<br>- នៅក្នុង **PPTA** មានការដាក់បញ្ចូលការចូលរួមរបស់អ្នកពាក់ព័ន្ធ ទៅក្នុងការវិភាគ និងការបង្កើតក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដាន **(DMF)**, ផែនការយេនឌ័រ/សង្គម និងការពារផលប៉ះពាល់សង្គម និងបរិស្ថាន (សង្ខេបនៅក្នុង យុទ្ធសាស្ត្រសង្ខេបស្តីពីការកាត់បន្ថយភាពក្រីក្រ និងសង្គម **[SPRSS]**) និង យុទ្ធសាស្ត្រប្រាស្រ័យទាក់ទង ជាមួយនឹងអ្នកពាក់ព័ន្ធ (មានបង្ហាញនៅក្នុងសៀវភៅណែនាំ អំពីការចាត់ចែងគម្រោង **[PAM]**) | - ឧបករណ៍ទី១ :ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល<br>- ឧបករណ៍ទី២ :ការបង្កើនការចូលរួមក្នុង ឱ្យដល់កម្រិតអតិបរមា (ទំព័រទី៣៣)<br>- ឧបករណ៍ទី៣ : ការវាយតម្លៃដោយមានការចូលរួម<br>- ឧបករណ៍ទី៤ :ការបង្កើតផែនការស្តីពីការចូលរួម (ទំព័រទី ៤១)<br>- ឧបករណ៍ទី៥ :ការបង្កើតយុទ្ធសាស្ត្រស្តីពី ការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ (ទំព័រទី ៤៧) | **ការបង្កើត/ចែករំលែកព័ត៌មាន និងការពិគ្រោះយោបល់ ADB/រដ្ឋាភិបាល ចែករំលែកគំនិតអំពីគម្រោង អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀត ចែករំលែកការស្រាវជ្រាវ និងបទពិសោធន៍**<br><br>**ការសហការ**<br>**អង្គការសង្គមស៊ីវិលត្រូវបាន ជួលឱ្យធ្វើការវាយតម្លៃដោយមានការចូលរួម**<br><br>**ភាពជាដៃគូ**<br>**ការរៀបចំគម្រោងរួមគ្នា** | ក្រុមការងារគម្រោងរបស់ **ADB** (រួមទាំងអ្នកពិគ្រោះការផ្នែកអភិវឌ្ឍន៍សង្គម និង **PPTA**) មន្ត្រីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធសំខាន់ៗ |

| **វដ្តគម្រោង** | **ការចូលរួម** | **ឧបករណ៍** | **វិធីសាស្ត្រ/ឧទាហរណ៍** | **អ្នកដែលមានតួនាទីសំខាន់ៗ** |
|---|---|---|---|---|
| ៣. ការរៀបចំផែនការប្រតិបត្តិ (ការត្រៀមរួចជាស្រេចរបស់គម្រោង / ការរៀបចំផែនការការងារ) | - **DMF, SPRSS,** និង **PAM** ភ្ជាប់ទំនាក់ទំនងជាមួយ របាយការណ៍ និងអនុសាសន៍ របស់ប្រធានធនាគារ ដើម្បីសុំការឯកភាព បន្ទាប់ពីបានទទួលការឯកភាព លើគម្រោងរួច សម្របសម្រួលជាមួយអ្នកពាក់ព័ន្ធរបស់គម្រោងដើម្បីរៀបចំការអនុវត្ត។ បង្ហើយបញ្ចប់កិច្ចសន្យា និងកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូ។ | - ឧបករណ៍ទី១ :ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់<br>- ឧបករណ៍ទី ៦ : ការធ្វើការងារជាមួយអង្គការសង្គមស៊ីវិល (សូមមើលទំព័រទី ៥១) | **ដូចដំណើរការគម្រោងខាង លើ** | ក្រុមការងារគម្រោងរបស់ **ADB /** មន្ត្រីរបស់ប្រទេស កំពុងអភិវឌ្ឍជាសមាជិកនិងអ្នកពាក់ព័ន្ធសំខាន់ៗ របស់គម្រោង |
| ៤. ការអនុវត្ត ការពិនិត្យតាមដាន និងការរាយការណ៍ | អនុវត្តវិធីសាស្ត្រដែលមានការចូលរួម និងពិនិត្យតាម ដាន និងពិនិត្យឡើងវិញលើ ការអនុវត្ត ឧ. តាមរយៈ របាយការណ៍ប្រចាំត្រីមាស របស់ទីភ្នាក់ងារប្រតិបត្តិ **(EA)** របាយការណ៍បេសកកម្ម នៅ ពេលដែលក្រុមការងារវិលមកការិយាល័យវិញវឌ្ឍនភាពរបស់កម្រោងលទ្ធផលគម្រោងនិងការពិនិត្យតាមដានដោយឯករាជ្យ។ យន្តការគណនេយ្យភាពរបស់ **ADB** នៅក្នុងប្រតិបត្តិការ។ | - ឧបករណ៍ទី ៦ : ការធ្វើការងារជាមួយអង្គការសង្គមស៊ីវិល<br>- ឧបករណ៍ទី ៧ : ការពិនិត្យតាមដាន និងការវាយតម្លៃ **(M&E)**ដោយមានការចូលរួម (សូមមើលទំព័រទី ៥៧) | **ការបង្កើត/ចែករំលែកព័ត៌មាន និងការពិគ្រោះយោបល់ដូចខាងលើដែររួមនឹងអង្គការ សង្គមស៊ីវិល ចែករំលែកការពិនិត្យតាមដាន និងការវាយតម្លៃដោយស្ម័គ្រចិត្ត ការសហការ អង្គការសង្គមស៊ីវិលត្រូវបានទទួលឱ្យធ្វើការពិនិត្យតាមដាន និងវាតម្លៃដោយឯករាជ្យ ឬអនុវត្តសមាសភាគណាមួយ របស់គម្រោងភាពជាដៃគូការអភិវឌ្ឍទៅតាមសេចក្តី ត្រូវការរបស់សហគមន៍ ការផ្តល់សហហិរញ្ញប្បទាន ។ល។** | ទីភ្នាក់ងារប្រតិបត្តិរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក និងទីភ្នាក់ងារអនុវត្តដទៃទៀតរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក អ្នកពាក់ព័ន្ធដែលចូលរួមក្នុងការអនុវត្ត និង ក្រុមការងារពិនិត្យឡើងវិញលើគម្រោងរបស់ **ADB** |
| ៥. ស្វ័យវាយតម្លៃ | ស្វ័យវាយតម្លៃដោយមានការចូលរួម តាមរយៈ របាយការណ៍ពាក់កណ្តាលអណត្តិ និងរបាយការណ៍បញ្ចប់គម្រោង ឧ. ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធជួលអ្នកពិនិត្យតាមដាន ឯករាជ្យ | - ឧបករណ៍ទី១ :ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់<br>- ឧបករណ៍ទី៦ : ការធ្វើការងារជាមួយអង្គការសង្គមស៊ីវិល<br>- ឧបករណ៍ទី៧ : ការពិនិត្យតាមដាន និងការវាយតម្លៃ **(M&E)**ដោយមានការចូលរួម | **ការពិគ្រោះយោបល់ការពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួមពីអ្នកដែលរងផលប៉ះពាល់ ការផ្តល់ធាតុចូលរបស់អង្គការសង្គមស៊ីវិលសម្រាប់ការវាយតម្លៃ**<br>**ការសហការ**<br>**អង្គការសង្គមស៊ីវិលត្រូវបានជួលឱ្យវាយតម្លៃគម្រោងនិងធានានិរន្តរភាពសកម្មភាព** | ទីភ្នាក់ងារប្រតិបត្តិ ក្រុម ការងារគម្រោង និងក្រុម ការ-ងារពិនិត្យឡើងវិញលើការបញ្ចប់គម្រោងរបស់ **ADB** ក្រុមការងារវាយតម្លៃក្រោយបញ្ចប់គម្រោងអ្នកវាយតម្លៃឯករាជ្យ និងអ្នកពាក់ព័ន្ធនានា |

| វដ្តគម្រោង | ការចូលរួម | ឧបករណ៍ | វិធីសាស្ត្រ/ឧទាហរណ៍ | អ្នកដែលមានតួនាទីសំខាន់ៗ |
|---|---|---|---|---|
| ៦. ការបញ្ចប់គម្រោង និងការវាយតម្លៃក្រោយបញ្ចប់គម្រោង | **ការវាយតម្លៃក្រោយបញ្ចប់ គម្រោងដោយមានការចូល រួម ដោយនាយកដ្ឋានវាយ តម្លៃឯករាជ្យរបស់ ADB ឬដោយអ្នកទទួល/អតិថិជនពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ** | **ដូចស្ម័យវាយតម្លៃខាង លើ** | **ដូចស្ម័យវាយតម្លៃខាង លើ** | **ដូចស្ម័យវាយតម្លៃខាងលើ** |

គេហទំព័ររបស់ ADB មានបង្ហាញលំអិតអំពីវដ្តគម្រោងទាំងនោះ ។[២០] ដំបូន្មាន និងឧបករណ៍ខាងក្រោមអាចយកមកកែសម្រួល និងប្រើប្រាស់ក្នុងបរិបទភាគច្រើន ។ នៅក្នុងគម្រោងមួយចំនួន មានឱកាសជាច្រើនសម្រាប់ការចូលរួម ឧទាហរណ៍កម្មវិធីផ្តល់ហិរញ្ញប្បទានពហុផ្នែក (MFF) ផ្តល់លទ្ធភាពឱ្យមានការបង្កើតភាពជាដៃគូរយៈពេលវែង ជាមួយនឹងការផ្តល់ហិរញ្ញប្បទានតាមផ្នែក ក្នុងរយៈពេលមួយ ។ ប្រតិបត្តិការវិស័យឯកជនដែលអនុវត្តទៅតាម ដំណើរការផ្តល់ការឯកភាពលើឥណទានផ្សេងត្រូវបានរៀបរាប់ដោយឡែក ។ តារាងបង្ហាញពីការចូលរួមក្នុងវដ្តគម្រោងរដ្ឋរបស់ ADB បង្ហាញពីឱកាសសម្រាប់ចូលរួមនៅក្នុងវដ្តគម្រោង ។ បន្ទាប់មកវារំលេចនូវឧបករណ៍ផ្សេងៗ ដែលមាននៅដំណាក់កាលនីមួយៗ ឧទាហរណ៍ដែលបង្ហាញពីប្រភេទនៃការចូលរួមផ្សេងៗ និងអ្នកដែលមានតួនាទី នៅដំណាក់កាលនីមួយៗ ។

## ដំណាក់កាលទី ១ : ការរៀបចំកម្មវិធីប្រចាំប្រទេស

CPS កំណត់ពីគម្រោងដែលមាននៅក្នុងផែនការ ។ បន្ទាប់មកការពិនិត្យឡើងវិញលើប្រតិបត្តិការធុរកិច្ចប្រចាំឆ្នាំ ផ្តួចផ្តើមឱ្យមានដំណើរការដែលមានការចូលរួម សម្រាប់គម្រោង ដែលត្រូវការពេលវេលាបន្ថែម ។

## ដំណាក់កាលទី ២ : ដំណើរការគម្រោង

ការចូលរួម ផ្អែកទៅតាមគោលដៅ និងផែនការស្តីពីការចូលរួមក្នុង CPS ហើយចាប់ផ្តើម នៅដើម ដំណាក់កាលបង្កើតឯកសារទស្សនាទាន ។ ការវិភាគបឋមលើភាពក្រីក្រ និងសង្គម (IPSA) គឺជាចំណុចផ្តើមមួយសម្រាប់ការចូលរួម ។[២១] នៅក្នុងទម្រង់ IPSA ផ្នែក ខ នៃផ្នែកស្តីពីបញ្ហាអភិវឌ្ឍន៍សង្គម ពិនិត្យលើការចូលរួម ។

នៅដំណាក់កាលនេះការវិភាគបឋមលើអ្នកពាក់ព័ន្ធ ធ្វើការកំណត់ ក) តើក្រុមណាខ្លះដែលចាប់អារម្មណ៍ចំពោះគម្រោង? និង ខ) ការចាប់អារម្មណ៍ និងសមត្ថភាពរបស់ក្រុមទាំងនោះដើម្បីគាំទ្រ ឬពន្យារពេលការអនុវត្ត ។ ការវិភាគនេះក៏អាចកំណត់ផងដែរពីទំនាស់ផលប្រយោជន៍ដែលអាចកើតឡើងរវាងអ្នកពាក់ព័ន្ធនានា (សូមមើលឧបករណ៍ទី១ : ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ទំព័រទី ២៥) ។ IPSAក្តោបលើបញ្ជីបឋមនៃអ្នកពាក់ព័ន្ធ និងព័ត៌មាន អំពីប្រភេទនៃការចូលរួមដែលនឹងមាន នៅក្នុងពេលដំណើរការគម្រោង និងថាតើចាំបាច់ត្រូវ បង្កើតផែនការស្តីពីការចូលរួមដែរឬទេ (លេខយោងចុងក្រោយទី ២១) ។

សម្រាប់កម្មវិធីហិរញ្ញប្បទានពហុផ្នែក ពុំមានលក្ខខណ្ឌតម្រូវឱ្យមានការរៀបចំ IPSA ថ្មីសម្រាប់ផ្នែកទី ២ និង ផ្នែកដែលនឹងមាននាពេលអនាគតនោះទេ។ ប៉ុន្តែការឯកភាពលើផ្នែកបន្តបន្ទាប់តម្រូវឱ្យមានការបង្ហាញភ័ស្តុតាងពីការ អនុលោមទៅតាមផែនការស្តីពីការការពារផលប៉ះពាល់បរិស្ថាន និងសង្គមដូចដែលមានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀង ស្តីពីក្របខ័ណ្ឌរបស់កម្មវិធីហិរញ្ញប្បទានពហុផ្នែក (ដែលអនុវត្តចំពោះគ្រប់ផ្នែកទាំងអស់)។ ការធ្វើបែបនេះផ្តល់លទ្ធភាពឱ្យមានការចូលរួមបន្ថែមទៀតពីអ្នកពាក់ព័ន្ធ នៅពេលដែលចាំបាច់។

## ការលើកកម្ពស់ឱ្យមានការចូលរួម នៅក្នុងការរៀបចំគម្រោង

នៅក្នុងកំឡុងពេលបង្កើតគម្រោងមួយបុគ្គលិករបស់ ADB និងមន្ត្រីរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិកគួរសួរខ្លួនឯង និងសហការីរបស់ពួកគេនូវសំណួរខាងក្រោម ដើម្បីធ្វើឱ្យមានគុណភាពនៅពេលចាប់ផ្តើមដំបូង :

- តើមានអ្វីខ្លះដែលត្រូវបានដាក់បញ្ចូលទៅក្នុងផែនការស្តីពីការចូលរួម នៅដំណាក់កាលរៀបចំគម្រោងរបស់អ្នក និងតើមានការអនុវត្តយ៉ាងដូចម្តេចរហូតមកដល់ពេលបច្ចុប្បន្ននេះ?
- តើមានការចូលរួមគ្រប់គ្រាន់ដែរឬទេ? តើមានការបែងចែកពេលវេលា និងធនធានគ្រប់គ្រាន់ដែរឬទេ?
- តើអ្នករៀនសូត្រអ្វីខ្លះពីការចូលរួម និងថាតើមេរៀននេះជួយកំណត់/កែលំអការរៀបចំគម្រោងដោយរបៀបណា?
- តើមានហានិភ័យអ្វីដែរឬទេចំពោះគម្រោង ដែលត្រូវបានកំណត់តាមរយៈដំណើរការនៃការចូលរួមកន្លងមក និងតើអ្នកបានដាក់ចេញនូវវិធានការដើម្បីកាត់បន្ថយហានិភ័យទាំងនេះ ដែរឬទេ?
- តើមានអ្វីខ្លះដែលត្រូវបានដាក់បញ្ចូលក្នុងផែនការស្តីពីការចូលរួមរបស់អ្នក ដើម្បីអនុវត្ត?

**ការអភិវឌ្ឍទៅតាមតម្រូវការរបស់សហគមន៍ សម្រាប់ប្រជាពលរដ្ឋក្រីក្ររស់នៅក្នុងតំបន់ក្រុងក្នុងតំបន់ Ger ប្រទេសម៉ុងហ្គោលី (វិធីសាស្រ្តចូលរួម : ការសហការ និងភាពជាដៃគូ, ភាពស៊ីជម្រៅ : ខ្ពស់)**

ការអភិវឌ្ឍទៅតាមតម្រូវការរបស់សហគមន៍ (CDD) ផ្តល់ឱ្យក្រុមសហគមន៍នូវសិទ្ធិគ្រប់គ្រងលើការសម្រេចចិត្ត និងធនធាននានា។ ជារឿយៗ ក្រុមក្រៅផ្លូវការទាំងនេះធ្វើការងារជាដៃគូជាមួយនឹងអង្គការគាំទ្រ និងអ្នកផ្តល់សេវានានា ដូចជារដ្ឋាភិបាលនៅថ្នាក់មូលដ្ឋានវិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីបង្កើតនូវសេវាសង្គម និងហេដ្ឋារចនាសម្ព័ន្ធ រៀបចំសកម្មភាពសេដ្ឋកិច្ចគ្រប់គ្រងធនធាន និងលើកកម្ពស់អភិបាលកិច្ច។ ឧទាហរណ៍ តាមរយៈធនធានពីជំនួយឥតសំណងសម្រាប់ CDD របស់ ADB សហគមន៍នៅក្នុងតំបន់ *ger* (ដែលរស់នៅក្រោមតង់បែបប្រពៃណេ) ក្នុងប្រទេសម៉ុងហ្គោលី អាចកសាងនូវហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់នានា (ដូចជាការសំអាតទឹកកខ្វក់ និងការដាក់ភ្លើងបំភ្លឺតាមផ្លូវ) បំពេញសកម្មភាពប្រមូលចំណូល (ផលិតផលិតផលពីទឹកដោះគោ ចិញ្ចឹមឃ្មុំ) និងទទួលខុសត្រូវលើការអភិវឌ្ឍសហគមន៍របស់ពួកគេ។ សំណើអនុគម្រោងរបស់សហគមន៍ត្រូវបានវាយតម្លៃលើកម្រិតនៃប្រយោជន៍សម្រាប់សហគមន៍ទាំងមូល ការប្តេជ្ញាចិត្តរបស់សហគមន៍ និងការចូលរួមវិភាគទាន (ជាសាច់ប្រាក់ និងមិនមែនជាសាច់ប្រាក់) ដែលសន្យាដោយរដ្ឋាភិបាលមូលដ្ឋាន។ សហគមន៍ត្រូវចែករំលែកយ៉ាងហោចណាស់២០% (មិនមែនសាច់ប្រាក់ ឬកម្លាំងពលកម្ម ១៧% និងសាច់ប្រាក់ ៣%) នៃជំនួយឥតសំណង ហើយត្រូវដាក់ការរួមវិភាគទានជាសាច់ប្រាក់ នៅក្នុងគណនីធនាគាររបស់សហគមន៍។ គម្រោងបានជួលមជ្ឈមណ្ឌលធនធានអភិវឌ្ឍន៍ទីក្រុង (UDRC) ដែលជាអង្គការដែលមានមូលដ្ឋាននៅ Ulaanbaatar ឱ្យអភិវឌ្ឍសមត្ថភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីអនុវត្តគម្រោងអភិវឌ្ឍន៍នៅតាមសហគមន៍។ UDRC បានធ្វើការពិគ្រោះយោបល់ដើម្បីកំណត់នូវបញ្ហារៀបចំសំណើ និងជ្រើសរើសគម្រោងដែលអាចអនុវត្តទៅបានសម្រាប់ការអនុវត្តដោយមានការចូលរួម។

ប្រភព : ADB. 2007. *Grant to Mongolia for Community-Driven Development for Urban Poor in Ger Areas.* Manila.

ការចូលរួមរបស់អ្នកពាក់ព័ន្ធបន្តមាននៅពេលរៀបចំគម្រោង និងនៅពេលរៀបចំក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដាន(DMF)។ អាស្រ័យទៅតាមគម្រោងអ្នកពាក់ព័ន្ធមានឥទ្ធិពលលើដំណើរការនៃការរៀបចំចាប់ពីកម្រិតខ្ពស់មកកម្រិតទាប។ ក្នុងគម្រោងមួយចំនួនដូចជាគម្រោងនៅសហគមន៍ក្នុងប្រទេសម៉ុងហ្គោលី ដូចដែលរៀបរាប់ខាងលើការចូលរួមមានសារៈសំខាន់យ៉ាងខ្លាំងដើម្បីសម្រេចគោលដៅស្នូល។ នៅក្នុងគម្រោងផ្សេងទៀតរាប់បញ្ចូលទាំងគម្រោងហេដ្ឋារចនាសម្ព័ន្ធភាគច្រើនផងដែរ ភាពពាក់ព័ន្ធផ្នែកការការពារផលប៉ះពាល់សង្គម និងបរិស្ថានធ្វើឱ្យការចូលរួមមានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីធ្វើការស្វែងយល់ពីផលប៉ះពាល់មកលើជីវិតរបស់ប្រជាពលរដ្ឋ និងធានាយ៉ាងណាឱ្យផែនការនានាត្រូវបានកែសម្រួលបានយ៉ាងល្អបំផុត និងធានាយ៉ាងណាឱ្យប្រជាពលរដ្ឋទទួលបានសំណងបានល្អបំផុត។ ចុងក្រោយមានគម្រោងដែលមានឱកាស និងប្រយោជន៍តិចតួចសម្រាប់ការចូលរួម។ គម្រោងប្រភេទនេះមានដូចជាគម្រោងគាំទ្រដល់ការកសាងសមត្ថភាពរបស់រដ្ឋាភិបាលផ្នែកជំនាញបច្ចេកទេសជាក់លាក់ដូចជាជំនាញវិស្វកម្ម ឬគណនេយ្យជាដើម។

ឧបករណ៍ទី១ ផ្តល់ការណែនាំអំពីការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ (ទំព័រទី ២៥) ខណៈពេលដែលឧបករណ៍ទី២ ពិនិត្យជាក់លាក់លើការបង្កើនការចូលរួមឱ្យដល់កម្រិតអតិបរមានៅក្នុង DMF (ទំព័រទី ៣៣)។[២២] ADB និងប្រទេសកំពុងអភិវឌ្ឍជាសមាជិក កំពុងទទួលបានបទពិសោធន៍ក្នុងការរៀបចំសិក្ខាសាលាស្តីពី DMF ជាមួយអ្នកពាក់ព័ន្ធនានា ដើម្បីឈានទៅទទួលបានការឯកភាពគ្នាលើការរៀបចំគម្រោង និងនៅក្នុងការប្រើប្រាស់ការវិភាគដើមឈើបញ្ហា និងគោលដៅដើម្បីបង្កើនគុណភាពរបស់គម្រោង និងភាពជាម្ចាស់នៅមូលដ្ឋាន។ ការវាយតម្លៃដោយមានការចូលរួមក៏អាចផ្តល់ព័ត៌មានដល់ការរៀបចំគម្រោងផងដែរ ហើយឧបករណ៍ទី៣ ផ្តល់នូវទិដ្ឋភាពជារួម (ទំព័រទី ៣៧)។ ការចូលរួមនៅក្នុង DMF មានទិដ្ឋភាព ២ ដោយឡែកពីគ្នា ប៉ុន្តែមានទំនាក់ទំនងជាមួយគ្នា: ការជម្រុញឱ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធ នៅក្នុងការរៀបចំ និងការដាក់បញ្ចូលគោលដៅដែលមានការចូលរួម និងសកម្មភាពនានា សម្រាប់ការអនុវត្ត។

ការិយាល័យសេវាប្រតិបត្តិការកណ្តាល(COSO)របស់ ADBផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិក ADB និងមន្ត្រីរដ្ឋាភិបាលអំពីការអនុវត្ត DMF។ COSOក៏បណ្តុះបណ្តាលអ្នកសម្របសម្រួលនៅតាមប្រទេសកំពុងអភិវឌ្ឍជាសមាជិកផងដែរ ដោយបង្កើតនូវអ្នកជំនាញមួយក្រុមដើម្បីគាំទ្រដល់ការពិគ្រោះយោបល់។

ការចូលរួមក៏គួរដាក់បញ្ចូលទៅក្នុងការវិភាគភាពក្រីក្រ សង្គម និងការវិភាគដទៃទៀត ឬការវាយតម្លៃលើផលប៉ះពាល់ ដើម្បីផ្តល់ព័ត៌មានដល់ការរៀបចំគម្រោង និងការបង្កើតនូវផែនការស្តីពីការចូលរួមផែនការយេនឌ័រ និងផែនការការពារផលប៉ះពាល់សង្គម និងបរិស្ថាន។ ឧទាហរណ៍ ការដាក់បញ្ចូលការវិភាគល្អិតល្អន់លើអ្នកពាក់ព័ន្ធ និងការវិភាគទំនាក់ទំនងទៅក្នុងការវិភាគសេដ្ឋកិច្ច សម្រាប់រៀបចំគម្រោងផ្តល់សេវាសាធារណៈ គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាព។[២៣] ឱកាសសម្រាប់ចូលរួមនៅក្នុងការវាយតម្លៃ និងការកាត់បន្ថយផលប៉ះពាល់សង្គម និងបរិស្ថានត្រូវបានរៀបរាប់លំអិតនៅក្នុងផ្នែកដោយឡែកស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាននៃមគ្គុទេសក៍នេះ។ ទាំងអស់នេះផ្តល់ព័ត៌មានសម្រាប់បញ្ចប់ការបង្កើតយុទ្ធសាស្ត្រសង្ខេបអំពីការកាត់បន្ថយភាពក្រីក្រ និងសង្គម (SPRSS)។ SPRSS មានដាក់បញ្ចូលនូវផ្នែកមួយ ដែលនិយាយពីការចូលរួម (ផ្នែក ខ នៃការវិភាគសង្គម និង យុទ្ធសាស្ត្រ)។[២៤] យុទ្ធសាស្ត្រនេះសង្ខេបពីដំណើរការចូលរួម នៅក្នុងការរៀបចំគម្រោង និងថាតើមានការរៀបចំផែនការស្តីពីការចូលរួមដែរឬទេ។ សេចក្តីពិពណ៌នាអំពីលក្ខណៈសំខាន់ៗនឹងត្រូវផ្តល់ឱ្យប្រសិនបើចម្លើយឆ្លើយថា "មាន" ហើយប្រសិនបើទេត្រូវមានការពន្យល់ពីហេតុផល។

ផែនការស្តីពីការចូលរួម មិនចាំបាច់តែជាផែនការតែឯកឯងនោះទេ ហើយជាធម្មតា ត្រូវបានដាក់បញ្ចូលទៅ ក្នុងផែនការសកម្មភាពដទៃទៀត (ដូចជាផែនការស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាន, យេនឌ័រ និងសង្គមជាដើម)។ ប៉ុន្តែ ផែនការនេះគួរកំណត់ពីការចូលរួមរបស់អ្នកពាក់ព័ន្ធជាក់លាក់ គោលវិធីភាពស៊ីជម្រៅ និងវិធីសាស្ត្រសម្រាប់ប្រើប្រាស់ នៅដំណាក់កាលនីមួយៗ នៃវដ្តគម្រោងដោយធ្វើការពិចារណាពី

ឧបសគ្គផ្នែកពេលវេលា និងធនធាន។ ឧបករណ៍ទី៤ បង្ហាញលំអិតអំពីការណែនាំអំពីការបង្កើតផែនការ (សូមមើលទំព័រទី ៤១) ហើយឧបករណ៍ដទៃទៀតសម្រាប់វដ្តគម្រោង ពន្យល់ពីវិធីសាស្រ្តជាក់លាក់ (ដូចជាការពិនិត្យតាមដាន និងការវាយតម្លៃដោយមានការចូលរួមជាដើម)។ ការចំណាយពេលវេលារបស់បុគ្គលិក និងការចំណាយហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ផែនការស្តីពី ការចូលរួមនេះជាធម្មតាត្រូវបានដាក់បញ្ចូលទៅក្នុងចំណាយជារួមរបស់បេសកកម្ម។

បន្ទាប់មកមានការរៀបចំសៀវភៅណែនាំអំពីការរៀបចំគម្រោង (PAM) នៅពេលមានការស្វែងរកការពិតអំពីកម្ចី។ នេះនឹងកំណត់ពីកិច្ចព្រមព្រៀង និងព័ត៌មានលំអិតអំពីការអនុវត្តគម្រោងដូចជា ផ្នែកការការពារផលប៉ះពាល់សង្គម និងបរិស្ថាន យេនឌ័រ និងសង្គមផ្សេងទៀត។ PAM សម្រាប់គម្រោងនីមួយៗ រួមមានយុទ្ធសាស្រ្តស្តីពីការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធដែលរៀបរាប់ពី"ព័ត៌មានគម្រោងដែលត្រូវផ្សព្វផ្សាយ, មធ្យោបាយសម្រាប់ធ្វើការប្រាស្រ័យទាក់ទង, អ្នកដែលត្រូវផ្តល់ព័ត៌មាន, ក្រុមគោលដៅ និងភាពញឹកញាប់នៃការប្រាស្រ័យទាក់ទង"។ ការធ្វើបែបនេះបន្ថែមតម្លៃដល់ផែនការស្តីពីការចូលរួម ប៉ុន្តែផ្តោតការយកចិត្តទុកដាក់ខ្លាំងជាងលើការចែករំលែកព័ត៌មាន និង ការពិគ្រោះយោបល់។ ឧបករណ៍ទី ៥ រៀបរាប់ពីដំណើរការបង្កើតយុទ្ធសាស្រ្តប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ(សូមមើលទំព័រទី ៤៧)។ មានការណែនាំអំពីការចាត់ចែងគម្រោងជាក់លាក់ សម្រាប់ "អនុវត្តគម្រោងតូចៗ ដោយ មានការចូលរួមពីសហគមន៍"។[២៥] នេះរៀបរាប់ពីយន្តការងាយៗ សម្រាប់ធ្វើការសហការជាមួយនឹងអង្គការនៅតាមសហគមន៍ (CBOs) និងអង្គការក្រៅរដ្ឋាភិបាលនៅមូលដ្ឋាន។

## គោលនយោបាយស្តីពីការប្រាស្រ័យទាក់ទងសាធារណៈរបស់ ADB ពង្រឹងឱ្យមានការចូលរួមបន្ថែមទៀតនៅក្នុងគម្រោង

គោលនយោបាយនេះមានគោលបំណងសម្រួលឱ្យមានកិច្ចពិគ្រោះយោបល់ជាមួយអ្នកដែលរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធដទៃទៀត ដូចជា ស្រ្តី ប្រជាពលរដ្ឋក្រីក្រ និងក្រុមដែលងាយរងគ្រោះដទៃទៀត។ ព័ត៌មានអំពីគម្រោង ឬកម្មវិធីរដ្ឋ ឬមិនមែនរដ្ឋ (និងព័ត៌មានអំពីបញ្ហាបរិស្ថាន និងសង្គម) ត្រូវមានសម្រាប់ក្រុមទាំងនេះក្នុងទម្រង់ និងភាសាដែលពួកគេអាចយល់បាន និងបង្ហាញនៅកន្លែងដែលពួកគេអាចមើលបាន។ ADB ត្រូវធ្វើការងារឱ្យបានជិតស្និទ្ធជាមួយនឹងអ្នកខ្ចី ឬអតិថិជនដើម្បីធានាឱ្យមានការផ្តល់នូវព័ត៌មានទាំងនេះ និងធានាឱ្យមានការស្នើសុំព័ត៌មានត្រឡប់សម្រាប់ការរៀបចំគម្រោងដែលបានស្នើឡើយ ហើយត្រូវមានការតែងតាំងជន បង្គោលម្នាក់សម្រាប់ធ្វើទំនាក់ទំនងជាប្រចាំជាមួយនឹងអ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត។ ដំណើរការនេះនឹងចាប់ផ្តើមនៅដើមដំណាក់កាលរៀបចំគម្រោងដែលផ្តល់លទ្ធភាពឱ្យមានការពិចារណាយ៉ាងគ្រប់គ្រាន់លើគំនិត យោបល់របស់ពួកគេនៅក្នុងដំណាក់កាលរៀបចំគម្រោងដំបូង និងបន្តមានទៀតនៅដំណាក់កាលនីមួយៗ នៃការរៀបចំការដំណើរការ និងការអនុវត្តគម្រោង ឬកម្មវិធី។ ADB ត្រូវធានាថាការរៀបចំគម្រោង ឬកម្មវិធី នឹងផ្តល់លទ្ធភាពឱ្យអ្នកពាក់ព័ន្ធអាចផ្តល់នូវព័ត៌មានត្រឡប់ ក្នុងកំឡុងពេលអនុវត្ត។ ADB ត្រូវធានាយ៉ាងណាឱ្យមានការចែករំលែកព័ត៌មានពាក់ព័ន្ធនានា អំពីការផ្លាស់ប្តូរធំៗចំពោះវិសាលភាពរបស់គម្រោង និងផលប៉ះពាល់ដែលអាចមានជាមួយនឹងអ្នករងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធដទៃទៀត។

ប្រភព៖ ADB. 2011. *Public Communications Policy 2011*. Manila.

លក្ខខណ្ឌប្រតិបត្តិ (ToR) របស់អ្នកពិគ្រោះការសម្រាប់ PPTA អាចដាក់បញ្ចូលនូវធាតុចេញមួយចំនួន ឬធាតុចេញទាំងអស់នេះ ។ ធាតុចេញទាំងនេះគួរត្រូវបានបង្កើតឡើង រួមជាមួយនឹងអ្នកពាក់ព័ន្ធដើម្បីជួយធានាយ៉ាងណាឱ្យការរៀបចំគម្រោងអាចឆ្លើយតបទៅនឹងតម្រូវការនៅមូលដ្ឋាន ។ DMF, SPRSS,PAM និងផែនការស្តីពីយេនឌ័រ សង្គម និងការការពារផលប៉ះពាល់សង្គម និងបរិស្ថានគឺជាឧបសម្ព័ន្ធនៃរបាយការណ៍ និងអនុសាសន៍របស់ប្រធានធនាគារ (RRP) ដែលដាក់ជូនសម្រាប់ធ្វើការចរចា និងទទួលបានការឯកភាពមុនពេលដែលគម្រោងចាប់ផ្តើម ។

## ដំណាក់កាលទី ៣ : ការរៀបចំផែនការប្រតិបត្តិ

មុនពេលអនុវត្តគម្រោងការឯកភាពត្រូវបានធ្វើឡើង បន្ទាប់ពីការរៀបចំផែនការប្រតិបត្តិ ។ កិច្ចសន្យា ឬភាពជាដៃគូទាំងឡាយត្រូវបានបង្ហើយបញ្ចប់ ហើយការប្រាស្រ័យទាក់ទងរវាងអ្នកពាក់ព័ន្ធរបស់គម្រោង ដោះស្រាយនូវបញ្ហានានា ដែលមាន និងធានាយ៉ាងណាឱ្យអ្វីៗត្រូវបានរៀបចំរួចជាស្រេចសម្រាប់បេសកកម្មចាប់ផ្តើមគម្រោង និង សម្រាប់ការអនុវត្តគម្រោង ។

## ដំណាក់កាលទី ៤ : ការអនុវត្តការពិនិត្យតាមដាន និងការរាយការណ៍

គោលវិធី ដែលមានការចូលរួម ធ្វើឱ្យលទ្ធផលការងាររបស់គម្រោងមានភាពកាន់តែប្រសើរ និងបង្កើនភាពជាម្ចាស់នៅក្នុងកំឡុងពេលអនុវត្ត ។ គម្រោងមួយចំនួនដូចជា គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ជីវភាពរស់នៅ ឬអភិវឌ្ឍន៍សហគមន៍ (CDD) ជាដើម បានធ្វើឱ្យការចូលរួមមានភាពផ្លូវការ ។ គម្រោងផ្សេងទៀតដូចជាគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលអនុវត្តដោយរដ្ឋាភិបាលជាដើម ផ្តោតលើការផ្សព្វផ្សាយផែនការនានា ជាមួយនឹងអ្នកពាក់ព័ន្ធ ។ ផែនការចូលរួមសម្រាប់ការអនុវត្តគម្រោង ឆ្លុះបញ្ចាំងឱ្យឃើញពីភាពខុសប្លែកគ្នាទាំងនេះ ។ សកម្មភាពរបស់ផែនការចូលរួម រួមមានការបន្តធ្វើការពិគ្រោះយោបល់ ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធជាមួយនឹងស្ថាប័នអនុវត្តគម្រោងផ្តោតសំខាន់លើការកៀងគរសហគមន៍ ឬប្រើប្រាស់អង្គការសង្គមស៊ីវិលដើម្បីផ្តល់សេវា និងធ្វើការប្រាស្រ័យទាក់ទងដោយឯករាជ្យ ។ ឧបករណ៍ទី៦ ណែនាំអំពីការធ្វើការងារជាមួយនឹងអង្គការសង្គមស៊ីវិលដើម្បីគាំទ្រដល់សមាសភាគដែលមានការចូលរួម របស់ការអនុវត្តគម្រោង ។

PAM មានដាក់បញ្ចូលផែនការអនុវត្តគម្រោងដើម្បីកត់ត្រានូវធាតុចេញរួមជាមួយនឹងសកម្មភាពអនុវត្តសំខាន់ៗ (ប្រចាំខែ ឬប្រចាំត្រីមាស) ដូចជាសកម្មភាពដែលពាក់ព័ន្ធជាមួយនឹង DMF ផែនការស្តីពីយេនឌ័រ សង្គម និងការការពារផលប៉ះពាល់សង្គម និងបរិស្ថាន (រាប់បញ្ចូលទាំងការចូលរួមផង) និងយុទ្ធសាស្ត្រស្តីពីការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកពាក់ព័ន្ធ ។ អ្នកទទួល និង/ឬអតិថិជន ផ្ញើផែនការមក ADB ជារៀងរាល់ឆ្នាំដោយមានភ្ជាប់មកជាមួយនូវកិច្ចសន្យា និងការព្យាករអំពីការបើកផ្តល់ប្រាក់សម្រាប់ឆ្នាំបន្ទាប់ ។ របាយការណ៍ប្រចាំត្រីមាសរបស់ទីភ្នាក់ងារប្រតិបត្តិ ក៏គួរដាក់បញ្ចូលផងដែរនូវវឌ្ឍនភាពនានា ធៀបជាមួយនឹងផែនការស្តីពីការចូលរួមរបស់គម្រោង និងចំណុចដៅ និងសូចនាករស្តីពីលទ្ធផលការងារពាក់ព័ន្ធ ដែលត្រូវបានដាក់បញ្ចូលក្នុង DMF ។

## ដំណាក់កាលទី ៥ : ស្វ័យវាយតម្លៃ

ការបន្តពិនិត្យតាមដាន និងវាយតម្លៃ ដោយមានការចូលរួម គឺជាសកម្មភាពដ៏មានប្រយោជន៍ សម្រាប់គម្រោងដែលមានការចូលរួមក្នុងកម្រិតខ្ពស់ ។ សូមមើលឧបករណ៍ទី ៧ ទំព័រទី ៩៧ សម្រាប់ការណែនាំបន្ថែម ។ តែទោះជាយ៉ាងណាក៏ដោយ គ្រប់ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ និងពេលបញ្ចប់គម្រោងទាំងអស់គួរដាក់បញ្ចូលសកម្មភាពដែលមានការចូលរួម ។ សិក្ខាសាលាការពិភាក្សាក្រុមគោលដៅ និងវិធីសាស្ត្រដទៃទៀត

ផ្តល់លទ្ធភាពឱ្យមានការផ្តល់ធាតុចូលដ៏ច្រើនពីអ្នកពាក់ព័ន្ធ ក៏ដូចជាបង្កើនការចូលរួម និងភាពជាម្ចាស់នៅមូលដ្ឋាន។ បន្តិចម្តងៗ នេះអាចបង្កើននិរន្តរភាព ដោយផ្តល់ឱ្យអ្នកទទួលផលមានភាពពាក់ព័ន្ធ នៅក្នុងការបន្តគម្រោង ក្រោយកាល បរិច្ឆេទបញ្ចប់ផ្លូវការ។

របាយការណ៍ពាក់កណ្តាលអណត្តិ និងបញ្ចប់គម្រោង គឺជាកន្លែងដ៏សមស្រប ដើម្បីដាក់បញ្ចូលលទ្ធផលរកឃើញអំពីវិធីសាស្ត្រចូលរួម ដែលបានអនុវត្ត និងភាពស៊ីជម្រៅ ដែលសម្រេចបាន សម្រាប់វិធីសាស្ត្រនីមួយៗ។ ការវាយតម្លៃលើលទ្ធផល ផលសម្រេច និងភាពគ្រប់គ្រាន់នៃការចូលរួមដោយធ្វើការប្រៀបធៀបជាមួយនឹងគោលដៅ និង ផែនការស្តីពីការចូលរួម បង្កើតបាននូវមេរៀន សម្រាប់សកម្មភាពបន្តទៀត នៅក្នុងវិស័យដដែលនេះ។

## ដំណាក់កាលទី ៦ : ការវាយតម្លៃក្រោយពេលបញ្ចប់គម្រោង

ជាធម្មតារបាយការណ៍របស់នាយកដ្ឋានវាយតម្លៃឯករាជ្យរបស់ ADB តែងមានដាក់បញ្ចូលនូវទស្សនៈរបស់អ្នកពាក់ព័ន្ធដូចជាសង្គមស៊ីវិលជាដើម អំពីគម្រោង។ នៅក្នុងការរៀបចំការវាយតម្លៃគម្រោង (របាយការណ៍ស្តីពីលទ្ធផល និងសវនកម្មគម្រោង) ដែលមានដាក់បញ្ចូលទិដ្ឋភាពអំពីការចូលរួមពួកគេតែងសម្ភាស និងប្រមូលទិន្នន័យអំពីប្រជាជនដែលរស់នៅក្នុងតំបន់គម្រោងពី CBO រដ្ឋាភិបាលមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល។[២៦]

## ឧទាហរណ៍ដែលបង្ហាញពីការចូលរួម នៅក្នុងវដ្តគម្រោងរបស់ ADB

រូបភាពនេះបង្ហាញពីរបៀបដែលគម្រោងរដ្ឋផ្សេងៗ បានប្រើប្រាស់គោលវិធីដែលមានការចូលរួមនៅតាមដំណាក់កាលផ្សេងៗនៃវដ្តគម្រោង :



## ការចូលរួមនៅក្នុងប្រតិបត្តិការវិស័យឯកជន

ប្រតិបត្តិការមិនមែនរដ្ឋ នៅក្នុងវិស័យឯកជនជាទូទៅផ្តោតលើ (i) ហេដ្ឋារចនាសម្ព័ន្ធ និង (ii) ទីផ្សារមូលធន និងហិរញ្ញវត្ថុ (រាប់បញ្ចូលទាំងអន្តរការីហិរញ្ញវត្ថុ [FIs] ដូចជាធនាគារ ក្រុមហ៊ុនមូលបត្រ និងមូលនិធិវិនិយោគជាដើម)។ ប្រតិបត្តិការវិស័យឯកជនអនុវត្តតាមដំណើរការឯកភាពលើតណាទានមួយផ្សេង បើធៀបជាមួយនឹងគម្រោងរដ្ឋ ប៉ុន្តែនេះក៏មានរួមបញ្ចូលផងដែរនូវឱកាសសម្រាប់ការចូលរួមជាពិសេសសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ។ ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គមនៃអតិថិជនដែលជាអន្តរការីហិរញ្ញវត្ថុ មានដាក់បញ្ចូលនូវការណែនាំអំពីការចូលរួមក្នុងគម្រោង ដែលពាក់ព័ន្ធជាមួយនឹងអន្តរការីហិរញ្ញវត្ថុ។

ចំណុចខាងក្រោម អនុវត្តបានតែចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធតែប៉ុណ្ណោះ។ អតិថិជនវិស័យឯកជនអាចអនុវត្តសកម្មភាពចូលរួមមុនពេលមានការចូលរួមរបស់ ADB ហើយតួនាទីរបស់ ADB ផ្តោតជាពិសេសលើការធានាឱ្យមានភាពត្រឹមត្រូវ និងលើការផ្តល់ដំបូន្មាន ដើម្បីធានាយ៉ាងណាឱ្យសកម្មភាពចូលរួមនានា អាចបំពេញបានទៅតាមការអនុវត្តល្អជាអន្តរជាតិ។ នៅក្នុងករណីដែលមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងរក្សាការសម្ងាត់ ADB មិនបង្ហាញព័ត៌មាន ឬឱ្យអង្គការសង្គមស៊ីវិលចូលរួមនៅដំណាក់កាលកំណត់គម្រោង និងដំណាក់កាលបង្កើតឯកសារទស្សនទានរបស់គម្រោងឡើយ។ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានបង្កើតនូវសៀវភៅណែនាំអំពីការអនុវត្តល្អដ៏មានប្រយោជន៍មួយស្តីពីការប្រាស្រ័យទាក់ទង និងការបង្ហាញព័ត៌មានប្រកបដោយប្រសិទ្ធភាព និងសៀវភៅណែនាំមួយទៀតអំពីការឆ្លើយតបចំពោះទិដ្ឋភាពសង្គមនៃគម្រោងវិស័យឯកជន។[២៧]

### ដំណាក់កាលទី ១ : ការពិនិត្យឡើងវិញលើទស្សនាទាន

ក្នុងកំឡុងពេលពិនិត្យឡើងវិញលើទស្សនាទាននេះ ក្រុមការងារគម្រោងរបស់ ADB ស្នើសុំព័ត៌មានបឋមអំពីការរៀបចំគម្រោង និងធ្វើការកំណត់ថាតើប្រតិបត្តិការដែលស្នើឡើងនេះ អនុលោមទៅតាមគោលនយោបាយ និងគោលការណ៍របស់ ADB ដែរឬទេមុនពេលធ្វើការចរចាអំពីលក្ខខណ្ឌទូទៅជាមួយនឹងអតិថិជន។ ADB ចុះហត្ថលេខាលើកិច្ចព្រមព្រៀងរក្សាការសម្ងាត់ជាមួយនឹងអតិថិជន ហើយបន្ទាប់មកក្រុមការងាររៀបចំឯកសារពិនិត្យឡើងវិញលើទស្សនាទាននេះ ដើម្បីសុំការឯកភាពពីគណៈកម្មាធិការវិនិយោគ។ ប្រសិនបើព័ត៌មានដែលអតិថិជនវិស័យឯកជនផ្តល់ឱ្យក្រុមការងារគម្រោងមានភាពគ្រប់គ្រាន់នោះ IPSA នឹងត្រូវបានព្រាងឡើង សម្រាប់បម្លើយបញ្ចប់នៅក្នុងដំណាក់កាលពិនិត្យលើភាពត្រឹមត្រូវ។ នៅដំណាក់កាលនេះ អតិថិជនពិនិត្យឡើងវិញលើវិសាលភាពនៃការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធ (សូមមើលឧបករណ៍ទី ១ : ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ ទំព័រទី ២៥)។

## ដំណាក់កាលទី ២ : ការពិនិត្យឡើងវិញលើប្រតិបត្តិការ

អតិថិជនវិស័យឯកជនអាចចាប់ផ្ដើម ឬបញ្ចប់ការសិក្សាពីលទ្ធភាពអនុវត្ត និងការវាយតម្លៃលើបរិស្ថាន និងសង្គមដែលពាក់ព័ន្ធ។ នៅដំណាក់កាលនេះ ADB រៀបចំដំណើរការពិនិត្យលើភាពត្រឹមត្រូវ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយមួយ ដើម្បីវាយតម្លៃពីហានិភ័យសំខាន់ៗ ដែលមានមកលើប្រតិបត្តិការដូចជាហានិភ័យពាក់ព័ន្ធនឹងបរិស្ថាន និង សង្គមធ្វើការផ្ទៀងផ្ទាត់ថា ពិតជាមានសកម្មភាពចូលរួមនៅក្នុងពេលរៀបចំគម្រោង និងពិនិត្យថាតើមានការរៀបចំដើម្បីផ្ដល់លទ្ធភាពឱ្យមានការចូលរួមនាពេលអនាគត ដូចជា យន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្តជាដើម។ អតិថិជនរ៉ាប់រងចំណាយលើការវាយតម្លៃ និងការពិនិត្យលើភាពត្រឹមត្រូវ។ ជាធម្មតាផែនការស្ដីពីការចូលរួមត្រូវបាន ដាក់បញ្ចូលទៅក្នុងរបាយការណ៍ និងផែនការវាយតម្លៃបរិស្ថាន និងសង្គម។ នៅក្នុងដំណើរការពិនិត្យលើភាពត្រឹមត្រូវរបស់គម្រោង ដែលមានផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមខ្ពស់ក្រុមការងារគម្រោងរបស់ ADB ចូលរួម នៅក្នុង សកម្មភាពពិគ្រោះយោបល់ ដើម្បីស្វែងយល់ពីការព្រួយបារម្ភរបស់អ្នកដែលរងផលប៉ះពាល់ និងធានាយ៉ាងណាឱ្យមានការចូលរួមរបស់អ្នកទាំងនោះក្នុងការរៀបចំគម្រោង និងការរៀបចំផែនការស្ដីពីការការពារផលប៉ះពាល់សង្គម និង បរិស្ថាន។

## ដំណាក់កាលទី ៣ : ការពិនិត្យឡើងវិញចុងក្រោយ

ក្រុមការងារគម្រោងរៀបចំ និងផ្សព្វផ្សាយសេចក្ដីព្រាង RRP ដើម្បីឱ្យមានការពិនិត្យឡើងវិញជាលក្ខណៈអន្តរនាយកដ្ឋាន។ ដូចគ្នានឹងប្រតិបត្តិការរដ្ឋដែរ RRP មានដាក់បញ្ចូលដែលមានផ្នែកមួយនិយាយពីការចូលរួម (សូមមើលឧបករណ៍ទី ៤ : ការបង្កើតផែនការស្ដីពីការចូលរួម ទំព័រទី ៤១)។

## ដំណាក់កាលទី ៤ : ការឯកភាពរបស់ក្រុមប្រឹក្សាភិបាល

ឯកសារដែលពាក់ព័ន្ធជាមួយនឹងបរិស្ថាន និងសង្គមរួមជាមួយ RRP ត្រូវបានបង្ហោះផ្សាយលើគេហទំព័ររបស់ ADB ដោយមានរៀបរាប់លំអិតពីការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធបន្ថែមទៀត ដែលអតិថិជនវិស័យឯកជនធ្វើឡើងនៅក្នុងពេលរៀបចំគម្រោង និងអំពីការរៀបចំសម្រាប់ការពិគ្រោះយោបល់នាពេលអនាគត រាប់បញ្ចូលទាំង យន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្តផង។

## ដំណាក់កាលទី ៥ : ការបញ្ចប់

កិច្ចព្រមព្រៀងតាមផ្លូវច្បាប់ដែលត្រូវបានចុះហត្ថលេខារួមជាមួយនឹងអ្នកខ្ចី មានលើកឡើងពីការអនុវត្ត ផែនការបរិស្ថាន និងសង្គម និងមានដាក់បញ្ចូលសកម្មភាពដែលមានការចូលរួម នៅក្នុងដំណាក់កាលអនុវត្តគម្រោង។

## ចំណាក់កាលទី ៦ : ការពិនិត្យតាមដាន និងការគ្រប់គ្រងឥណទាន

អតិថិជនវិស័យឯកជនរាយការណ៍ពីវឌ្ឍនភាព ដែលសម្រេចបានធៀបជាមួយនឹងផែនការស្ដីពីការចូលរួមនៅក្នុងរបាយការណ៍ស្ដីពីការពិនិត្យតាមដានបរិស្ថាន និងសង្គមប្រចាំត្រីមាស និងប្រចាំឆមាសរបស់ពួកគេ។

សុច្ឆន្ទៈ និងការឯកភាពគ្នា ដែលបង្កើតឡើងរវាងអ្នកពាក់ព័ន្ធនៅមូលដ្ឋាន និងអ្នកទទួលជំនួយ/កម្ចី និង/ឬអតិថិជន ក្នុងកំឡុងពេលអនុវត្តគម្រោងរួមចំណែកបង្កើននិរន្តរភាពរបស់ប្រតិបត្តិការ។ គំនិតផ្ដួចផ្ដើមអភិវឌ្ឍន៍សហគមន៍ ដែលត្រូវបានអនុវត្តឡើងជាផ្នែកមួយនៃកម្មវិធីទទួលខុសត្រូវសង្គមជារួមជារឿយៗ តែងទទួលបានជោគជ័យ នៅពេលប្រើប្រាស់គោលវិធីដែលមានការចូលរួម។

### គម្រោងឧស្ម័នធម្មជាតិ Tangguh Liquefied ប្រទេសឥណ្ឌូនេស៊ី
### ( គោលវិធីចូលរួម : ការពិគ្រោះយោបល់ ការសហការគ្នាភាពជាដៃគូ, ភាពស៊ីជម្រៅ : ខ្ពស់)

ជាផ្នែកមួយនៃការរៀបចំការវាយតម្លៃ និងផែនការស្ដីពីបរិស្ថាន និងសង្គមក្រុមហ៊ុន BP Berau limited បានរៀបចំឱ្យមានកិច្ចពិគ្រោះយោបល់ និងការផ្ដល់ព័ត៌មានយ៉ាងទូលំទូលាយមួយដោយប្រើប្រាស់មធ្យោបាយជាច្រើន។ មធ្យោបាយទាំងនេះរួមមានការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព និងអេឡិចត្រូនិចនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ការពិគ្រោះយោបល់ជាមួយនឹងក្រុមពាក់ព័ន្ធនៅក្រុងចាកាតា និងប៉ាពួ, ការធ្វើបទបង្ហាញដល់ក្រុមពាក់ព័ន្ធនានា ដូចជាសហគមន៍មូលដ្ឋាន រដ្ឋាភិបាលមូលដ្ឋាន អ្នកដឹកនាំសហគមន៍ អង្គការក្រៅរដ្ឋាភិបាល សកលវិទ្យាល័យក្នុងស្រុក និងប្រព័ន្ធផ្សព្វផ្សាយជាដើម និងការរៀបចំសិក្ខាសាលាជាមួយនឹងអ្នកដែលរងផលប៉ះពាល់។ ចាប់តាំងពីពេលដែលគម្រោងចាប់ផ្ដើមមក យ៉ាងហោចណាស់មានមនុស្សចំនួន១៦២២នាក់បានចូលរួមនៅក្នុងការពិគ្រោះយោបល់ ហើយមានយោបល់ជាង ១៦០០ ត្រូវបានដាក់បញ្ចូលក្នុងផែនការអនុវត្តចុងក្រោយ។ គណៈកម្មាធិការនានា ត្រូវបានបង្កើតឡើងដើម្បីតំណាងឱ្យភូមិដែលរងផលប៉ះពាល់ដោយសារការតាំងទីលំនៅនៅក្នុងការជ្រើសរើសទីតាំងសម្រាប់តាំងទីលំនៅរៀបចំសាងសង់ និងគ្រប់គ្រងការផ្លាស់ប្ដូរពីទីតាំងចាស់ ទៅទីតាំងថ្មី។ គណៈកម្មាធិការនីមួយៗដែលមានសមាជិកប្រមាណជា ២០នាក់ ត្រូវបានបោះឆ្នោតជ្រើសរើសដោយអ្នកភូមិ ហើយទទួលបានការបណ្ដុះបណ្ដាលអំពីការអភិវឌ្ឍសហគមន៍ស្ត្រី និងការអភិវឌ្ឍ និងបរិស្ថាន ។ល។ ពីអង្គការក្រៅរដ្ឋាភិបាល។ នៅក្នុងពេលធ្វើលទ្ធកម្មដីធ្លី និងអនុវត្តផែនការតាំងទីលំនៅ BP បានជួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ បង្កើតជាសហករណ៍តាមមុខរបរចិញ្ចឹមជីវិត និងស្វែងរកស្ថាប័នខាងក្រៅ ដើម្បីអនុវត្តកម្មវិធីស្ដារជីវភាពរស់នៅឡើងវិញ ដូចជាកម្មវិធីផ្សព្វផ្សាយកសិកម្មជាដើម ទៅឱ្យអង្គការសង្គមស៊ីវិលដែលភាគច្រើនជាសកលវិទ្យាល័យក្នុងស្រុក។ សហករណ៍ Mayri កំពុងទទួលបានជំនួយដើម្បីដំណើរការ និងថែទាំសេវាអគ្គិសនី និងទឹកនៅ Tanah Merah Baru និងគ្រប់គ្រប់មូលនិធិ ដែលទទួលបានពីក្រុមហ៊ុន BP និងរដ្ឋាភិបាល kabupaten (ឬស្រុកដែលជារដ្ឋាភិបាលថ្នាក់ក្រោមជាតិទាបជាងខេត្តមួយកម្រិត)។

ជាផ្នែកមួយនៃកម្មវិធីសង្គម គម្រោងនេះក៏គាំទ្រផងដែរដល់ការពង្រឹងអង្គការសង្គមស៊ីវិល នៅក្នុងតំបន់ក្បាលបក្សីប៉ាពួដើម្បីផ្តល់លទ្ធភាពឱ្យពួកគេធ្វើជាតំណាង និងឆ្លើយតបចំពោះតម្រូវការរបស់ក្រុមគោលដៅរបស់ពួកគេ។ កម្មវិធីមួយដើម្បីពង្រឹងស្ថាប័ន *adat*[ក] ក៏ត្រូវបានរៀបចំឡើងផងដែរ ដើម្បីធានាយ៉ាងណាឱ្យស្ថាប័នទាំងនោះអាចឆ្លើយតបចំពោះការផ្លាស់ប្តូរនានា ដែលបង្កឡើងដោយគម្រោង Tangguh និងដើម្បីប្រមូលផ្តុំនូវឥទ្ធិពលជាប្រវត្តិសាស្ត្រនានាមកលើប្រព័ន្ធ *adat* និងការទទួលស្គាល់ និងស្ថានភាពរបស់ *adat* ដូចដែលបានកំណត់ដោយច្បាប់ស្តីពីស្វ័យភាពពិសេសរបស់ប៉ាពួ។

[ក] ស្ថាប័ន *Adat* គឺជាប្រព័ន្ធគុណតម្លៃផ្នែកវប្បធម៌ និងមនោគមវិជ្ជាអំពីទិដ្ឋភាពសំខាន់ៗនៃជីវិត ដោយបានផ្តល់នូវការណែនាំ និងការ តម្រង់ទិសដ៏មានតម្លៃដល់ជីវិតរបស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន។

ប្រភព៖ BP Berau Limited. 2006. *INO: Tangguh LNG Project – Summary EIA, Land Acquisition and Resettlement Plan, Integrated Social Program;* GHD. 2010. *Tangguh Liquefied Natural Gas Project–Seventh Compliance Monitoring Report.* Available from www.adb.org/projects/project.asp?id=38919

## ឧបករណ៍សម្រាប់ចូលរួម នៅក្នុងវដ្តគម្រោង

ការប្រើប្រាស់គោលវិធី និងវិធីសាស្ត្រដែលមានការចូលរួមផ្អែកទៅតាមភ័ស្តុតាងជាក់ស្តែង បង្កើនផលរយៈពេលវែងនិងនិរន្តរភាពរបស់គម្រោង។ ឧបករណ៍ និងគោលវិធីដែលមានការចូលរួមជាច្រើនមានភាពសមស្រប ទៅនឹងប្រតិបត្តិការរបស់ ADB និងប្រតិបត្តិការរបស់អ្នកទទួលជំនួយ/កម្ចី និង/ឬអតិថិជន។ ផ្នែកនេះបង្ហាញ ពីឧបករណ៍ចំនួន ៧ ដែលត្រូវបានសម្រិតសម្រាំងឡើងជុំវិញវដ្តគម្រោងរបស់ ADB។ ឧបករណ៍ជាច្រើនជាពិសេស ឧបករណ៍ទី ១ ៖ ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់មានភាពពាក់ព័ន្ធក្នុងកម្រិតខ្ពស់ចំពោះការ ពិនិត្យឡើងវិញលើគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធី។

## ឧបករណ៍ទី ១ : ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់

ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ធានាឱ្យមានការដាក់បញ្ចូលគំនិតយោបល់ពីភាគីពាក់ព័ន្ធជាច្រើន នៅក្នុងការបង្កើត និងការពិនិត្យឡើងវិញលើគោលនយោបាយកម្មវិធី និងគម្រោងនានា។ ឧបករណ៍នេះជួយដោះស្រាយបញ្ហាស្មុគស្មាញ ស្វែងរកការឯកភាព និងការគាំទ្រពីអ្នកពាក់ព័ន្ធ កាត់បន្ថយបញ្ហានៅក្នុងការអនុវត្ត និងបង្កើនផលរយៈពេលវែង។

## សេចក្តីផ្តើម

អ្នកពាក់ព័ន្ធ គឺជាបុគ្គលក្រុម និងស្ថាប័នទាំងឡាយដែលចាប់អារម្មណ៍ចំពោះសកម្មភាពណាមួយរបស់ ADB ឬរបស់អ្នកទទួលជំនួយ/កម្ចី និង/ឬអតិថិជន។ ពួកគេអាចទទួលរងផលប៉ះពាល់ អាចមានឥទ្ធិពលយ៉ាងសំខាន់ ឬជាអ្នក ដែលមានសារៈសំខាន់ ដើម្បីសម្រេចលទ្ធផលដែលបានលើកឡើង។ នៅពេលធ្វើការពិនិត្យឡើងវិញលើគោលនយោបាយយុទ្ធសាស្ត្រ ឬកម្មវិធីប្រចាំប្រទេស (ដូចដែលបានកំណត់ ដោយ CPS) និងនៅពេលរៀបចំ និងអនុវត្តគម្រោងអ្វីមួយ ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់

- កំណត់ពីអ្នកដែលចាប់អារម្មណ៍ចំពោះសកម្មភាពអ្វីមួយ
- កំណត់ពីការចាប់អារម្មណ៍របស់ក្រុមអ្នកពាក់ព័ន្ធ (ការយល់ឃើញ សមត្ថភាព ធនធាន)
- ទាញប្រយោជន៍ពីបទពិសោធន៍ និងជំនាញរបស់អ្នកពាក់ព័ន្ធ
- ទទួលបានការឯកភាពលើបញ្ហាសំខាន់ៗ បង្កើនភាពជាម្ចាស់ និងជម្រុញឱ្យអ្នកពាក់ព័ន្ធចូលរួមកាន់តែច្រើនជាងមុន នៅ ក្នុងការគាំទ្រដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព និង
- បង្កើតនូវវេទិកាសម្រាប់សកម្មភាពដែលមានការចូលរួម

ការវិភាគអ្នកពាក់ព័ន្ធ គឺជាដំណើរការដើម្បីកំណត់ និងស្វែងយល់ពីការចាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធ។ ការពិគ្រោះយោបល់ គឺជាសកម្មភាពត្រួតគ្នានឹងការវិភាគ ហើយជាសកម្មភាពដែលប្រើប្រាស់ការវិភាគផងដែរ។ អ្នកពាក់ព័ន្ធត្រូវបានស្នើឱ្យផ្តល់នូវគំនិតយោបល់ហើយគំនិតយោបល់របស់ពួកគេត្រូវបានយកមកធ្វើការពិចារណា សម្រាប់ដំណើរការរៀបចំ ឬពិនិត្យឡើងវិញលើគោលនយោបាយកម្មវិធី ឬគម្រោង។ គោលនយោបាយស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាន កំណត់ពីការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ (សូមមើលមគ្គុទេសក៏ត្រូវផ្នែកស្តីពីការចូលរួមនៅក្នុងការការពារផលប៉ះពាល់សង្គម និងបរិស្ថាន ទំព័រទី ៦៣) (លេខយោងចុងក្រោយទី ៨)។

ចុងក្រោយការវិភាគ និងការពិគ្រោះយោបល់បង្កើនគុណភាពនៃការសម្រេចចិត្ត កាត់បន្ថយការអាក់ខានក្នុងកំឡុងពេលអនុវត្តគម្រោងហើយការជម្រុញឱ្យប្រជាពលរដ្ឋចូលរួមធ្វើសេចក្ដីសម្រេចចិត្តដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ គឺជាការចូលរួមចំណែកដ៏សំខាន់មួយចំពោះអភិបាលកិច្ចល្អ។

## តើការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ សមស្របជាមួយនឹងវដ្តគម្រោងរបស់ ADB យ៉ាងដូចម្ដេច?

ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ធ្វើឡើង នៅពេលបង្កើត និងពិនិត្យឡើងវិញលើកម្មវិធីប្រចាំប្រទេស និងគម្រោងភាគច្រើនដូចជាកម្ចី ជំនួយឥតសំណង និងជំនួយបច្ចេកទេសជាដើម (លេខយោងចុងក្រោយទី ១៧ និង ២២)។

ជាពិសេសការដាក់បញ្ចូលការស្វែងយល់ពីទំនាក់ទំនងរបស់អ្នកពាក់ព័ន្ធទៅក្នុងការវិភាគសេដ្ឋកិច្ច និងការវិភាគផ្សេងទៀត ធ្វើឱ្យការរៀបចំគម្រោងកាន់តែមានភាពប្រសើរជាងមុន (លេខយោងចុងក្រោយទី២៣)។ ឧបករណ៍ទី២ ៖ ការបង្កើនការចូលរួមក្នុង DMF ដល់កម្រិតអតិបរមា ពន្យល់យ៉ាងច្បាស់លាស់អំពីរបៀបដែលការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់នេះមានលក្ខណៈសមស្របជាមួយនឹងការរៀបចំគម្រោងរបស់ ADB។

ការវិភាគ និងការពិគ្រោះយោបល់ គួរបន្តមាននៅក្នុងវដ្តគម្រោងទាំងមូល ហើយគួរតែបន្តធ្វើឱ្យបាន សកម្ម។ ឧបករណ៍ទី ៤ និងទី ៥ ពិនិត្យលើការបង្កើតផែនការស្ដីពីការចូលរួម និងយុទ្ធសាស្ត្រស្ដីពីការប្រាស្រ័យទាក់ទង ជាមួយនឹងអ្នកពាក់ព័ន្ធ ដែលអាចដាក់ចេញនូវផែនការអំពីទម្រង់នៃការពិគ្រោះយោបល់ ក្នុងកំឡុងពេលអនុវត្ត ពិនិត្យ តាមដាន និងវាយតម្លៃគម្រោង (សូមមើលទំព័រទី ៤១ និង ៤៧)។

ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ក៏មានសារៈសំខាន់ផងដែរ ចំពោះការបង្កើត និងការពិនិត្យឡើងវិញលើគោលនយោបាយ ឬយុទ្ធសាស្ត្រណាមួយ។ តម្រូវការជាក់ស្ដែង និងលក្ខណៈនៃការពិនិត្យឡើងវិញខាងក្រៅ អាស្រ័យទៅតាមប្រភេទ និងប្រធានបទរបស់ឯកសារ (លេខយោងចុងក្រោយទី ១៣)។ សូមមើលផ្នែកទី ២ ៖ ការចូលរួមនៅក្នុងការពិនិត្យឡើងវិញលើគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសរបស់ ADB។

### ជំហានសម្រាប់ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ប្រកបដោយជោគជ័យ

- **ធ្វើការងារឱ្យបានជិតស្និទជាមួយដៃគូ** ៖ ធានាយ៉ាងណាឱ្យសមភាគី(បុគ្គលិកADBនិវាសនដ្ឋានប្រចាំប្រទេសមន្ត្រីរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក អតិថិជនវិស័យឯកជន) មានការប្ដេជ្ញាចិត្តចំពោះគោលវិធីដោយមានការចូលរួមនេះ។
- បង្កើតការវិភាគអ្នកពាក់ព័ន្ធឱ្យបានល្អិតល្អន់ ៖ នេះនឹងកំណត់រក និងរំលេចឱ្យឃើញពីចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធសំខាន់ៗ និងជួយរៀបចំដំណើរការពិគ្រោះយោបល់។ ធានាយ៉ាងណាឱ្យអ្នកពាក់ព័ន្ធអាចសម្ដែងនូវការយល់ឃើញផ្សេងៗគ្នា និងភាពជាតំណាងរបស់ពួកគេ

តទៅទំព័របន្ទាប់

តារាង ត

## ជំហានសម្រាប់ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ប្រកបដោយជោគជ័យ

(សូមប្រើប្រាស់បញ្ជីត្រួតពិនិត្យខាងក្រោម) ។ ធ្វើការផ្សព្វផ្សាយដល់ក្រុមបាត់បង់ឱកាស និងក្រុមដែលមិនត្រូវបានគេ យកចិត្តទុកដាក់ហើយឱ្យមានការចូលរួមពីអ្នកគាំទ្រផង និងអ្នកប្រឆាំងផងដើម្បីបញ្ចៀសមិនឱ្យមានបញ្ហានៅពេលអនុវត្តនៅពេលក្រោយ ។

- ដាក់ចេញនូវគោលដៅឱ្យបានច្បាស់លាស់សម្រាប់កិច្ចពិគ្រោះយោបល់ : នៅក្នុងការរៀបចំកិច្ចពិគ្រោះយោបល់ ស្វែងរកការឯកភាពពីក្រុមការងារខាងក្នុង និងខាងក្រៅដែលមានចំណេះដឹងពិសេស អំពីគោលនយោបាយយុទ្ធសាស្ត្រ ឬគម្រោង ។ ដើម្បីបញ្ចៀសមិនឱ្យមានការរំពឹងទុកដែលមានលក្ខណៈមិនប្រាកដនិយម ត្រូវមានភាពច្បាស់លាស់ពីដើមដំបូងអំពីអ្វីដែលត្រូវយកមកធ្វើការពិចារណា និងអ្វីដែលមិនត្រូវយកមកធ្វើការពិចារណា និងអ្វីដែល ADB ឬអ្នកទទួលជំនួយ/កម្ចី និង/ឬអតិថិជន អាចមានឥទ្ធិពល លើ ។
- **រៀបចំផែនការឱ្យបានប្រុងប្រយ័ត្ន** : គិតរកឱកាសដើម្បីធ្វើការពិគ្រោះយោបល់ នៅក្នុងដំណាក់កាលសំខាន់ៗនៃដំណើរការរៀបចំ ឬពិនិត្យឡើងវិញ ។ ផ្អែកលើចំណុចនេះ និងលើការវិភាគអ្នកពាក់ព័ន្ធរៀបចំផែនការពិគ្រោះយោបល់ ។ បែងចែកពេលវេលា និងធនធានឱ្យបានគ្រប់គ្រាន់ (រួមទាំងសម្រាប់ការបកប្រែផង) ។

ប្រើប្រាស់ធនធានក្នុងស្រុក នៅពេលដែលអាចធ្វើទៅបាន និងកំណត់ពីឱកាសដើម្បីធ្វើសុខដុមនីយកម្មជាមួយនឹងអ្នកផ្តល់ជំនួយដទៃទៀត ។

**សម្រិតសម្រាំងគោលវិធីដែលប្រើប្រាស់សម្រាប់ធ្វើការពិគ្រោះយោបល់** : ជ្រើសរើសវិធីសាស្ត្រដើម្បីផ្សព្វផ្សាយដល់ក្រុមសំខាន់ៗ ដោយធ្វើការពិចារណាពីបញ្ហាភាសាអក្ខរកម្ម និងការដឹងពីបញ្ហា និងទីតាំងរបស់ពួកគេ (សូមមើលឧបករណ៍ទី១ : ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះ **យោបល់ទំព័រទី២៥ និងឧបករណ៍ទី៣** : ការវាយតម្លៃដែលមានការចូលរួមទំព័រទី ៣៧) ។ ធានាយ៉ាងណាឱ្យមានបរិយាកាសដែលផ្តល់លទ្ធភាពឱ្យអ្នកពាក់ព័ន្ធចូលរួមដោយចំហ ហើយគំនិតយោបល់របស់ពួកគេត្រូវបានគេយកទៅធ្វើការពិចារណា ។

***ប្រើប្រាស់គោលវិធីផ្អែកតាមយេនឌ័រ*** : ទាំងបុរស ទាំងស្ត្រី សុទ្ធតែត្រូវការការពិគ្រោះយោបល់ ហើយនៅក្នុងវប្បធម៌មួយចំនួនការពិគ្រោះយោបល់នេះគួរធ្វើឡើងដោយឡែកៗ ពីគ្នាដោយកំណត់ពេលវេលាទៅតាមបន្ទុកកិច្ចការក្នុងគ្រួសារ និងក្នុងការងារ ។ អង្គការស្ត្រីនៅមូលដ្ឋានអាចជួយរៀបចំការពិគ្រោះយោបល់ជាមួយនឹងស្ត្រី នៅក្នុងសហគមន៍ ។

***ចាប់ផ្តើមការពិគ្រោះយោបល់ឱ្យបានឆាប់*** : ចាប់ផ្តើមមុនពេលដែលសេចក្តីព្រាងដំបូងត្រូវបានសរសេរសម្រាប់គោលនយោបាយនៅក្នុងដំណាក់កាលរៀបចំផែនទីបង្ហាញផ្លូវតាមវិស័យ និងការវិភាគលើកម្មវិធីប្រចាំប្រទេស និងក្នុងដំណាក់កាលរៀបចំទស្សនាទានគម្រោង ។ ប្រើប្រាស់ដំណើរការដែលមានស្រាប់ ឧ. សម្រាប់ការរៀបចំកម្មវិធីប្រចាំប្រទេស សូមប្រើប្រាស់ដំណើរការរៀបចំឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ។

- **បង្កើនតម្លាភាពឱ្យដល់កម្រិតអតិបរមា** : ប្រើប្រាស់គេហទំព័រ និងច្រកផ្សេងទៀតដើម្បីផ្តល់ព័ត៌មានដល់អ្នកដែលពុំអាចចូលមើលគេហទំព័រ ឬដែលមិនចេះភាសាអង់គ្លេស (ឧ. ខិតប័ណ្ណព័ត៌មាន កិច្ចប្រជុំផ្សព្វផ្សាយព័ត៌មាន ដោយប្រើប្រាស់ភាសាមូលដ្ឋាន) ដើម្បីផ្សព្វផ្សាយផែនការដោយធ្វើការពន្យល់លំអិតអំពីដំណើរការពិគ្រោះយោបល់គោលដៅ និងខ្លឹមសារពង្រាង ។ ធានាឱ្យមានការយល់ដឹងពីយន្តការគណនេយ្យភាព ។
- **ធ្វើការតាមដានបន្ត និងរក្សាដំណើរការឱ្យនៅតែមានភាពរស់រវើក** : ដើម្បីរក្សាភាពជឿជាក់ និងសុចរិតភាពផ្តល់ព័ត៌មានត្រឡប់ ថាតើគំនិតយោបល់នានាត្រូវបាន ឬមិនបានយកទៅធ្វើការពិចារណា ហើយពន្យល់ពីមូលហេតុ ។ ចែករំលែកព័ត៌មានសង្ខេបអំពីការពិគ្រោះយោបល់ជាមួយអ្នកចូលរួមភ្លាមៗ ហើយអញ្ជើញឱ្យពួកគេផ្តល់នូវការកែតម្រូវ ។ បកប្រែឯកសារចុងក្រោយជាភាសាមូលដ្ឋាន ហើយដាក់

តទៅទំព័របន្ទាប់

តារាង ត

| |
|---|
| ឯកសារនេះឱ្យគេអាចចូលមើលបាន។ ធ្វើឱ្យដំណើរការពិគ្រោះយោបល់មានភាពផ្លូវការ នៅក្នុងរយៈពេលនៃ គោលនយោបាយ កម្មវិធីប្រចាំប្រទេស ឬគម្រោង (សូមមើលឧបករណ៍ទី ៤ និងទី ៥) ដើម្បីប្រមូលព័ត៌មានអំពីការប្រែប្រួលនៃ កាលៈទេសៈ និងចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធ។ |

## ការកំណត់អ្នកពាក់ព័ន្ធ

ចាប់ផ្តើមដោយប្រើប្រាស់បញ្ជីត្រួតពិនិត្យដើម្បីកំណត់ពីអ្នកពាក់ព័ន្ធសំខាន់ៗ។ ក្រុមសំខាន់ៗទាំង ៣ រួមមានរដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិល។ ក្រុមនីមួយៗ មានអនុក្រុមជាច្រើន។ ADB ផ្តល់កម្ចីច្រើនជាងគេដល់រដ្ឋាភិបាលប៉ុន្តែក៏មានអតិថិជនវិស័យឯកជនផងដែរ។ អ្នកទទួលកម្ចី/ជំនួយ និង/ឬអតិថិជន ត្រូវធានាយ៉ាងណា ឱ្យក្រុមដទៃទៀតអាចចូលរួមបាន។ ការចូលរួមរបស់សង្គមស៊ីវិល មានសារៈសំខាន់យ៉ាងខ្លាំងចំពោះការចូលរួមប្រកបដោយអត្ថន័យ។ អ្នកពាក់ព័ន្ធមួយចំនួនមានដូចខាងក្រោម (នៅថ្នាក់ជាតិ ថ្នាក់មធ្យម និងថ្នាក់ក្រោមជាតិ) :[២៨]

### សង្គមស៊ីវិល

- សាធារណជនទូទៅ : ក្រុមប្រជាជន និងអនុក្រុម (ឧ. យុវជន ក្មេងស្រី និងក្រុមស្ត្រី) និងក្រុមជនជាតិដើមភាគតិច (ជនជាតិដើមភាគតិច ដែលរស់នៅក្នុងរដ្ឋដែលមានភាពផុយស្រួយ និងដែលរងផលប៉ះពាល់ដោយសារជម្លោះ តែងតែ ជាអ្នកដែលងាយរងគ្រោះជាពិសេស និងជាអ្នកដែលត្រូវបានគេមើលរំលង) ដែលរងផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល។
- អង្គការសង្គមស៊ីវិល : អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ អង្គការតាមសហគមន៍ មូលនិធិ សហជីព និងស្ថាប័ន ស្រាវជ្រាវឯករាជ្យ។

### រដ្ឋាភិបាល

- រដ្ឋាភិបាល : មន្ត្រីនៅតាមក្រសួង ខុទ្ទកាល័យ ។ល។
- សភាតំណាង : ស្ថាប័នរដ្ឋាភិបាល ដែលត្រូវបានជ្រើសតាំង តាមរយៈការបោះឆ្នោត (ឧ. រដ្ឋសភា សភាជាតិ និងក្រោមជាតិ និងអ្នកដឹកនាំសហគមន៍ដែលត្រូវបានជ្រើសតាំង តាមរយៈការបោះឆ្នោត)
- ស្ថាប័នរដ្ឋាភិបាលទ្វេភាគី និងពហុភាគី : ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (ឧ. ធនាគារពិភពលោក អ្នកផ្តល់ជំនួយទ្វេភាគី (ឧ. USAID) ។ល។

### វិស័យឯកជន

- វិស័យឯកជន : ក្រុមហ៊ុនឯកជន ក្រុមសមាជិកភាពដែលតំណាងឱ្យក្រុមនានានៅក្នុងវិស័យឯកជន និងសភាពាណិជ្ជកម្ម

ផ្សព្វផ្សាយបញ្ជីអ្នកពាក់ព័ន្ធបឋម និងពន្យល់ពីរបៀបបន្ថែម និងរបៀបដែលអ្នកពាក់ព័ន្ធ អាចដាក់ខ្លួនឯងចូលក្នុងបញ្ជី។ ស្វែងរកដំបូន្មានពីអ្នកជំនាញអ្នកដឹកនាំសហគមន៍ និងសហការី។ អង្គការសមាជិកភាពដែលអាចជឿជាក់បានដូចជាវេទិកាអង្គការក្រៅរដ្ឋាភិបាលស្តីពី ADB ឬបុគ្គលិករបស់ NGOC អាចជួយដល់ការផ្សព្វផ្សាយព័ត៌មាន ដល់អ្នកពាក់ព័ន្ធមកពីសង្គមស៊ីវិលបាន។

វិភាគលើបញ្ជីអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីកំណត់ពីការដាក់បញ្ចូលពួកគេនាពេលបច្ចុប្បន្ន ទៅក្នុងដំណើរការ របស់ ADB និងរបស់រដ្ឋាភិបាល។ សម្រាប់ក្រុមដែលមិនត្រូវបានរាប់បញ្ចូល ឬយ៉ាងហោចណាស់ក្រុមដែលមិនបានចូល រួម កំណត់ពីឧបសគ្គ ដែលរារាំងក្រុមទាំងនេះមិនឱ្យចូលរួម និងរបៀបជំនះឧបសគ្គទាំងនេះ។ ចៀសវាងផ្តោតការយកចិត្តទុកដាក់លើអ្នកពាក់ព័ន្ធដែលងាយស្រួលទាក់ទង និងអ្នកដែលមានទំនាក់ទំនងរួចទៅហើយ។ ទំនាក់ទំនង និងដាក់បញ្ចូលក្រុមជួបប្រទះការលំបាកដែលកម្រចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ ជនជាតិដើមភាគតិច ប្រជាពលរដ្ឋដែលក្រីក្រខ្លាំង និងស្ត្រីអាចត្រូវការការគាំទ្រជាពិសេស។ ប្រើប្រាស់សកម្មភាពផ្សព្វផ្សាយព័ត៌មាន និងពិគ្រោះយោបល់ដើម្បីជម្រុញឱ្យមានការចូលរួមពីពួកគេ (ដូចជាវិធីសាស្ត្រដែលមានការចូលរួម ដែលមិនចាំបាច់តម្រូវឱ្យចេះអក្សរទើបអាចចូលរួមបាន)។ ជម្រុញឱ្យមានការចូលរួមពីអ្នកដែលមានទស្សនៈអវិជ្ជមាន ឬទស្សនៈប្រឆាំងចំពោះបញ្ហាទាំងនេះ ហើយធានាយ៉ាងណាឱ្យមានការវិភាគលើគ្រប់ទស្សនៈទាំងអស់។ មុនពេលកំណត់ពីចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធ សូមឆ្លើយនឹងសំណួរខាងក្រោម។

**Final Checklist for Identifying Stakeholders**

- **តើនិវាសនដ្ឋានប្រចាំប្រទេស (ឧ. វេទិកាអង្គការក្រៅរដ្ឋាភិបាល ជាដើម) និងអ្នកផ្តល់ព័ត៌មានសំខាន់ៗដទៃទៀតបានជួយកំណត់ អ្នកពាក់ព័ន្ធដែរឬទេ?**
- **តើគ្រប់អ្នកពាក់ព័ន្ធទាំងអស់ត្រូវបានកំណត់ និងមានឈ្មោះក្នុងបញ្ជីដែរឬទេ?**
  - ក្រុមដែលជួបប្រទះការលំបាក និងក្រុមដែលងាយរងគ្រោះ (ជាពិសេសក្រុមដែលក្រីក្របំផុត ជនជាតិដើមភាគតិច គ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងក្រុមជនចំណាកស្រុក)?
  - ក្រុមអតិថិជន/អ្នកទទួលផលសំខាន់ៗ?
  - ក្រុមដែលទទួលរងផលប៉ះពាល់ជាអវិជ្ជមាន ដោយសារគម្រោង?
  - គ្រប់អ្នកគាំទ្រ និងអ្នកប្រឆាំងគម្រោងទាំងអស់?
  - អ្នកពាក់ព័ន្ធគ្រប់ប្រភេទទាំងអស់ (ដោយប្រើប្រាស់ការវិភាគយេនឌ័រ ប្រសិនបើចាំបាច់)?
- **តើអ្នកពាក់ព័ន្ធទាំងនេះគួរត្រូវបែងចែកទៅតាមក្រុមអ្នកប្រើប្រាស់ ការងារ អាយុ ចំណូល ឬក្រុមជនជាតិភាគតិចដែរឬទេ?**

## កំណត់ពីចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធ

ដំណាក់កាលបន្ទាប់ គឺការកំណត់ពីចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធក្នុងគោលនយោបាយ កម្មវិធី ឬគម្រោងដោយធ្វើការស្វែងយល់ពីការយល់ឃើញរបស់ពួកគេចំពោះបញ្ហាអភិវឌ្ឍន៍ ដែលគោលនយោបាយ កម្មវិធី ឬគម្រោងព្យាយាមដោះស្រាយ ក៏ដូចជា សមត្ថភាព និងធនធានរបស់ពួកគេដើម្បីចូលរួមក្នុង (ឬដើម្បីប្រឆាំង/ធ្វើឱ្យរាំងស្ទះ ដល់) គោលនយោបាយកម្មវិធី ឬគម្រោងនេះ។ នេះតម្រូវឱ្យមានការប្រើប្រាស់វិធីសាស្ត្រដែលត្រូវបានជ្រើសរើសយ៉ាងប្រុងប្រយ័ត្នដើម្បីកសាងនូវការឯកភាពគ្នា និងធានាឱ្យមានការទទួលព័ត៌មានត្រឡប់ប្រកបដោយអត្ថន័យ។ វិធីសាស្ត្រមានប្រសិទ្ធភាពបំផុត ប្រសិនបើវាត្រូវបានអនុវត្តជាមួយអ្នកពាក់ព័ន្ធ ដែលចូលរួម ដើម្បីបង្កើតឱ្យមានការ ឯកភាពគ្នា និងភាពជាម្ចាស់។

មានវិធីជាច្រើនសម្រាប់ធ្វើការពិគ្រោះយោបល់ ហើយមានលក្ខខណ្ឌជាច្រើន ដែលមានឥទ្ធិពលលើវិធីសាស្ត្រ ដែលនឹងផ្តល់នូវព័ត៌មាន ដែលមានប្រយោជន៍ជាងគេ។ សូមធ្វើការពិចារណាឱ្យបានប្រុងប្រយ័ត្នអំពីគោលបំណងនៃការ ពិគ្រោះយោបល់ លក្ខណៈរបស់អ្នកដែលត្រូវបានគេពិគ្រោះ



ការវិភាគអ្នកពាក់ព័ន្ធ ចេញពីការបណ្តុះបណ្តាលអំពីការចូលរួម ជាមួយនឹងមន្ត្រីរដ្ឋាភិបាល នៅរាជធានីភ្នំពេញ ប្រទេស កម្ពុជា ខែ មីនា ឆ្នាំ ២០១២?

លក្ខណៈរបស់អ្នកដែលត្រូវ)យោបល់ជាមួយ (ភាសា កម្រិតអក្ខរកម្ម ទីតាំងបទពិសោធន៍ជាមួយបញ្ហា) និងពេលវេលា/ធនធានដែលមាន នៅពេលបង្កើតផែនការស្តីពីការចូលរួម។ ឧទាហរណ៍ បុគ្គលិករបស់អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ អាចជម្រុញឱ្យមានការចូលរួមផ្សេងៗពីគ្នាពីសមាជិកសហគមន៍មូលដ្ឋាន ដែលទទួលរងផលប៉ះពាល់។ ពេលខ្លះ ការនិយាយទៅកាន់ប្រជាពលរដ្ឋ មានតម្លៃជាងការសរសេរលិខិតផ្ញើឱ្យពួកគេ។ ការប្រើប្រាស់វិធីសាស្ត្រលើសពីមួយ ផ្តល់នូវការឆ្លើយតបបានប្រសើរជាងទាំងគុណភាព ទាំងបរិមាណ។ វិធីសាស្ត្រផ្សេងៗពីគ្នា ក៏អាចបង្កើតនូវលទ្ធផលផ្សេងៗពីគ្នាផងដែរ។ ចំណុចសំខាន់បំផុត គឺត្រូវទទួលបាន ទស្សនៈឱ្យបានទូលំទូលាយបំផុត ពីអ្នកដែលនឹងរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ និងពីអ្នកដែលមានគំនិតយោបល់ច្រើនដើម្បីចូលរួម។

តារាងខាងក្រោមបង្ហាញពីវិធីសាស្ត្រ និងគោលវិធីមួយចំនួន ដែលគេតែងប្រើប្រាស់ញឹកញាប់សម្រាប់ការពិគ្រោះយោបល់ និងកាលៈទេសៈ ដែលវិធីសាស្ត្រ និងគោលវិធីទាំងនេះមានសារៈប្រយោជន៍ជាពិសេស ។

## វិធីសាស្ត្រសម្រាប់ធ្វើការពិគ្រោះយោបល់

| វិធីសាស្ត្រ | សេចក្តីពិពណ៌នា |
|---|---|
| ការពិគ្រោះយោបល់ តាមអនឡាញ និង ជាលាយលក្ខណ៍អក្សរ Consultation | ជាធម្មតា វិធីសាស្ត្រនេះរួមមានការប្រើប្រាស់គេហទំព័រពិសេស សម្រាប់ការពិគ្រោះយោបល់ ដើម្បីបង្ហាញពី គោលនយោបាយ យុទ្ធសាស្ត្រ ឬគម្រោង និងពីគោលបំណងរបស់ការពិគ្រោះយោបល់ ។ ការរៀបចំការពិគ្រោះ យោបល់មានការប្រែប្រួល ។ គេអាចប្រើប្រាស់ឯកសារពង្រាង ប្រធានបទទូលំទូលាយ ឬសំណួរបើក ដើម្បីផ្តល់ ការណែនាំអំពីការផ្តល់យោបល់ ឬប្រើរបៀបជាការអង្កេត ដោយប្រើសំណួរបិទ ។ យោបល់របស់សាធារណជន ទូទៅ ផ្តល់លទ្ធភាពឱ្យមានការពិភាក្សារវាងអ្នកពាក់ព័ន្ធ ។ គេអាចប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមផងដែរ ។ ការពិគ្រោះយោបល់តាមអនឡាញ ផ្តល់លទ្ធភាពឱ្យមានការពិគ្រោះយោបល់ជាសាធារណៈដោយចំហ ប៉ុន្តែវាអាច ទៅដល់តែអ្នកដែលចេះអក្សរ និងមានអ៊ីនធឺណិតប្រើប្រាស់តែប៉ុណ្ណោះ និងមិនអាចបានទៅដល់អ្នកដែលជួបប្រទះ ការលំបាកខ្លាំងជាងគេនោះឡើយ ។ ការបង្ហោះផ្សាយ ឬការផ្ញើអ៊ីមែលអំពីព័ត៌មានត្រឡប់ ក៏ជាវិធីសាស្ត្រ ដែលគេ និយមប្រើប្រាស់ផងដែរ ។ |
| **កិច្ចប្រជុំជាសាធារណៈ** | កិច្ចប្រជុំ គឺជាវិធីសាស្ត្របើកចំហ សម្រាប់ធ្វើការពិគ្រោះយោបល់ជាមួយនឹងសាធារណជនទូទៅ ។ កិច្ចប្រជុំអាចធ្វើ បាននៅកម្រិតណាមួយក៏បាន (កម្រិតសហគមន៍ តំបន់ ជាតិ ។ល ។) ។ ធានាយ៉ាងណាឱ្យមនុស្ស គ្រប់រូបអាចចូលរួមក្នុងកិច្ចប្រជុំទាំងនេះ និងផ្តល់សេចក្តីជូនដំណឹងឱ្យបានគ្រប់គ្រាន់ ដល់ភាគីដែលពាក់ព័ន្ធ ។ លើសពីនេះទំហំនៃកិច្ចប្រជុំអាចប៉ះពាល់ដល់ការចូលរួម ។ កិច្ចប្រជុំដែលមានសមាជិកតិចជាង ២០នាក់ អាចធានាបានថា គ្រប់គ្នាសុទ្ធតែអាចនិយាយបាន ។ ការបំបែកក្រុមពិភាក្សា និងវិធីសាស្ត្រដោយមានការចូលរួម (ឧ. ការដាក់ចំណាត់ថ្នាក់ជ្យាក្រាម) អាចជួយក្តាប់បាននូវគ្រប់ទស្សនៈយោបល់ទាំងអស់ ។ |
| **សិក្ខាសាលា** | សិក្ខាសាលា គឺជាការប្រមូលផ្តុំមនុស្សមួយក្រុម ដើម្បីទទួលបានព័ត៌មានត្រឡប់ពីពួកគេ ក្នុងទម្រង់មួយដែលមាន ការរៀបចំត្រឹមត្រូវ ។ ទម្រង់ជួបប្រជុំគ្នាដោយផ្ទាល់បែបនេះផ្តល់លទ្ធភាពឱ្យមានការប្រមូលគំនិត និងធ្វើតេស្តលើគំនិតនានា ។សិក្ខាសាលាច្រើនអាចផ្តល់នូវលទ្ធផលកាន់តែច្រើន ។ សាកល្បងសិក្ខាសាលាឱ្យបានច្រើនប្រភេទ (ឧ. សិក្ខាសាលានៅទីវាល សិក្ខាសាលាសរសេរ វិធីសាស្ត្រដែលមានការចូលរួម) ។ ការសម្របសម្រួលមានសារៈសំខាន់ យ៉ាងខ្លាំង ហើយបុគ្គលដែលមានជំនាញ និងអព្យាក្រឹត អាចជួយធានាឱ្យវិធានរបស់ក្រុមមានភាពច្បាស់លាស់ គ្រប់គំនិតយោបល់ទាំងអស់ត្រូវបានយកទៅធ្វើការពិចារណា ហើយមិនមានសិក្ខាកាមណាម្នាក់និយាយតែឯងនោះឡើយ ។ សម្រាប់ព័ត៌មានបន្ថែម សូមមើលបញ្ជីធនធាន នៅក្នុងមគ្គុទេសក៍នេះ និងឧបករណ៍ទី ៣ : ការវាយតម្លៃ ដោយមានការចូលរួម ។ |
| ការពិភាក្សាក្រុមគោលដៅ (FGD) | ការពិភាក្សាបែបគុណវិស័យពាក់កណ្តាលរចនាសម្ព័ន្ធ ជាមួយនឹងក្រុមតូច (ជាទូទៅ មានអ្នកចូលរួម ៥-១២ នាក់ បូកនឹងអ្នកសម្របសម្រួលដែលមានជំនាញ ១-២ នាក់) ។ ការពិភាក្សាដោយហចំហ អាចស្វែងយល់ពីអាកប្បកិរិយា ការព្រួយបារម្ភ និងចំណង់ចំណូលចិត្តរបស់មនុស្ស ចំពោះបញ្ហាជាក់លាក់អ្វីមួយ ដោយចុងក្រោយមានការប្រមូល គំនិតយោបល់ផ្សេងៗ ។ ក្រុមមនុស្សចម្រុះ គឺអាស្រ័យទៅតាមគោលបំណង ប៉ុន្តែជាធម្មតាចំនួននេះត្រូវកំណត់ មិនឱ្យលើសពី ១៥ នាក់ ។ សមាជិកសហគមន៍ ដែលមិនធ្លាប់ចូលរួមក្នុងកិច្ចប្រជុំផ្លូវការ អាចមានអារម្មណ៍ងាយ ស្រួលក្នុងការសម្តែងមតិយោបល់របស់ខ្លួន នៅក្នុងកិច្ចពិភាក្សាក្រុមគោលដៅ (ឧ. ស្ត្រី ជនជាតិដើមភាគតិច ឬក្រុមដែលគ្មានឱកាស ជនពិការ ឬជន និងគ្រួសារក្រីក្រ) ។ |
| **កិច្ចសម្ភាសស៊ីជម្រៅ** | ការសម្ភាសបែបគុណវិស័យតាមទូរស័ព្ទ ឬដោយផ្ទាល់ ជាមួយនឹងបុគ្គល (ដូចជា សមាជិកសហគមន៍ អ្នកផ្តល់ ព័ត៌មានសំខាន់ៗ ឬអ្នកដឹកនាំអង្គការសង្គមស៊ីវិល) អាចឱ្យយើងដឹងពីទស្សនវិស័យរបស់អ្នកពាក់ព័ន្ធ ។ ការសម្ភាស ទាំងនេះអាចរៀបចំឡើងពេញលេញ (ការសម្ភាសបែបផ្លូវការ ហើយត្រូវធ្វើទៅតាមការណែនាំជាលាយល័ក្ខណ៍ អក្សរសម្រាប់ការសម្ភាស) រៀបចំឡើងពាក់កណ្តាល (មើលតាមការណែនាំអំពីការសម្ភាសតែត្រង់ចំណុចមួយ ចំនួន ប៉ុន្តែមានលក្ខណៈជាការសន្ទនាគ្នាដោយចំហ ដើម្បីផ្តល់លទ្ធភាពឱ្យអ្នកតបសម្ភាសលើកឡើងពីប្រធានបទដទៃទៀត ដែលពួកគេចាប់អារម្មណ៍) ឬមិនមានការរៀបចំជាមុន (រៀបចំឡើងជុំសំណួរ ឬប្រធានបទទូទៅមួយ ចំនួនតូច ប៉ុន្តែមានលក្ខណៈក្រៅផ្លូវការ និងប្រើប្រាស់សំណួរបើក) អាស្រ័យទៅតាមបរិបទ ។ ការសម្ភាសដែលមានការរៀបចំជាមុន ទំនងជាអាចផ្តល់ព័ត៌មានដែលអាចយកមកធ្វើការប្រៀបធៀប និងបង្ហាញជាទូទៅបាន ខណៈពេលដែលការសម្ភាសដែលមានការរៀបចំតិចតួច អាចស្វែងយល់ពីបញ្ហាអ្វីមួយឱ្យបានស៊ីជម្រៅ និងផ្តល់លទ្ធភាពឱ្យមានការលើកឡើងពីបញ្ហា ដែលពាក់ព័ន្ធ ។ ការសម្ភាសជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលមានចំណេះដឹងជាពិសេសអំពីបញ្ហាអ្វីមួយ គឺជាការសម្ភាសដ៏មានប្រយោជន៍ជាពិសេស ។ |

| វិធីសាស្ត្រ | សេចក្ដីពិពណ៌នា |
|---|---|
| **ការអង្កេត** | ការអង្កេតផ្ដល់នូវចម្លើយជាក់លាក់ចំពោះបញ្ហាអ្វីមួយ។ ការអង្កេតអាចបង្ហាញយ៉ាងរហ័សអំពីអ្នកដែលចាប់ អារម្មណ៍ និងមូលហេតុ និងផ្ដល់នូវទិន្នន័យបែបបរិមាណវិស័យ។ ការអង្កេតបង្ហាញពីទម្ងន់សម្រាប់ទស្សនៈផ្សេងៗ ពីគ្នា។ ការអង្កេតអាចធ្វើឡើងតាមអនឡាញ ឬដោយផ្ទាល់។ |

ប្រភព : Government of the United Kingdom. 2008. *The Compact. Consultation and Policy Appraisal Compact Code of Good Practice.* London; World Bank. 2007. *Consultations with Civil Society. A Sourcebook.* Working Document. Washington, DC.

ការប្រើប្រាស់ទម្រង់វិភាគអ្នកពាក់ព័ន្ធដ៏សាមញ្ញខាងក្រោម ជួយដល់ការទទួលបានលទ្ធផលរកឃើញនានា។ ជំហានដែលបង្ហាញខាងក្រោម ផ្ដល់ការណែនាំអំពីការស្វែងយល់អំពីចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធ។ បើទោះបីជាទម្រង់ នេះសមស្របជាពិសេសទៅនឹងសិក្ខាសាលា ដែលមានការសម្របសម្រួល ឬកិច្ចប្រជុំប្រមូលគំនិតក៏ដោយ ក៏គេអាច ប្រើប្រាស់ទម្រង់នេះជាមួយនឹងវិធីសាស្ត្រដទៃទៀតផងដែរ។[២៩]

## ជំហានសំខាន់ៗសម្រាប់វិភាគអ្នកពាក់ព័ន្ធ

ទម្រង់គំរូសម្រាប់វិភាគអ្នកពាក់ព័ន្ធ

| ក្រុមអ្នកពាក់ព័ន្ធ | ចំណាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធ | ការយល់ឃើញអំពីបញ្ហា | ធនធាន | អណត្តិការងារ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |

**ជំហានទី ១ :** បញ្ជាក់ពីបញ្ហាអភិវឌ្ឍន៍ដំបូង តំបន់ និង/ឬវិស័យគោលដៅ និងអ្នកទទួលផល

**ជំហានទី ២ :** រៀបចំតារាងអ្នកពាក់ព័ន្ធទទេមិនទាន់មានសរសេរអ្វីទាំងអស់

**ជំហានទី ៣ :** សរសេរគ្រប់អ្នកពាក់ព័ន្ធទាំងអស់ដាក់លើប័ណ្ណ ហើយរៀបទៅតាមប្រភេទអ្នកពាក់ព័ន្ធ ឧ. សង្គមស៊ីវិល វិស័យឯកជន ទីភ្នាក់ងារផ្ដល់ជំនួយ និងរដ្ឋាភិបាល។ ដាក់ក្រុមនីមួយៗ ក្នុងជួរផ្សេងៗពីគ្នា (គួឡោនទី ១)។

**ជំហានទី ៤ :** ពិភាក្សាពីចំណាប់អារម្មណ៍របស់ក្រុមនីមួយៗ យោងទៅតាមបញ្ហាអភិវឌ្ឍន៍ខាងលើ-តើពួកគេពាក់ព័ន្ធយ៉ាងដូចម្ដេចខ្លះ និងដោយសារមូលហេតុអ្វី ការរំពឹងទុករបស់ពួកគេ និងសក្ដានុពល ដើម្បីឱ្យពួកគេអាចទទួលបានប្រយោជន៍ ឬទទួលរងគ្រោះ ដោយសារការផ្លាស់ប្ដូរ។ ក្រុមនីមួយៗសរសេរលើប័ណ្ណមួយ ដែលឆ្លុះបញ្ចាំងពីចំណាប់អារម្មណ៍សំខាន់ៗរបស់ពួកគេ (គួឡោនទី ២)។

**ជំហានទី ៥ :** បញ្ជាក់ពីការយល់ឃើញរបស់ក្រុមនីមួយៗចំពោះបញ្ហាអភិវឌ្ឍន៍នេះ (គួឡោនទី ៣)។ ប្រើប្រាស់ប័ណ្ណមួយសន្លឹកសម្រាប់មួយក្រុម ហើយឱ្យក្រុមលើកឡើងពីបញ្ហាដែលពួកគេយល់ឃើញនេះឱ្យបានច្បាស់លាស់។ ស្នើសុំឱ្យមានការលើកឡើងពីប្រយោគអវិជ្ជមាន មិនមែនលើកឡើងពាក់ព័ន្ធនឹងដំណោះស្រាយនោះទេ ឧ. ផ្លូវថ្នល់មិនមាន ការថែទាំបានល្អ (ត្រឹមត្រូវ), ពុំមានប្រព័ន្ធថែទាំផ្លូវថ្នល់ (មិនត្រឹមត្រូវ)។

**ជំហានទី ៦ :** ពិភាក្សាពីសមត្ថភាព និងធនធានដែលក្រុមអាចមានសម្រាប់គាំទ្រឬប្រឆាំងនឹងបញ្ហាអភិវឌ្ឍន៍នេះ ។ ពិចារណាលើធនធានហិរញ្ញវត្ថុផង និងមិនមែនហិរញ្ញវត្ថុផង ។ ខណៈពេលដែលអង្គការផ្លូវការនានាអាចមាននូវធនធាន ហិរញ្ញវត្ថុផង និងមិនមែនហិរញ្ញវត្ថុផង ប្រជាពលរដ្ឋទូទៅ និងក្រុមសង្គមស៊ីវិលក្រៅផ្លូវការ អាចមានធនធានមិនមែន ហិរញ្ញវត្ថុ ។ ធនធានទាំងនេះរួមមានកម្លាំងពលកម្ម ឥទ្ធិពលនយោបាយអ្នកស្ម័គ្រចិត្ត សម្លេងឆ្នោត កូដកម្ម និងការដាក់សម្ពាធជាសាធារណៈ (គូឡោនទី ៤) ។

**ជំហានទី ៧ :** សរសេររៀបរាប់ពីអណត្តិការងារ ឬសមត្ថកិច្ចជាផ្លូវការ ដែលអ្នកពាក់ព័ន្ធមាន សម្រាប់មុខងារណាមួយ ។ ជាទូទៅក្រុមប្រជាជនដូចជា ក្រុមដែលមានចំណូលទាប កសិករ និងស្ត្រីជាដើម ពុំមានអណត្តិការងារនោះទេ (គូឡោនទី ៥) ។

**ជំហានទី ៨ :** សិក្ខាសាលាអាចបន្តពិភាក្សាអំពីការរៀបចំគោលនយោបាយ ឬគម្រោងដែលស្នើឡើង ឱ្យបានកាន់តែលំអិតបន្ថែមទៀត ឬអាចប្រើប្រាស់ការពិគ្រោះយោបល់តាមដានបន្ត។

## ឧទាហរណ៍បង្ហាញពីការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់

ប្រអប់ខាងក្រោមនេះបង្ហាញពីសារៈសំខាន់នៃការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ ចំពោះជោគជ័យរបស់ គម្រោងឥន្ធនៈស្អាតដាកា ។

### ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់អំពីការកាត់បន្ថយការបំពុលបរិស្ថាន នៅទីក្រុងដាកា

- **សាវតារ :** នៅទីក្រុងដាកា "កូនតាក់ស៊ី" គឺជាមធ្យោបាយដឹកជញ្ជូនដ៏ងាយស្រួល និងមានតម្លៃថោកសម្រាប់ការធ្វើដំណើរពីកន្លែង មួយទៅកន្លែងមួយទៀត ប៉ុន្តែគឺជាប្រភពនៃផលប៉ះពាល់មកលើសុខភាពដ៏ធ្ងន់ធ្ងរផងដែរ ។
- **អ្នកពាក់ព័ន្ធសំខាន់ៗ :** អ្នកពាក់ព័ន្ធសំខាន់ៗ រួមមានអ្នកធ្វើដំណើរតាមកូនតាក់ស៊ី ម្ចាស់កូនតាក់ស៊ី ម្ចាស់ហាងសាំង អង្គការក្រៅ រដ្ឋាភិបាល រដ្ឋាភិបាល និងអ្នកផ្តល់ជំនួយអន្តរជាតិ ។
- **គោលដៅ :** ដំបូង ធ្វើការស្វែងយល់ពីបញ្ហា និងបន្ទាប់មក ស្វែងយល់ពីទស្សនៈរបស់អ្នកពាក់ព័ន្ធអំពីតម្រូវការលទ្ធភាពចំណាយ និងតម្រូវការ និងផលប៉ះពាល់របស់គម្រោង ។ ទីពីរស្វែងយកការគាំទ្រពីសាធារណៈ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីប្រើប្រាស់យាន ជំនិះស្អាតជំនួសឱ្យកូនតាក់ស៊ីបច្ចុប្បន្ន ។
- **វិធីសាស្ត្រ :** កំណត់ ជួប និងបន្តពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធសំខាន់ៗ ។ ឧទាហរណ៍ ប្រើប្រាស់ដំណើរទស្សនកិច្ចសិក្សា ដើម្បីជួបជាមួយអ្នកផលិត និងអ្នកប្រើប្រាស់ បន្តសម្របសម្រួលជាមួយប្រព័ន្ធផ្សព្វផ្សាយ និងធ្វើការពិគ្រោះយោបល់ជាមួយម្ចាស់អ្នកបើកបរគ្រួសារ ។ល ។ (គ្លីនិកសម្រាប់អ្នកបើកកូនតាក់ស៊ី ដើម្បីចងក្រងទុកជាឯកសារអំពីផលប៉ះពាល់នៃការបំពុលបរិស្ថាន និងពិភាក្សាអំពីដំណោះស្រាយដែលអាចមាន) ។ ដឹកនាំយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈអំពីប្រយោជន៍នៃការប្រើប្រាស់ឧស្ម័ន ធម្មជាតិ ការកាត់បន្ថយការបំពុលខ្យល់ និងការលើកកម្ពស់សុខភាព ។
- **លទ្ធផល :** ទទួលបានការគាំទ្រលើការដកចេញកូនតាក់ស៊ីទាំងនេះក្នុងពេលមួយយប់ តាមរយៈការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ។

ប្រភព : ADB. 2001. *Loan to Bangladesh for the Dhaka Clean Fuel Project*. Manila.

ខាងក្រោមនេះ គឺជាទម្រង់សម្រាប់វិភាគអ្នកពាក់ព័ន្ធសម្រាប់គម្រោងនេះ ឬសម្រាប់គម្រោងស្រដៀងគ្នានេះ :

**ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ : សមាសភាគបម្លែងរថយន្តតាក់ស៊ី នៃគម្រោងឥន្ទនៈស្អាតសម្រាប់ ទីក្រុង។**

| ក្រុមអ្នកពាក់ព័ន្ធ | ផលប្រយោជន៍របស់ អ្នកពាក់ព័ន្ធ | ការយល់ឃើញអំពី បញ្ហា | ធនធាន | ភារកិច្ច |
|---|---|---|---|---|
| **រដ្ឋាភិបាល** | | | | |
| ក្រសួងហិរញ្ញវត្ថុ | អ្នកទទួលកម្ចី ADB ទទួលខុសត្រូវសងកម្ចី មកវិញ | ការពឹងផ្អែកលើប្រេង នាំចូលដែលមានតម្លៃថ្លៃ,គុណភាពខ្យល់មានកម្រិតទាប ដោយសារតែម៉ាស៊ីន ២ លេខដែលមានផលប៉ះពាល់ដល់សុខភាព | កម្ចី ADB (៨០ លានដុល្លារ) | គ្រប់គ្រង និងត្រួត ពិនិត្យថវិការដ្ឋ |
| ក្រសួងថាមពល និង ធនធានរ៉ែ | ជាម្ចាស់ និងជាអ្នកគ្រប់គ្រង ក្រុមហ៊ុនប្រេងរបស់ជាតិ | ការពឹងផ្អែកលើប្រេង នាំចូលដែលមានតម្លៃថ្លៃ ឧស្ម័នធម្មជាតិក្នុង ស្រុកត្រូវការការផ្សព្វ ផ្សាយបន្ថែម | ថវិកា និងបុគ្គលិករបស់ ក្រសួងថាមពល | គ្រប់គ្រង និងត្រួត ពិនិត្យសកម្មភាពរបស់រដ្ឋាភិបាលនៅក្នុង វិស័យថាមពល |
| ក្រសួងទំនាក់ទំនង | ទទួលខុសត្រូវលើការដឹកជញ្ជូនក្នុងទីក្រុង | ម៉ាស៊ីន ២ លេខ ដែលប្រើក្នុង "រថយន្ត តាក់ស៊ី" រួមចំណែកធ្វើ ឱ្យខ្យល់មានគុណភាព ទាប ប៉ុន្តែជាមធ្យោបាយធ្វើដំណើរដែលថោក និងងាយស្រួល | ថវិកា និងបុគ្គលិក របស់ក្រសួង | គ្រប់គ្រង និងត្រួតពិនិត្យ សកម្មភាពរបស់ រដ្ឋាភិបាល នៅក្នុងវិស័យដឹកជញ្ជូន |
| ក្រសួងឧស្ម័ន | ទីភ្នាក់ងារប្រតិបត្តិអ្នកទទួលកម្ចីរបស់ ADB ដែលត្រូវបានឱ្យខ្ចីបន្ត | ហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ឧស្ម័នក្នុងស្រុកនៅមិនទាន់មានការអភិវឌ្ឍរួមទាំងការប្រើប្រាស់ម៉ាស៊ីន ៤ លេខ | ៨០ លានដុល្លារ និង បុគ្គលិករបស់ក្រុមហ៊ុន | ក្រុមហ៊ុនដែលប្រកប អាជីវកម្មឧស្ម័នធម្មជាតិហើយជាកម្មសិទ្ធិរបស់ក្រុមហ៊ុនប្រេងរដ្ឋ |
| **សង្គមស៊ីវិល** | | | | |
| សមាគមអ្នកបើកតាក់ស៊ី | គម្រោងមានផែនការហាម ឃាត់មិនឱ្យមានតាក់ស៊ីប្រើប្រាស់ម៉ាស៊ីន ២ លេខ | ហាមឃាត់រថយន្ត ២ លេខ នឹងធ្វើឱ្យប៉ះពាល់ ដល់ជីវភាពរស់នៅ របស់អ្នកបើកតាក់ស៊ី ប្រសិនបើមានការ អនុវត្តផែនការនេះ នោះអ្នកបើកតាក់ស៊ី ទាំងនេះត្រូវការការ គាំទ្រ ដើម្បីបម្លែងរថយន្តរបស់ខ្លួនឱ្យ ប្រើម៉ាស៊ីន ៤ លេខវិញ | ថ្លៃសមាជិកភាព អ្នកបើកបរ | តំណាងឱ្យប្រយោជន៍ របស់អ្នកបើកបរ |
| អ្នកប្រើប្រាស់តាក់ស៊ី | គម្រោងមានផែនការហាម ឃាត់សេវាដឹកជញ្ជូនដ៏មាន សារៈសំខាន់ | ការហាមឃាត់ម៉ាស៊ីន២លេខនឹងរំខានដល់សេវាដឹកជញ្ជូននៅក្នុងទីក្រុង | សម្ពាធជាសាធារណៈ | តំណាងឱ្យតម្រូវការ ផ្ទាល់ខ្លួន |
| អង្គការហ្គ្រីនភីសអន្តរជាតិ (អង្គការក្រៅរដ្ឋាភិបាល [NGO]) | ចែករំលែកគោលដៅរបស់ គម្រោងដើម្បីកាត់បន្ថយការបំពុលបរិស្ថាន និងធ្វើឱ្យបរិស្ថានមានភាព ប្រសើរឡើង | ម៉ាស៊ីន ២ លេខ បង្កការខូចខាតធ្ងន់ធ្ងរ ចំពោះបរិស្ថាន ហើយគួរហាមឃាត់ | ហិរញ្ញប្បទានពីជំនួយ/ ជំនួយឥតសំណង សម្ពាធជាសាធារណៈ ឥទ្ធិពលនយោបាយ | រៀបចំយុទ្ធនាការ និង សកម្មភាពដើម្បី ការពារបរិស្ថាន |

| ក្រុមអ្នកពាក់ព័ន្ធ | ផលប្រយោជន៍របស់ អ្នកពាក់ព័ន្ធ | ការយល់ឃើញអំពី បញ្ហា | ធនធាន | ភារកិច្ច |
|---|---|---|---|---|
| អង្គការជីវិតសហគមន៍ (អង្គការក្រៅ រដ្ឋាភិបាល) | ចែករំលែកគោលដៅរបស់ គម្រោង ដើម្បីកាត់បន្ថយការ បំពុលបរិស្ថានចៀសវាងផល ប៉ះពាល់ជា អវិជ្ជមានដទៃទៀត លើគុណភាពរបស់ជីវិត | ម៉ាស៊ីន ២ លេខ បំពុល បរិស្ថានធ្ងន់ធ្ងរ និងបង្ក ឱ្យមានបញ្ហាសុខភាពសម្រាប់ ប្រជាពលរដ្ឋ រស់នៅក្នុងទីក្រុង ប៉ុន្តែ មានតម្លៃថោកនិងមានភាពងាយស្រួល | ហិរញ្ញប្បទានពីជំនួយ/ ជំនួយឥតសំណង បុគ្គលិកអ្នកស្ម័គ្រចិត្ត | អនុវត្តគម្រោងតស៊ូមតិ និង អភិវឌ្ឍន៍ សហគមន៍ដើម្បី គាំទ្រដល់ប្រជាពលរដ្ឋ |
| សហជីពវេជ្ជបណ្ឌិត | ចែករំលែកគោលដៅរបស់ គម្រោងដើម្បីលើកកម្ពស់ សុខភាពធានាយ៉ាងណា ឱ្យប្រជាពលរដ្ឋយល់ពី ម៉ាស៊ីន ៤ លេខ | ម៉ាស៊ីន ២ លេខ ដែលដាក់ក្នុងរថយន្ត តាក់ស៊ី ធ្វើឱ្យមានបញ្ហាផ្លូវ ដង្ហើមនៅ ក្នុងទីក្រុង | ថ្លៃសមាជិកភាពមុខងារ វិជ្ជាជីវៈ/ ឥទ្ធិពល | ការពារសុខភាព និងសុខមាល ភាពរបស់អ្នកជំងឺ |
| **វិស័យឯកជន** | | | | |
| អ្នកបើក "រថយន្តតាក់ស៊ី" | ការហាមឃាត់តាក់ស៊ីម៉ាស៊ីន ២ លេខ ធ្វើ ឱ្យប៉ះពាល់ដល់ ការប្រកបអាជីវកម្ម | ការហាមឃាត់តាក់ស៊ី ម៉ាស៊ីន ២ លេខ គឺជារឿងមិនចាំបាច់ តាក់ស៊ីកំពុង ពេញនិយម | ប្រាក់ចំណេញរបស់ អាជីវកម្មបុគ្គលិក | ចាត់ចែងអាជីវកម្មផលិត រថយន្តតាក់ស៊ី ដែលផ្តល់នូវ ប្រាក់ចំណេញខ្ពស់ |
| ម្ចាស់ហាងចាក់សាំង | ការហាមឃាត់តាក់ស៊ីម៉ាស៊ីន ២ លេខ ធ្វើ ឱ្យប៉ះពាល់ដល់ ការប្រកបអាជីវកម្ម | ការហាមឃាត់តាក់ស៊ី ម៉ាស៊ីន ២ លេខ គឺជារឿងមិនចាំបាច់តាក់ស៊ីកំពុង ពេញនិយម | ប្រាក់ចំណេញរបស់ អាជីវកម្មបុគ្គលិក | ចាត់ចែងអាជីវកម្ម លក់ប្រេង និងទំនិញ និងសេវាផ្សេងទៀត ដែលផ្តល់នូវប្រាក់ ចំណេញខ្ពស់ |
| **អ្នកផ្តល់ជំនួយអន្តរជាតិ** | | | | |
| ធនាគារពិភពលោក | គម្រោងគាំទ្រដល់គោលដៅ នៃការងារ របស់ពួកគេ | ការហាមឃាត់តាក់ស៊ី ម៉ាស៊ីន ២ លេខ នឹង ជួយដល់ការងារ សុខភាពបរិស្ថាន របស់ពួកគេ | ការរួមវិភាគទានរបស់ រដ្ឋាភិបាលជាសមាជិក | គាំទ្រដល់ការអភិវឌ្ឍ នៅតាម ប្រទេសកំពុង អភិវឌ្ឍជា សមាជិក |

## ឧបករណ៍ទី ២ : បង្កើនការចូលរួមជាអតិបរមា នៅក្នុងក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដាន

ការផ្តល់លទ្ធភាពឱ្យអ្នកពាក់ព័ន្ធអាចចូលរួម នៅក្នុងរៀបចំគម្រោងជំនួយអភិវឌ្ឍន៍ មានសារៈសំខាន់យ៉ាងខ្លាំងដើម្បីឱ្យជំនួយកាន់តែមានប្រសិទ្ធភាព និងជួយសម្រេចលទ្ធផល។

តាមពិតទៅការសម្រេចលទ្ធផល គឺអាស្រ័យយ៉ាងធំធេងលើការចូលរួមរបស់អ្នកពាក់ព័ន្ធការសហការ និងការឯកភាពគ្នាដែលពង្រឹងការរៀបចំបង្កើតភាពជាម្ចាស់បង្កើនអភិបាលកិច្ច និងលើកកម្ពស់និរន្តរភាព។ ដូច្នេះគ្រប់គម្រោងទាំងអស់គួរប្រើប្រាស់គោលវិធីដែលមានការចូលរួម សម្រាប់បង្កើតក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដាន។

ប្រភព : ADB. 2007. *Guidelines for Preparing a Design and Monitoring Framework*. Manila.

### សេចក្តីផ្តើម

គោលការណ៍ណែនាំរបស់ ADB ស្តីពីការរៀបចំ DMF (២០០៧) រៀបរាប់ពីដំណើរការ ដែលមានការចូលរួមដោយអនុវត្តទៅតាមជំហានធំៗទាំង ៥ ខាងក្រោម។ ឧបករណ៍រៀបចំ និងគ្រប់គ្រង DMF បង្កើតឱ្យមានការឯកភាព គ្នាជារួមជាមួយនឹងអ្នកពាក់ព័ន្ធ និងបង្កើតឱ្យមានភាពជាម្ចាស់លើគម្រោង។ អ្នកពាក់ព័ន្ធចូលរួមនៅក្នុងការវិភាគផ្សេងៗ (ឧ. ការវិភាគអ្នកពាក់ព័ន្ធ ការវិភាគបញ្ហា) តាមរយៈសិក្ខាសាលា ការពិភាក្សាក្រុមគោលដៅ កិច្ចប្រជុំប្រមូល គំនិត ។ល។ ការចូលរួម គឺមាននៅគ្រប់ដំណាក់កាលទាំងអស់ ចាប់ពីដំណាក់កាលវិភាគ និងបង្កើតទស្សនាទានរហូតដល់ការសិក្សាពីលទ្ធភាពអនុវត្ត រហូតដល់ការរៀបចំ និងការអនុវត្តចុងក្រោយ។

**ដំណាក់កាលទី ១ : ការវិភាគស្ថានភាព**

១. *ការវិភាគអ្នកពាក់ព័ន្ធ*

— កំណត់ និងបញ្ជាក់ពីតួនាទីរបស់អ្នកពាក់ព័ន្ធសំខាន់ៗ ឧ. សម្រាប់បញ្ហានៃការអភិវឌ្ឍ ឬវិស័យអ្វីមួយ

២. *ការវិភាគបញ្ហា*

— កំណត់ពីបញ្ហាចាប់ផ្តើម : បញ្ហាដំបូង ដែលត្រូវដោះស្រាយ

— កំណត់ពីបញ្ហាដំបូង និងមូលហេតុដែលបង្កឱ្យមានបញ្ហានេះ

— បញ្ជាក់ពីផលប៉ះពាល់របស់បញ្ហា

**ដំណាក់កាលទី ២ : ការកំណត់គម្រោង**

*៣. ការវិភាគលើគោលដៅ*

— បម្លែងបញ្ហានីមួយៗឱ្យក្លាយជាគោលដៅ — ដំណោះស្រាយចំពោះបញ្ហានាពេលអនាគត — រួមជាមួយអ្នកពាក់ព័ន្ធ

*៤. ការវិភាគសង្វាក់លទ្ធផល*

— អ្នកពាក់ព័ន្ធកំណត់ពីសង្វាក់លទ្ធផល

— អ្នកពាក់ព័ន្ធវាយតម្លៃលើលទ្ធផលសម្រេចលទ្ធផលរបស់ពួកគេ និងសម្រេចចិត្តលើការចូលរួម ក្នុងការរៀបចំគម្រោង

**ដំណាក់កាលទី ៣ : ការបញ្ចប់ DMF**

*៥. តារាង DMF*

— អ្នកពាក់ព័ន្ធប្រកាសពីសង្វាក់លទ្ធផល ដែលពួកគេអាចសម្រេចទៅបាន

— បូកសរុបសង្វាក់លទ្ធផល និងឯកភាពលើលទ្ធផលរបស់គម្រោង (រួមចំណែកសម្រេចផលរយៈពេលវែង) រួមជាមួយអ្នកពាក់ព័ន្ធ

— បញ្ចប់តារាង DMF ដូចដែលបញ្ជាក់នៅក្នុងគោលការណ៍ណែនាំ

— កែសម្រួល DMF ជាទៀងទាត់ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនៃវិសាលភាពគម្រោង ឬការលេចឡើងនូវបញ្ហាថ្មីៗ ឬអ្នកពាក់ព័ន្ធថ្មីៗ

គោលការណ៍ណែនាំនេះផ្តល់ជាអនុសាសន៍ឱ្យមានការប្រើប្រាស់ឧបករណ៍វិភាគផ្សេងៗ (ឧ. ការវិភាគអ្នកពាក់ ព័ន្ធ ការវិភាគបញ្ហា) រួមជាមួយនឹងអ្នកពាក់ព័ន្ធដែលចូលរួមតាមរយៈសិក្ខាសាលា ការពិភាក្សាក្រុមគោលដៅកិច្ចប្រជុំប្រមូលគំនិត ។ល។ ក្រោយពេលរៀបចំដំណើរការដែលមានការចូលរួម បន្តធ្វើបែបនេះទៀតនៅក្នុងការអនុវត្ត នៅពេលដែលអាចលេចឡើងនូវអ្នកពាក់ព័ន្ធ និងបញ្ហាផ្សេងៗ ។

## ការចូលរួមនៅក្នុង DMF

ការចូលរួមនៅក្នុង DMF មានទិដ្ឋភាពចំនួន ២ ហើយការគ្រប់គ្រងការងារទីមួយប្រកបប្រសិទ្ធភាព ធ្វើឱ្យការងារទីពីរកាន់តែមានប្រសិទ្ធភាព ។

i. ជម្រុញឱ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធ នៅក្នុងដំណើរការរៀបចំ និង

ii. ដាក់បញ្ចូលសមាសភាពដែលមានការចូលរួម (សកម្មភាព លទ្ធផល ។ល។) ទៅក្នុង DMF ជាក់ស្តែង

ជំហានខាងក្រោមនេះ បំពេញបន្ថែមលើគោលការណ៍ណែនាំនេះ និងគាំទ្រដល់ការបំពេញអនុសាសន៍ស្ដីពីការ ចូលរួមនៅក្នុងការរៀបចំ DMF ។

## ជំហាន ដើម្បីបង្កើនការចូលរួមឱ្យដល់កម្រិតអតិបរមា

- **ចៀសវាងប្រើប្រាស់គោលវិធីពីលើចុះក្រោម :** ធានាយ៉ាងណាមិនឱ្យបញ្ហា ឬដំណោះស្រាយ ដែលគេបានដឹងជាមុនគ្របដណ្ដប់លើការ វិភាគ និងធានាយ៉ាងណាឱ្យក្រុមការងារគម្រោងទទួលយកគំនិតថ្មីៗ ។ ការវិភាគគួរដាក់បញ្ចូលទស្សនវិស័យរបស់សមាជិកសហគមន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀត ដែលមានបទពិសោធន៍ដោយផ្ទាល់នៅមូលដ្ឋាន ។ ឆ្លើយតបចំពោះការយល់ឃើញ ផ្សេងៗពីគ្នា មុនពេលបង្ហើយបញ្ចប់ការរៀបចំ ។ ការឯកភាពជារួមលើការរៀបចំគម្រោង គួរដាក់បញ្ចូលនូវកិច្ចពិគ្រោះយោបល់ក្នុង ទម្រង់ផ្សេងៗពីគ្នាជាមួយនឹងអ្នកពាក់ព័ន្ធសិក្ខាសាលារៀបចំផែនការដោយមានការចូលរួម និងកិច្ចប្រជុំប្រមូលគំនិត ។ កិច្ចប្រជុំ រៀបចំផែនការតែម្ដង មិនសូវមានប្រសិទ្ធភាពនោះឡើយ ។
- **ជម្រុញឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ នៅក្នុងការវិភាគអ្នកពាក់ព័ន្ធការវិភាគបញ្ហា និងការវិភាគគោលដៅ :** ប្រើប្រាស់សិក្ខាសាលា ការពិភាក្សាក្រុមគោលដៅ កិច្ចប្រជុំប្រមូលគំនិត និងវិធីសាស្ត្រដទៃទៀត ។ ការពិគ្រោះយោបល់ជាមួយនឹងអ្នកសម្របសម្រួលដែលមានជំនាញ អាចគ្របដណ្ដប់លើជំហានទាំងអស់នេះ ហើយធានាថាវិធីសាស្ត្រទាំងនេះមានភាពសមស្របជាមួយនឹង ភាសា កម្រិតអក្ខរកម្ម និងបទពិសោធន៍របស់ក្រុមផ្សេងៗគ្នា ។
- **ពិនិត្យឡើងវិញ និងកែសម្រួលលទ្ធផលនៃការវិភាគអ្នកពាក់ព័ន្ធ ការវិភាគបញ្ហា និងការវិភាគគោលដៅ :** បញ្ហាថ្មីៗ ដែលមិនធ្លាប់ មានកន្លងមក ហើយដែលត្រូវបានកំណត់ក្នុងកំឡុងពេលធ្វើការវិភាគ តម្រូវឱ្យមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ឬអ្នក ជំនាញបច្ចេកទេសដទៃទៀត ។ ប្រហែលជាចាំបាច់ត្រូវមានការផ្ទៀងផ្ទាត់លើបញ្ហានានា ឬលទ្ធភាពសម្រេចគោលដៅផ្សេងៗ ប្រហែលជាចាំបាច់ត្រូវមានការបញ្ជាក់ឱ្យបានច្បាស់លាស់ជាមួយអ្នកពាក់ព័ន្ធនានា ។ ជារឿយៗ ដើមឈើបញ្ហា និងគោលដៅតែងឆ្លងកាត់ការកែសម្រួល ។ ចុងក្រោយដំណើរការ ដែលមានការចូលរួម និងមានភាពបត់បែន ផ្ដល់លទ្ធភាពឱ្យមានការយល់ដឹងជារួម យ៉ាងច្បាស់លាស់អំពីសកម្មភាពដែលចាំបាច់អំពីលំដាប់លំដោយនៃសកម្មភាពទាំងនោះ និងអំពីលទ្ធផលដែលចង់បាន ។ ដំណើរការ នេះក៏ពង្រឹងផងដែរនូវភាពជាម្ចាស់ និងចក្ខុវិស័យរួម ។
- **ពិភាក្សាពីជម្រើសនីមួយៗ (សង្វាក់លទ្ធផល) ជាមួយនឹងអ្នកពាក់ព័ន្ធសមស្រប :** ក្រុមអ្នកពាក់ព័ន្ធនីមួយៗ ដូចជាទីភ្នាក់ងារប្រតិបត្តិ និងក្រុមការងារគម្រោង ជាដើម ចាំបាច់ត្រូវស្វែងយល់ពីផលប៉ះពាល់ ដែលសង្វាក់លទ្ធផលអាចមានមកលើពួកគេទាំងផលប៉ះពាល់វិជ្ជមាន និងផលប៉ះពាល់អវិជ្ជមាន ។ ការពិភាក្សានេះអាចធ្វើឱ្យសមាជិកក្រុមការងារចៀសវាងជ្រើសរើសដំណោះស្រាយ ដែលពួកគេចង់បាន ឬដែលពួកគេធ្លាប់ដឹង ប៉ុន្តែដែលអាចមិនមានភាពពាក់ព័ន្ធជាមួយនឹងកាលៈទេសៈនៅមូលដ្ឋាន ឬមិនមាន សុពលភាព ធៀបជាមួយនឹងលក្ខណៈវិនិច្ឆ័យដែលចង់បានរបស់អ្នកពាក់ព័ន្ធ ។ កិច្ចព្រមព្រៀងអាចតម្រូវឱ្យមានការត្រឡប់ទៅមើលដើមឈើបញ្ហា ឬគោលដៅ និងការពិចារណាឡើងវិញ ។

- **ឯកភាពរួមគ្នាលើក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដាន (DMF) និងជំហានបន្ទាប់ :** ការឯកភាពគ្នាលើសូចនាករ និងចំណុចដៅក្នុងចំណោមអ្នករៀបចំ អ្នកអនុវត្ត និងអ្នកទទួលបានប្រយោជន៍បង្កើនតម្លាភាព និងភាពជាម្ចាស់។ ការជម្រុញឱ្យមានការចូលរួមពីអ្នក ពាក់ព័ន្ធ នៅក្នុងការបង្កើត DMF ក៏គួរគាំទ្រផងដែរដល់ការដាក់បញ្ចូលនូវសមាសភាពដែលមានការចូលរួម និងបង្កើនឆន្ទៈរបស់ពួកគេ ក្នុងការចូលរួម។ នេះអាចរួមមានការកំណត់គោលដៅផ្នែកការចូលរួមរបស់ក្រុមណាមួយ នៅក្នុងសកម្មភាពគម្រោង, ការជម្រុញ ឱ្យមានការចូលរួមរបស់អ្នកកៀងគរសហគមន៍, ការដាក់បញ្ចូលតំណាងរបស់អតិថិជន/អ្នកទទួលផល នៅក្នុងបេសកកម្ម និង សិក្ខាសាលាពិនិត្យគម្រោងឡើងវិញ, ការប្រើប្រាស់ប័ណ្ណពិន្ទុរបស់ប្រជាពលរដ្ឋ ដើម្បីវាយតម្លៃការអនុវត្តគម្រោង និងការលើក ទឹកចិត្តឱ្យអង្គការសង្គមស៊ីវិលចូលរួមពិនិត្យតាមដានគម្រោងដោយឯករាជ្យ។

## ឧទាហរណ៍ដែលបង្ហាញពី DMF ដែលមានការចូលរួម

ឧទាហរណ៍ខាងក្រោមនេះ បង្ហាញពីទម្រង់ដែលអាចមាននៃ DMF សម្រាប់គម្រោងផ្លូវថ្នាក់ដែលមានការចូលរួម :

**ក្របខ័ណ្ឌរៀបចំ និងការពិនិត្យតាមដាន-គម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ ដែលផ្ដោតលើការអភិវឌ្ឍសង្គម**

| សេចក្តីសង្ខេបអំពីការរៀបចំ | ចំណុចដៅ/សូចនាករនៃការបំពេញការងារ | ប្រភពទិន្នន័យ/យន្តការសម្រាប់រាយការណ៍ | ការសន្មត/ហានិភ័យ |
|---|---|---|---|
| **ផលរយៈពេលវែង**<br>លើកកម្ពស់ការអប់រំ និងការថែទាំសុខភាព នៅតាមសហគមន៍មូលដ្ឋានមួយចំនួន នៅក្នុងគម្រោងអភិវឌ្ឍន៍បណ្ដាញផ្លូវថ្នល់ | • អត្រាសិក្សា (សម្រាប់ក្មេងប្រុស និងក្មេងស្រី)នៅក្នុងគម្រោង កើនឡើង ៥% នៅមុនឆ្នាំ ២០២០ ពី 'x' ដែលជាទិន្នន័យគោលឆ្នាំ ២០០៧<br>• អត្រាអ្នកទទួលបានការថែទាំ ផ្ទៃពោះ និងជំនួយក្នុងពេលសម្រាលកូន នៅក្នុងតំបន់គម្រោង បានកើនឡើង ១០% នៅឆ្នាំ២០២០ បើធៀបជាមួយនឹងអត្រា 'x' ដែលជាទិន្នន័យគោលឆ្នាំ ២០០៧ | • របាយការណ៍របស់ក្រសួងអប់រំ<br>• ការអង្កេតអំពីជីវភាពរស់នៅ និងការអង្កេតសុខភាពប្រជាសាស្ត្រ<br>• ការពិនិត្យឡើងវិញ និងការ វាយតម្លៃលើសូចនាករគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ | **ការសន្មត**<br>មានការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងសហគមន៍ចំពោះការធ្វើកំណែទម្រង់គោលនយោបាយ<br><br>**ហានិភ័យ**<br>អស្ថិរភាពនយោបាយ និង ស្ថានភាពសន្តិសុខ |
| **លទ្ធផលរយៈពេលមធ្យម**<br>បង្កើនលទ្ធភាពទទួលបានសេវាសង្គមសម្រាប់សហគមន៍នៅក្នុងតំបន់'x' | • ពេលវេលាធ្វើដំណើរទៅកាន់ សាលារៀន និងគ្លីនិកសុខភាព នៅក្នុងតំបន់គម្រោងមានការថយចុះ ចំនួន ១០% នៅឆ្នាំ ២០១៥ ពី 'x' ដែលជាទិន្នន័យគោលឆ្នាំ ២០០៧<br>• សេវាថែទាំសុខភាព ដែលបាន ទទួលកើនឡើងពី 'x' ដែលជា ទិន្នន័យគោលនៅក្នុងឆ្នាំ ២០០៧ ដល់ 'y' នៅមុនឆ្នាំ ២០១៥ | • បាយការណ៍របស់ក្រសួងអប់រំ<br>• របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងសុខាភិបាល | **ការសន្មត**<br>មានអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលធ្វើការងារក្នុងគម្រោងនេះ<br><br>**ហានិភ័យ**<br>ភាពយឺតយ៉ាវនៅក្នុងដំណើរការវិមជ្ឈការ |

| សេចក្តីសង្ខេបអំពីការរៀបចំ | ចំណុចដៅ/សូចនាករនៃការបំពេញការងារ | ប្រភពទិន្នន័យ/យន្តការសម្រាប់រាយការណ៍ | ការសន្មត/ហានិភ័យ |
|---|---|---|---|
| **ធាតុចេញ** *<br>ផ្លូវថ្នល់និងហេដ្ឋា-រចនាសម្ព័ន្ធខ្នាតតូច ត្រូវបានស្តារឡើងវិញនិងថែទាំដោយភ្នាក់ងារសហគមន | • ផ្លូវលំប្រហែល ៩០ គីឡូម៉ែត្រ<br>• ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល និង អប់រំចំនួន ២០ កន្លែង ត្រូវបាន ស្តារឡើងវិញ នៅមុនឆ្នាំ ២០១៥<br>• ប្រជាពលរដ្ឋក្រីក្រ និងងាយ រងគ្រោះដែលរស់នៅតំបន់ជនបទ ចំនួន ៨០០ នាក់ (យ៉ាងហោចណាស់ ៣០% គឺជាស្ត្រី) ចូលរួមនៅក្នុងការថែទាំហេដ្ឋារចនាសម្ព័ន្ធ ខ្នាតតូច នៅមុនឆ្នាំ ២០១៥ | • របាយការណ៍ប្រចាំឆ្នាំស្តីពី បណ្តាញផ្លូវថ្នល់របស់អាជ្ញាធរ ផ្លូវថ្នល់<br>• District Health and Education Authority quarterly report<br>• District/local authority road maintenance reports | **ការសន្មត**<br>មានការបែងចែកមូលនិធិស្រុក សម្រាប់ការស្តារ និង ថែទាំផ្លូវជនបទ<br><br>**ហានិភ័យ**<br>ខ្វះការសម្របសម្រួលពីក្រសួងជំនាញ |
| **សកម្មភាព រួមជាមួយនឹងចំណុចដៅ**<br>**ធាតុចេញទី ១**<br>• ជ្រើសរើសទីតាំងផ្លូវជនបទ សម្រាប់ស្តារឡើងវិញ និងថែទាំ (ត្រីមាសទី ៣ ឆ្នាំ ២០១១)<br>• សហគមន៍ដែលចូលរួម រៀបចំធ្វើការវាយតម្លៃរហ័សលើលក្ខខណ្ឌផ្លូវថ្នល់នៅក្នុងសហគមន៍ (ត្រីមាសទី ៤ ឆ្នាំ ២០១១)<br>• សហគមន៍រៀបចំកិច្ចសន្យាក្នុងសហគមន៍ សម្រាប់ការស្តារ និងការថែទាំផ្លូវថ្នាក់ និង ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន (ត្រីមាសទី ១ ឆ្នាំ ២០១២)<br>• ជ្រើសរើសភ្នាក់ងារសហគមន៍ (យ៉ាងហោចណាស់មានស្ត្រី ៣០%) ដែលស្ថិតក្រោមការគ្រប់គ្រង របស់ប្រធាន suco រដ្ឋបាលថ្នាក់ស្រុក និងអ្នកឯកទេសផ្នែកអភិវឌ្ឍន៍សហគមន៍។ លក្ខណៈវិនិច្ឆ័យ សម្រាប់ធ្វើការជ្រើសរើស មានដាក់បញ្ចូលទិដ្ឋភាពយេនឌ័រ និងភាពងាយរងគ្រោះ (ត្រីមាសទី ១ ឆ្នាំ ២០១២)<br>• សហគមន៍អនុវត្តការងារសាធារណការ (ត្រីមាសទី ៤ ឆ្នាំ ២០១៣)<br>• រដ្ឋបាលស្រុកឯកភាពលើការអនុវត្ត និងការពិនិត្យតាមដានលើការងារហេដ្ឋារចនាសម្ព័ន្ធជនបទ ក្នុងសហគមន៍ (ត្រីមាសទី ៤ ឆ្នាំ ២០១៣)<br>• មេរៀន ដែលទទួលបានពីការសាកល្បងការគ្រប់គ្រងការងារហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនៅ សហគមន៍ ដោយស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិត្រូវបានបង្ហាញ និងចែករំលែកតាមរយៈសិក្ខាសាលា និងការបោះពុម្ពផ្សាយនានា (ត្រីមាសទី ៤ ឆ្នាំ ២០១៤) | | | **ធនធាន**<br>មូលនិធិជប៉ុនសម្រាប់ការកាត់បន្ថយភាពក្រីក្រ : ៣,០ លានដុល្លារ<br>រដ្ឋាភិបាល : ៤៥៦០០០ ដុល្លារ<br>សហគមន៍ : ១៤៤០០ ដុល្លារ |

* សម្គាល់ : មានតែធាតុចេញតែមួយប៉ុណ្ណោះដែលត្រូវបានលើកមកផ្តល់ជាឧទាហរណ៍។ DMF ពេញត្រូវមានធាតុចេញច្រើនជាងនេះ។ លទ្ធភាពដែលអាចមានរួមមានធាតុចេញទី ២ : សហគមន៍ដែលត្រូវបានជ្រើសរើសមួយចំនួនបង្កើនការយល់ដឹងអំពីសុវត្ថិភាពចរាចរណ៍ ការថែទាំសុខភាពបឋម និងការអប់រំ, ធាតុចេញទី ៣ : គម្រោងត្រូវបានគ្រប់គ្រាន់បានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។

# ឧបករណ៍ទី ៣ : ការវាយតម្លៃដោយមានការចូលរួម

ការវាយតម្លៃដោយមានការចូលរួម ផ្តល់លទ្ធភាពឱ្យអ្នកពាក់ព័ន្ធត្រួតពិនិត្យលើបញ្ហារបស់ពួកគេ។ ការវាយ តម្លៃនេះប្រើប្រាស់ចំណេះដឹងនៅមូលដ្ឋាន ពង្រឹងឥទ្ធិពលរបស់អ្នកពាក់ព័ន្ធលើការធ្វើសេចក្តីសម្រេចចិត្ត និងលើកទឹក ចិត្តឱ្យមានភាពជាម្ចាស់ពីសំណាក់ប្រជាពលរដ្ឋ ដែលជីវិតរងផលប៉ះពាល់ដោយសារគម្រោង។ ការវាយតម្លៃដោយមាន ការចូលរួម ដាក់បញ្ចូលនូវគោលវិធីជាច្រើន ដែលប្រែប្រួលទៅតាមកម្រិត និងវិសាលភាពនៃការចូលរួម។

## សេចក្តីផ្តើម

វិធីសាស្ត្រ និងគោលវិធីវាយតម្លៃដោយមានការចូលរួម ត្រូវបានបង្កើតឡើង ដើម្បីស្វែងយល់ពីបរិបទសង្គម និងវប្បធម៌នៃការអភិវឌ្ឍ និងដើម្បីរៀបចំអន្តរាគមន៍សម្រាប់ស្ថានភាពនៅមូលដ្ឋាន។ ការចូលរួម កាន់តែទទួលបានការទទួលស្គាល់ថាជាផ្នែកមួយដ៏សំខាន់នៃការវាយតម្លៃ ហើយរួមមានការធ្វើការ យ៉ាងជិតស្និទជាមួយអ្នកពាក់ព័ន្ធ ដើម្បីធានាយ៉ាងណាឱ្យកម្មវិធី និងគម្រោងនានាអាចឆ្លើយតបចំពោះតម្រូវការរបស់ ពួកគេបាន។[៣០] ភាពជាម្ចាស់ ដែលកើតឡើង នៅពេលដែលគេធ្វើការសម្រេចចិត្តរួមគ្នាពីរបៀបដោះស្រាយបញ្ហារបស់ ពួកគេ នឹងបង្កើនប្រសិទ្ធភាព និងនិរន្តរភាពរបស់ប្រតិបត្តិការ។

### គោលការណ៍ស្នូលនៃការវាយតម្លៃដោយមានការចូលរួម

- មានការចូលរួមពីអ្នកពាក់ព័ន្ធ ក្នុងនាមជាអ្នកចូលរួមដែលសកម្ម ពោលគឺមិនមែនត្រឹមតែជាប្រភពព័ត៌មាននោះទេ
- លើកកម្ពស់ការសិក្សារៀនសូត្ររវាង ADB/អ្នកទទួលជំនួយ/កម្ចី/អតិថិជន និងអ្នកពាក់ព័ន្ធ នៅកម្រិតផ្សេងៗគ្នា
- កសាងសមត្ថភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ក្នុងការធ្វើការវិភាគ ឆ្លុះបញ្ចាំង និងធ្វើសកម្មភាព
- ជម្រុញការប្តេជ្ញាចិត្តឱ្យក្លាយជាសកម្មភាពជាក់ស្តែង

## តើត្រូវប្រើប្រាស់ការវាយតម្លៃដោយមានការចូលរួម នៅក្នុងវដ្តគម្រោងរបស់ ADB នៅពេលណា

ការប្រមូលទិន្នន័យ ដោយប្រើប្រាស់វិធីសាស្ត្រវាយតម្លៃដោយមានការចូលរួម អាចរួមចំណែកចំពោះការ រៀបចំគម្រោង និងគាំទ្រដល់ការវិភាគភាពក្រីក្រ និងសង្គម។ មានឱកាសមួយចំនួនសម្រាប់ធ្វើការវាយតម្លៃដោយ មានការចូលរួមនៅដំណាក់កាលរៀបចំកម្មវិធីប្រចាំប្រទេស (ការបង្កើត CPS) និងដំណាក់កាលរៀបចំគម្រោង នៅក្នុងវដ្តរបស់គម្រោង។ កម្រិតនៃការចូលរួម គឺអាស្រ័យទៅតាមប្រភេទ និងចំណាត់ថ្នាក់គម្រោង។[៣១]

- **ការរៀបចំកម្មវិធីប្រចាំប្រទេស :** ការវិភាគភាពក្រីក្រប្រចាំប្រទេស ការវាយតម្លៃយេនឌ័រប្រចាំប្រទេស ការវាយ តម្លៃហានិភ័យអភិបាលកិច្ច និងផែនទីបង្ហាញផ្លូវតាមវិស័យ គួរមានដាក់បញ្ចូលគោលវិធីវាយតម្លៃ ដែលមានការចូលរួម (ឧ. ការវាយតម្លៃភាពក្រីក្រ ដែលមានការចូលរួម) ។
- **ការរៀបចំគម្រោង :** នៅក្នុងការរៀបចំ IPSA គេអាចប្រើប្រាស់ទិន្នន័យប្រយោល និងធនធានដ៏មានប្រយោជន៍ ដែលទទួលបានពីអង្គការក្រៅរដ្ឋាភិបាល អ្នកស្រាវជ្រាវ និងអ្នកពាក់ព័ន្ធដទៃទៀត ។ គេក៏អាចប្រើប្រាស់វិធីសាស្ត្រ ដែលមានការចូលរួមក្នុងកម្រិតតិចតួចផងដែរ ដើម្បីប្រមូលទិន្នន័យផ្ទាល់ ដើម្បីឱ្យគម្រោងអាចផ្តោតគោលដៅលើគ្រួសារ ឬ បុគ្គលនានា ដូចជា ការពិភាក្សាក្រុមគោលដៅជាមួយនឹងក្រុមប្រជាជនអ្នកដឹកនាំសហគមន៍ អង្គការក្រៅរដ្ឋាភិបាល និងអង្គការសហគមន៍ ។[៣២] នៅពេលរៀបចំ SPRSS ការវាយតម្លៃយេនឌ័រការវាយតម្លៃសង្គម ការវាយតម្លៃភាពក្រីក្រ និងការវាយតម្លៃដទៃទៀត (អាស្រ័យទៅតាមចំណាត់ថ្នាក់របស់គម្រោង) មានឱកាសបន្ថែមទៀត សម្រាប់ធ្វើការវាយតម្លៃដោយមានការចូលរួម ។[៣៣] ឧទាហរណ៍ បង្កើតព័ត៌មានសង្ខេបអំពីសង្គមសេដ្ឋកិច្ច ឬអ្នកទទួលផល និង/ឬ អតិថិជន និងស្នើសុំគំនិតយោបល់ តាមរយៈការវាយតម្លៃលើអ្នកទទួលផល ។

## ជំហ្វន្ទានសម្រាប់ការប៉ាន់ប្រមាណ ការពិនិត្យតាមដាន និងការវាយតម្លៃដោយមានការចូលរួមប្រកបដោយជោគជ័យ (សូមមើលឧបករណ៍ទី ៧)

- **ជំនាញឯកទេស :** ផ្តល់លទ្ធភាពឱ្យមានការចូលរួមពីបុគ្គលិក អ្នកពិគ្រោះការ ឬអង្គការសហគមន៍ ដែលមានបទពិសោធន៍ផ្នែកការ ចូលរួមនៅក្នុងពេលវិភាគលើគម្រោង ។ បន្ទាប់មកអ្នកឯកទេសត្រូវផ្សព្វផ្សាយពីដំណើរការពិនិត្យតាមដាន និងវាយតម្លៃ (M&E) ដែលមានការចូលរួម ។ មានអង្គការក្រៅរដ្ឋាភិបាលជាច្រើន ដែលមាន បទពិសោធន៍ជាមួយនឹងវិធីសាស្ត្រទាំងនេះ ។ លក្ខខណ្ឌប្រតិបត្តិ (ToRs) គំរូស្តីពីសកម្មភាពដែលមានការចូលរួម រួមទាំង លក្ខខណ្ឌប្រតិបត្តិសម្រាប់ទីប្រឹក្សាពិនិត្យតាមដាន និងវាយតម្លៃដោយមាន ការចូលរួម អាចរកបានលើគេហទំព័ររបស់ ADB ។[ក]
- **ធនធាន :** ការប៉ាន់ប្រមាណ និងការពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួម តម្រូវឱ្យមានការចំណាយពេល និងថវិកា ឱ្យបានគ្រប់គ្រាន់ ។ វិធីសាស្ត្រដែលមានការចូលរួមទាំងនេះ ត្រូវការពេលវេលាយូរជាងគោលវិធីធម្មតា ប៉ុន្តែជម្រុញឱ្យមានការអនុវត្តរលូនជាងមុន និងមានប្រសិទ្ធភាពជាងមុន និងអាចកសាងជំនាញវិភាគ និងការយល់ដឹងរបស់សហគមន៍អំពីគណនេយ្យភាព ។
- ***ភាពបត់បែន និងវេទយិតភាព* :** ការប៉ាន់ប្រមាណ និងការពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួមអាចធ្វើឱ្យអ្នកផ្តល់ ជំនួយ និងទីភ្នាក់ងារប្រតិបត្តិមានភាពបត់បែន សាកល្បងលើគំនិតបឋម និងការសន្មតរបស់ពួកគេពិនិត្យឡើងវិញលើវឌ្ឍនភាព និងដោះស្រាយបញ្ហា ដែលត្រូវបានកំណត់ ។ ការងារជាច្រើនពឹងអាស្រ័យលើកម្រិតនៃការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន ការបន្តការសិក្សា និង ការយល់ដឹងពីវប្បធម៌របស់អ្នកអនុវត្ត ។

[ក] ADB. 2007. *Handbook on Social Analysis.* Manila. p. 67 (Sample TOR for IPSA) and p. 69 (Sample TOR for social analysis in project design; TOR for Consultation/Participation Specialists: www.adb.org/participation/toolkit-term-reference.asp).

- **ការវិភាគអ្នកពាក់ព័ន្ធ ដើម្បីកំណត់ពីការចូលរួមរបស់អ្នកពាក់ព័ន្ធ :** ការវិភាគនេះកំណត់ពីតម្រូវការ ប្រយោជន៍ និង សមត្ថភាពរបស់អ្នកពាក់ព័ន្ធ និងផ្តល់ព័ត៌មានអំពីអ្នកដែលត្រូវចូលរួម និងរបៀបចូលរួមរបស់ពួកគេ។
- **គោលដៅ និងការរៀបចំផែនការច្បាស់លាស់ :** ទីភ្នាក់ងារអនុវត្តត្រូវកំណត់គោលដៅនៃការប៉ាន់ប្រមាណ និងការពិនិត្យតាមដាន និង វាយតម្លៃដោយមានការចូលរួមឱ្យបានច្បាស់លាស់ រៀបចំផែនការដោយប្រុងប្រយ័ត្ន និងធានាយ៉ាងណាឱ្យអ្នកទទួលផលមិនមាន ការរំពឹងទុក ដែលមិនប្រាកដនិយម។ គោលដៅដែលអាចមាន រួមមាន ការផ្តល់នូវភាពស្របច្បាប់ដល់ការរៀបចំ និងការពិនិត្យតាមដានគម្រោង ការបង្កើនប្រសិទ្ធភាព ឬការកសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធ។ ការធ្វើបែបនេះនឹងកំណត់ពីកម្រិត និងទម្រង់ នៃការចូលរួម។
- **ដំណើរការតាមដានបន្ត :** គេត្រូវការដំណើរការមួយ ដើម្បីធានាឱ្យមានការតាមដានបន្តលើលទ្ធផលរកឃើញ ដែលទទួលបានពីការប៉ាន់ប្រមាណ និងការពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួមនិងការរួមចំណែកនៃលទ្ធផលរកឃើញទាំងនេះ ចំពោះការធ្វើឱ្យកាន់តែប្រសើរនូវការងារ ដែលកំពុងអនុវត្ត។ គោលការណ៍នៃការរៀនសូត្រ ភាពបត់បែន និងតម្លាភាព មាន សារៈសំខាន់យ៉ាងខ្លាំងចំពោះការតាមដានបន្ត។

## វិធីសាស្ត្រ និងឧបករណ៍

វិធីសាស្ត្រដែលមានការចូលរួម ខុសប្លែកពីវិធីសាស្ត្រស្រាវជ្រាវធម្មតា (ឧ. ការអង្កេតតំណាង ជាដើម) នៅក្នុងការជួយឱ្យអ្នកទទួលផលអាចគ្រប់គ្រងលើការវិភាគពីបញ្ហារបស់ពួកគេ និងបង្កើតនូវដំណោះស្រាយ។[៣៤] ADB ប្រើប្រាស់ពាក្យ "ការវាយតម្លៃរហ័សដែលមានការចូលរួម(PRA)" ដើម្បីប្រើប្រាស់វិធីសាស្ត្រទាំងនេះ។

**ការវាយតម្លៃរហ័សដែលមានការចូលរួម** មានគោលបំណងផ្តល់លទ្ធភាពឱ្យអ្នកពាក់ព័ន្ធធ្វើការវិភាគពីបញ្ហារបស់ពួកគេ និងចូលរួម នៅក្នុងការរៀបចំផែនការការអនុវត្ត និងការវាយតម្លៃលើដំណោះស្រាយ ដែលបានឯកភាពគ្នា។ បច្ចេកទេសទាំងនេះផ្តោតសំខាន់ លើការវិភាគជារូបភាព និងជាសម្លេងដើម្បីធានាយ៉ាងណាឱ្យដំណើរការប្រមូលទិន្នន័យ និងការពិភាក្សា ធ្វើឡើងជាសាធារណៈ តម្លាភាព និងផ្តោតលើក្រុម។

ប្រភព : ADB. 2007. *Handbook on Social Analysis.* Manila.

តារាងខាងក្រោម រៀបរាប់ពីវិធីសាស្ត្រ PRA មួយចំនួន ដែលគេនិយមប្រើប្រាស់។ ប្រភេទនៃការវាយតម្លៃ និងគោលដៅនៃការវាយតម្លៃ នឹងកំណត់ពីវិធីសាស្ត្រដែលល្អបំផុត។ ព័ត៌មានបន្ថែមអាចរកបានក្នុងបញ្ជីធនធានសៀវភៅណែនាំអំពីការវិភាគសង្គម និងគេហទំព័ររបស់ ADB។[៣៥] វិធីសាស្ត្រជាច្រើន ដែលពន្យល់ខាងក្រោមនេះ មាន ទម្រង់ជាក្រាហ្វិច និងអន្តរកម្ម និងមិនតម្រូវឱ្យអ្នកចូលរួមចេះអក្សរ ទើបអាចរួមចំណែក និងចូលរួមនោះទេ។ គេក៏អាចកែសម្រួលវិធីសាស្ត្រទាំងនេះ សម្រាប់ក្រុមដែលមានការអប់រំខ្ពស់ផងដែរ និងអាចប្រើប្រាស់រួមជាមួយនឹងវិធីសាស្ត្រស្រាវជ្រាវបែបប្រពៃណីដទៃទៀត។

## វិធីសាស្ត្រវាយតម្លៃ ដែលមានការចូលរួម

| វិធីសាស្ត្រ | សេចក្តីពិពណ៌នា |
|---|---|
| ប្រតិទិន | ប្រមូលព័ត៌មានអំពីរបៀបដែលសកម្មភាពមានការផ្លាស់ប្តូរនៅក្នុងរយៈពេលមួយថ្ងៃ ឬនៅក្នុងរដូវ |
| ការវិភាគហេតុការណ៍សំខាន់ៗ | ប្រមូលព័ត៌មានពីហេតុការណ៍សំខាន់ៗ (វិជ្ជមាន ឬអវិជ្ជមាន) តាមរយៈការនិទានរឿងរបស់អ្នកចូលរួម។ បន្ទាប់មកមានការប្រមូលអង្គហេតុនានា និងមានការកំណត់ពីបញ្ហា។ ក្រោយមកធ្វើការសម្រេចចិត្តពីរបៀបដោះស្រាយបញ្ហាទាំងនេះផ្អែកទៅតាមដំណោះស្រាយដែលអាចមាន ហើយមានការវាយតម្លៃលើលទ្ធភាពទទួលបានជោគជ័យ ក្នុងការដោះស្រាយមូលហេតុ ដែលជា ឫសគល់របស់បញ្ហា។ |
| ដើមឈើបញ្ហា | ប្រើប្រាស់ដ្យាក្រាមដើមឈើ ដើម្បីបង្ហាញពីទំនាក់ទំនងនានា និងជួយគាំទ្រដល់ការធ្វើសេចក្តី សម្រេចចិត្ត ឧ. ដើមឈើបញ្ហាបង្ហាញពីមូលហេតុ និងផលប៉ះពាល់នៃបញ្ហាអ្វីមួយ ខណៈពេលដែល ដើមឈើគោលដៅបម្លែងបញ្ហាឱ្យក្លាយជាគោលដៅ និងបង្កើតនូវមធ្យោបាយ ទំនាក់ទំនងចុង ក្រោយ (សូមមើលឧបករណ៍ទី ២)។ |
| ការសង្កេតមូលដ្ឋាន និងការសង្កេតអ្នកចូលរួម | ការពង្រីកការចូលរួមឱ្យបានជិតស្និទ្ធជាមួយប្រជាពលរដ្ឋ នៅក្នុងបរិយាកាសធម្មតារបស់ពួកគេ និង ការសង្កេតមើលការអនុវត្តរបស់ពួកគេ លើកកម្ពស់ឱ្យមានការយល់ដឹងស៊ីជម្រៅ។ គេអាចប្រើប្រាស់វិធីសាស្ត្រគុណវិស័យដទៃទៀត ដូចជាការសម្ភាស និងការពិភាក្សាក្រុមជាដើម។ |
| ការសម្ភាសស៊ីជម្រៅ និងការពិភាក្សាក្រុម គោលដៅ | សូមមើលឧបករណ៍ទី ១ ៖ ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ តារាងបង្ហាញពី វិធីសាស្ត្រពិគ្រោះយោបល់។ |
| ការបង្កើតផែនទី ឬការបង្កើតគំរូ | ប្រជាពលរដ្ឋនៅមូលដ្ឋាន ដែលចូលរួមនៅក្នុងការពិភាក្សាក្រុមគោលដៅ ឬការពិភាក្សាក្នុងក្រុមធំ អាចរៀបរាប់ឱ្យឃើញពីរូបភាពរបស់តំបន់នៅមូលដ្ឋាន។<br>ពួកគេអាចគូសរូបដោយដៃ ឬដាក់សញ្ញាលើផែនទី ដែលបានរៀបចំរួចជាស្រេច។ ផែនទីដែលគេ និយមប្រើប្រាស់រួមមាន ផែនទីធនធានផែនទីសុខភាព និងផែនទីស្ថាប័ន។ ផែនទីផ្តល់នូវទិន្នន័យជាមូលដ្ឋាន សម្រាប់ការវិភាគតាមបែបចូលរួមបន្ត បង្ហាញពីការព្រួយបារម្ភនានា និងកំណត់ពី ដំណោះស្រាយ។ |
| ប្រវត្តិផ្ទាល់មាត់/បន្ទាត់ពេលវេលា | កត់ត្រារក្សា និងបកស្រាយបទពិសោធន៍ផ្ទាល់ខ្លួន និងគំនិតយោបល់របស់បុគ្គល ឬជនបង្គោល សំខាន់ៗ (អ្នកដឹកនាំព្រះវិហារ មេភូមិ ចាស់ព្រឹទ្ធាចារ្យ ។ល។) អំពីការផ្លាស់ប្តូរនានា នៅក្នុង រយៈពេលមួយ និងការផ្លាស់ប្តូរព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនានា។ |

| វិធីសាស្ត្រ | សេចក្តីពិពណ៌នា |
|---|---|
| ការដាក់ចំណាត់ថ្នាក់/ការដាក់ពិន្ទុ | រៀបចំដាក់ចំណាត់ថ្នាក់/ពិន្ទុ នៅក្នុងការពិភាក្សាក្រុមគោលដៅ ឬនៅក្នុងក្រុមធំៗ។ នៅក្នុងការដាក់ចំណាត់ថ្នាក់លើចំណង់ចំណូលចិត្ត មនុស្សកំណត់ពីអ្វីដែលពួកគេចូលចិត្ត/មិនចូលចិត្តអំពីទំនិញសេវា ឬសកម្មភាពណាមួយ ដាក់ចំណាត់ថ្នាក់ទំនិញសេវាកម្ម ឬសកម្មភាពទាំងនោះ និងស្វែងយល់ ពីមូលហេតុ ដែលធ្វើឱ្យមានចំណង់ចំណូលចិត្តទាំងនេះ។ ការដាក់ចំណាត់ថ្នាក់លើទ្រព្យសម្បត្តិ រួមមានការកំណត់ពីលក្ខណៈវិនិច្ឆ័យសមស្រប សម្រាប់ធ្វើការវាស់វែងទ្រព្យសម្បត្តិ/ភាពក្រីក្រ (ឧ. ប្រភេទផ្ទះ កម្មសិទ្ធិលើទ្រព្យសម្បត្តិ ស្ថានភាពនៅក្នុងសហគមន៍ ការជាប់បំណុល) បន្ទាប់មកមាន ការដាក់ចំណាត់ថ្នាក់ឱ្យបុគ្គល និងគ្រួសារដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យទាំងនេះ។ នៅក្នុងការធ្វើ ជំរឿនអំពីបញ្ហា ក្រុមកំណត់ វិភាគ និងដាក់ពិន្ទុឱ្យបញ្ហា និងលើកឡើងពីដំណោះស្រាយដែលអាចមាន។ |
| ការនិទានរឿង | បុគ្គល និងក្រុមនិទានរឿងរបស់ពួកគេដោយផ្ទាល់ ឬតាមរយៈការសម្តែងតួ។ ការនិទានរឿងអាច បំផុសឱ្យមានការពិភាក្សាគួរឱ្យចាប់អារម្មណ៍ជាមួយនឹងក្រុមអ្នកពាក់ព័ន្ធនានា។ គេក៏អាចប្រើប្រាស់វីដេអូ និងរូបថត ដើម្បីបង្ហាញពីការផ្លាស់ប្តូរនានាផងដែរ ទៅតាមលំដាប់លំដោយនៃរូបភាព ដែលប្រើប្រាស់ដើម្បីបង្ហាញអ្វីដែលគេឃើញ និងបកស្រាយអំពីអ្វីដែលបានកើតមានឡើងនៅក្នុងជីវិត និងសហគមន៍របស់ពួកគេ។ |
| ការដើរមើលក្នុង សហគមន៍ | នេះគឺជាការដើរតាមផ្លូវណាមួយ នៅក្នុងមូលដ្ឋានដោយអ្នកស្រាវជ្រាវ រួមជាមួយនឹងអ្នកផ្តល់ ព័ត៌មានជាបុរស និងជាស្ត្រីម្នាក់ ឬច្រើននាក់ ដើម្បីស្វែងយល់ពីបរិយាកាសនៅមូលដ្ឋាន ទីតាំង ធនធាន ការប្រើប្រាស់ដីធ្លី និងលក្ខណៈដទៃទៀត។ |
| ការវិភាគពីនិន្នាការ | ចែករំលែក និងប្រមូលព័ត៌មានជាមូលដ្ឋាន ក្នុងរយៈពេលមួយ ចាប់ពីរយៈពេលមួយ ទៅរយៈពេល មួយទៀត។ ជម្រើសមួយទៀត ចែករំលែកគំនិតអំពីទិដ្ឋភាពណាមួយរបស់បញ្ហាមួយ (កម្រិត ចំនួន អ្វីមួយ)។ ការវិភាគនិន្នាការអាចពិនិត្យលើលក្ខណៈអត្តនោម័ត និងសត្យានុម័ត (ខ្ញុំរស់នៅចម្ងាយ ‘x’ គីឡូម៉ែត្រ ពីមណ្ឌលសុខភាពដែលនៅជិតបំផុត ធៀបនឹងខ្ញុំរស់នៅឆ្ងាយពីមណ្ឌលសុខភាព ដែល នៅជិតបំផុត)។ |

ប្រភព ៖ ADB website: www.adb.org/participation/toolkit-methods-approaches.asp; Food and Agriculture Organization of the United Nations. 1990. *The Community’s Toolbox. The idea, methods and tools for participatory assessment, monitoring and evaluation in community forestry.* Rome; World Bank. 1996. *Participation and Social Assessment. Tools and Techniques.* Washington, DC.

ការប្រើប្រាស់វិធីសាស្ត្រតាមបែបចូលរួមបញ្ចូលគ្នាក្នុងលក្ខណៈជាប្រព័ន្ធ បង្កើតនូវគោលវិធី និងឧបករណ៍ សម្រាប់ធ្វើការវាយតម្លៃដោយមានការចូលរួម (ឧ. ការសិក្សា និងការបំពេញសកម្មភាពដោយមានការចូលរួម ការវាយតម្លៃតំបន់ ជនបទដោយមានការចូលរួម ការវាយតម្លៃអ្នកទទួលផល) (លេខយោងចុងក្រោយទី៣៤)។ នៅផ្នែកខាងចុងបំផុតនៃការចូលរួម គឺគោលវិធីកៀងគរសហគមន៍។ សេចក្តីពិពណ៌នាខាងក្រោមរៀបរាប់ពីឧបករណ៍ ដែល ADB ប្រើប្រាស់ និងបង្ហាញពីព័ត៌មានបន្ថែមទៀត។

- **ការវាយតម្លៃភាពក្រីក្រដោយមានការចូលរួម (PPA)** ៖ PPA គឺជាឧបករណ៍មួយសម្រាប់ដាក់បញ្ចូលទស្សនៈរបស់ ប្រជាពលរដ្ឋក្រីក្រទៅក្នុងការវិភាគភាពក្រីក្រ និងការបង្កើតយុទ្ធសាស្ត្រដើម្បីកាត់បន្ថយភាពក្រីក្រតាមរយៈគោលនយោបាយសាធារណៈ។[៣៦] នៅក្នុងឆ្នាំ២០០៤-២០០៥ ADB និងធនាគារពិភពលោក បានគាំទ្រដល់ការិយាល័យស្ថិតិជាតិរបស់ប្រទេសម៉ុងហ្គោលី ក្នុងការរៀបចំនូវ PPA មួយដើម្បីស្វែង

យល់ឱ្យបានស៊ីជម្រៅអំពីភាពក្រីក្រនិងនិន្នាការរបស់វា ។ ការពិភាក្សាត្រូវបានរៀបចំឡើងជាមួយនឹងក្រុមបុរស ស្ត្រី យុវជន ចាស់ព្រឹទ្ធាចារ្យ និងជន ដែលងាយរងគ្រោះ ។ ក្រុមសហគមន៍ និងអ្នកដឹកនាំសហគមន៍សំខាន់ (ដូចជា ភ្នាក់ងារសង្គម វេជ្ជបណ្ឌិត) ត្រូវបានពិគ្រោះយោបល់ជាមួយ ។ ក៏មានការគាំទ្រដល់ការវាយតម្លៃបែបនេះនៅក្នុងប្រទេសកម្ពុជា និងប្រទេសឡាវផងដែរ ។[៣៧]

- **ការវាយតម្លៃអ្នកទទួលផល (BA) :** BA គឺជាឧបករណ៍គុណវិស័យដែលមានការចូលរួមមួយ ដែលបង្កើនផលរយៈពេលវែងនៃប្រតិបត្តិការអភិវឌ្ឍន៍នានា តាមរយៈការប្រមូលទស្សនៈយោបល់របស់អ្នកទទួលផលអំពីអន្តរាគមន៍ ដែលកំពុងមានក្នុងផែនការឬដែលកំពុងអនុវត្តបន្ត ។ ឧបករណ៍នេះបំពេញបន្ថែមលើវិធីសាស្ត្របែបបរិមាណវិស័យ ដោយផ្តល់នូវព័ត៌មានគុណវិស័យស៊ីជម្រៅ ដែលអាចជឿទុកចិត្តបានអំពីស្ថានភាពសង្គម-វប្បធម៌ និងអំពីការយល់ឃើញរបស់ក្រុម គោលដៅរបស់គម្រោង តាមរយៈការពិភាក្សាក្រុមគោលដៅ ការសម្ភាស និងវិធីសាស្ត្រដទៃទៀត ។[៣៨] BA ត្រូវបានប្រើប្រាស់ជាផ្នែកមួយនៃការវាយតម្លៃគម្រោងដោយមានការចូលរួមលើសកម្មភាពសហគមន៍របស់ ADB នៅក្នុង គម្រោងលើកកម្ពស់អនាម័យក្នុងខេត្តសានតុង ប្រទេសចិន ។ ការវាយតម្លៃនេះរួមមានការពិគ្រោះយោបល់ជាមួយអ្នកទទួលផលរបស់គម្រោង និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីកំណត់ពីបញ្ហាចេញពីការយល់ឃើញរបស់ពួកគេ រៀបចំសកម្មភាពរបស់គម្រោង និងបង្កើតនូវមូលដ្ឋានសម្រាប់បន្តការងារអភិវឌ្ឍន៍ ដោយមានការចូលរួម ។[៣៩]

- **គោលវិធីសិក្សារៀនសូត្រអំពីការកៀងគរសហគមន៍ :** គោលវិធីកៀងគរសហគមន៍ ប្រើប្រាស់បែបផែននៃការរៀបចំផែនការការអនុវត្តសកម្មភាពការសង្កេត និងការវាយតម្លៃ ដោយមានការចូលរួម ដែលបន្តមានពេញមួយវដ្តគម្រោង ។ គម្រោងអប់រំ និងរៀនសូត្របរិស្ថានដោយផ្ទាល់ (IIEE) បានបង្កើតនូវគោលវិធីសិក្សារៀនសូត្រមួយ ជាផ្នែកនៃគម្រោង ADB TA-6123 ដែលមានឈ្មោះថា លើកកម្ពស់គោលនយោបាយ និងការអនុវត្តការគ្រប់គ្រងទឹកប្រកបដោយប្រសិទ្ធភាព ។[៤០]

The inventory lists further resources as does Tool 7: Participatory Monitoring and Evaluation, page 57. Assessment methods often double as monitoring and evaluation methods if implemented through project implementation ។

## ឧបករណ៍ទី ៤ : ការបង្កើតផែនការស្តីពីការចូលរួម

ផែនការស្តីពីការចូលរួម មិនថាជាផែនការតែឯង ឬត្រូវបានដាក់បញ្ចូលទៅក្នុងឯកសារគម្រោងដទៃទៀតនោះទេ ផ្តល់ការណែនាំអំពីការចូលរួមរបស់អ្នកពាក់ព័ន្ធនៅក្នុងវដ្តគម្រោងទាំងមូល ។ ផែនការនេះគ្របដណ្តប់លើសកម្មភាពនានា និងផ្តល់លទ្ធភាពឱ្យមានការចងក្រងទុកជាឯកសារ និងការវាយតម្លៃលើសកម្មភាពទាំងនោះ ។

### សេចក្តីផ្តើម

នៅក្នុង ADB ការចូលរួមគ្របដណ្តប់លើគោលវិធីសំខាន់ៗចំនួន ៤ : ការប្រមូល និងការចែករំលែកព័ត៌មាន ការពិគ្រោះយោបល់ ការសហការគ្នា និងភាពជាដៃគូ ។ គោលវិធីទាំងនេះគ្របដណ្តប់លើទំនាក់ទំនងជាច្រើនដែលក្នុង នោះកម្រិតនៃគំនិតផ្តួចផ្តើម និងសកម្មភាពរបស់ភាគីផ្សេងៗមានខុសៗគ្នា ។

ផែនការស្តីពីការចូលរួម (ដែលពីមុនហៅថាផែនការស្តីពីការពិគ្រោះយោបល់ និងការចូលរួម) រួមមានការ ធ្វើសេចក្តីសម្រេចចិត្តជាប្រព័ន្ធអំពីអ្នកពាក់ព័ន្ធដែលត្រូវចូលរួម របៀបចូលរួមរបស់ពួកគេ និងពេលដែលពួកគេត្រូវចូល រួម នៅក្នុងវដ្តគម្រោង ។

### តើផែនការស្តីពីការចូលរួមមានភាពសមស្របយ៉ាងដូចម្តេច នៅក្នុងវដ្តគម្រោងរបស់ ADB?

IPSA ដែលត្រូវបានបញ្ចប់ នៅក្នុងដំណាក់កាលចាប់ផ្តើម បង្ហាញឱ្យឃើញថាតើនឹងមានការបង្កើតផែនការស្តីពីការចូលរួមដែរឬអត់ ។ សម្រាប់គម្រោងភាគច្រើន គេអាចលើកឡើងពីអំណះអំណាងច្បាស់លាស់ ដើម្បីឱ្យមានការចូលរួម ។ បើតាមគោលការណ៍ណែនាំអំពីទម្រង់គំរូនៃ IPSA "ចាំបាច់ត្រូវមានផែនការស្តីពីការចូលរួម នៅក្នុងករណីដែលបញ្ហាស្តីពីការ ការពារផលប៉ះពាល់សង្គម គឺជាបញ្ហាធំ ។ ផែនការស្តីពីការចូលរួមគួរតែមាននៅពេលដែលការចូលរួមរបស់បុគ្គល និងក្រុមត្រូវបានគេចាត់ទុកថាជាការចូលរួមសំខាន់" ។ នៅក្នុងការរៀបចំគម្រោង SPRSS ត្រូវការព័ត៌មានអំពីកម្រិតនៃ ការចូលរួម ដែលរៀបចំសម្រាប់អនុវត្ត និងអំពីថាតើមានការរៀបចំផែនការស្តីពីការចូលរួមដែរឬទេ និងលក្ខណៈ សំខាន់ៗរបស់ផែនការនេះ ។ សូមមើលផ្នែកទី ៣ : ការចូលរួមនៅក្នុងវដ្តគម្រោងសម្រាប់ IPSA និងផ្នែកទម្រង់គំរូរបស់ SPRSS ស្តីពីការចូលរួម ។

ផែនការស្តីពីការចូលរួម គួរតែនៅបន្តមានភាពរស់រវើក ។ ដំណាក់កាលទី ១ នៃផែនការនេះ នឹងផ្តល់នូវការណែនាំអំពីការចូលរួមនៅក្នុងការរៀបចំគម្រោង និងការណែនាំលំអិតបន្ថែមទៀតសម្រាប់ដំណាក់កាលអនុវត្ត បន្ទាប់មកផែនការនេះនឹងត្រូវបង្កើតឡើងបន្តិចម្តងៗ នៅក្នុងកំឡុងពេលរៀបចំត្រៀមអនុវត្តគម្រោង ។

ផែនការនេះអាចជាផែនការតែឯង ឬដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពយេនឌ័រ ផែនការសកម្មភាពអភិវឌ្ឍន៍សង្គម ផែនការតាំងទីលំនៅ និងផែនការកាត់បន្ថយផលប៉ះពាល់សង្គម និងបរិស្ថានផ្សេងទៀត ។ ផែនការ អភិវឌ្ឍន៍សង្គម សម្រាប់គម្រោងវារីអគ្គិសនី Nam Theun ២ ដែលជា

គម្រោងអភិវឌ្ឍន៍នៅក្នុងប្រទេសឡាវ ផ្តល់នូវឧទាហរណ៍ដ៏មានប្រយោជន៍អំពីការដាក់បញ្ចូលនូវផ្នែកលំអិតមួយ ដែលនិយាយពីការពិគ្រោះយោបល់ជាសាធារណៈការចូលរួម និងការបង្ហាញព័ត៌មានដោយចំហ។[៤១]

## បង្កើតផែនការស្តីពីការចូលរួម

តារាងសង្ខេប ដែលបង្ហាញពីផែនការស្តីពីការចូលរួម មាននៅក្នុង*សៀវភៅណែនាំអំពីការវិភាគសង្គម* (សំណៅបច្ចុប្បន្នកម្មខាងក្រោម) ដែលមានបង្ហាញពីក្របខ័ណ្ឌពេលវេលាគំរូ សង្ខេបពីកិច្ចការនីមួយៗ។[៤២]

ផែនការស្តីពីការចូលរួម ប្រើប្រាស់ព័ត៌មានដែលបានមកពីការវិភាគអ្នកពាក់ព័ន្ធ ដែលផ្តល់ការណែនាំអំពី ការជ្រើសរើសក្រុមដែលត្រូវចូលរួម។

| | **គោលដៅនៃអន្តរាគមន៍របស់ពួកគេ** | | **វិធីសាស្ត្រចូលរួម** *(ឧ. សិក្ខាសាលា ការវាយតម្លៃដែលមានការចូលរួម ការអង្កេត ការកៀងគរ សហគមន៍ ឬការផ្តល់សេវាដោយអង្គការសង្គមស៊ីវិល ការពិនិត្យតាមដាន និងការ វាយតម្លៃដោយមានការ ចូលរួម)* | | **ក្របខ័ណ្ឌ ពេលវេលា** | | |
|---|---|---|---|---|---|---|---|
| **ក្រុមអ្នកពាក់ ព័ន្ធ** | **មូលហេតុនៃការចូលរួម** | **គោលវិធីនៃការចូល រួម** *(ការបង្កើត/ចែករំលែកព័ត៌មាន ការពិគ្រោះយោបល់ ការសហការ ឬភាពជា ដៃគូ)* **និងភាពស៊ីជម្រៅ** *(ទាប មធ្យម ខ្ពស់)* | **វិធីសាស្ត្រ** | **អ្នកទទួល ខុសត្រូវ** | **កាល បរិច្ឆេទ ចាប់ ផ្តើម** | **កាលបរិច្ឆេទ បញ្ចប់** | **ចំណាយ ប៉ាន់ស្មាន** |
| រដ្ឋាភិបាល | | | | | | | |
| សង្គមស៊ីវិល | | | | | | | |
| វិស័យឯកជន | | | | | | | |

បន្ទាប់មក ការអភិវឌ្ឍត្រូវបានធ្វើឡើង រួមជាមួយនឹងអ្នកពាក់ព័ន្ធដោយខ្លួនឯង។ នេះអាចរួមមានការរៀបចំ សិក្ខាសាលាដំបូង ដើម្បីរៀបរាប់ពីការចូលរួម នៅក្នុងការរៀបចំគម្រោង និងកិច្ចប្រជុំផ្សេងទៀត ដើម្បីបង្កើតផែនការអនុវត្ត។ ឧបករណ៍ផ្សេងទៀតសម្រាប់វដ្តគម្រោង ដែលមានបង្ហាញនៅក្នុងមគ្គុទ្ទេសក៍នេះ អាចជួយជម្រុញឱ្យមានការ ចូលរួមរបស់អ្នកពាក់ព័ន្ធ តាមបែបផ្សេងៗពីគ្នា (ឧ. តាមរយៈការប្រើប្រាស់ CSOs [ឧបករណ៍ទី ៦] ឬដោយអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃដោយមានការចូលរួម ឱ្យឧបករណ៍ទី ៧)។

ចុងក្រោយអ្នកពាក់ព័ន្ធសំខាន់ៗ គោលដៅនៃការចូលរួមរបស់ពួកគេ និងទិដ្ឋភាពនានា (គោលវិធី/ភាពស៊ី ជម្រៅ និងវិធីសាស្ត្រ) ត្រូវការការឯកភាព និងការដាក់បញ្ចូលទៅក្នុងផែនការ ដែលមានក្របខ័ណ្ឌពេលវេលា និង ការប៉ាន់ប្រមាណអំពីធនធាន។ ជាធម្មតា អ្នកពាក់ព័ន្ធរួមមានអ្នកទទួលជំនួយ/កម្ចីរបស់ប្រទេសកំពុងអភិវឌ្ឍជា សមាជិក និង/ឬស្ថាប័នរបស់អតិថិជន ដែលដឹកនាំការអនុវត្តសកម្មភាព ដែលមានការចូលរួម។

ជារឿយៗ ស្ថាប័ននេះសំដៅលើរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន ដែលនៅកៀកនឹងសហគមន៍ និងប្រជាពលរដ្ឋជាងគេ។ អ្នកពាក់ព័ន្ធទាំងនេះក៏រួមមានអ្នកពាក់ព័ន្ធមកពីសង្គមស៊ីវិល (អង្គការសង្គមស៊ីវិល អ្នកដែលរងផលប៉ះពាល់ ។ល។) ដែលត្រូវបានពិគ្រោះយោបល់ជាមួយ ឬដែលជាអ្នកអនុវត្តសកម្មភាពដែលមានការចូលរួមផងដែរ ។ ពេលខ្លះ ក៏មានការជម្រុញឱ្យមានការចូលរួមពីវិស័យឯកជនផងដែរ ។

បញ្ជីត្រួតពិនិត្យខាងក្រោមធានាឱ្យមានការដាក់បញ្ចូលបញ្ហា និងសមាសភាគសំខាន់ៗ ទៅក្នុងផែនការនេះ :

## បញ្ជីត្រួតពិនិត្យសម្រាប់បង្កើតផែនការស្តីពីការចូលរួម

- តើក្រុមអ្នកពាក់ព័ន្ធណាខ្លះ ដែលកំពុងចូលរួមនៅក្នុងដំណើរការដែលមានការចូលរួម ផ្អែកទៅតាមការវិភាគអ្នកពាក់ព័ន្ធបឋម?
- តើមានការសម្រេចចិត្តអ្វីខ្លះដែលត្រូវបានធ្វើឡើង តាមរយៈការចូលរួម? និងតើការសម្រេចចិត្តនេះ ត្រូវបានធ្វើឡើងដោយរបៀបណា?
- តើការចូលរួមនឹងមានទំនាក់ទំនងជាមួយនឹងលក្ខខណ្ឌ ដែលតម្រូវដោយយុទ្ធសាស្ត្រសង្ខេបស្តីពីការកាត់បន្ថយភាពក្រីក្រ និងសង្គម និងការការពារផលប៉ះពាល់សង្គម និងបរិស្ថាន?
- តើការចូលរួមនឹងត្រូវប្រើប្រាស់យ៉ាងដូចម្តេចខ្លះ នៅក្នុងកំឡុងពេលអនុវត្ត?
- តើវិធីសាស្ត្រចូលរួមអ្វីខ្លះ ដែលនឹងត្រូវយកមកប្រើប្រាស់?
- តើសកម្មភាពចូលរួមមានក្របខ័ណ្ឌពេលវេលាយ៉ាងដូចម្តេច?
- តើមានការកំណត់លំដាប់លំដោយនៃវិធីសាស្ត្រចូលរួម ដោយរបៀបណា?
- តើមានការបែងចែកតួនាទី និងការទទួលខុសត្រូវ សម្រាប់រៀបចំការចូលរួម យ៉ាងដូចម្តេចខ្លះ ក្នុងចំណោមនិវាសនដ្ឋានប្រចាំប្រទេស ទីភ្នាក់ងារប្រតិបត្តិ ទីប្រឹក្សាអង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នដទៃទៀត
- តើចាំបាច់ត្រូវមានអ្នកសម្របសម្រួលការចូលរួមដែរឬទេ?
- តើផែនការស្តីពីការចូលរួមត្រូវការចំណាយប៉ុន្មាន ដើម្បីអនុវត្ត និងត្រូវប្រើប្រាស់ថវិកាអ្វី?

ផែនការស្តីពីការចូលរួម គួរផ្តល់នូវព័ត៌មានសម្រាប់បង្កើតយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយនឹងអ្នកពាក់ព័ន្ធ (SCS)។ PAM ដែលផ្តល់ការណែនាំអំពីការអនុវត្តគម្រោង មានដាក់បញ្ចូលការបង្កើត SCS សម្រាប់គ្រប់គម្រោងទាំងអស់ (សូមមើលឧបករណ៍ទី ៥ : ការបង្កើតយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ ទំព័រទី ៤៧)។

នៅក្នុងការអនុវត្តជាក់ស្តែង ការពិនិត្យឡើងវិញជាប្រចាំលើផែនការនេះ លើអ្វីដែលបានអនុវត្ត និងលើកម្រិតជោគជ័យ ជួយដល់ការគ្រប់គ្រងការងារ ដែលកំពុងអនុវត្ត (លេខយោងចុងក្រោយលេខ ៤២)។ ការពិនិត្យតាមដានគម្រោង តាមរយៈបេសកកម្មពិនិត្យឡើងវិញ របាយការណ៍ប្រចាំត្រីមាសរបស់ទីភ្នាក់ងារប្រតិបត្តិ និងយន្តការដទៃទៀត គួររាយការណ៍អំពីវឌ្ឍនភាពនានា ដែលសម្រេចបាន។

## ឧទាហរណ៍អំពីផែនការស្តីពីការចូលរួម

ទម្រង់គំរូខាងក្រោមសង្ខេបអំពីផែនការសម្រាប់គម្រោងធារាសាស្ត្រសហគមន៍នៅប្រទេសនេប៉ាល់ របស់ ADB ។[៤៣]

**អ្នកពាក់ព័ន្ធសំខាន់ៗ ចេញពីការវិភាគអ្នកពាក់ព័ន្ធ និងសង្គម**

| | |
|---|---|
| **មន្ត្រីរដ្ឋាភិបាលនៅថ្នាក់ក្រសួង/នៅថ្នាក់មូលដ្ឋាន** | |
| មន្ត្រីនៅថ្នាក់ស្រុក | មន្ត្រីមកពីក្រសួងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន កសិកម្ម និងផ្លូវថ្នល់ (DOLLDAR) (ទីភ្នាក់ងារប្រតិបត្តិ) |
| **សភាតំណាង និងគណៈកម្មាធិការ** | |
| អ្នកដឹកនាំនៅថ្នាក់ស្រុក | តំណាងគណៈកម្មាធិការអភិវឌ្ឍន៍ស្រុក (DDCs) (ផ្នែកនៃក្រសួង អភិវឌ្ឍន៍) |
| តំណាងក្រុមដែលមានឱកាសតិចតួចនៅថ្នាក់ស្រុក (DAG) | តំណាងក្រុម DDCs DAG |
| អ្នកដឹកនាំគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(VDC) | VDC កម្រិតរដ្ឋបាលទាបបំផុតនៃក្រសួងអភិវឌ្ឍន៍មូលដ្ឋានរបស់ប្រទេសនេប៉ាល់, ស្រុកនីមួយៗមាន VDCs ជាច្រើន ដែលទទួលខុសត្រូវលើអន្តរកម្មរវាងរដ្ឋាភិបាល និងសាធារណជនទូទៅ |
| តំណាងក្រុម និងក្រុមដែលជួបប្រទះការលំបាក | តំណាង DAG និងក្រុម នៅក្នុង VDCs (VDC នីមួយៗត្រូវបាន បែងចែក-ជាក្រុម) |
| **ក្រុមអ្នកទទួល/ប្រជាពលរដ្ឋក្រីក្រ និងក្រុមដែលងាយរងគ្រោះ** | |
| ក្រុមជនជាតិ/វណ្ណៈ/សាសនា | |
| Brahmin-Chhetri, ក្រុមជនជាតិដើមភាគតិចដែលមានឱកាស ច្រើន (IP) (Newar, Thakali), ក្រុមវណ្ណៈកណ្តាល Terai | ក្រុមធំទូទៅមិនត្រូវការការគាំទ្រ សម្រាប់ការចូលរួមនោះឡើយ |
| ក្រុមជនជាតិដើមភាគតិចជួបប្រទះការលំបាកដែលរស់នៅតាមភ្នំ និង Terai Dalit, (Sherpa, Rai, Gurung, Magar), ក្រុមជនជាតិដើមភាគតិចដែលមានឱកាសតិចតួច (Tamang, kumal, Tharu), ក្រុមជនជាតិដើមភាគតិចដែលប្រឈមនឹងគ្រោះថ្នាក់ និងមាន ឱកាសតិចតួច (Majhi, Rajbanshi), ក្រុមសាសនាភាគតិច (មូស្លីម) | ក្រុមគ្មានឱកាស និងក្រុមជនជាតិដើមភាគតិច ត្រូវការការគាំទ្រ សម្រាប់ការចូលរួម |
| ភូមិសាស្ត្រ | |
| ភូមិទទួលផលសំខាន់ៗ ភូមិនៅជិតខាងដែលអាចទទួលរងផល ប៉ះពាល់ | ក្រុមធំទូទៅមិនត្រូវការការគាំទ្រ សម្រាប់ការចូលរួមនោះឡើយ |
| ភូមិដាច់ស្រយាល (ដើរជាង ១ ម៉ោង ទើបទៅដល់ផ្លូវថ្នល់) | ភូមិដែលនៅដោយឡែកពីគេ ត្រូវការការគាំទ្រ សម្រាប់ការ ចូលរួម |
| ស្ថានភាពសេដ្ឋកិច្ច | |
| ក្រុមដែលជាអ្នកទទួលផលទូទៅ គ្រួសារដែលមានសន្តិសុខ ស្បៀង | ក្រុមធំទូទៅមិនត្រូវការការគាំទ្រ សម្រាប់ការចូលរួមនោះឡើយ |
| ប្រជាពលរដ្ឋដែលក្រខ្សត់ខ្លាំង (រស់នៅក្រោមបន្ទាត់នៃភាព ក្រីក្រ) អ្នកដែលធ្លាប់ធ្វើការងារដោះបំណុល | ក្រុមដែលមានស្ថានភាពសេដ្ឋកិច្ចទាបត្រូវការការគាំទ្រ សម្រាប់ ការចូលរួម |
| យេនឌ័រ | |
| បុរស | មិនត្រូវការការគាំទ្រ |
| អង្គការសង្គមស៊ីវិល (CSOs) | Require support to participate |
| **អង្គការសង្គមស៊ីវិល (CSOs)** | |
| អង្គការសង្គមស៊ីវិល | អង្គការសង្គមស៊ីវិល ដែលធ្វើការងារនៅថ្នាក់ស្រុក ក្នុងតំបន់ គម្រោង |

**ក្រុមអ្នកពាក់ព័ន្ធសំខាន់ៗ :** អ្នកពាក់ព័ន្ធដែលត្រូវចូលរួម រួមមានមន្ត្រីរដ្ឋាភិបាល សមាជិកស្ថាប័នតំណាង អ្នកទទួលផលទូទៅក្រុមដែលគ្មានឱកាស និងអង្គការសង្គមស៊ីវិល។

**គោលដៅនៃការចូលរួម :** គម្រោងនេះត្រូវបានកំណត់ថាជាគម្រោងដែលមានការចូលរួមខ្ពស់ ហើយមានគោលបំណង កសាងសមត្ថភាពរបស់អ្នកប្រើប្រាស់ ឱ្យក្លាយជាម្ចាស់ និងទទួលខុសត្រូវលើគ្រប់ទិដ្ឋភាពទាំងអស់នៃប្រតិបត្តិការ និងការថែទាំសមិទ្ធផលរបស់គម្រោង។ គោលដៅធំៗរួមមាន :

- ធានាឱ្យមានភាពជាម្ចាស់នៅមូលដ្ឋាន
- ដាក់បញ្ចូលគ្រប់ក្រុមអ្នកពាក់ព័ន្ធទាំងអស់ នៅក្នុងដំណើរការនៃការចូលរួម និងការបែងចែកផលប្រយោជន៍ និង
- ផ្សព្វផ្សាយលទ្ធផល និងមេរៀនដែលទទួលបានដល់សហគមន៍ទូទៅ រួមទាំងដល់រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល

**ទិដ្ឋភាពនៃការចូលរួម :** ការចូលរួម រួមមានការបណ្តុះបណ្តាលការសាងសង់ការសម្រេចចិត្តដែលមានការចូលរួមនៅ ក្នុងសកម្មភាពខាងក្រោម :

i. ការជ្រើសរើស *Ilakas* ដោយអ្នកពាក់ព័ន្ធនៅថ្នាក់ស្រុក (ស្រុកចែកចេញជា *Ilakas*)
ii. ការជ្រើសរើសអនុគម្រោង ដោយអ្នកពាក់ព័ន្ធនៅកម្រិត VDC
iii. ការសម្រេចចិត្តអំពីការរៀបចំប្រព័ន្ធ
iv. ការសម្រេចចិត្តអំពីប្រព័ន្ធប្រតិបត្តិការ និងតំហែទាំ កម្រិតនៃការរួមវិភាគទានហិរញ្ញវត្ថុ
v. ការសម្រេចចិត្តអំពីទម្រង់ និងការគ្រប់គ្រងសំណង់
vi. ការសម្រេចចិត្តអំពីការចូលរួម នៅក្នុងសមាគមអ្នកប្រើប្រាស់ទឹក (WUA) និងក្រុមអ្នកប្រើប្រាស់ទឹក (WUG)
vii. ការសម្រេចចិត្តអំពីភាពជាតំណាងរបស់អនុក្រុមដែលគ្មានឱកាស នៅក្នុង WUA ការបណ្តុះបណ្តាល និង
viii. ការធានាឱ្យមានការចូលរួមប្រកបដោយអត្ថន័យ នៅក្នុងគ្រប់កិច្ចប្រជុំ ក្រុម និងសកម្មភាពខាងលើ

ក្រុមការងារនៅតាមភូមិ (VBFT) បំពេញតួនាទីជាអ្នកកៀងគរសហគមន៍ និងអ្នកសម្របសម្រួល ដើម្បីកសាងសមត្ថភាពរបស់អ្នកប្រើប្រាស់ក្នុងការរៀបចំ អនុវត្ត និងបង្កើនការយល់ដឹងអំពីសកម្មភាពរបស់គម្រោង។

Participation Plan: Nepal Community Irrigation Project

| ក្រុមអ្នកពាក់ព័ន្ធ | គោលដៅនៃអន្តរាគមន៍របស់ពួកគេ<br>មូលហេតុនៃការចូលរួម | គោលវិធីនៃការចូលរួម និងភាពស៊ីជម្រៅ | វិធីសាស្ត្រចូលរួម<br>វិធីសាស្ត្រ | អ្នកទទួលខុសត្រូវ | ក្របខ័ណ្ឌ ពេលវេលា<br>កាលបរិច្ឆេទចាប់ផ្តើម | កាលបរិច្ឆេទបញ្ចប់ | ចំណារបាន់ស្មាន |
|---|---|---|---|---|---|---|---|
| **មន្ត្រីរដ្ឋាភិបាលនៅមូលដ្ឋាន អ្នកដឹកនាំថ្នាក់ស្រុកតំណាង** | **តំណាង ទីភ្នាក់ងារប្រតិបត្តិរបស់រដ្ឋាភិបាល (EA: DoIIDAR) ដែលទទួល ខុសត្រូវលើការអនុវត្តគម្រោង និង អ្នកធ្វើការសម្រេចចិត្តដែលតំណាងឱ្យផល ប្រយោជន៍របស់ស្រុក** | ភាពជា ដៃគូ (ខ្ពស់) | • **ការជ្រើសរើស** ***Ilakas:*** មន្ត្រីអ្នកដឹកនាំ និងតំណាងក្រុមដែលគ្មានឱកាសជួយគណៈកម្មាធិការអភិវឌ្ឍន៍ស្រុក (DDC) ជ្រើសរើសលលាកាស ដែលជួបប្រទះការ លំបាកជាងគេចំនួន ៤ ដើម្បីចូលរួមនៅ ក្នុងគម្រោង<br>• **ការពិនិត្យតាមដាន :** DoIIDAR ផ្ទេរបាយការណ៍វឌ្ឍនភាពប្រចាំខែចំនួន៣ (ការអង្កេតលើគម្រោង និងការវាយតម្លៃដោយមានការចូលរួមត្រូវបានធ្វើឡើង)<br>• **ការពិនិត្យឡើងវិញ/ផែនការប្រចាំឆ្នាំថ្នាក់ស្រុក :** កិច្ចប្រជុំពិនិត្យឡើងវិញ និងរៀបចំផែនការជាមួយនឹងអ្នកពាក់ព័ន្ធមកពីគណៈកម្មាធិការអភិវឌ្ឍន៍ស្រុក/ភូមិ | – មន្ត្រីថ្នាក់ស្រុក<br>– អ្នកដឹកនាំថ្នាក់ស្រុក<br>– តំណាងក្រុមដែលគ្មានឱកាសថ្នាក់ស្រុក | | | |
| **គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (និងក្រុមការងារតាមភូមិ)** | **សមាជិក VDCs ដែលទទួលខុសត្រូវលើទំនាក់ទំនងរវាងរដ្ឋាភិបាល និងសាធារណជនលើការងារអភិវឌ្ឍន៍នៅមូលដ្ឋាន** | ភាពជាដៃគូ (ខ្ពស់) | • **ការជ្រើសរើសអនុគម្រោង :** ក្រុមការងារតាមភូមិ (VBFTs) រៀបចំកិច្ចប្រជុំសាធារណៈ នៅកម្រិតក្រុម ពន្យល់ពីគម្រោងគោលវិធីដែលមានការចូលរួមរបស់គម្រោង និងលក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសអនុគម្រោង អញ្ជើញក្រុមប្រជាពលរដ្ឋ និងសមាគម អ្នកប្រើប្រាស់ទឹក (WUAs) ឱ្យធ្វើសំណើ, VDC ជ្រើសរើសគម្រោង និងស្នើសុំការឯកភាពពី DDC<br>• **ការពិនិត្យតាមដាន :** VDCs រួមចំណែកចំពោះរបាយការណ៍វឌ្ឍនភាព<br>• **កិច្ចប្រជុំពិនិត្យឡើងវិញប្រចាំឆ្នាំរបស់ VDC:** កិច្ចប្រជុំពិនិត្យឡើងវិញរួមជាមួយអ្នកពាក់ព័ន្ធ VDC និង WUAs<br>• **ការពិនិត្យឡើងវិញ/ផែនការប្រចាំឆ្នាំនៅថ្នាក់ស្រុក :** សូមមើលខាងលើ | – អ្នកដឹកនាំ VDC<br>– តំណាងក្រុម VDC និងDAG | | | |
| **អ្នកទទួលផល/ប្រជាពលរដ្ឋក្រីក្រ និងអ្នកដែលងាយរងគ្រោះ** | **អ្នកទទួលផល និងអ្នកដែលចុងក្រោយក្លាយជាម្ចាស់គម្រោង** | ភាពជាដៃគូ (ខ្ពស់) | • **ការសម្រេចចិត្តអំពីការចូលរួមនៅក្នុង WUAs និងក្រុមអ្នកប្រើប្រាស់ទឹក (WUG):** សហគមន៍កំណត់ពីការចូលរួម ដោយមានការគាំទ្រពី VBFTs, ធានាយ៉ាងណាឱ្យសកម្មភាពនេះធ្វើឡើង ដោយមានការចូលរួម និងដាក់បញ្ចូលតំណាងរបស់អនុក្រុមដែលជួបប្រទះការលំបាក | – WUA/WUG<br>– អ្នកប្រើប្រាស់សំខាន់ៗរបស់អនុគម្រោងធារាសាស្ត្រ ឡិភច<br>– ISP DAG<br>– ISP ជាស្ត្រី | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| អង្គការសង្គមស៊ីវិល (ឧ. អង្គការក្រៅរដ្ឋាភិបាល សហជីព ។ល ។) | តំណាងសង្គម ស៊ីវិល | ការសហការ (ខ្ពស់) | • **ការសម្រេចចិត្តអំពីការរៀបចំប្រព័ន្ធ ដំណើរការ និងទម្រង់នៃការសាងសង់ :** WUAs បង្កើតសំណើសម្រាប់អនុគម្រោងធារាសាស្ត្រ ដោយមានជំនួយពី VBFT និងក្រុមគាំទ្របច្ចេកទេស (TST)<br>• **ការកសាងសមត្ថភាពរបស់** WUA : VBFTs ផ្ដល់ការបណ្ដុះបណ្ដាលអំពីការ ពិនិត្យតាមដាន និងការគ្រប់គ្រងការសាងសង់, សហព័ន្ធជាតិនៃសមាគមអ្នក ប្រើប្រាស់ទឹកពីប្រព័ន្ធធារាសាស្ត្ររបស់ប្រទេសនេប៉ាល់ផ្ដល់ការបណ្ដុះបណ្ដាលអំពីការគ្រប់គ្រង<br>• **ការពិនិត្យតាមដាន :** WUAs បង្កើតគណៈកម្មាធិការពិនិត្យតាមដានការសាងសង់<br>• **ការបណ្ដុះបណ្ដាលអំពីកសិកម្ម និងមុខរបរចិញ្ចឹមជីវិត :** សហគមន៍ទទួលបានការបណ្ដុះបណ្ដាលអំពីកសិកម្ម និងឥណទានខ្នាតតូច ដោយផ្ដោតជាពិសេសលើការបំពេញ តម្រូវការរបស់ស្ត្រី និងក្រុមដែលគ្មានឱកាស<br>• **កិច្ចប្រជុំពិនិត្យឡើងវិញប្រចាំឆ្នាំរបស់** VDC សូមមើលខាងលើ<br>• **តំណាងអង្គការសង្គមស៊ីវិលដែលជាសមាជិករបស់** DDCs | – អង្គការសង្គមស៊ីវិលនៅថ្នាក់ ស្រុក | | | |
| | **អ្នកដែលមានជំនាញផ្នែកអភិវឌ្ឍន៍សហគមន៍** | ការសហការ (មធ្យម) | • **ការគ្រប់គ្រង និងការអនុវត្តគម្រោង :** អង្គការក្រៅរដ្ឋាភិបាលត្រូវបានជួលឱ្យផ្ដល់ការគាំទ្រដល់ DoIIDAR និង DDCs, សេវានានា រួមមាន ការកំណត់ និងត្រួតពិនិត្យអនុគម្រោងដែលអាចអនុវត្តទៅ បានការពង្រឹង WUAs និងការវាយតម្លៃលើលទ្ធភាពអនុវត្តអនុគម្រោងដែលមានការចូលរួម | – អង្គការក្រៅរដ្ឋាភិបាល | | | |

# ឧបករណ៍ទី ៥ : ការបង្កើតយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ

យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ ប្រើប្រាស់ និងពង្រីកផែនការស្ដីពីការចូលរួម និងផ្ដោតសំខាន់លើការចែករំលែកព័ត៌មាន និងការពិគ្រោះយោបល់។ យុទ្ធសាស្ត្រនេះផ្ដល់ការណែនាំអំពីការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ ក្នុងកំឡុងពេលអនុវត្តគម្រោង។

## សេចក្ដីផ្ដើម

ការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ រួមមាន ការដាក់បញ្ចូលការប្រាស្រ័យទាក់ទងជាយុទ្ធសាស្ត្រ ទៅក្នុង គម្រោងអភិវឌ្ឍន៍។ ការប្រាស្រ័យទាក់ទងនេះ រួមមានការផ្សព្វផ្សាយព័ត៌មានការអប់រំ និងការបង្កើនការយល់ដឹង និងមានការធ្វើសកម្មភាពបន្ថែមទៀត ដើម្បីលើកទឹកចិត្តឱ្យមានការពិគ្រោះយោបល់ លើកកម្ពស់ឱ្យមានការផ្លាស់ប្ដូរឥរិយាបថ និងកាត់បន្ថយហានិភ័យនានា។ ការប្រាស្រ័យទាក់ទងនេះតម្រូវឱ្យមានការផ្ដល់ព័ត៌មានដល់ក្រុមគោលដៅមួយចំនួន (សហគមន៍ មន្ត្រីរដ្ឋាភិបាល អង្គការសង្គមស៊ីវិល វិស័យឯកជន ។ល។) ការស្ដាប់ព័ត៌មានត្រឡប់របស់ពួកគេ និងការឆ្លើយតប។

ការប្រាស្រ័យទាក់ទង មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការចូលរួម ហើយក្នុងចំណោមគោលវិធីទាំង ៤ របស់ ADB (សូមមើលសេចក្ដីផ្ដើម) ការប្រាស្រ័យទាក់ទងគ្របដណ្ដប់លើការប្រមូល/ចែករំលែកព័ត៌មាន និងការពិគ្រោះយោបល់។ ការប្រាស្រ័យទាក់ទងជាយុទ្ធសាស្ត្រ គឺជាឧបករណ៍ដ៏មានអានុភាពមួយ ដែលផ្ដល់ការគាំទ្រដល់ ប្រតិបត្តិការរបស់គម្រោង និងបង្កើនឱកាសទទួលបានជោគជ័យ។ មិនថាគម្រោងស្ថិតក្នុងវិស័យណា ឬជាគម្រោងប្រភេទណានោះទេ គោលដៅសំខាន់គឺផ្ដោតលើការកសាង ការឯកភាពគ្នាជារួមតាមរយៈការបង្កើន ការយល់ដឹងជាសាធារណៈ និងការបង្កើតឱ្យមានកិច្ចពិគ្រោះយោបល់ ក្នុងចំណោមអ្នកពាក់ព័ន្ធនានា។[៤៤]

## តើការប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធមានភាពសមស្របយ៉ាងដូចម្ដេច នៅក្នុងវដ្ដគម្រោងរបស់ ADB?

PAM ដែលរៀបរាប់ពីការរៀបចំការអនុវត្តគម្រោង មានដាក់បញ្ចូលការបង្កើតយុទ្ធសាស្ត្រស្ដីពីការប្រាស្រ័យ ទាក់ទងជាមួយនឹងអ្នកពាក់ព័ន្ធ (SCS)។ យុទ្ធសាស្ត្រនេះតម្រូវឱ្យមន្ត្រីគម្រោងកំណត់ពីគោលដៅ និងហានិភ័យសំខាន់ៗ ផ្នែកការប្រាស្រ័យទាក់ទង រៀបចំសារសំខាន់ៗ និងកំណត់ពីច្រកប្រាស្រ័យទាក់ទងដែលមានប្រសិទ្ធភាព ដើម្បីជម្រុញ ឱ្យមានការចូលរួមពីក្រុមគោលដៅសំខាន់ៗ។ យុទ្ធសាស្ត្រនេះប្រើប្រាស់ និងគាំទ្រដល់ផែនការចូលរួម ដែលមានលក្ខណៈ ទូលំទូលាយ (សូមមើលឧបករណ៍ទី ៤ : បង្កើតផែនការស្ដីពីការចូលរួម)។ គោលនយោបាយប្រាស្រ័យទាក់ទងសាធារណៈឆ្នាំ ២០១១ របស់ ADB បង្ហាញពីសារៈសំខាន់នៃការប្រាស្រ័យទាក់ទង និងការប្ដេជ្ញាចិត្តរបស់ ADB ដើម្បី ជួយដល់រដ្ឋាភិបាលរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក និងអតិថិជនវិស័យឯកជន នៅក្នុងការបង្កើតយុទ្ធសាស្ត្រ ប្រាស្រ័យទាក់ទងរបស់គម្រោង ឬកម្មវិធី ដែលជាផ្នែកដ៏សំខាន់មួយនៃការចូលរួមរបស់អ្នកដែលរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធដទៃទៀត។[៤៥] SPS តម្រូវឱ្យប្រទេសកំពុងអភិវឌ្ឍជាសមាជិក ធ្វើការ

ប្រាស្រ័យទាក់ទងជាមួយនឹងអ្នក ដែលរងផលប៉ះពាល់ (សូមមើលផ្នែកនៅក្នុងមគ្គុទេសក៏ ដែលនិយាយពីការចូលរួម នៅក្នុងការការពារផលប៉ះពាល់សង្គម និងបរិស្ថាន ទំព័រទី ៦៣) ។ សមាសភាគនានា ដែលមាននៅក្នុង SCS បំពេញគោលបំណងផ្សេង១ពីគ្នា ហើយអាចដាក់បញ្ចូលការប្រាស្រ័យទាក់ទងជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ និងអ្នកពាក់ព័ន្ធខាងក្រៅផ្សេងទៀត ការជម្រុញ ឱ្យមានការចូលរួមពីសហគមន៍ និងការគាំទ្រដល់ការអភិវឌ្ឍសហគមន៏ និងការសសម្របសម្រួលជាមួយនឹងក្រុមការងារ ដែលធ្វើការពាក់ព័ន្ធជាមួយនឹងផលប៉ះពាល់សង្គម និងបរិស្ថាន (ឧ. ការតាំងទីលំនៅ) ជាដើម ។

## ការបង្កើតយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ

PAM មានដាក់បញ្ចូលនូវទម្រង់គំរូមួយ សម្រាប់បង្កើតយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ (សូមមើលខាងក្រោម) ។ ដំណើរការរៀបចំផែនការប្រាស្រ័យទាក់ទង មានជំហានដូចខាងក្រោម :

| គោលដៅ | ហានិភ័យ/ បញ្ហាប្រឈមសំខាន់ៗ | ក្រុមគោលដៅ/ អ្នកពាក់ព័ន្ធសំខាន់ៗ | សារ(ព័ត៌មានដែលត្រូវផ្សព្វផ្សាយ) | មធ្យោបាយ ធ្វើការប្រាស្រ័យទាក់ទង (ច្រក/ ភាសា/ សកម្មភាព) | ក្របខ័ណ្ឌពេលវេលា/ ភាពញឹកញាប់ | ការទទួលខុសត្រូវ | ធនធាន (មនុស្ស ហិរញ្ញវត្ថុ ) |
|---|---|---|---|---|---|---|---|
| • | • | • | • | • | • | • | • |
| • | • | • | • | • | • | • | • |

ដំណើរការរៀបចំផែនការប្រាស្រ័យទាក់ទងមានជំហានដូចខាងក្រោម :

### ជំហានទី ១ : គោលដៅ

កំណត់ពីគោលដៅប្រាស្រ័យទាក់ទងសំខាន់ៗពី ២ ទៅ ៣។ តើគួរផ្សព្វផ្សាយពីទស្សនវិស័យ/សកម្មភាព/ការ ផ្លាស់ប្តូរអ្វីខ្លះ ដើម្បីឱ្យគម្រោងទទួលបានជោគជ័យ? បង្កើនព័ត៌មានត្រឡប់របស់អ្នកពាក់ព័ន្ធអំពីការអនុវត្ត? ពង្រីកការគាំទ្ររបស់អ្នកពាក់ព័ន្ធសម្រាប់គម្រោង? ផ្លាស់ប្តូរឥរិយាបថរបស់អ្នកពាក់ព័ន្ធ (ឧ. បង្កើនការលាងដៃតាមរយៈការបង្កើនការយល់ដឹងអំពីការឆ្លង និងការបង្ការជំងឺដែលឆ្លងតាមទឹក)?

ឧទាហរណ៍ : ចែករំលែកព័ត៌មាន និងពិគ្រោះយោបល់ជាមួយនឹងសហគមន៏ដែលអាចទទួលរងផលប៉ះពាល់ដោយសារគម្រោង ។ ស្វែងរកទស្សនៈរបស់ពួកគេជាប្រចាំ ដើម្បីបញ្ចៀសមិនឱ្យមានផលប៉ះពាល់អវិជ្ជមានដោយចៃដន្យនៅក្នុងការអនុវត្ត ។

### ជំហានទី ២ : ហានិភ័យ/បញ្ហាប្រឈមសំខាន់ៗ

កំណត់ពីឧបសគ្គសំខាន់ៗ ដែលធ្វើឱ្យរាំងស្ទះចំពោះការសម្រេចគោលដៅ ។ ហានិភ័យអាចកើតឡើង ដោយសារការយល់ឃើញរបស់អ្នកពាក់ព័ន្ធ បរិយាកាសនៅក្នុងប្រទេស (ហានិភ័យសង្គម សេដ្ឋកិច្ច វប្បធម៌) ការអនុវត្តគម្រោង (សមត្ថភាពអនុវត្ត អភិបាលកិច្ចនៅខ្សោយ) និងបញ្ហា

ប្រឈមដទៃទៀត ដែលពាក់ព័ន្ធជាមួយនឹង គម្រោង (ឧ. ការរៀបចំការការពារផលប៉ះពាល់)។ តើសហគមន៍មានការព្រួយបារម្ភធំៗអ្វីខ្លះ? តើចាំបាច់ត្រូវគ្រប់ គ្រងការរំពឹងទុកអ្វីខ្លះ?

ឧទាហរណ៍ : សហគមន៍មានការព្រួយបារម្ភខ្លាចមានគេយកដីរបស់ពួកគេ។ ស្តាប់ការព្រួយបារម្ភរបស់ពួកគេ។ ធ្វើការវាយតម្លៃថាតើផលប៉ះពាល់នេះអាចកាត់បន្ថយឱ្យនៅជាអប្បបរមាដែរឬទេ និងធ្វើការផ្សព្វផ្សាយឱ្យបានច្បាស់ លាស់អំពីសិទ្ធិទទួលបានសំណង។

## ជំហានទី ៣ : អ្នកពាក់ព័ន្ធសំខាន់ៗ

តើអ្នកណាខ្លះ ដែលជាអ្នកពាក់ព័ន្ធសំខាន់ៗ ដែលត្រូវចូលរួម ដើម្បីសម្រេចគោលដៅសំខាន់ៗ និងកាត់បន្ថយ ហានិភ័យ? ជាធម្មតាអ្នកពាក់ព័ន្ធទាំងនេះ គឺជាអ្នកពាក់ព័ន្ធក្រៅរដ្ឋាភិបាលដែល ADB ឬរដ្ឋាភិបាលត្រូវធ្វើការប្រាស្រ័យទាក់ទងជាមួយ។

ឧទាហរណ៍ : អ្នកដឹកនាំសហគមន៍តាមបែបប្រពៃណីដែលត្រូវបានគេជឿទុកចិត្ត និងគោរព គឺជាក្រុមគោលដៅដ៏សំខាន់។ ប្រើប្រាស់ពួកគេ ដើម្បីផ្សព្វផ្សាយព័ត៌មានដល់សហគមន៍ទូទៅ និងប្រមូលគំនិតយោបល់របស់ពួកគេ។

## ជំហានទី ៤ : សារ

រៀបចំសារសម្រាប់ក្រុមអ្នកពាក់ព័ន្ធនីមួយៗ។ សារនានាគួរមានភាពសុក្រឹត សង្ខេបភាពច្បាស់លាស់ពាក់ព័ន្ធ និងសមស្របទៅតាមវប្បធម៌។ សូមធ្វើតេស្តលើសារជាមុន មុនពេលពេលធ្វើការផ្សព្វផ្សាយ។

ឧទាហរណ៍ : សារសំខាន់ ដែលសហគមន៍ត្រូវយល់គឺ គ្រប់គ្រួសារទាំងអស់ ដែលត្រូវចាកចេញពីដីរបស់ខ្លួន នឹងទទួលបានដីថ្មីដែលមានទំហំ/គុណភាពស្មើ ឬធំជាងនៅក្នុងសហគមន៍នេះ។

## ជំហានទី ៥ : មធ្យោបាយនៃការប្រាស្រ័យទាក់ទង (ច្រក/ភាសា/សកម្មភាព)

តើច្រកប្រាស្រ័យទាក់ទងអ្វី ដែលល្អប្រសើរជាងគេ ដើម្បីអាចធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកពាក់ព័ន្ធ សំខាន់ៗបាន (ប្រហែលជាចាំបាច់ត្រូវប្រើប្រាស់ច្រកផ្សេងៗពីគ្នា ដើម្បីធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកពាក់ព័ន្ធផ្សេងៗគ្នា)? តើចាំបាច់ត្រូវប្រើប្រាស់ភាសាអ្វី ដើម្បីធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកពាក់ព័ន្ធ ដែលបានកំណត់? តើមានសកម្មភាពអ្វីខ្លះ ដែលអាចផ្តល់ឱ្យអ្នកពាក់ព័ន្ធសំខាន់ៗ ជាពិសេសអ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង នូវព័ត៌មានដែលងាយស្រួលយល់ និងងាយស្រួលទទួល? តើសកម្មភាពអ្វីខ្លះ ដែលនឹងធានាថាអ្នកពាក់ព័ន្ធសំខាន់ៗអាច ផ្តល់នូវព័ត៌មានត្រឡប់ប្រកបដោយអត្ថន័យអំពីការរៀបចំផែនការ និងការអនុវត្តគម្រោង?

វិធីសាស្ត្រ ឬសកម្មភាពសម្រាប់ធ្វើការពិគ្រោះយោបល់ជាច្រើន ដែលមាននៅក្នុងតារាង ក្នុងឧបករណ៍ទី ១ ក៏ ផ្តល់លទ្ធភាពឱ្យមានការប្រាស្រ័យទាក់ទងផងដែរ។ សៀវភៅធនធានសម្រាប់ការប្រាស្រ័យទាក់ទងអំពីការអភិវឌ្ឍរបស់ធនាគារពិភពលោក រៀបរាប់ពីច្រកបន្ថែមមួយចំនួនដូចជា ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិច (ឧ. វិទ្យុ ទូរទស្សន៍)ប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព (ឧ. កាសែត ខិតប័ណ្ណ) ច្រកបែបប្រពៃណី (ឧ. ការសម្តែងសិល្បៈ ការនិទានរឿង) និងអ្នកដឹកនាំផ្នែកគំនិត។[៦]

ឧទាហរណ៍ : បុគ្គលិកគម្រោងនៅមូលដ្ឋាន ដែលមានចំណេះដឹងអំពីសហគមន៍ អាចធ្វើការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយនឹងអ្នកដឹកនាំបែបប្រពៃណី ។ បន្ទាប់មកអ្នកដឹកនាំទាំងនេះចែករំលែកព័ត៌មានជាមួយនឹងសមាជិក សហគមន៍របស់ពួកគេ តាមរយៈកិច្ចប្រជុំក្នុងភូមិ និងរចនាសម្ព័ន្ធដែលមាន (ឧ. ក្រុមកសិករ ក្រុមស្ត្រី ក្រុមអ្នកប្រើប្រាស់ទឹក) ។

## ជំហានទី ៧ : ក្របខ័ណ្ឌពេលវេលា

តើសកម្មភាពនីមួយៗនឹងត្រូវអនុវត្តនៅពេលណា ក្នុងរយៈពេលប៉ុន្មាន និងញឹកញាប់កម្រិតណា?

ឧទាហរណ៍ បន្ទាប់ពីការជួបទាក់ទងដំបូង រៀបចំកាលវិភាគសម្រាប់ការចុះតាមដានបន្តរៀងរាល់ត្រីមាស ដើម្បីចែករំលែកព័ត៌មាន និងទទួលបានព័ត៌មានត្រឡប់ ។

## ជំហានទី ៨ : ការទទួលខុសត្រូវ

តើអ្នកណាជាអ្នកទទួលខុសត្រូវដឹកនាំ និងអនុវត្តសកម្មភាពនីមួយៗ? តើភាគីដែលបានកំណត់មានសមត្ថភាព ដើម្បីអនុវត្តយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងនេះប្រកបដោយប្រសិទ្ធភាពដែរឬទេ?

ឧទាហរណ៍ : ការទទួលខុសត្រូវលើសកម្មភាពទាំងនេះ គឺជាការទទួលខុសត្រូវរបស់សមាជិកមូលដ្ឋានរបស់ក្រុមអនុវត្តគម្រោង ។

## ជំហានទី ៩ : ធនធានដែលចាំបាច់

កំណត់ពីធនធានមនុស្ស និងធនធានហិរញ្ញវត្ថុដែលចាំបាច់សម្រាប់ការអនុវត្ត ។

## គំរូយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ

ខាងក្រោមនេះ គឺជាយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ សម្រាប់គម្រោងធម្មតាណាមួយរបស់ ADB :

គំរូយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ :

| គោលដៅ | ហានិភ័យ/ បញ្ហាប្រឈមសំខាន់ៗ | ក្រុមគោលដៅ/ អ្នកពាក់ព័ន្ធសំខាន់ៗ | សារ (ព័ត៌មានដែលត្រូវផ្សព្វផ្សាយ) | មធ្យោបាយធ្វើការប្រាស្រ័យទាក់ទង (ច្រក / ភាសា / សកម្មភាព) | ក្របខ័ណ្ឌពេលវេលា/ ភាពញឹកញាប់ | ការទទួលខុសត្រូវ | ធនធាន (មនុស្ស ហិរញ្ញវត្ថុ) |
|---|---|---|---|---|---|---|---|
| ធានាឱ្យមានលំហូរជាទៀងទាត់នូវព័ត៌មានគម្រោងដែលអាចជឿទុកចិត្តបាន (ឯកទិស) | • ការជឿទុកចិត្តលើប្រភពព័ត៌មាន<br>• ភាសា/វប្បធម៌<br>• អក្ខរភាព<br>• គ្រប់គ្រងការរំពឹងទុក | • អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង<br>• សមាជិកសហគមន៍<br>• អង្គការសង្គមស៊ីវិលដូចជាអង្គការក្រៅរដ្ឋាភិបាល ក្រុមស្ត្រី ។ល។<br>• វិស័យឯកជនក្នុងមូលដ្ឋាន<br>• រដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន<br>• ប្រព័ន្ធផ្សព្វផ្សាយនៅថ្នាក់មូលដ្ឋាន | • ប្រយោជន៍សំខាន់ៗរបស់គម្រោង<br>• ផលរយៈពេលវែងសំខាន់ៗ (ល្អ និងអាក្រក់)<br>• ដំណើរការនៃការអនុវត្តគម្រោង<br>• សិទ្ធិដែលអាចទទួលបាន<br>• មធ្យោបាយផ្តល់ព័ត៌មានអំពីការព្រួយបារម្ភ/ បញ្ហា<br><br>*រៀបចំឡើងសម្រាប់អ្នកពាក់ព័ន្ធផ្សេងៗពីគ្នា* | • ក្រុមតូច<br>• វេទិកាសហគមន៍<br>• ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ (វិទ្យុ កាសែត គេហទំព័រ ។ល។)<br>• អ្នកដឹកនាំនៅមូលដ្ឋាន<br>• បណ្តាញសាសនា<br>• សម្ភារៈបោះពុម្ព (ខិតប័ណ្ណ ។ល។)<br>• សិក្ខាសាលាព័ត៌មាន/បង្កើនការយល់ដឹង<br>• ព្រឹត្តិការណ៍វប្បធម៌/សាសនា<br><br>*ផ្តោតលើច្រក/ សកម្មភាពជាក់លាក់ដើម្បីអាចផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធជាក់លាក់* | • ចាប់ពីដើមគម្រោង<br>• មានការរៀបចំព្រឹត្តិការណ៍ជាទៀងទាត់ដើម្បីធ្វើបច្ចុប្បន្នកម្មអំពីការវិវឌ្ឍនានា (រៀងរាល់ ២ ខែម្តង) | • ក្រុមអនុវត្តគម្រោង<br>• អ្នកគ្រប់គ្រងអនុគម្រោង | • ការចំណាយសម្រាប់រៀបចំខ្លឹមសារ និងធ្វើការបោះពុម្ពផ្សាយ<br>• ការចំណាយលើមន្ត្រីសម្របសម្រួលសហគមន៍ និងអ្នកគ្រប់គ្រងការប្រាស្រ័យទាក់ទងរបស់អនុគម្រោង<br>• ចំណាយភ័ស្តុភារ<br>• ចំណាយលើការរៀបចំព្រឹត្តិការណ៍ |

## ឧបករណ៍ទី ៦ : ការធ្វើការងារជាមួយនឹងអង្គការសង្គមស៊ីវិល

អង្គការសង្គមស៊ីវិល មានគោលបំណងដូចគ្នាទៅនឹងគោលបំណងរបស់ ADB និងប្រទេសកំពុងអភិវឌ្ឍជាសមាជិក ដើម្បីកាត់បន្ថយភាពក្រីក្រ។ ចំណេះដឹង និងជំនាញរបស់ពួកគេ ធ្វើឱ្យពួកគេក្លាយជាដៃគូដែលមានតម្លៃមិនអាចកាត់ថ្លៃបាន នៅក្នុងគម្រោងអភិវឌ្ឍន៍នានា។

## សេចក្តីផ្តើម

អង្គការសង្គមស៊ីវិល មានទំហំការងារ និងមុខងារផ្សេងៗពីគ្នា ប៉ុន្តែអាចត្រូវបានគេពិពណ៌នាដោយទូលំ ទូលាយថាជាអង្គការ ដែលមានលក្ខណៈផ្សេងគ្នាពីរដ្ឋាភិបាល និងសង្គមស៊ីវិល ដែលបំពេញការងារជុំវិញប្រយោជន៍ គោលបំណង និងគុណតម្លៃរួម។ តារាងខាងក្រោមនេះបង្ហាញពីប្រភេទអង្គការសង្គមស៊ីវិលសំខាន់ៗ ៖

| ប្រភេទ | និយមន័យ |
|---|---|
| **អង្គការក្រៅរដ្ឋាភិបាលជាតិ / អន្តរជាតិ (LNGOs/INGOs)** | អង្គការជំនាញ មិនរកប្រាក់ចំណេញ ដែលបំពេញនាទីជាអន្តរការីទាំងនេះ ផ្តល់ ឬតស៊ូមតិឱ្យមានការផ្តល់សេវា ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម សិទ្ធិមនុស្ស សុខមាលភាពសាធារណៈ ឬការជួយសង្គ្រោះបន្ទាន់។ ឈ្មោះរបស់អង្គការទាំងនេះរួមមានអង្គការមហាជន (នៅក្នុងសាធារណរដ្ឋប្រជាមានិតចិន និងអតីតសហភាពសូវៀត) និងអង្គការស្ម័គ្រចិត្តឯកជន។ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិគឺជាអង្គការអន្តរជាតិដែលមិនត្រូវបានបង្កើតឡើងដោយអនុសញ្ញាអន្តរជាតិ។ជាធម្មតាអង្គការទាំងនេះមានការិយាល័យកណ្តាល នៅក្នុងប្រទេស អភិវឌ្ឍ។[ក]<br>ឧទាហរណ៍ : សមាគមកាកបាទក្រហម សហព័ន្ធស្ត្រីជាតិ (LNGO) WWF អង្គការអុកហ្វាមអន្តរជាតិ(INGO) |
| **អង្គការដែលមានមូលដ្ឋាននៅសហគមន៍ (CBOs)** | អង្គការនៅមូលដ្ឋានទាំងនេះ ខិតខំដោះស្រាយការព្រួយបារម្ភនៃសមាជិករបស់ពួកគេដោយផ្ទាល់ និងលើកកម្ពស់ សុខមាលភាពនៃសមាជិករបស់ពួកគេ។ មុខងាររបស់អង្គការទាំងនេះ រួមមានសកម្មភាព ដែលពាក់ព័ន្ធនឹងបញ្ហា សេដ្ឋកិច្ច សង្គម សាសនា និងការកែកម្សាន្ត។<br>ឧទាហរណ៍ : ក្រុមអ្នកប្រើប្រាស់ទឹក សមាគមមីក្រូហិរញ្ញវត្ថុ |
| **ក្រុមសង្គមស៊ីវិលក្រៅផ្លូវការ ឬ មិនរៀបរយ** | ក្រុមសង្គមស៊ីវិលទាំងនេះលេចឡើង ជាការឆ្លើយតបពីក្រោមឡើងលើ ចំពោះបញ្ហា ឬតម្រូវការណាមួយ។ ពួកគេមិនបានចុះបញ្ជីកាស្របច្បាប់នោះឡើយ ដូច្នេះពួកគេមិនស្ថិតនៅក្រោមយន្តការនិយ័តកម្មណាមួយឡើយ។<br>ឧទាហរណ៍ : បណ្តាញសហគមន៍ក្រៅផ្លូវការ |
| **មូលនិធិ** | ស្ថាប័នក្រៅរដ្ឋាភិបាលទាំងនេះ អាចជាសាជីវកម្មមិនរកប្រាក់ចំណេញ ឬអង្គការមនុស្សធម៌ ផ្តល់នូវជំនួយឥតសំណង ដល់អង្គការដែលមិនពាក់ព័ន្ធ ស្ថាប័ន ឬបុគ្គលនានា សម្រាប់គោលបំណងវិទ្យាសាស្ត្រ អប់រំ វប្បធម៌ សាសនា ឬ គោលបំណងមនុស្សធម៌ដទៃទៀត។<br>**ឧទាហរណ៍ : មូលនិធិហ្វដ មូលនិធិ Aga Khan** |

[ក] UNESCO definition in ADB. 2008. *Civil Society Organization Sourcebook: A Staff Guide to Cooperation with Civil Society Organizations.* Manila.

សម្គាល់ : សូមមើលសៀវភៅធនធានសម្រាប់អង្គការសង្គមស៊ីវិលរបស់ ADB សម្រាប់ព័ត៌មានលំអិតបន្ថែមទៀត។

| ប្រភេទ | និយមន័យ |
|---|---|
| សមាគមវិជ្ជាជីវៈ | អង្គការទាំងនេះតំណាងឱ្យប្រយោជន៍នៃសមាជិករបស់ខ្លួន ដែលបំពេញការងារ ឬវិជ្ជាជីវៈណាមួយ។ ពួកគេក៏ អាចអនុវត្តស្តង់ដាចំពោះវិជ្ជាជីវៈនៃសមាជិករបស់ពួកគេផងដែរ។<br>ឧទាហរណ៍ : សមាគមវិស្វករ សភាពាណិជ្ជកម្ម |
| វិទ្យាស្ថានស្រាវជ្រាវឯករាជ្យ | អង្គការមិនរកប្រាក់ចំណេញឯករាជ្យទាំងនេះ ធ្វើការស្រាវជ្រាវ និងវិភាគ និងផ្សព្វផ្សាយពីលទ្ធផលរកឃើញ និងអនុសាសន៍របស់ពួកគេ។<br>ឧទាហរណ៍ : វិទ្យាស្ថានស្រាវជ្រាវអំពីសាធារណការ |
| សហជីពការងារ | សមាគមកម្មករនិយោជិត ដែលត្រូវបានរៀបចំឡើងជាផ្លូវការទាំងនេះ ធ្វើការងាររួមគ្នា ដើម្បីលើកកម្ពស់ទស្សនៈ សមូហភាពរបស់ពួកគេលើបញ្ហាដែលពាក់ព័ន្ធនឹងការងារ ហើយជារឿយៗ ពួកគេត្រូវបានបង្កើតឡើងទៅ តាមឧស្សាហកម្ម ឬការងារ។ ជាញឹកញាយ សហជីពទាំងនេះភ្ជាប់ទំនាក់ទំនងខ្លួនឯងទៅនឹងសហព័ន្ធ សមាជ និង បណ្តាញនានា។<br>ឧទាហរណ៍ : សមាជសហជីពរបស់ប្រទេសហ្វីលីពីន |
| សម្ព័ន្ធភាព/បណ្តាញអង្គការសង្គមស៊ីវិល/អង្គការសមាជិកភាព | អង្គការសង្គមស៊ីវិលទាំងនេះ ធ្វើការងាររួមគ្នា ទៅតាមទីតាំងភូមិសាស្ត្រ សមាជិកភាព គោលដៅ ឬសកម្មភាព រួមគ្នា។<br>ឧទាហរណ៍ : វេទិកាអង្គការក្រៅរដ្ឋាភិបាលស្តីពីកម្ពុជា |

ឧបករណ៍នេះបង្ហាញពីរបៀបកំណត់ និងធ្វើការវាយតម្លៃសមត្ថភាពរបស់អង្គការសង្គមស៊ីវិល និងបង្ហាញឱ្យឃើញពីតួនាទីផ្សេងៗគ្នារបស់ពួកគេ។

## តើអង្គការសង្គមស៊ីវិលអាចបន្ថែមគុណតម្លៃនៅពេលណា?

អង្គការសង្គមស៊ីវិលផ្សេងៗគ្នា បំពេញមុខងារផ្សេងៗពីគ្នានៅក្នុងប្រតិបត្តិការរបស់ ADB និងរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក។ តំណាងអង្គការសង្គមស៊ីវិលដែលមានឯកទេស និងជំនាញភាសាក្នុងមូលដ្ឋាន និងមានឯករាជ្យភាពពីរដ្ឋាភិបាលមានតួនាទីយ៉ាងសំខាន់។



ការបណ្តុះបណ្តាលអំពីការចូលរួមជាមួយនឹងមន្ត្រីរដ្ឋាភិបាលនៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ខែ មីនា ឆ្នាំ ២០១១

- **ការពិគ្រោះយោបល់ និងការផ្តល់ប្រឹក្សា :** អង្គការសង្គមស៊ីវិលមានការយល់ដឹងស៊ីជម្រៅអំពីបញ្ហាអភិវឌ្ឍន៍នៅមូលដ្ឋាន និងមានបទពិសោធន៍ដោយផ្ទាល់ជាមួយនឹងបញ្ហាជាក់ស្តែង។ អង្គការទាំងនេះផ្តល់នូវគំនិតយោបល់ដ៏មានតម្លៃនៅក្នុងការពិគ្រោះយោបល់អំពីការរៀបចំ និងការអនុវត្តគម្រោង។
  - អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ (INGOs) មានបទពិសោធន៍ និងការអនុវត្តល្អជាអន្តរជាតិ ខណៈពេលដែលអង្គការក្រៅរដ្ឋាភិបាលជាតិ និងអង្គការតាមសហគមន៍ ផ្តល់នូវទស្សនវិស័យក្នុងមូលដ្ឋានជាក់ស្តែង។
  - សមាគមវិជ្ជាជីវៈផ្តល់នូវជំនាញបច្ចេកទេស ទៅតាមវិស័យរបស់ពួកគេ។

## សង្គមស៊ីវិលនៅក្នុងសាធារណរដ្ឋ Kyrgyz ផ្តល់នូវជំហ្វឹងនានាអំពីការអប់រំកុមារ ដែលមានតម្រូវការពិសេស

នៅក្នុងសាធារណរដ្ឋ Kyrgyz, ADB កំពុងធ្វើការងារជាមួយនឹងអង្គការសង្គមស៊ីវិលជាច្រើន ដើម្បីសាកល្បងនូវគោលវិធីរួមមួយ ដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព សម្រាប់កុមារដែលមានតម្រូវការពិសេស។ សមាគមមាតាបិតាកុមារពិការបំពេញតួនាទីជាទីប្រឹក្សា ផ្តល់នូវជំនាញឯកទេសសម្រាប់ឆ្លើយតបទៅនឹងតម្រូវការរបស់កុមារពិការ។ អង្គការចំនួន ៤ ដែលមានមូលដ្ឋានក្នុងសហគមន៍ជនបទ តែងធ្វើការពិគ្រោះយោបល់ជាទៀងទាត់ជាមួយនឹងមាតាបិតារបស់កុមារពិការ តាមរយៈកិច្ចពិភាក្សាតុមូល និងកិច្ចប្រជុំនានា។

ប្រភព : ADB. 2007. *JFPR Grant to Kyrgyz Republic Improving Access to Quality Basic Education for Children with Special Needs.* Manila.

- **ការភ្ជាប់ទំនាក់ទំនង ADB រដ្ឋាភិបាល និងសហគមន៍ :** នៅពេលដែលទំនាក់ទំនងមានកម្រិតខ្សោយ អង្គការសង្គមស៊ីវិលអាចកសាងស្ពានរវាងប្រជាពលរដ្ឋ និងសហគមន៍ជាមួយនឹងរដ្ឋាភិបាល ស្ថាប័នដែលធ្វើការងារអភិវឌ្ឍន៍ និងអ្នកផ្តល់ជំនួយ។
  - អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិធំៗ សហជីព និងអង្គការសមាជិកភាពអាចភ្ជាប់ទំនាក់ទំនងក្រុមគោលដៅរបស់ពួកគេ ជាមួយនឹងរដ្ឋាភិបាល ហើយអង្គការជាច្រើនមានទំនាក់ទំនងទាំងនេះរួចទៅហើយ។ អង្គការក្រៅរដ្ឋាភិបាលតូចៗ និងអង្គការតាមសហគមន៍មានលទ្ធភាពច្រើន ក្នុងការបង្កើតទំនាក់ទំនងនៅថ្នាក់មូលដ្ឋាន និងថ្នាក់តំបន់។
- **ការកៀងគរសហគមន៍ :** អង្គការសង្គមស៊ីវិលមានបទពិសោធន៍ជាច្រើនអំពីយុទ្ធសាស្ត្រ ដើម្បីជួយកៀងគរសហគមន៍មូលដ្ឋានដើម្បីសម្រេចនូវលទ្ធផលនៃការងារអភិវឌ្ឍន៍សំខាន់ៗ។
  - អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលជាតិជាច្រើន មានបទពិសោធន៍យ៉ាងច្រើន ផ្នែកការ កៀងគរសហគមន៍។ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយចំនួនដឹងពីយុទ្ធសាស្ត្រចុងក្រោយ ដែលត្រូវបានប្រើប្រាស់ជាអន្តរជាតិ ខណៈពេលដែលអង្គការក្រៅរដ្ឋាភិបាលជាតិយល់ច្រើនពីវប្បធម៌ក្នុងស្រុក។ គេអាចជួលអង្គការទាំងពីរ ប្រភេទនេះឱ្យបង្កើតអង្គការតាមសហគមន៍បាន។
  - សហជីពក៏អាចកៀងគរសហគមន៍បានដែរ ជាពិសេសប្រសិនបើសហជីពទាំងនោះមានចំនួនសមាជិកច្រើន ហើយតំណាងឱ្យវិស័យសំខាន់ណាមួយនៅក្នុងកម្លាំងពលកម្ម។

## អង្គការក្រៅរដ្ឋាភិបាល នៅក្នុងប្រទេសបង់ក្លាដេស ជួយកៀងគរសហគមន៍

នៅក្នុងប្រទេសបង់ក្លាដេស ADB បានចាប់ដៃគូជាមួយនឹងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនជាតិដើមភាគតិច (CIPD) អង្គការផ្តល់ជំនួយដល់ជនជាតិដើម (Alo) និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដទៃទៀត ដើម្បីកៀងគរសហគមន៍ជនបទ ក្នុងការកំណត់ និងអនុវត្តគម្រោងតូចៗ (ឧ. អភិវឌ្ឍន៍សហគមន៍ធារាសាស្ត្រ) ប្រតិបត្តិការមីក្រូឥណទាន និងការបណ្តុះបណ្តាលអ្នកទទួល ផលនៅជ្រលងភ្នំ Chittagong (ChT) ។

ប្រភព : ADB. 2000. *Loan to Bangladesh for the Chittagong Hill Tracts Rural Development Project.* Manila.

- **ការច្នៃប្រឌិតថ្មី :** នៅពេលដែលគេត្រូវការភាពបត់បែនភាពឆ្លើយតប និងភាពច្នៃប្រឌិតថ្មី អង្គការសង្គមស៊ីវិល តែងតែប្រតិកម្មយ៉ាងរហ័សទៅនឹងការផ្លាស់ប្តូរនៃកាលៈទេសៈ ហើយតែងមានបំណងពិសោធន៍សាកល្បងគោលវិធីថ្មីៗ ។
  - អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ បំពេញការងារយ៉ាងមានប្រសិទ្ធភាព នៅក្នុងកម្មវិធីសាកល្បង ដើម្បីបង្កើនការចូលរួម ។
  - វិទ្យាស្ថានស្រាវជ្រាវមួយចំនួនមានមោទនភាពចំពោះខ្លួនឯង ដែលបានបង្កើតនូវដំណោះស្រាយថ្មីៗ ។
- **ការផ្តល់សេវា :** អង្គការសង្គមស៊ីវិល អាចជាអ្នកផ្តល់សេវា នៅកម្រិតផ្សេងៗពីគ្នា ។ ជារឿយៗ ពួកគេបំពេញគម្លាតនៅពេលដែលពុំមានសេវារបស់រដ្ឋាភិបាល ហើយពេលខ្លះ រដ្ឋាភិបាលជួលពួកគេឱ្យបំពេញការងារ ។
  - អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ អាចធ្វើជាអ្នកផ្តល់សេវានៅថ្នាក់តំបន់ និងនៅថ្នាក់ជាតិ (សេវាសង្គមជា មូលដ្ឋាន) ។
  - អង្គការតាមសហគមន៍ចូលរួមបំពេញការងារនៅកម្រិតសហគមន៍ ដូចជាការគ្រប់គ្រងការផ្គត់ផ្គង់ទឹក ក្រុមមីក្រូឥណទាន និងសេវានៅកម្រិតសហគមន៍ដទៃទៀត ។

## អង្គការក្រៅរដ្ឋាភិបាល នៅក្នុងកម្មវិធីសាកល្បងផ្តល់សេវាសង្គមនៅប៉ាស៊ីហ្វិច

ដើម្បីជួយកាត់បន្ថយផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចជាសកល និងគ្រោះមហន្តរាយធម្មជាតិ ដែលបានកើតឡើងកាលពីពេលថ្មីៗ នេះនៅតំបន់ប៉ាស៊ីហ្វិច អង្គការក្រៅរដ្ឋាភិបាល និងក្រុមវិហារកាតូលិចកំពុងអនុវត្តនូវកម្មវិធីសាកល្បងផ្តល់សេវាសង្គមជា ច្រើន ដោយផ្តោតគោលដៅលើក្រុមដែលងាយរងគ្រោះ ដូចជាយុវជនដែលគ្មានការងារធ្វើ និងស្ត្រីជាដើម ។

ប្រភព : ADB. 2009. *Grant to Tonga for the Economic Support Program.* Manila; ADB. 2010. *Grant for Social Protection of the Vulnerable in the Pacific.* Manila.

- **ការប៉ាន់ប្រមាណ ការពិនិត្យតាមដាន និងការវាយតម្លៃ :** អង្គការសង្គមស៊ីវិលមួយចំនួនអាចធ្វើការប៉ាន់ប្រមាណដោយមានការចូលរួមសម្រាប់ការរៀបចំគម្រោង និងការពិនិត្យតាមដាន និងវាយតម្លៃដោយឯករាជ្យ ។ ប៉ុន្តែសូមកុំប្រើប្រាស់អង្គការតែមួយ ជាដៃគូអនុវត្តផង និងជាអ្នកវាយតម្លៃឯករាជ្យផង ។ អ្នកពិនិត្យតាមដានមកពីសង្គមស៊ីវិលបំពេញ តួនាទីយ៉ាងសំខាន់ នៅក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ (សូមមើលផ្នែករបស់មគ្គុទេសក៍នេះ ដែលនិយាយអំពី អភិបាលកិច្ចល្អ និងការអភិវឌ្ឍសមត្ថភាពទំព័រទី ៧១) ។
  - អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងវិទ្យាស្ថានស្រាវជ្រាវមួយចំនួន មានឯកទេសផ្នែកបច្ចេកទេសស្រាវជ្រាវតាមបែបរហ័ស ហើយមានបទពិសោធន៍ជាច្រើន នៅក្នុងការអនុវត្តការប៉ាន់ប្រមាណការពិនិត្យតាមដាន និងការវាយតម្លៃ ។

### អង្គការសង្គមស៊ីវិលនៅក្នុងសាធារណរដ្ឋ Kyrgyz ផ្តល់ការគាំទ្រដល់ការផ្តល់សេវា និងការពិនិត្យតាមដាននៅកម្រិតសហគមន៍

ADB កំពុងធ្វើការងារជាមួយនឹងស្ថាប័នស្វ័យអភិបាលកិច្ច និងអង្គការតាមសហគមន៍ ដើម្បីផ្គត់ផ្គង់ទឹក និងផ្តល់សេវាអនាម័យ ដ៏មានសារៈសំខាន់ នៅក្នុងភូមិចំនួន ២០០ ដែលបម្រើប្រជាពលរដ្ឋចំនួន ៣០០០០០ នាក់ នៅតាមតំបន់ជនបទនានារបស់ សាធារណរដ្ឋ Kyrgyz ។ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយដែលមានឈ្មោះថា Taza Tabigat កំពុងធ្វើការពិនិត្យតាមដានដោយឯករាជ្យ ។

ប្រភព : ADB. 2008. *Grant to the Kyrgyz Republic for Community-Based Infrastructure Service Sector Project.* Manila.

## ការកំណត់រកអង្គការសង្គមស៊ីវិល

ការវិភាគលម្អិតល្អន់លើអ្នកពាក់ព័ន្ធ គួរអាចកំណត់ពីអង្គការសង្គមស៊ីវិល ដែលចាប់អារម្មណ៍លើសកម្មភាពណាមួយ និងផ្តល់លទ្ធភាពឱ្យអង្គការទាំងនោះចូលរួមនៅក្នុងកិច្ចពិគ្រោះយោបល់ នៅក្នុងពេលរៀបចំគម្រោង និងនៅពេលបង្កើតផែនការស្តីពីការចូលរួម ។ នៅពេលដែលតួនាទីរបស់អង្គការសង្គមស៊ីវិលត្រូវបានកំណត់រួចហើយ ប្រើប្រាស់ ច្រកខាងក្រោមបញ្ចូលគ្នា ដើម្បីកំណត់រកដៃគូ ដែលមានសក្តានុពលផ្សេងទៀត :

១. **ស្ថាប័នដែលផ្តល់ការទទួលស្គាល់ :** ស្ថាប័នទាំងនេះមានវត្តមានជាអន្តរជាតិ និងនៅតាមប្រទេសមួយចំនួន ហើយអាចផ្តល់នូវការទទួលស្គាល់ដោយខ្លួនឯង ឬដោយឯករាជ្យ ។ ឧទាហរណ៍ នៅក្នុងប្រទេសកម្ពុជា គណៈកម្មាធិការ សហការដើម្បីកម្ពុជាបានបង្កើតនូវប្រព័ន្ធបញ្ជាក់ដោយស្ម័គ្រចិត្តមួយសម្រាប់អង្គការក្រៅរដ្ឋាភិបាល ។ នៅក្នុងប្រទេស ហ្វីលីពីន ក្រុមប្រឹក្សាផ្តល់ការបញ្ជាក់ដល់អង្គការក្រៅរដ្ឋាភិបាលរបស់ប្រទេសហ្វីលីពីន ផ្តល់វិញ្ញាបនបត្របញ្ជាក់ដល់ អង្គការសង្គមស៊ីវិលទាំងឡាយ ដែលអាចបំពេញបានទៅតាមលក្ខណៈវិនិច្ឆ័យអប្បបរមាផ្នែកការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យភាព ។ នៅក្នុងប្រទេសប៉ាគីស្ថាន មជ្ឈមណ្ឌលស្នេហាមនុស្សជាតិប៉ាគីស្ថាន មានបញ្ជីអង្គការមិនរកប្រាក់ចំណេញ ដែលអាចបំពេញបានទៅតាមស្តង់ដាផ្នែកអភិបាលកិច្ច ការអនុវត្តកម្មវិធី និងការគ្រប់គ្រងហិរញ្ញវត្ថុ ។[៤៧]

២. **អង្គការសមាជិកភាព :** ប្រទេសជាច្រើនមានអង្គការសមាជិកភាព ដែលមានចំណេះដឹងស៊ីជម្រៅអំពី សមត្ថភាពនៃសមាជិករបស់ពួកគេ ។ ក៏អាចមានផងដែរនូវបណ្តាញ ឬក្រុមការងារជាក់លាក់តាមវិស័យ (ឧ. យេនឌ័រមេរោគអេដស៍ជាដើម) ។

៣. **ផែនទី និងរបាយការណ៍របស់សង្គមស៊ីវិល :** នៅតាមប្រទេសជាច្រើន មានការបង្កើតផែនទីបង្ហាញពីសង្គមស៊ីវិល ឬការាយការណ៍អំពីស្ថានភាពរបស់វិស័យនេះ ។ គេអាចទទួលបានព័ត៌មានទាំងនេះលើគេហទំព័រ ។

៤. **អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ :** អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិជាច្រើន ធ្វើការងារជាមួយនឹងអង្គការ សង្គមស៊ីវិលជាដៃគូនៅថ្នាក់ជាតិ តំបន់ និងមូលដ្ឋានហើយមានរក្សាទុកព័ត៌មានអំពីអង្គការក្នុងស្រុកដែលអាចជឿទុកចិត្តបាន ។ សន្ទស្សន៍សង្គមស៊ីវិលរបស់ CIVICUS ធ្វើការវាយតម្លៃលើសង្គមស៊ីវិលនៅក្នុងប្រទេសណាមួយ ។ គេអាចទទួលបានរបាយការណ៍ទាំងនេះ តាមរយៈគេហទំព័ររបស់អង្គការទាំងនេះ ។[៤៨]

៥. **បុគ្គលិក និងដៃគូរបស់ ADB :** និវាសនដ្ឋានប្រចាំប្រទេស តែងមានចំណេះដឹងអំពីអង្គការសង្គមស៊ីវិល ដែលធ្វើការងារក្នុងប្រទេស ជាពិសេស មានឯកសារបង្ហាញពីប្រវត្តិរបស់អង្គការ ដែលធ្លាប់ចូលរួមក្នុងគម្រោងមុនៗ។ និវាសនដ្ឋានមួយចំនួន មានបញ្ជីដៃគូជាសក្តានុពល។ អ្នកឯកទេសនៅការិយាល័យកណ្តាល ក៏អាចដឹងពីអង្គការសង្គម ស៊ីវិលដែលអាចជឿទុកចិត្តបានដែលធ្វើការងារក្នុងជំនាញរបស់ពួកគេ ហើយសហការីរបស់ពួកគេ ដែលធ្វើការងារ ឱ្យដៃគូអភិវឌ្ឍន៍ដទៃទៀត ជាពិសេស អ្នកផ្តល់ជំនួយទ្វេភាគី ក៏អាចមានព័ត៌មាននេះផងដែរ។ មជ្ឈមណ្ឌលអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល (NGOC) ក៏បានបង្កើតនូវឯកសារសង្ខេបមួយអំពីសង្គមស៊ីវិលនៅក្នុងប្រទេសនិងរក្សា NGOlink ដែលមានដាក់បញ្ចូលមូលដ្ឋានទិន្នន័យអំពីប្រវត្តិរបស់អង្គការក្រៅរដ្ឋាភិបាល។ មេរៀនដែលទទួលបានពីគោលវិធីតាមបែបចូលរួមក៏អាចរកបាននៅក្នុងមូលដ្ឋានទិន្នន័យនៃប្រព័ន្ធព័ត៌មានស្តីពីការវាយតម្លៃរបស់ IED ផងដែរ។

៦. **ប្រភពរដ្ឋាភិបាល :** បុគ្គលិកមួយចំនួនដឹងពីកេរ្តិ៍ឈ្មោះ និងសមត្ថភាពរបស់អង្គការសង្គមស៊ីវិល ដែលធ្វើការងារក្នុងវិស័យផ្សេងៗ។

## ការវាយតម្លៃអង្គការសង្គមស៊ីវិល

សំណួរខាងក្រោមនេះ គាំទ្រដល់ការវាយតម្លៃសមត្ថភាពរបស់អង្គការសង្គមស៊ីវិល ក្នុងការសហការ ឬធ្វើ ការងារក្នុងភាពជាដៃគូជាមួយនឹង ADB ឬប្រទេសកំពុងអភិវឌ្ឍ។ សំណួរទាំងនេះ ផ្តល់នូវការណែនាំ ជាជាងជាបញ្ជី ត្រួតពិនិត្យ។ នៅក្នុងស្ថានភាពដែលសង្គមស៊ីវិលមិនសូវមានការអភិវឌ្ឍមានអង្គការមួយចំនួនតូចតែប៉ុណ្ណោះ ដែលអាចបំពេញទៅតាមលក្ខណៈវិនិច្ឆ័យទាំងនេះបាន។ ចាំបាច់ត្រូវមានការវិនិច្ឆ័យដើម្បីធ្វើការសម្រេចចិត្តថាតើត្រូវមានករណី លើកលែងអ្វីខ្លះ និងថាតើចាំបាច់ត្រូវមានការកសាងសមត្ថភាពដែរឬទេ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យនេះ។ លើសពីនេះលក្ខណៈវិនិច្ឆ័យទាំងនេះមិនគួរនាំឱ្យមានការដកចេញក្រុមដែលក្រីក្រ និងមានឱកាសតិចតួចជាងគេ ឬក្រុមដែលមានការរៀបចំមិនសូវរៀបរយនោះទេ។

ចាំបាច់ត្រូវមានការស្រាវជ្រាវបន្ថែមទៀត ដើម្បីធ្វើការវាយតម្លៃពីសមត្ថភាពរបស់អង្គការណាមួយ ដើម្បី បំពេញតួនាទីជាក់លាក់អ្វីមួយ ឧ. ការស្រាវជ្រាវ ឬការវាយតម្លៃជាដើម។[៤៥] មានប្រភពព័ត៌មានជាច្រើន ដូចជាការស្វែងរកតាមអ៊ីនធឺណិត (គេហទំព័ររបស់អង្គការសង្គមស៊ីវិល។ ធនធានវាយតម្លៃសមត្ថភាពបែបស៊ីជម្រៅបន្ថែម ទៀត អាចរកបាន នៅក្នុងបញ្ជីធនធាន។

### សំណួរណែនាំអំពីការវាយតម្លៃសមត្ថភាពអង្គការសង្គមស៊ីវិល សម្រាប់សហការ ឬចាប់ដៃគូជាមួយ

- **ស្ថានភាពផ្លូវច្បាប់ :** តើអង្គការសង្គមស៊ីវិលនេះត្រូវបានបង្កើតឡើង និងចុះបញ្ជិការស្របច្បាប់ដែរឬទេ?
- **ភាពអាចជឿទុកចិត្តបាន :** តើអង្គការសង្គមស៊ីវិលនេះត្រូវបានគេទទួលស្គាល់ (តាមគម្រោងក្នុងប្រទេស) មានឈ្មោះក្នុងបញ្ជី ឈ្មោះអង្គការសង្គមស៊ីវិល និងមានតម្លាភាពអំពីប្រភពថវិកា និងសកម្មភាពរបស់ខ្លួនដែរឬទេ?
- **បេសកកម្ម និងអភិបាលកិច្ច :** តើអង្គការសង្គមស៊ីវិលនេះមានភាពច្បាស់លាស់អំពីចក្ខុវិស័យ គោលដៅ និងតួនាទីរបស់ខ្លួនដែរឬ ទេ? តើអង្គការនេះមានតម្លាភាពអំពីរចនាសម្ព័ន្ធចាត់តាំង និងអភិបាលកិច្ចរបស់ខ្លួនដែរឬទេ?
- **សមាជិកភាព និងការគាំទ្រ :** តើសមាជិករបស់អង្គការសង្គមស៊ីវិលនេះទទួលបានព័ត៌មាន និងផ្តល់ការគាំទ្រដែរឬទេ? តើអង្គការ នេះគឺជាសមាជិករបស់ក្រុមតាមវិស័យ ឬអង្គការសមាជិកភាពណាមួយដែរឬទេ? តើអង្គការនេះមានភាពជាដៃគូជាមួយនឹងអង្គការ អភិវឌ្ឍន៍ល្បីឈ្មោះដទៃទៀតដែរឬទេ?
- **សមត្ថភាពបច្ចេកទេស :** តើអង្គការសង្គមស៊ីវិលនេះប្រើប្រាស់គោលវិធីដែលមានប្រសិទ្ធភាព ដើម្បីផ្តល់សេវាដល់គោលដៅរបស់ ខ្លួន និងមានវត្តមានប្រកបដោយប្រសិទ្ធភាព នៅនឹងមូលដ្ឋានដែរឬទេ?
- **សមត្ថភាពគ្រប់គ្រង :** តើកម្រងឯកសាររបស់អង្គការសង្គមស៊ីវិលនេះបង្ហាញពីផែនការយុទ្ធសាស្ត្ររឹងមាំ ដែលត្រូវបានប្រែក្លាយ ឱ្យទៅជាគម្រោង និងការវាយតម្លៃ ដែលមានការរៀបចំបានល្អ ដែរឬទេ?
- **សមត្ថភាពរដ្ឋបាល :** តើអង្គការសង្គមស៊ីវិលនេះមានហេដ្ឋារចនាសម្ព័ន្ធភ័ស្តុភារ និងរូបវ័ន្តគ្រប់គ្រាន់ដែរឬទេ?
- **សមត្ថភាពហិរញ្ញវត្ថុ :** តើអង្គការសង្គមស៊ីវិលនេះមាននីតិវិធី ដើម្បីគ្រប់គ្រងលុយក្នុងចំនួនដែលចាំបាច់ត្រូវមាន និងមានឯកសារ បង្ហាញពីការគ្រប់គ្រងនេះប្រកបដោយជោគជ័យដែរឬទេ? តើអង្គការនេះមានរក្សាគណនីដែលមានការរៀបចំបានល្អមានសុក្រិតភាព និងផ្តល់នូវព័ត៌មានច្រើនដែរឬទេ?

## ចៀសវាងបញ្ហាដែលអាចកើតមានឡើង

នៅក្នុងវដ្តគម្រោងទាំងមូល ចាប់ពីដំណាក់កាលដំបូងពេលធ្វើការសម្រេចចិត្តធ្វើការងារជាមួយនឹងអង្គការ សង្គមស៊ីវិល រហូតដល់ពេលអនុវត្តគម្រោងជាក់ស្តែង មានបញ្ហាជាច្រើនដែលអាចកើតមានឡើង។ គេអាចជំនះបញ្ហាភាគច្រើន ជាមួយនឹងការរៀបចំផែនការ និងការគ្រប់គ្រងគម្រោងឱ្យបានល្អ។

### ជំហ្វូនាន ដើម្បីមានទំនាក់ទំនងល្អជាមួយនឹងអង្គការសង្គមស៊ីវិល

- រៀបចំឱ្យមានកិច្ចពិគ្រោះយោបល់ឱ្យបានល្អជាមួយនឹងអង្គការសង្គមស៊ីវិល នៅពេលចាប់ផ្តើមដំណាក់កាលរៀបចំ។ ការចាត់ទុក ពួកគេថាជាអ្នកម៉ៅការជាលក្ខណៈពាណិជ្ជកម្ម សម្រាប់ការអនុវត្តគម្រោងអាចបង្កើតឱ្យមានភាពតានតឹង។ ជាធម្មតា អង្គការក្រៅរដ្ឋាភិបាលចាត់ទុកអ្នកផ្តល់ជំនួយថាជាដៃគូ ហើយអាចចុះកិច្ចសន្យាបំពេញការងារ ដោយមានការរំពឹងទុកផ្សេងពី ADB។ បើអាចធ្វើ ទៅបាន រៀបចំឱ្យមានការធ្វើសេចក្តីសម្រេចចិត្តរួមគ្នា នៅក្នុងប្រតិបត្តិការការងារដើម្បីជួយបង្កើតឱ្យមានការយល់ដឹងពីគ្នាទៅវិញ ទៅមក និងចៀសវាងវិវាទផ្សេងៗ។
- ធានាឱ្យមានតម្លាភាពនៅក្នុងការដេញថ្លៃផ្តល់សេវាផ្សេងៗ។
- កំណត់ពីសូចនាករ និងចំណុចដៅសម្រាប់ពិនិត្យតាមដានសកម្មភាពរបស់អង្គការសង្គមស៊ីវិលឱ្យបានច្បាស់លាស់។ អង្គការសង្គមស៊ីវិលមាននិន្នាការផ្តោតលើដំណើរការ ជាជាងលើលទ្ធផលនៅក្នុងរយៈពេលខ្លី។
- ត្រូវដឹងថាអង្គការសង្គមស៊ីវិលមួយចំនួន ទទួលរងផលប៉ះពាល់ ដោយសារអត្រាបុគ្គលិកឈប់ និងចូលថ្មីខ្ពស់។ ខណៈពេលដែលមាន ការទទួលស្គាល់ថានេះគឺជាហានិភ័យមួយ ការផ្តល់នូវសំណងសម្រាប់ហានិភ័យនេះ តាមរយៈការធានានូវទំនាក់ទំនងមិនពឹងអាស្រ័យ តែលើមនុស្សទំនាក់ទំនងសំខាន់ៗម្នាក់ ឬពីរនាក់នោះទេ។ ដូចគ្នាដែរអង្គការសង្គមស៊ីវិលមួយចំនួន ត្រូវបានដឹកនាំដោយបុគ្គលិក ដែលការលើកទឹកចិត្តរយៈពេលវែងតែមួយចំនួនតូចប៉ុណ្ណោះ។
- ត្រូវដឹងថាអង្គការសង្គមស៊ីវិល មានថវិកាសម្រាប់ខ្ទង់ផ្សេងៗ តិចតួចដូច្នេះពួកគេត្រូវការ ការផ្តល់ថវិកាឱ្យបានទាន់ពេលវេលា។
- ត្រូវមានភាពប្រាកដនិយមអំពីសមត្ថភាព។ នៅក្នុងស្ថានភាពក្រោយជម្លោះ ឬក្នុងបរិបទដែលអង្គការសង្គមស៊ីវិលទើបតែត្រូវបានបង្កើតឡើងកាលពីពេលថ្មីៗនេះ គេប្រហែលជាចាំបាច់ត្រូវដាក់បញ្ចូលការកសាងសមត្ថភាព នៅក្នុងការរៀបចំគម្រោងមុនពេលជួលអង្គការណាមួយឱ្យបំពេញការងារ។

# ឧបករណ៍ទី ៧ : ការពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួម

ការពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួម (PM&E) គឺជាដំណើរការ ដែលអ្នកពាក់ព័ន្ធចូលរួមធ្វើការពិនិត្យតាមដាន ឬវាយតម្លៃលើគម្រោងកម្មវិធី ឬគោលនយោបាយណាមួយ, ចែករំលែកការគ្រប់គ្រងលើខ្លឹមសារដំណើរការ និងលទ្ធផល និងជួយចាត់ ឬកំណត់វិធានការកែតម្រូវ។ តាមរយៈការជម្រុញឱ្យមានការចូលរួមពីអ្នកនៅ មូលដ្ឋានដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងជាជាងពឹងផ្អែកទាំងស្រុងលើអ្នកជំនាញខាងក្រៅ PM&E អាច បង្ហាញឱ្យឃើញពីមេរៀនអំពីការអនុវត្តគម្រោង សម្រាប់អ្នកពាក់ព័ន្ធផ្សេងៗពីគ្នា និងបង្កើនការចូលរួមរបស់ ប្រជាពលរដ្ឋ និងភាពជាម្ចាស់លើសកម្មភាពអភិវឌ្ឍន៍នានា។

## សេចក្តីផ្តើម

PM&E ត្រូវបានបង្កើតឡើង ដើម្បីជម្រុញឱ្យមានការចូលរួមឱ្យបានសកម្មភាពអ្នកដែលរងផលប៉ះពាល់ ដោយសារគម្រោង នៅក្នុងដំណើរការពិនិត្យតាមដាន និងវាយតម្លៃ។ PM&E ផ្តល់នូវវិធីសាស្ត្រថ្មីៗ សម្រាប់ធ្វើការវាយតម្លៃ និងរៀនសូត្រពីការផ្លាស់ប្តូរ ដែលមានការចូលរួម និងឆ្លើយតបច្រើនជាង ទៅនឹងសេចក្តីត្រូវការ និងបំណង ប្រាថ្នារបស់អ្នកពាក់ព័ន្ធ។ នេះឆ្លុះបញ្ចាំងពីសនិទានភាពនៃការវាយតម្លៃដែលមានការចូលរួមហើយគោលវិធីទាំងពីរនេះមានគោលការណ៍ស្នូល និងវិធីសាស្ត្រដូចគ្នាជាច្រើន (សូមមើលឧបករណ៍ទី ៣ : ការវាយតម្លៃដោយមានការចូលរួម ទំព័រទី ៣៧)។ ដំបូន្មាននៅក្នុងឧបករណ៍ទី ៣ ក៏អាចយកមកអនុវត្តចំពោះ PM&E ផងដែរ។

| ភាពខុសប្លែកគ្នា | ការពិនិត្យតាមដាន និងការវាយតម្លៃធម្មតា | ការពិនិត្យតាមដាន និងការវាយតម្លៃដោយមានការចូលរួម |
|---|---|---|
| តើអ្នកជាអ្នករៀបចំផែនការ និងគ្រប់គ្រងដំណើរការនេះ | ជាធម្មតា បុគ្គលិករបស់ ADB មន្ត្រីរបស់ ទីភ្នាក់ងារប្រតិបត្តិ និងទីប្រឹក្សា | បុគ្គលិក ADB ម្នាក់សរសេរលក្ខខណ្ឌប្រតិបត្តិបឋម ល្អបំផុត ដោយមានការចូលរួមពីតំណាងសហគមន៍។ ទីប្រឹក្សាបំពេញតួនាទីជាអ្នកសម្របសម្រួល។ ប្រជាពលរដ្ឋនៅមូលដ្ឋាន បុគ្គលិកគម្រោង មន្ត្រីរដ្ឋាភិបាលនៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀត បំពេញតួនាទីសំខាន់ នៅក្នុងការគ្រប់គ្រង ទិដ្ឋភាពជាក់លាកនៃដំណើរការនេះ។ |
| តួនាទីរបស់អ្នកពាក់ព័ន្ធ | ផ្តល់ព័ត៌មាន | ជួយរៀបចំក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃ ដោយមានការចូលរួម (PM&E) ប្រមូល និងវិភាគ ព័ត៌មាន ចែករំលែកលទ្ធផលដែលបានរកឃើញ និង បង្កើតសំណើសកម្មភាពដែលត្រូវអនុវត្តនាពេល អនាគត។ ដើម្បីជម្រុញឱ្យមានការចូលរួមពីអ្នកដែល មិនមានការអប់រំ ឬអ្នកមិនចេះអក្សរ នៅក្នុងតួនាទី នេះ ចាំបាច់ត្រូវមានការគាំទ្រ និងការកសាង សមត្ថភាពឱ្យបានច្រើន។ |
| តួនាទីរបស់ទីប្រឹក្សា | ផ្តល់នូវជំនាញសម្រាប់ធ្វើការវាស់វែងលទ្ធផល ការងារ ធៀបជាមួយនឹងគោលដៅនានា ដោយ ប្រើប្រាស់វិធីសាស្ត្រ/ឧបករណ៍ដែលមាន លក្ខណៈស្តង់ដា | ការជួយឱ្យក្រុមអ្នកពាក់ព័ន្ធអាចធ្វើការពិនិត្យតាម ដាន និងវាយតម្លៃដោយមានការចូលរួមបាន តម្រូវ ឱ្យមានការប្រាស្រ័យទាក់ទងឱ្យបានល្អ ការសម្របសម្រួល និងជំនាញវិភាគ |
| ការវាស់វែងជោគជ័យ | កំណត់/វាយតម្លៃពីខាងក្រៅ ជារឿយៗ ធៀបជាមួយនឹងការសន្មតបឋមរបស់កម្មវិធី | កំណត់នៅខាងក្នុង ស្វែងរកការយល់ឃើញ និងការ មិនឯកភាពគ្នាផ្សេងៗ ធានាឱ្យសម្លេងរបស់អ្នក ទទួលផលបញ្ចេញបានច្បាស់លាស់ និងត្រូវបានគេ ស្តាប់ឮ |
| គោលវិធី | កំណត់ជាមុន និងមិនអាចកែប្រែបាន | ជាលក្ខណៈបង្ហាញ និងអាចបត់បែនបាន ផ្តោត សំខាន់លើការរៀនសូត្រ |

ប្រភព : NZAID. 2006. *Guideline on Participatory Evaluation*. Auckland.

## តើត្រូវប្រើប្រាស់ការពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួមនៅពេលណានៅក្នុងវដ្តគម្រោងរបស់ADB

នៅក្នុងកំឡុងពេលរៀបចំគម្រោង ទីប្រឹក្សាម្នាក់ធ្វើការប្រមូលព័ត៌មានអំពីសូចនាករ និងចំណុចដៅដែលអាចមាន។
ទីប្រឹក្សារូបនោះត្រូវស្វែងយល់ពីប្រព័ន្ធព័ត៌មានដែលមានស្រាប់ហើយប្រសិនបើចាំបាច់ត្រូវប្រមូលទិន្នន័យបន្ថែម។ គាត់ត្រូវធ្វើការស្រាវជ្រាវអំពី

i. របៀបប្រមូលព័ត៌មាន ឧ. ការអង្កេតគំរូ ឬការអង្កេតពេញលេញ ឯកសារគម្រោងវិធីសាស្ត្រវាយតម្លៃ ជនបទដោយមានការចូលរួមការពិភាក្សាក្រុមគោលដៅ ឬការសង្កេតនៅមូលដ្ឋានជាក់ ស្តែង

ii. អ្នកដែលនឹងប្រមូលទិន្នន័យ ឧ. បុគ្គលិកគម្រោងទីភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត សហគមន៍អ្នកទទួលផល ទីភ្នាក់ងារដែលត្រូវបានជួលឱ្យបំពេញការងារអង្គការក្រៅរដ្ឋាភិបាល ឬទីប្រឹក្សា។

នៅត្រង់ចំណុចនេះ សូមធ្វើការសម្រេចចិត្តថា តើត្រូវប្រើប្រាស់គោលវិធីតាមបែបចូលរួម ដើម្បីធ្វើការពិនិត្យតាមដាន និងវាយតម្លៃដែរឬទេ។ ការអនុវត្តការពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួម ហាក់បីដូចជាមានភាពសមស្របជាងគេ នៅក្នុងគម្រោងដែលមានការចូលរួមពីអ្នកពាក់ព័ន្ធនៅមូលដ្ឋាន នៅក្នុងពេលរៀបចំផែនការដំបូង។ ប្រជាពលរដ្ឋមានអារម្មណ៍ថា ខ្លួនមានភាពជាម្ចាស់ច្រើនជាងមុនលើគម្រោងអ្វីមួយ ហើយមានឆន្ទៈចំណាយពេលវេលាពិនិត្យតាមដានការអនុវត្តគម្រោង និងធ្វើការឆ្លុះបញ្ចាំងពីតម្លៃនៃការចូលរួមរបស់ពួកគេ។ ការពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួមប្រើប្រាស់ព័ត៌មានដែលទទួលបានពីការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងការវាយតម្លៃដំបូងដោយមានការចូលរួម ហើយជម្រុញលើកទឹកចិត្តឱ្យមានការចូលរួមនៅក្នុងការអនុវត្ត។
ប្រសិនបើមិនមានការចូលរួមជាបន្តនោះទេ ប្រជាពលរដ្ឋអាចមិនជឿទុកចិត្តថា គេពិតជាផ្តល់តម្លៃដល់គំនិត យោបល់របស់ពួកគេប្រាកដមែន។ ខណៈពេលដែលដំណើរការនៃការពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួម នីមួយៗមានលក្ខណៈមិនដូចគ្នា ខាងក្រោមនេះគឺជាជំហានសំខាន់ៗមួយចំនួននៅក្នុងដំណើរការ PM&E ដែលមាន លក្ខណៈស្តង់ដា។[៥០]

## នៅក្នុងពេលដំណើរការគម្រោង

១. **ការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធ នៅទីតាំងគម្រោង :** ពន្យល់ពីមូលហេតុ ដែលអ្នកចូលរួម គួរចូលរួមនៅក្នុងការពិនិត្យតាមដាន និងវាយតម្លៃ និងធ្វើការកំណត់ថាតើអ្នកណាខ្លះនឹងចូលរួមនៅក្នុងក្រុមការងារ PM&E។ ពិភាក្សាពីការធ្វើឱ្យមានតុល្យភាពយេនឌ័រ និងពីក្រុមពាក់ព័ន្ធនានា ដែលគួរចូលរួម។

២. **កំណត់ពីសំណួរ និងវិធីសាស្ត្រវាយតម្លៃសំខាន់ៗ :** រៀបចំសិក្ខាសាលាបឋមមួយ ជាមួយនឹងក្រុមការងារ PM&E ដើម្បីកំណត់ពីគោលដៅសូចនាករ និងវិធីសាស្ត្រសំខាន់ៗ។

៣. **បង្កើត DMF និងប្រព័ន្ធគ្រប់គ្រងលទ្ធផលការងាររបស់គម្រោង (PAM ។ល។) :** រៀបរាប់នៅក្នុងប្រព័ន្ធ គ្រប់គ្រងលទ្ធផលការងាររបស់គម្រោងអំពីរបៀបដែលក្រុមអ្នកទទួលផល និងក្រុមដែលរងផលប៉ះពាល់ដោយសារគម្រោងដទៃទៀតនឹងចូលរួមនៅក្នុង PM&E ។ជម្រុញឱ្យមានការចូលរួមពីស្ថាប័នស្រាវជ្រាវ ឬអង្គការសង្គមស៊ីវិលក្នុងមូលដ្ឋានឱ្យពិនិត្យតាមដានគម្រោងដោយឯករាជ្យ (ឬលើទិដ្ឋភាពមួយចំនួនរបស់គម្រោង ដូចជាផែនការតាំង ទីលំនៅជាដើម)។

**ក្នុងកំឡុងពេលរៀបចំផែនការប្រតិបត្តិការគម្រោង**

៤. **ការបណ្តុះបណ្តាល/ការពិភាក្សា :** បណ្តុះបណ្តាលក្រុមការងារពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួមអំពីឧបករណ៍ និងវិធីសាស្ត្រដែលមានការចូលរួម ។ ពិភាក្សាពីគោលការណ៍ណែនាំនានា ដូចជាកិរិយាបថ និងអាកប្បកិរិយាជាដើម ។

៥. **បង្កើតនូវផែនការអនុវត្តលំអិត :** ធ្វើការសម្រេចចិត្តអំពីតើអ្នកណាត្រូវធ្វើអ្វីខ្លះនៅពេលណា សំណាកគំរូណាខ្លះ អន្តរាគមន៍ណាខ្លះដែលត្រូវចុះទៅមើល នៅពេលណា និងដោយរបៀបណា ។

**នៅក្នុងកំឡុងពេលអនុវត្តគម្រោង**

៦. **ការពិនិត្យតាមដាន ការវិភាគ និងការផ្តល់ព័ត៌មានត្រឡប់ :** ក្រុមការងារ PM&E ធ្វើការពិនិត្យតាមដាន កត់ត្រាសកម្មភាព និងចែករំលែកព័ត៌មាននានា ។ វិភាគ និងវាយតម្លៃជាប្រចាំលើផលប៉ះពាល់នានា ដោយធៀបជាមួយ នឹងគោលដៅបឋម ។ ផ្ទៀងផ្ទាត់ និងផ្តល់ព័ត៌មានត្រឡប់អំពីលទ្ធផលរកឃើញដល់អ្នកពាក់ព័ន្ធទូទៅ ។

៧. **ការកែលំអគម្រោង :** ពិភាក្សា និងអនុវត្តការកែសម្រួលគម្រោង ផ្អែកទៅតាមលទ្ធផលដែលបានរកឃើញ ។

៨. **ការពិភាក្សា/ការរៀនសូត្រអំពីដំណើរការវាយតម្លៃ :** ពិភាក្សាអំពីវិធីសាស្ត្រ និងការវិភាគជារួម ជាមួយនឹង ក្រុមអ្នកពាក់ព័ន្ធទូទៅ ។ ចែករំលែករបាយការណ៍នានា ។

## ឧបករណ៍ និងវិធីសាស្ត្រ

មានឧបករណ៍ និងវិធីសាស្ត្រផ្សេងៗគ្នា ដែលគាំទ្រដល់ PM&E ដោយបង្កើតឱ្យមានការចូលរួមនៅកម្រិតផ្សេងៗពីគ្នា ។ សម្រាប់គោលវិធីដែលមានការចូលរួមច្រើនជាងគេ អ្នកពាក់ព័ន្ធគឺជាអ្នកគ្រប់គ្រង PM&E និងជាអ្នកបែងចែកធនធាននានា ។ ដំណើរការនេះមានគោលបំណងវាស់វែងប្រសិទ្ធភាពរបស់គម្រោង អភិវឌ្ឍសមត្ថភាពរបស់អ្នកទទួលផល និងបង្កើនគណនេយ្យភាព និងតម្លាភាព ។ ឧបករណ៍ CRC និង CBM ខាងក្រោម បង្ហាញពីរបៀបដែលទម្រង់ PM&E បង្កើនគណនេយ្យភាពស្ថាប័នផ្តល់សេវាសាធារណៈ ។ ការវាយតម្លៃតាមធម្មតាក៏អាចកាន់តែមានការចូលរួមផងដែរ ដោយប្រើប្រាស់ការវិភាគបែបគុណវិស័យបើក ដើម្បីដឹងពីលទ្ធផលដែលមិនបានរំពឹងទុក ឬដោយប្រើប្រាស់គោលវិធីតាមបែបចូលរួមដើម្បីទាញយកនូវគំនិតយោបល់ចម្រុះ ប៉ុន្តែក្នុងពេលជាមួយគ្នាមិនបានផ្ទេរការងារគ្រប់គ្រងឡើយ ។

ឧបករណ៍ទី ៣ : ការវាយតម្លៃដោយមានការចូលរួម មានដាក់បញ្ចូលនូវតារាងមួយអំពីវិធីសាស្ត្រវាយតម្លៃសំខាន់ៗ ដោយមានការចូលរួម (ឧ. ការពិភាក្សាក្រុមគោលដៅ ការដើរមើលក្នុងសហគមន៍ ការបង្កើតផែនទី និងការ ដាក់ពិន្ទុ) ដែលគេនិយមប្រើប្រាស់នៅក្នុង PM&E ។ ប៉ុន្តែអ្វីដែលសំខាន់ជាងគេ មិនមែនជាវិធីសាស្ត្រដែលប្រើប្រាស់នោះទេ ប៉ុន្តែជាឱកាសដែលត្រូវបានបង្កើតឡើង ដើម្បីឱ្យមានការចែករំលែកដោយស្មោះត្រង់អំពីផលប៉ះពាល់ដែលអន្តរាគមន៍នេះ មានមកលើជីវិតរបស់ប្រជាពលរដ្ឋ ។[៥១]

ការប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួមផ្សេងៗគ្នារួមជាមួយគ្នា បង្កើតបាននូវគោលវិធី PM&E ដែល មានការរៀបចំត្រឹមត្រូវ ។ គោលវិធីមួយចំនួន ដែលត្រូវបានប្រើប្រាស់ នៅក្នុងប្រតិបត្តិការរបស់ ADB ត្រូវបានរៀបរាប់ ដូចខាងក្រោម ។ ការវាយតម្លៃលើអ្នកទទួលផល និងការវាយតម្លៃលើភាពក្រីក្រ ដោយមានការចូលរួមនៅក្នុងឧបករណ៍ទី ៣ : ការវាយតម្លៃដោយមានការចូលរួម ក៏អាចយកមកប្រើប្រាស់សម្រាប់ PM&E ផងដែរ ។ បញ្ជីធនធានមានបង្ហាញនូវធនធានបន្ថែមទៀត ។

## បច្ចេកទេសបម្លាស់ប្តូរសំខាន់ៗជាងគេ

បច្ចេកទេសបម្លាស់ប្តូរសំខាន់ៗជាងគេ (MSC) គឺជាគោលវិធី PM&E បែបគុណវិស័យមួយ ។ បច្ចេកទេសមានការចូលរួមពីអ្នកពាក់ព័ន្ធរបស់គម្រោងនៅក្នុងការកំណត់ពីប្រភេទនៃបម្លាស់ប្តូរ ដែលត្រូវកត់ត្រាទុក និងនៅក្នុង ការវិភាគលើទិន្នន័យ ។ ដំណើរការនេះរួមមានការប្រមូលរឿងរ៉ាវអំពីបម្លាស់ប្តូរសំខាន់ៗ (SC) ដែលកើតមាននៅនឹងមូលដ្ឋាន ហើយក្រុមអ្នកពាក់ព័ន្ធ និងបុគ្គលិកធ្វើការជ្រើសរើសបម្លាស់ប្តូរដែលសំខាន់ជាងគេក្នុងចំណោមបម្លាស់ប្តូរទាំងនេះ ។[៥២] MSC ត្រូវបានប្រើប្រាស់នៅក្នុងគម្រោងស្រាវជ្រាវរបស់ ADB ដែលមានឈ្មោះថា ធ្វើឱ្យទីផ្សារអាចបំពេញការងារបានកាន់តែប្រសើរជាងមុនសម្រាប់ប្រជាពលរដ្ឋក្រីក្រ (MMwB4P) នៅក្នុងប្រទេសវៀតណាម ។ បុគ្គលិកគម្រោងប្រមូលរឿងរ៉ាវអំពីបម្លាស់ប្តូរ ពីអ្នកស្រាវជ្រាវដែលទទួលបានថវិកាគាំទ្រ និងពីអ្នកចូលរួមនៅក្នុង សិក្ខាសាលាផ្សព្វផ្សាយ ។ រឿងរ៉ាវទាំងនេះបញ្ជាក់យ៉ាងច្បាស់ពីដំណើរការតាក់តែងគោលនយោបាយដែលពាក់ព័ន្ធ (នេះគឺជាផ្នែកសំខាន់របស់ MSC) និងកំណត់ពីបណ្តាញ រវាងអ្នកតាក់តែងគោលនយោបាយ និងគម្រោង ។[៥៣]

## ការវិភាគលើគន្លងផលរយៈពេលវែងដែលមានការចូលរួម

ការវិភាគលើគន្លងផលរយៈពេលវែងដែលមានការចូលរួម (PIPA) គឺជាគោលវិធី PM&E ដែលត្រូវបានរៀបចំឡើង ដើម្បីជួយឱ្យអ្នកដែលពាក់ព័ន្ធក្នុងគម្រោងកម្មវិធី ឬស្ថាប័នណាមួយអាចពន្យល់ពីទ្រឹស្តីនៃការផ្លាស់ប្តូររបស់ពួកគេបាន (ពោលតើពួកគេមើលឃើញខ្លួនឯងយ៉ាងដូចម្តេចនៅក្នុងការសម្រេចនូវគោលដៅ និងធ្វើឱ្យមានផលរយៈពេលវែង) ។[៥៤] គន្លងផលប៉ះពាល់របស់គម្រោង រៀបរាប់ពីរបៀបដែលគម្រោងបង្កើតនូវផលិតផលចំណេះដឹងរបស់ខ្លួន និងធ្វើការផ្សព្វផ្សាយមេរៀន និងលទ្ធផលរបស់គម្រោងដល់អ្នកនៅខាងក្រៅគម្រោង ដែលចាំបាច់ត្រូវប្រើប្រាស់ព័ត៌មានទាំងនេះ ដើម្បីឱ្យមានផលរយៈពេលវែងលើការអភិវឌ្ឍ ។ ការបង្កើតនូវគោលវិធីទាំងនេះធ្វើឡើង នៅក្នុងសិក្ខាសាលាដែលមានការចូលរួមពីអ្នកពាក់ព័ន្ធ (ឧ. បង្កើតដើមឈើបញ្ហា ធ្វើលំហាត់កំណត់ពីចក្ខុវិស័យ) ។ បន្ទាប់មកគន្លងនេះត្រូវបានបែងចែកជាគំរូចំនួន ២ ។ គំរូបង្ហាញពីលទ្ធផលរយៈពេលមធ្យម (outcomes logic model) រៀបរាប់ពីគោលដៅរយៈពេលមធ្យមរបស់គម្រោង សម្រាប់ធ្វើជាសម្មតិកម្ម : តើអ្នកដែលមានតួនាទីណាខ្លះដែលចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរ តើមានការផ្លាស់ប្តូរអ្វីខ្លះ និងតើចាំបាច់ត្រូវប្រើប្រាស់យុទ្ធសាស្ត្រអ្វីខ្លះ ដើម្បីសម្រេចឱ្យបាននូវការផ្លាស់ប្តូរទាំងនេះ ។ គំរូផលរយៈពេលវែង (impact logic model) រៀបរាប់ពីរបៀបដែលគម្រោងនឹងមានផលរយៈពេលវែងដល់ជីវភាព

រស់នៅរបស់ប្រជាពលរដ្ឋ តាមរយៈការជួលឱ្យសម្រេចនូវលទ្ធផលរំពឹងទុក។ អ្នកចូលរួមកំណត់ពីចំណុចដៅ នៃលទ្ធផលរយៈពេលមធ្យម ដែលត្រូវមានការកែសម្រួលជាទៀងទាត់ ដែលជាផ្នែកមួយនៃការពិនិត្យតាមដាន និងវាយតម្លៃគម្រោង។[៥៥] PIPA ត្រូវបានប្រើប្រាស់នៅក្នុងគម្រោងកែច្នៃស្រូវ ក្នុងប្រទេសវៀតណាម ដែលទទួលបាន ការគាំទ្រពី ADB ។ សិក្ខាសាលាអ្នកពាក់ព័ន្ធបានកំណត់ពីគន្លងផលរយៈពេលវែងរបស់គម្រោង និងបង្កើតនូវផែនការសម្រាប់វាយតម្លៃផលរយៈពេលវែងនេះ។[៥៦]

## ប័ណ្ណរាយការណ៍របស់ប្រជាពលរដ្ឋ

ប័ណ្ណរាយការណ៍របស់ប្រជាពលរដ្ឋ (CRC) គឺជាការអង្កេតបែបបរិមាណវិស័យ ដែលបង្កើតឡើងដោយប្រជាពលរដ្ឋ ឬប័ណ្ណរាយការណ៍អំពីលទ្ធផលការងារនៃសេវារបស់រដ្ឋាភិបាល។ ពួកគេប្រមូលព័ត៌មានតាមផ្ទះ និង/ឬពីបុគ្គលម្នាក់ៗ តាមរយៈបញ្ជីសំណួរ និងកំណត់ពីលទ្ធផលការងារនៅកម្រិតម៉ាក្រូ។ ជាធម្មតាការអង្កេតបែបនេះធ្វើឡើង ក្នុងរយៈពេលពី ៣-៦ ខែ។ ក្នុងនាមជាឧបករណ៍សាមញ្ញ តែមានអានុភាពមួយដើម្បីទាមទារឱ្យមានគណនេយ្យភាពជាសាធារណៈ CRCs គឺជារបៀបវារៈមួយ ដែលផ្តល់លទ្ធភាពឱ្យសហគមន៍ អង្គការសង្គមស៊ីវិល ឬរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋានអាចចូលរួមពិគ្រោះយោបល់ជាមួយនឹងអ្នកផ្តល់សេវា និងផ្តល់ឱ្យពួកគេនូវព័ត៌មានត្រឡប់ពីអ្នកប្រើប្រាស់ក្នុង លក្ខណៈជាប្រព័ន្ធអំពីគុណភាព និងភាពគ្រប់គ្រាន់នៃសេវាសាធារណៈ។ ការគ្រប់ដណ្តប់យ៉ាងទូលំទូលាយនៃប្រព័ន្ធផ្សព្វផ្សាយ និងការតស៊ូមតិរបស់សង្គមស៊ីវិល អាចជួយផ្សព្វផ្សាយលទ្ធផលដែលបានរកឃើញ។ ADB បានបង្កើតនូវកញ្ចប់ឧបករណ៍មួយ អំពីការប្រើប្រាស់វិធីសាស្ត្រនេះ (សូមមើលផ្នែកក្នុងមគ្គុទេសក៍អំពីអភិបាលកិច្ចសម្រាប់ព័ត៌មានបន្ថែមទំព័រទី ៧១)។[៥៧]

## ការពិនិត្យតាមដាននៅតាមសហគមន៍

ការពិនិត្យតាមដាននៅតាមសហគមន៍ (CBM) គឺជាការពិនិត្យតាមដាន និងវាយតម្លៃដែលធ្វើឡើងដោយសហគមន៍លើគំនិតផ្តួចផ្តើមអភិវឌ្ឍន៍នៅក្នុងសហគមន៍។ ការពិនិត្យតាមដាននេះប្រើប្រាស់វិធីសាស្ត្រ ដែលមានការចូលរួមដូចជា ការអង្កេតផែនទី ការពិភាក្សាក្រុមគោលដៅ ឬការជួបប្រជុំគ្នាក្នុងទីប្រជុំជន និង/ឬក្នុងភូមិ។[៥៨]

ប្រសិនបើការពិនិត្យតាមដានផ្តោតលើសេវាសាធារណៈ នោះប័ណ្ណពិន្ទុសហគមន៍អាចតាមដានពីលទ្ធផលការងារ។ ការពិនិត្យតាមដាននេះមានគោលបំណងស្រដៀងគ្នានឹង CRC ដែរ នៅក្នុងការទាមទារឱ្យមានគណនេយ្យភាព និងភាពឆ្លើយតបពីអ្នកផ្តល់សេវា។ ប៉ុន្តែទិន្នន័យដែលប្រមូលបាន គឺជាទិន្នន័យបែបគុណវិស័យ (តាមរយៈការពិភាក្សាក្រុមគោលដៅ) នៅនឹងមូលដ្ឋាន ហើយមានដាក់បញ្ចូលនូវអន្តរកម្មដោយផ្ទាល់រវាងអ្នកផ្តល់សេវា និងសហគមន៍ (តាមរយៈកិច្ចប្រជុំដោយផ្ទាល់) ដែលផ្តល់លទ្ធភាពឱ្យមានការផ្តល់នូវព័ត៌មានត្រឡប់ភ្លាមៗ។

គម្រោងសុខភាពជនបទរបស់ ADB នៅក្នុងប្រទេសវៀតណាម គាំទ្រដល់គំនិតផ្តួចផ្តើមរបស់ក្រសួង សុខាភិបាល នៅក្នុងការប្រើប្រាស់ CBM សម្រាប់ធ្វើជាឧបករណ៍ ដើម្បីជម្រុញឱ្យមានការចូលរួមរបស់សហគមន៍ នៅក្នុងការរៀបចំផែនការ និងការកែលំអសេវានៅកម្រិតឃុំ។[៥៩] ប្រទេសហ្វីលីពីនមានប្រព័ន្ធ CBM ដែលត្រូវបានបង្កើត ឡើងបានយ៉ាងល្អ នៅតាមតំបន់ជាច្រើន ហើយកំពុងត្រូវបានប្រើប្រាស់នៅទូទាំងប្រទេស។ សហគមន៍ធ្វើការប្រមូលទិន្នន័យ និងកំណត់ពីបញ្ហាសង្គម និងដំណោះស្រាយ។ ដំណើការនេះធ្វើឱ្យមានចំណងសាមគ្គីភាពកាន់តែស្អិតរមួត និងលើកទឹកចិត្តឱ្យសហគមន៍ធ្វើសកម្មភាព។[៦០]

# ៤ ការចូលរួមនៅក្នុងប្រតិបត្តិការការងាររបស់ ADB – បទពិសោធន៍ និងឧទាហរណ៍

ការចូលរួមមានសារៈសំខាន់យ៉ាងខ្លាំង នៅក្នុងគ្រប់ប្រតិបត្តិការការងារទាំងអស់របស់ ADB និង/ឬរបស់ ប្រទេសកំពុងអភិវឌ្ឍជាសមាជិក។ យុទ្ធសាស្ត្រឆ្នាំ ២០២០ រំលេចឱ្យឃើញពីផ្នែកសំខាន់ៗចំនួន ៥ (និងផ្នែកបន្ថែមចំនួន៣) និងកត្តាចំនួន ៥ ដែលជម្រុញឱ្យមានការផ្លាស់ប្តូរ ឱ្យមានការផ្តោតគោលដៅលើសកម្មភាពនានា។ ADB មាន បទពិសោធន៍ជាក់លាក់នៅក្នុងការអនុវត្តគោលវិធីដែលមានការចូលរួមជាលក្ខណៈស៊ីជម្រៅ ដែលពាក់ព័ន្ធជាមួយនឹងកត្តាដែលជម្រុញឱ្យមានការផ្លាស់ប្តូរសមធម៌យេនឌ័រ និងអភិបាលកិច្ចល្អ និងនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធស្នូល។

## សេចក្តីផ្តើម

ផ្នែកនេះបង្ហាញពីគោលវិធី និងឧបករណ៍នានា ដើម្បីគាំទ្រដល់ការចូលរួមនៅក្នុងផ្នែកសំខាន់ៗចំនួន ៥ ខាងក្រោម ដែលយកចេញពីយុទ្ធសាស្ត្រ ២០២០។ សមធម៌យេនឌ័រ និងអភិបាលកិច្ចល្អត្រូវបានរំលេចឱ្យឃើញថាជា កត្តាដែលជម្រុញឱ្យមានការផ្លាស់ប្តូរ ខណៈពេលដែលហេដ្ឋារចនាសម្ព័ន្ធ គឺជាផ្នែកប្រតិបត្តិការស្នូល :

១. ការការពារផលប៉ះពាល់សង្គម និងបរិស្ថាន

២. សមធម៌យេនឌ័រ

៣. អភិបាលកិច្ចល្អ និងការអភិវឌ្ឍសមត្ថភាព

៤. ហេដ្ឋារចនាសម្ព័ន្ធ - ការបង្ការមេរោគអេដស៍

៥. ហេដ្ឋារចនាសម្ព័ន្ធ - ទឹក និងអនាម័យ

មានកម្លាំងផ្ទុយជាច្រើនរវាងផ្នែកទាំងនេះ។ គ្រប់ផ្នែកទាំងអស់តម្រូវឱ្យមានការពិគ្រោះយោបល់ដោយមាន ការចូលរួមដើម្បីឱ្យគម្រោងដែលមានប្រសិទ្ធភាពអាចត្រូវបានរៀបចំឡើង និងអនុវត្ត។ ផ្នែកទាំងអស់អាចទទួលបាន ប្រយោជន៍ពីបច្ចេកទេសវិភាគ និងវាយតម្លៃដោយមានការចូលរួម ហើយគ្រប់ផ្នែកទាំងអស់អាចជម្រុញឱ្យមានការចូល រួមពីអង្គការសង្គមស៊ីវិលក្នុងការអនុវត្តសមាសភាគរបស់គម្រោងដែលមានការចូលរួម។ ឧបករណ៍វដ្តគម្រោង ដែល បង្ហាញនៅក្នុងមគ្គុទេសក៍នេះ បង្ហាញពីគោលវិធីអន្តរវិស័យទាំងនេះ ខណៈពេលដែលផ្នែកនេះផ្តោតសំខាន់លើដំបូន្មាន និងឧបករណ៍ដែលប្រើប្រាស់សម្រាប់គាំទ្រដល់ការចូលរួមនៅក្នុងផ្នែកទាំង៥នេះ និងលើកកម្ពស់ឱ្យមានការយកគំរូតាមការអនុវត្តល្អៗ។

## ១. Safeguards[៦១]

**សម្គាល់ ៖ ដំបូន្មាននៅក្នុងផ្នែកនេះ គឺជាអនុសាសន៍អំពីវិធីដែល** ADB **និងប្រទេសកំពុងអភិវឌ្ឍជាសមាជិក អាចយកទៅប្រើប្រាស់បាន ដើម្បីបំពេញទៅតាមលក្ខខណ្ឌតម្រូវឱ្យមានការចូលរួមនៅក្នុងគោលនយោបាយស្តីពីការការពារ ផលប៉ះពាល់សង្គម និងបរិស្ថាន** (SPS)**។ សូមមើល** SPS **សម្រាប់សេចក្តីលំអិតអំពីអ្វីដែលគោលនយោបាយនេះ តម្រូវឱ្យមាន។**
**ដូចនៅក្នុង** SPS **ដែរ ពាក្យថាអ្នកខ្ចី និង/ឬអតិថិជន ជាជាងអ្នកទទួល និង/ឬអតិថិជន ត្រូវបានប្រើប្រាស់ នៅក្នុងផ្នែកនេះដោយសារតែការផ្តោតសំខាន់ គឺលើសកម្មភាពកម្ចី។**

> គោលនយោបាយស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថានរបស់ ADB ចែងថាការពិគ្រោះយោបល់ និង ការចូលរួម និងជាពិសេស ការពិគ្រោះយោបល់ មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីសម្រេចគោលដៅនៅក្នុង គោលនយោបាយស្តីពីការពារផលប៉ះពាល់សង្គម និងបរិស្ថាន។ "ADB តម្រូវឱ្យអ្នកខ្ចី/អតិថិជន ចូលរួមជាមួយនឹងសហគមន៍ ក្រុម ឬអ្នកដែលរងផលប៉ះពាល់ ដោយសារគម្រោងដែលបានស្នើឡើង និងជាមួយនឹងសង្គមស៊ីវិល តាមរយៈ ការបង្ហាញព័ត៌មាន ការពិគ្រោះយោបល់ និងការចូលរួម នៅក្នុងបែបផែនមួយដែលសមស្របទៅនឹងហានិភ័យ និងផលប៉ះពាល់មកលើសហគមន៍ ដែលទទួលរងផលប៉ះពាល់។"
>
> ប្រភព៖ ADB. 2009. *Safeguard Policy Statement.* Manila.

## សេចក្តីផ្តើម

នៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិចនេះ មាននិន្នាការជាវិជ្ជមានឆ្ពោះទៅរកការអភិវឌ្ឍដែលធានានិរន្តរភាពសង្គម និងបរិស្ថានបានកាន់តែប្រសើរជាងមុន និងបង្កើនការរំពឹងទុកអំពីគណនេយ្យភាព តម្លាភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ។ គោលនយោបាយស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាន (SPS) ឆ្នាំ ២០០៩ របស់ ADB ផ្តោតជាពិសេសលើការបញ្ចៀស ឬការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននៃគម្រោងអភិវឌ្ឍន៍មកលើប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ (លេខយោងចុងក្រោយទី ៨)។[៦២] គម្រោង ADB ភាគច្រើន (ប្រមាណពី ៧០% ទៅ ៨០%) មានភាពពាក់ព័ន្ធផ្នែកកិច្ចការពារផលប៉ះពាល់សង្គម និងបរិស្ថាន។

ការចូលរួមមានសារៈសំខាន់យ៉ាងខ្លាំងចំពោះ SPS ហើយវាតម្រូវឱ្យមានការបង្កើនបន្តិចម្តងៗនូវកម្រិតនៃ ការពិគ្រោះយោបល់ និងការចូលរួមនៅក្នុងផ្នែក ៣ សំខាន់ៗ រួមមានបរិស្ថានការតាំងទីលំនៅ និងជនជាតិដើមភាគតិច (IPs)។ ទីភ្នាក់ងារប្រតិបត្តិត្រូវផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋអំពីអ្វីដែលគម្រោងគ្រោងនឹងធ្វើ និងរបៀបដែល គម្រោងនឹងមានផលប៉ះពាល់ដល់ពួកគេ ប៉ុន្តែក៏អាចផ្តល់ព័ត៌មានច្រើនជាងនេះផងដែរ។ ពួកគេត្រូវធ្វើការពិគ្រោះ យោបល់ជាមួយនឹងអ្នកដែលរងផលប៉ះពាល់ ដើម្បីស្វែងយល់ពីរបៀបកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន និងទទួលបានការឯកភាពពីជនជាតិដើមភាគតិច សម្រាប់គម្រោងមួយចំនួន។ អ្នកដែលរងផលប៉ះពាល់មានសិទ្ធិទទួលបានសំណង ហើយចាំបាច់ត្រូវមានភាពច្នៃប្រឌិត

ដើម្បីលើកកម្ពស់ឱ្យមានការបែងចែកប្រយោជន៍ ដែលទទួលបានពីកម្មវិធីអភិវឌ្ឍន៍ នានាដោយសមធម៌។ ការពិនិត្យតាមដានដោយឯករាជ្យ និងយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្តដែលអាចជឿទុកចិត្តបាន នឹងជួយធានាឱ្យមានការបែងចែកប្រកបដោយសមធម៌បែបនេះ។



ដំណើរការពិគ្រោះយោបល់របស់ ADB សម្រាប់ផ្លាស់ប្តូរទីលំនៅរបស់ជនដែលរងផលប៉ះពាល់ (ជនជាតិ Co Tu) សម្រាប់គម្រោងវារីអគ្គិសនី Song Bung ៤ នៅប្រទេសវៀតណាម។

SPS ចែងយ៉ាងច្បាស់លាស់អំពីការទទួលខុសត្រូវរួមលើការការពារផលប៉ះពាល់សង្គម និងបរិស្ថានរបស់ ADB និងរបស់អ្នកខ្ចី និង/ឬអតិថិជន។

| **ការទទួលខុសត្រូវលើការការពារផលប៉ះពាល់សង្គម និងបរិស្ថាន** | |
|---|---|
| **អ្នកខ្ចី និង/ឬអតិថិជនត្រូវ៖** | **ADB ត្រូវ៖** |
| • ធ្វើការវាយតម្លៃលើសង្គម និងបរិស្ថាន<br>• ធ្វើការពិគ្រោះយោបល់ជាមួយនឹងប្រជាពលរដ្ឋ និងសហគមន៍ដែលទទួលរងផលប៉ះពាល<br>• រៀបចំ និងអនុវត្តផែនការការពារផលប៉ះពាល់សង្គម និង បរិស្ថាន<br>• ពិនិត្យតាមដានការអនុវត្តផែនការទាំងនេះ<br>• រៀបចំ និងផ្ញើរបាយការណ៍ពិនិត្យតាមដានអនុវត្តកម្មវិធីកសាងសមត្ថភាព | • អនុវត្តកម្មវិធីកសាងសមត្ថភាព<br>• ធានាឱ្យមានភាពត្រឹមត្រូវ និងការពិនិត្យឡើងវិញ<br>• ពិនិត្យតាមដាន និងត្រួតពិនិត្យ |

Source: ADB. 2009. *Safeguard Policy Statement.* Manila.

ជំហាននៃការការពារផលប៉ះពាល់សង្គម និងបរិស្ថាន នៅដំណាក់កាលនីមួយៗរបស់វដ្តគម្រោង ត្រូវបានដាក់ បញ្ចូលទៅក្នុងមគ្គុទេសក៏ត្រង់ផ្នែកដែលនិយាយអំពីការចូលរួម នៅក្នុងវដ្តគម្រោងរបស់ ADB។ ជំហានខាងក្រោម គាំទ្រដល់ការបំពេញទៅតាមលក្ខខណ្ឌទូទៅនៃការបង្ហាញព័ត៌មាន និងការពិគ្រោះយោបល់ ការផ្តល់ការឯកភាពមុខរបរ ចិញ្ចឹមជីវិត ការពិនិត្យតាមដាន និងការរាយការណ៍ និងយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្ត។

## ជំហាន ដើម្បីបង្កើនការចូលរួមក្នុងការការពារផលប៉ះពាល់សង្គម និងបរិស្ថានឱ្យដល់កម្រិតអតិបរមា

- **រៀបចំផែនការដោយប្រុងប្រយ័ត្ន :** ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ទាមទារឱ្យមានការរៀបចំផែនការដោយប្រុងប្រយ័ត្ន ដើម្បីធានាយ៉ាងណាឱ្យមានធនធានគ្រប់គ្រាន់ គោលដៅច្បាស់លាស់ ការជ្រើសរើសវិធីសាស្ត្រឱ្យបានត្រឹមត្រូវ ការចាប់ផ្តើមការ ពិគ្រោះយោបល់ឱ្យបានឆាប់ និងការផ្តល់ព័ត៌មានត្រឡប់ដល់អ្នកចូលរួម (សូមមើលឧបករណ៍ទី ១ : ការវិភាគអ្នកពាក់ព័ន្ធ និងការ ពិគ្រោះយោបល់ទំព័រទី ២៥)។ នេះមានសារៈសំខាន់ជាពិសេសសម្រាប់ការការពារផលប៉ះពាល់ដែលពាក់ព័ន្ធជាមួយនឹងបញ្ហារសើប (ដូចជាការបាត់បង់ដីធ្លីការតាំងទីលំនៅ ។ល ។) យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយនឹងអ្នកពាក់ព័ន្ធ ត្រូវបានដាក់បញ្ចូល ទៅក្នុងសៀវភៅណែនាំអំពីការចាត់ចែងគម្រោង ហើយគួរកំណត់ឱ្យបានច្បាស់ពីផែនការបង្ហាញព័ត៌មាន និងប្រាស្រ័យទាក់ទងជាមួយ នឹងអ្នកពាក់ព័ន្ធ (សូមមើលឧបករណ៍ទី ៥ : ការបង្កើតយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយអ្នកពាក់ព័ន្ធ ទំព័រទី ៤៧)។
- **ធ្វើការងារជាមួយអ្នកនៅមូលដ្ឋាន ឬអង្គការនៅមូលដ្ឋាន ដើម្បីរៀបចំកិច្ចពិគ្រោះយោបល់ជាមួយនឹងសហគមន៍ ដែលទទួលរងផលប៉ះពាល់ :** អ្នកដឹកនាំ (ឧ. មេភូមិ នាយកសាលា) ភ្នាក់ងារសហគមន៍ ឬអង្គការសង្គមស៊ីវិល (អង្គការសហគមន៍ ឱ្យក្រុមអ្នកប្រើប្រាស់ទឹក ក្រុមស្ត្រី ឬអង្គការក្រៅរដ្ឋាភិបាល ដែលមានទំនាក់ទំនងស្រាប់) អាចផ្តល់ការគាំទ្រយ៉ាងមានប្រសិទ្ធភាពដល់ការពិគ្រោះយោបល់ ដែលមានលក្ខណៈរសើបផ្នែកវប្បធម៌។
- **ប្រើប្រាស់វិធីសាស្ត្រពិគ្រោះយោបល់ដោយផ្ទាល់បែបគុណវិស័យ :** ប្រើប្រាស់កិច្ចប្រជុំជាសាធារណៈក្នុងសហគមន៍ ការពិភាក្សាក្រុមគោលដៅ និងវិធីសាស្ត្រដែលមានការចូលរួម ដើម្បីបំពេញបន្ថែមលើការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដើម្បីបង្កើនការគ្របដណ្តប់នៃ ការពិគ្រោះយោបល់ឱ្យដល់កម្រិតអតិបរមា។ គេអាចធ្វើការផ្តោះប្តូរយោបល់ប្រកបដោយអត្ថន័យបន្ថែមទៀត ដោយប្រើប្រាស់ វិធីសាស្ត្រទាំងនេះ ហើយវាងាយស្រួលដោះស្រាយ និងឆ្លើយតបចំពោះបញ្ហាលំបាកៗ។
- **ទាញប្រយោជន៍ពីជំនាញ និងបទពិសោធន៍របស់អង្គការសង្គមស៊ីវិល :** អង្គការជាច្រើនមានបទពិសោធន៍យ៉ាងច្រើនផ្នែកការអនុវត្ត កម្មវិធីដែលពាក់ព័ន្ធជាមួយនឹងមុខរបរចិញ្ចឹមជីវិត និងកម្មវិធីស្តារចំណូលឡើងវិញ។ អង្គការទាំងនេះអាចបំពេញតួនាទីជាស្ពានទំនាក់ ទំនងរវាង ADB ទីភ្នាក់ប្រតិបត្តិ និងសហគមន៍ នៅក្នុងពេលអនុវត្ត (ឧ. ផ្តល់ព័ត៌មានដល់ជនដែលរងផលប៉ះពាល់អំពីសិទ្ធិទទួលបានសំណង នៅក្នុងការតាំងទីលំនៅ) ឬមានជំនាញពាក់ព័ន្ធ និងចំណេះដឹងស៊ីជម្រៅអំពីបរិបទក្នុងមូលដ្ឋាន ដើម្បីធ្វើការពិនិត្យតាមដានដោយឯករាជ្យ ឬលើកកម្ពស់ឱ្យមានការពិនិត្យតាមដាន និងការវាយតម្លៃដោយមានការចូលរួម (សូមមើលឧបករណ៍ទី ៧ : ការពិនិត្យតាមដាន និងវាយតម្លៃ ដោយមានការចូលរួមទំព័រទី ៥៧)។

- **ប្រើប្រាស់ចំណេះដឹង និងរចនាសម្ព័ន្ធនៅមូលដ្ឋាន សម្រាប់ដោះស្រាយការកើតទុក្ខមិនសុខចិត្ត ៖** យន្តការដោះស្រាយការកើតទុក្ខមិន សុខចិត្ត គឺជាឱកាសដ៏សំខាន់មួយ ដើម្បីធ្វើការងារជាមួយនឹងអ្នកដឹកនាំនៅមូលដ្ឋាន និងអង្គការនៅតាមសហគមន៍។ ការរៀបចំយន្តការបែបនេះ នឹងមានការលំបាក ប្រសិនបើមិនមានការប្រើប្រាស់ជំនួយរបស់អង្គការនៅមូលដ្ឋាន និងស្ថាប័នដែលធ្វើការសម្រេចចិត្ត (ឧ. *panchayats* សមាគមអ្នកប្រើប្រាស់ទឹក)។

## ការបង្ហាញព័ត៌មាន និងការពិគ្រោះយោបល់

> ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ សំដៅលើដំណើរការដែល (i) ចាប់ផ្តើមនៅដើមដំបូងនៃ ដំណាក់កាលរៀបចំគម្រោង ហើយត្រូវបន្តធ្វើជាប្រចាំ នៅក្នុងវដ្តគម្រោងទាំងមូល (ii) បង្ហាញព័ត៌មានពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា និងអាចយល់បាន ដល់អ្នកដែលរងផលប៉ះពាល់ (iii) ត្រូវបានធ្វើឡើង នៅក្នុងបរិយាកាសដែលពុំមានការគំរាមកំហែង ឬការបង្ខិតបង្ខំ (iv) មានលក្ខណៈចូលរួម និងឆ្លើយតបចំពោះយេនឌ័រ និងសម្រិតសម្រាំង ឡើងទៅតាមតម្រូវការរបស់ក្រុមដែលគ្មានឱកាស និងដែលងាយរងគ្រោះ និង (v) ផ្តល់លទ្ធភាពឱ្យមានការដាក់បញ្ចូល គ្រប់ទស្សនៈដែលពាក់ព័ន្ធទាំងអស់របស់អ្នកដែលរងផលប៉ះពាល់ និងអ្នកពាក់ព័ន្ធដទៃទៀត ទៅក្នុងការធ្វើសេចក្តី សម្រេចចិត្ត ដូចជា ការរៀបចំគម្រោង វិធានការកាត់បន្ថយផលប៉ះពាល់ ការចែករំលែកប្រយោជន៍ និងឱកាសនៃការអភិវឌ្ឍ និងបញ្ហានៃការអនុវត្ត។
>
> ប្រភព៖ ADB. 2009. *Safeguard Policy Statement.* Manila.

ADB ប្តេជ្ញាចិត្តចំពោះការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ។ នេះរួមមានការចែករំលែកព័ត៌មាន ជាមួយ អ្នកពាក់ព័ន្ធ និងការផ្តល់លទ្ធភាពឱ្យពួកគេចូលរួមចំណែកចំពោះការរៀបចំគម្រោង និងការរៀបចំផែនការការពារផលប៉ះពាល់សង្គម និងបរិស្ថាន។ វាមានន័យលើសពីការត្រឹមតែបង្ហោះផ្សាយឯកសារ ដែលចាំបាច់លើគេហទំព័រ ហើយអាចដាក់បញ្ចូលកិច្ចប្រជុំនៅក្នុងសហគមន៍ ការបង្កើតខិតប័ណ្ណព័ត៌មានឬការបង្កើតមណ្ឌលព័ត៌មាន ដែលមានការចូល រួមពីបុគ្គលិកគម្រោង ដែលមានព័ត៌មានច្រើន។ សូមមើលឧបករណ៍ទី ១ ៖ ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ និងឧបករណ៍ទី ៥ ៖ ការបង្កើតយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងជាមួយនឹងអ្នកពាក់ព័ន្ធ ដើម្បីទទួលបានការណែនាំបន្តទៀត។ ការពិគ្រោះយោបល់ គឺជាគោលដៅចុងក្រោយ ហើយនឹងកំណត់ពីការចូលរួមនៅដំណាក់កាលក្រោយៗ ទៀត។

### គម្រោងស្ពាន Padma ប្រទេសបង់ក្លាដេស

ខិតប័ណ្ណព័ត៌មានស្តីពីការតាំងទីលំនៅ ដែលមានបញ្ចូលព័ត៌មានអំពីសំណង និងប្រយោជន៍ដែលទទួលបានពីការតាំងទីលំនៅ នៅក្នុង Bangla ត្រូវបានចែកទៅឱ្យអ្នកដែលរងផលប៉ះពាល់។ ក៏មានការផ្សព្វផ្សាយព័ត៌មាន តាមរយៈកិច្ចប្រជុំសហគមន៍ផងដែរ។

ប្រភព៖ ADB. 2010. *Loan to Bangladesh for Padma Multipurpose Bridge Project*. Manila.

## គម្រោងអភិវឌ្ឍន៍ទីក្រុង Guangxi Wuzhou សាធារណរដ្ឋប្រជាមានិតចិន

ព័ត៌មានត្រូវបានផ្តល់ទៅឱ្យអ្នករងផលប៉ះពាល់ អំពីគម្រោង និងអំពីពង្រាងផែនការតាំងទីលំនៅ នៅក្នុងកិច្ចប្រជុំសហគមន៍ និងការ ពិភាក្សាក្រុមគោលដៅ ហើយមានការស្នើសុំព័ត៌មានត្រឡប់ពីអ្នកពាក់ព័ន្ធ។ បន្ទាប់មក កិច្ចប្រជុំជាសាធារណៈបាន ផ្តល់ព័ត៌មានដល់ ប្រជាពលរដ្ឋអំពីប្រយោជន៍ដែលត្រូវទទួលបាន និងកាលបរិច្ឆេទផ្តល់នូវប្រយោជន៍ទាំងនោះ។ សំណួរអំពី ប្រយោជន៍ដែលត្រូវទទួលបានត្រូវបានរៀបចំឡើង ដើម្បីធានាយ៉ាងណាឱ្យប្រជាពលរដ្ឋយល់ពីព័ត៌មាននេះឱ្យបានត្រឹមត្រូវ។

ប្រភព៖ ADB. 2008. *Guangxi Wuzhou Urban Development Project – Pingminchong Geohazard Resettlement and Prevention Project Resettlement Plan.* Manila.

## ការយល់ព្រម

គោលការណ៍នៃការយល់ព្រមជាមុន មានភាពពាក់ព័ន្ធជាងគេចំពោះជនជាតិដើមភាគតិច។ នៅក្នុងខែកញ្ញា ឆ្នាំ២០០៧ មហាសន្និបាតលើកទី៦១ នៃសហប្រជាជាតិ បានអនុម័តលើសេចក្តីប្រកាសសហប្រជាជាតិ ស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច (UNDRIP) ដែលត្រូវបានចុះហត្ថលេខា ដោយប្រទេសជាច្រើននៅអាស៊ី និងប៉ាស៊ីហ្វិច។ សេចក្តីប្រកាសនេះលើកឡើងពីការស្នើសុំការយល់ព្រមជាមុន ដោយសេរី ពីសហគមន៍ជនជាតិ ដើមភាគតិច មុនពេលអនុម័តលើគម្រោង ដែលមានផលប៉ះពាល់លើពួកគេ។ SPS តម្រូវឱ្យមានការសុំការយល់ព្រមពីសហគមន៍ជនជាតិដើម ភាគតិចដែលរងផលប៉ះពាល់ សម្រាប់គម្រោងចំនួន ៣ ប្រភេទ។ ការយល់ព្រមសំដៅលើការសម្តែងចេញជាលក្ខណៈ សមូហភាពរបស់សហគមន៍ ជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ តាមរយៈបុគ្គល និង/ឬតំណាងដែលពួកគេទទួលស្គាល់ អំពីការគាំទ្ររបស់សហគមន៍លើសកម្មភាព របស់គម្រោងទាំងនេះ។

ការសម្រេចចិត្តផ្តល់ការយល់ព្រម តម្រូវឱ្យមានដំណើរការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ និងប្រកប ដោយតម្លាភាព ដែលក្នុងនោះរួម មានការចែករំលែកព័ត៌មានប្រកបដោយតម្លាភាពជាមួយនឹងជនជាតិដើមភាគតិច ឱកាសផ្តល់ការបញ្ជាក់លើសំណួរ និងការព្រួយបារម្ភនានា និង វក្សាបរិយាកាស ដែលមិនមានការគំរាមកំហែង ឬការបង្ខិតបង្ខំ។ នៅក្នុងការធ្វើការវិនិច្ឆ័យថា តើមានការគាំទ្រយ៉ាងទូលំទូលាយពីសំណាក់ សហគមន៍ដែរឬទេ ADB ត្រូវតែមើលឃើញថា ការចូលរួមនេះគឺមិនត្រឹមតែពីអ្នកដឹកនាំសហគមន៍ និងក្រុមដែលមានអំណាចនោះទេ ប៉ុន្តែក្រុម ភាគតិច ឬក្រុមដែលបាត់បង់ឱកាសក៏ត្រូវបានគេស្តាប់យោបល់យ៉ាងគ្រប់គ្រាន់ផងដែរ។ ប្រសិនបើសំណុំឯកសាររបស់ទីភ្នាក់ងារប្រតិបត្តិមិនគ្រប់ គ្រាន់នោះទេ គេអាចសួរសំណួរដើម្បីស្វែងរកព័ត៌មានលំអិតបន្ថែមទៀត ឬធ្វើការប្រាស្រ័យទាក់ទង ដោយផ្ទាល់ជាមួយអ្នកពាក់ព័ន្ធតែម្តង។

## ចុះរបរចិញ្ចឹមជីវិត

នេះគឺជាចំណុចពាក់ព័ន្ធបំផុត ចំពោះការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត។ អ្នកទទួល និង/ឬអតិថិជន ត្រូវធានាថានឹងមិនមានការបាត់បង់ទីលំនៅ ឬប្រយោជន៍សេដ្ឋកិច្ចអ្វីឡើយ លុះត្រាតែជនដែលបាត់បង់ទីលំនៅបានទទួលសំណងយ៉ាងពេញលេញ ហើយត្រូវមានកម្មវិធីស្តារចំណូល និងជីវភាព ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដើម្បីជួយ ឱ្យពួកគេធ្វើការកែលំអ ឬយ៉ាងហោចណាស់បានស្តារចំណូល និងជីវភាពរស់នៅរបស់ខ្លួន។ អ្នកខ្ចី និង/ឬអតិថិជន ក៏ត្រូវបានលើកទឹកចិត្តឱ្យជម្រុញឱ្យមានការចូលរួមពីអ្នកដែលរងផលប៉ះពាល់ និងអ្នកទទួលផល ឱ្យបានទូលំទូលាយបំផុតតាម លទ្ធភាពដែលអាចធ្វើទៅបាន។ ការវាយតម្លៃលើផលប៉ះពាល់សង្គមគួរកំណត់ពីបុគ្គល និងក្រុមដែលនឹងទទួលរងផលប៉ះពាល់ដោយមិនសមស្រប និងលើកស្នើនូវវិធានការនានា ដើម្បីឱ្យពួកគេអាចចែករំលែកប្រយោជន៍ និងឱកាសដែលបានមកពីការអភិវឌ្ឍ។

### ការអភិវឌ្ឍសមត្ថភាព សម្រាប់ការស្តារចំណូលឡើងវិញ ប្រទេសកម្ពុជា

ជាផ្នែកមួយនៃគម្រោងផ្តល់ជំនួយបច្ចេកទេសដល់ការស្តារចំណូលសម្រាប់បំពេញបន្ថែម អង្គការក្រៅរដ្ឋាភិបាលមួយត្រូវបានជ្រើសរើសឱ្យធ្វើការរៀបចំ និងអនុវត្តគំនិតផ្តួចផ្តើមអភិវឌ្ឍន៍នៅតាមសហគមន៍។ ការងារនេះរួមមានបង្កើតក្រុមប្រជាពលរដ្ឋ និងរៀបចំនូវគំនិតផ្តួចផ្តើម អភិវឌ្ឍន៍មុខរបរចិញ្ចឹមជីវិតនានា ដូចជាមីក្រូហិរញ្ញវត្ថុ និងការអប់រំមនុស្សពេញវ័យនៅសហគមន៍ជាដើម។

ប្រភព ៖ ADB. 2009. *Technical Assistance to Cambodia for Capacity Development for Income Restoration Programs.* Manila.

### កម្មវិធីវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់វិស័យទេសចរណ៍ ប្រទេសឥណ្ឌា

អ្នកដែលរងផលប៉ះពាល់ ចូលរួមប្រកបដោយអត្ថន័យ នៅក្នុងការបង្កើតតារាងម៉ាទ្រិច បង្ហាញពីប្រយោជន៍ដែលត្រូវទទួលបាន។ នេះរួមមានការផ្តល់ការគាំទ្រដល់ការបណ្តុះបណ្តាល និងដល់សហគ្រិនភាពដើម្បីផ្តល់ប្រយោជន៍ផ្នែកសេដ្ឋកិច្ចដោយផ្ទាល់ដល់សហគមន៍ដែលនៅជុំវិញ។

ប្រភព ៖ ADB. 2010. *Loan to India for the Infrastructure Development Program for Tourism.* Manila.

## ការពិនិត្យតាមដាន និងការរាយការណ៍

អ្នកខ្ចី និង/ឬអតិថិជន និង ADB មានការទទួលខុសត្រូវដោយឡែកពីគ្នា នៅក្នុងការពិនិត្យតាមដាន។ ADB តម្រូវឱ្យអ្នកខ្ចី និង/ឬអតិថិជនបង្កើត និងរក្សានូវនីតិវិធី ដើម្បីធ្វើការពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការ ការពារផលប៉ះពាល់សង្គម និងបរិស្ថាន។ នេះរួមមានការរក្សាអ្នកជំនាញខាងក្រៅដែលមានសមត្ថភាព និងមានបទពិសោធន៍ ឬអង្គការក្រៅរដ្ឋាភិបាលដែលមានសមត្ថភាពដើម្បីធ្វើការផ្ទៀងផ្ទាត់ព័ត៌មានពិនិត្យ ដែលបានមកពីការ ពិនិត្យតាមដាន សម្រាប់គម្រោងដែលមានផលប៉ះពាល់ និងហានិភ័យខ្ពស់។ ធនាគារប្រើប្រាស់គណៈកម្មាធិការផ្តល់ប្រឹក្សាឯករាជ្យ ដើម្បីពិនិត្យតាមដានការអនុវត្តគម្រោង សម្រាប់គម្រោងដែលមានលក្ខណៈស្មុគស្មាញ និងមានភាព រសើបខ្ពស់សកម្មភាពពិនិត្យតាមដាន និងត្រួតពិនិត្យរបស់ ADB រួមមាន ការចុះត្រួតពិនិត្យតាមទីតាំងជាទៀងទាត់ និងការពិនិត្យមើលឯកសារពិនិត្យតាមដាន ដែលអ្នកខ្ចី និង/ឬអតិថិជនផ្ញើមក និងការធ្វើការងារជាមួយពួកគេដើម្បីកែតម្រូវបញ្ហានានា។

### សកម្មភាពតាំងទីលំនៅ នៃគម្រោងអភិវឌ្ឍន៍គមនាគមន៍ភាគខាងត្បូង ប្រទេសស្រីលង្កា

ការឆ្លើយតបចំពោះការស្នើ ដែលផ្ញើមកកាន់គណៈកម្មាធិការពិនិត្យឡើងវិញលើភាពអនុលោមរបស់ ADB ពីក្រុមអ្នករងផលប៉ះពាល់បានផ្តល់ជាអនុសាសន៍ ឱ្យមានការជួលស្ថាប័នឯករាជ្យណាមួយឱ្យពិនិត្យឡើងវិញលើវឌ្ឍនភាពនៃការតាំងទីលំនៅ និងកំណត់ពីចំណុចខ្វះខាតដែលត្រូវធ្វើការកែតម្រូវភ្លាមៗ។ អង្គការក្រៅរដ្ឋាភិបាលមួយត្រូវបានជួលឱ្យធ្វើជាអ្នកពិនិត្យតាមដាន អង្គការមួយទៀតត្រូវបានជួលឱ្យរៀបចំ និងអនុវត្តកម្មវិធីស្តារចំណូលឡើងវិញ ហើយឥឡូវនេះ អ្នកដែលទទួលរងផលប៉ះពាល់អាចប្រើប្រាស់យន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្តប្រកបដោយប្រសិទ្ធភាព។

ប្រភព ៖ ADB. 2005. *Technical Assistance to Sri Lanka for the Independent External Monitoring of Resettlement Activities of the Southern Transport Development Project.* Manila.

## យន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្តនៅមូលដ្ឋាន

ADB តម្រូវឱ្យអ្នកខ្ចី និង/ឬអតិថិជនបង្កើត និងរក្សានូវយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្តមួយ ដើម្បីទទួល និងជួយដោះស្រាយការព្រួយបារម្ភ និងការកើតទុក្ខមិនសុខចិត្តរបស់អ្នករងផលប៉ះពាល់ដោយសារគម្រោង ពាក់ព័ន្ធនឹងការបំពេញការងារផ្នែកសង្គម និងបរិស្ថានរបស់អ្នកខ្ចី និង/ឬអតិថិជន។ យន្តការនេះឆ្លុះបញ្ចាំងពីហានិភ័យ និងផលប៉ះពាល់របស់គម្រោង។ យន្តការនេះគួរអាចកាត់បន្ថយការព្រួយបារម្ភរបស់អ្នកដែលរងផលប៉ះពាល់ និងអាចដោះស្រាយពាក្យបណ្ដឹងនានាភ្លាមៗ ដោយប្រើប្រាស់ដំណើរការដែលអាចយល់បាន ប្រកបដោយតម្លាភាពដែលអាចឆ្លើយតបចំពោះយេនឌ័រ មានភាពសមស្របផ្នែកវប្បធម៌ និងអាចប្រើប្រាស់បាន ដោយគ្រប់អ្នករងផលប៉ះពាល់ទាំងអស់ ដោយមិនចាំបាច់ចំណាយ និងទទួលរងទោសពៃរ៍អ្វីទាំងអស់។ អ្នករងផលប៉ះពាល់នឹងទទួលបានព័ត៌មានយ៉ាងសមស្រប អំពីយន្តការនេះ។ អ្នកដែលរងផលប៉ះពាល់ក៏អាចផ្ញើពាក្យបណ្ដឹងរបស់ខ្លួន ទៅកាន់យន្តការគណនេយ្យភាពរបស់ ADB ផងដែរ។[៦៣]

### គម្រោងគាំទ្រដល់ស្ថានភាពអាសន្នក្រោយគ្រោះរញ្ជួយដី និងស៊ូណាមិ

យន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្ត មានសមាសភាគមួយនៅកម្រិតភូមិ។ ការកើតទុក្ខមិនសុខចិត្តយោបល់ និងសំណួរនានា ដែលទទួលបានពីបុគ្គលសហគមន៍ អង្គការសង្គមស៊ីវិល ។ល។ ត្រូវបានបញ្ជូនបន្តដោយផ្ទាល់ ឬផ្ញើតាមរយៈមេដឹកនាំសហគមន៍ ដូចជាអ្នកដឹកនាំសាសនា មេភូមិ មេឃុំ ឬដោយអង្គការក្រៅរដ្ឋាភិបាលដៃគូ ទៅកាន់អ្នកសម្របសម្រួលតាមភូមិដែលត្រូវបានជ្រើសរើស។

ប្រភព៖ Grievance Mechanisms under the Earthquake and Tsunami Emergency Support Project: www.adb.org/Documents/Books/Complaint-Handling-Rehabilitation/Smidt.pdf

### ធនធាន

សៀវភៅណែនាំ ដែលគាំទ្រដល់ការអនុវត្ត SPS ពាក់ព័ន្ធនឹងបរិស្ថាន ការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត និង ជនជាតិដើមភាគតិចអាចរកបានលើគេហទំព័ររបស់ ADB។ ធនធានដែលមានប្រយោជន៍ទាំងនេះ មានបង្ហាញព័ត៌មានលំអិតអំពីលក្ខខណ្ឌតម្រូវនៃការចូលរួម សម្រាប់ផ្នែកនីមួយៗ។

អង្គការអកស្វាម អូស្ត្រាលី បានចូលរួមចំណែកចំពោះការពិគ្រោះយោបល់អំពី SPS ហើយការបោះពុម្ពផ្សាយ របស់អង្គការនេះ ដែលមានចំណងជើងថា *ស្វែងយល់ពីគោលនយោបាយស្ដីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាន របស់ធនាគារអភិវឌ្ឍន៍អាស៊ី* គឺជាធនធានដ៏មានប្រយោជន៍ ជាពិសេស សម្រាប់ការពិនិត្យតាមដានរបស់សង្គមស៊ីវិល លើការអនុវត្តគោលនយោបាយស្ដីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាននេះ។[៦៤]

# ៧. សមធម៌យេនឌ័រ

## យេនឌ័រ និងការចូលរួម

សមធម៌យេនឌ័រ គឺជាកម្លាំងចលករនៃការផ្លាស់ប្តូរនៅក្នុងយុទ្ធសាស្ត្រ ២០២០ និងមានសារៈសំខាន់យ៉ាងខ្លាំងចំពោះការចូលរួម (លេខយោងទី២)។ គោលនយោបាយស្តីពីយេនឌ័រ និងការអភិវឌ្ឍរបស់ ADB បានអនុម័តយកការ បញ្ជ្រាបថាជាយុទ្ធសាស្ត្រដ៏សំខាន់មួយនៅក្នុងការលើកកម្ពស់សមធម៌យេនឌ័រ។[៦៥] ផែនការសកម្មភាពស្តីពីយេនឌ័រ និងការអភិវឌ្ឍ ២០០៨-២០១០ គាំទ្រឱ្យមានការប្រើប្រាស់គោលវិធីអនុវត្តគោលនយោបាយតាមបែបចូលរួម។[៦៦]

ADB ប្រើប្រាស់ផែនការសកម្មភាពស្តីពីយេនឌ័រ (GAPs) ដើម្បីធានាយ៉ាងណាឱ្យស្ត្រីអាចចូលរួមប្រកបដោយប្រសិទ្ធភាព នៅតាមគម្រោងនានា។[៦៧] GAP គឺជាឧបករណ៍រួមមួយ សម្រាប់ធ្វើការបញ្ជ្រាបយេនឌ័រ និងបាននាំឱ្យមានការកើនឡើងនូវការចូលរួមរបស់ស្ត្រី នៅក្នុងសកម្មភាពកម្មវិធីនានា ជាពិសេសតាមរយៈអង្គការតាមសហគមន៍។ ប្រអប់ខាងក្រោមនេះបង្ហាញពីចំណុចនេះ និងដំបូន្មានដទៃទៀតសម្រាប់បង្កើនការចូលរួមឱ្យដល់កម្រិតអតិបរមា នៅពេលឆ្លើយតបចំពោះការព្រួយបារម្ភផ្នែកយេនឌ័រនៅក្នុងគម្រោងនានា។

### ដំបូន្មាន សម្រាប់ការបង្កើនការចូលរួម នៅក្នុងការឆ្លើយតបចំពោះបញ្ហាយេនឌ័រ នៅក្នុងគម្រោងនានា

**ការរៀបចំគម្រោង**

- **ធ្វើឱ្យការវិភាគយេនឌ័រមានការចូលរួម :** សំណួរនានាត្រូវគ្របដណ្តប់ឱ្យបានទូលំទូលាយលើបញ្ហានៃការចូលរួម (ឧ.កំណត់ពីឧបសគ្គផ្នែកច្បាប់វប្បធម៌ ឬសាសនាដែលធ្វើឱ្យរាំងស្ទះដល់ការចូលរួមរបស់ស្ត្រី ឬក្មេងស្រីនៅក្នុងគម្រោង)។ សូមមើល *សៀវភៅណែនាំអំពីការវិភាគសង្គម និងបញ្ជី ត្រួតពិនិត្យយេនឌ័រតាមវិស័យ* ។[៦៨] ការវិភាគក៏មានដាក់បញ្ចូលផងដែរនូវការប្រើប្រាស់វិធីសាស្ត្រវិភាគ ដោយមានការចូលរួម ដើម្បីទទួលបាន ព័ត៌មានត្រឡប់ពីអ្នកពាក់ព័ន្ធ ដែលមិនអាចចូលរួមបាន ដោយសារបញ្ហា ដែលពាក់ព័ន្ធនឹងអក្ខរភាពភាសា និងបច្ចេកវិទ្យា។ វិធីសាស្ត្រទាំងនេះមាន ប្រយោជន៏បំផុតសម្រាប់ធ្វើការផ្សព្វផ្សាយព័ត៌មានដល់ស្ត្រី និងក្មេងស្រី (សូមមើលឧបករណ៍ទី ៣ :ការវាយតម្លៃដោយមានការចូលរួមទំព័រទី៣៧)។
- **ប្រើប្រាស់គោលវិធីពិគ្រោះយោបល់បែងចែកទៅតាមយេនឌ័រ :** ធ្វើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយនឹងបុរស និងស្ត្រី។ បរិយាកាសវប្បធម៌ប្រហែលជាតម្រូវឱ្យមានការពិគ្រោះយោបល់ដោយឡែកៗពីគ្នា ។គួរមានការជ្រើសរើសពេលវេលាដោយប្រុងប្រយ័ត្ន ទៅតាមពេលវេលាដែលអ្នកពាក់ព័ន្ធចំណាយជាមួយគ្រួសារ និងការងារ។ អង្គការស្ត្រីនៅមូលដ្ឋានអាចជួយរៀបចំការពិគ្រោះយោបល់ជាមួយស្ត្រី នៅក្នុងសហគមន៍មួយបាន (សូមមើលឧបករណ៍ទី ១ : ការវិភាគយេនឌ័រ និងការពិគ្រោះយោបល់ ទំព័រទី ២៥)។

- **បង្កើតផែនការសកម្មភាពយេនឌ័រ ៖** ការជម្រុញឱ្យអ្នកពាក់ព័ន្ធ (ទាំងបុរស ទាំងស្ត្រី) នៅក្នុងការរៀបចំបង្កើតផែនការមួយមានសារៈសំខាន់យ៉ាងខ្លាំង។ ផែនការនេះមានដាក់បញ្ចូលនូវចំណុច ដើម្បីធានាយ៉ាងណាឱ្យគម្រោងនេះអាចមានការចូលរួមពីគ្រប់យេនឌ័រ និងមានសមាសភាគ ដើម្បីផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់ស្ត្រី ឬក្មេងស្រី។ សូមមើល *ADB Briefing Note: Project Gender Action Plans.*[ខ]

## ការអនុវត្តគម្រោង

- **ឆ្លើយតបចំពោះបញ្ហាយេនឌ័រនៅក្នុងការអនុវត្ត ៖** នេះអាចមានទម្រង់ផ្សេងៗជាច្រើន ដូចជាការបន្តពិគ្រោះយោបល់ជាមួយនឹងក្រុមស្ត្រី សកម្មភាពប្រមូលផ្តុំសហគមន៍ ការផ្តល់ការបណ្តុះបណ្តាល និងសកម្មភាពអភិវឌ្ឍមុខរបរចិញ្ចឹមជីវិតសម្រាប់ស្ត្រី និងការផ្តល់នូវសេវាថែទាំសុខភាពដល់ស្ត្រី។ អង្គការសង្គមស៊ីវិល (CSOs) ដែលមានបទពិសោធន៍ផ្នែកយេនឌ័រ អាចអនុវត្តសមាសភាគនៃគម្រោងទាំងនេះបាន។[គ]
- **ប្រើប្រាស់គោលវិធីពិនិត្យតាមដាន និងវាយតម្លៃ បែងចែកទៅតាមយេនឌ័រ ៖** ដាក់បញ្ចូលចំណុចដៅ និងសូចនាករដែលពាក់ព័ន្ធជាមួយនឹងការ ចូលរួមរបស់ស្ត្រី និងលទ្ធភាពរបស់ស្ត្រី ក្នុងការទទួលបានប្រយោជន៍ពីគម្រោង ទៅក្នុងក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដាន និងផែនការសកម្មភាព យេនឌ័រ (GAP) ដូចជាចំនួន/ភាគរយអ្នកទទួលផល និងអ្នកអនុវត្ត (អ្នកកៀងគរសហគមន៍ អ្នកសម្របសម្រួលរបស់អង្គការក្រៅរដ្ឋាភិបាល ។ល។) ដែលជាស្ត្រី (សូមមើលឧបករណ៍ទី ៧ ៖ ការពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួម)។ ការពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួម ដែលមានការចូលរួមរបស់ស្ត្រី ក៏មានតម្លៃដូចគ្នាទៅនឹងការពិនិត្យតាមដានដោយឯករាជ្យ ដែលធ្វើឡើងដោយអង្គការសង្គមស៊ីវិល លើផលប៉ះពាល់ផ្នែកយេនឌ័ររបស់គម្រោងផងដែរ។

## ទូទៅ

- **ជួលមនុស្សដែលមានជំនាញផ្នែកយេនឌ័រ និងការចូលរួម ៖** មនុស្ស ឬអង្គការដែលត្រូវបានជ្រើសរើសឱ្យធ្វើការវិភាគយេនឌ័រ បង្កើត GAPs ឬអនុវត្តសមាសភាគនានារបស់គម្រោងត្រូវមានជំនាញឯកទេស និងបទពិសោធន៍ផ្នែកយេនឌ័រ និងការអភិវឌ្ឍន៍។[ឃ] អង្គការសង្គមស៊ីវិលខ្លួនឯង អាចជាដៃគូ ដែលមានប្រសិទ្ធភាពខ្ពស់។ អង្គការជាច្រើនផ្តោតការងារជាក់លាក់លើបញ្ហាស្ត្រី និងយេនឌ័រ ហើយមានបទពិសោធន៍ និងទំនាក់ទំនងជាច្រើនឆ្នាំជាមួយនឹងសហគមន៍។
- **បែងចែកពេលវេលា និងធនធានឱ្យបានគ្រប់គ្រាន់សម្រាប់ការងារដែលពាក់ព័ន្ធជាមួយនឹងយេនឌ័រ និងការចូលរួម ៖** ចាំបាច់ត្រូវតែមានធនធាន ឱ្យបានគ្រប់គ្រាន់ប្រសិនបើចង់គ្រប់គ្រងបញ្ហាយេនឌ័រ និងការចូលរួមឱ្យមានប្រសិទ្ធភាព នៅក្នុងការរៀបចំ និងការអនុវត្តគម្រោង។ នេះតម្រូវឱ្យមានការចូលរួមពីក្រុមការងារគម្រោងរបស់ ADB ដោយអាចជួលអ្នកដែលមានជំនាញបន្ថែម និងបែងចែកធនធាន ដើម្បីផ្តល់លទ្ធភាពឱ្យស្ត្រី និង ក្មេងស្រី អាចចូលរួមបាន។ សូមមើល *សៀវភៅណែនាំអំពីបញ្ជីត្រួតពិនិត្យសម្រាប់ការវិភាគសង្គម និងយេនឌ័រ នៅក្នុងការរៀបចំគម្រោង* ("តើមានការបែងចែកថវិកាដោយឡែកសម្រាប់ជម្រុញឱ្យមានការចូលរួមពីស្ត្រី និង/ឬក្មេងស្រីដែរឬទេ?") និងបញ្ជីត្រួតពិនិត្យតាមវិស័យ។[ក]

[ក] ADB. 2007. *Handbook on Social Analysis.* Manila. pp. 123–127; ADB. Sector Gender Checklists. http://beta.adb.org/themes/gender/checklists-toolkits

[ខ] ADB. 2009. *Briefing Note. Project Gender Action Plans.* Manila. www.adb.org/Documents/Brochures/Project-Gender-Action-Plans/gender-briefing-note.pdf

[គ] Examples of ADB projects addressing gender concerns. http://beta.adb.org/themes/gender/checklists-toolkits

[ឃ] ADB. 2007. *Handbook on Social Analysis.* Manila. pp. 67–72 (sample terms of reference for contracting consultants with gender and participation expertise in the IPSA and social analysis in project design).

ប្រអប់ខាងក្រោមនេះ បង្ហាញពីឧទាហរណ៍អំពីគម្រោងដែលមានកម្រិតចូលរួមខ្ពស់ និងផ្ដោតសំខាន់លើ សមធម៌យេនឌ័រ ។

**គម្រោងសាកល្បងផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី សាធារណរដ្ឋប្រជាមានិតចិន**
**(គោលវិធីចូលរួម : ការចូលរួម, ភាពស៊ីជម្រៅ : ខ្ពស់)**

គម្រោងនេះមានគោលបំណងបង្កើនចំណូលក្នុងគ្រួសាររបស់ស្ត្រី និងអំណាចធ្វើសេចក្តីសម្រេចចិត្ត នៅក្នុងតំបន់គោលដៅ ។ នេះរួមមានការបង្កើតក្រុម ផលិតកម្មកសិកម្ម ដែលដំណើរការជាមួយនឹងឥណទានខ្នាតតូច និងមានទំនាក់ទំនងជាមួយនឹងសមាគមកសិករដែលមានស្រាប់,បង្កើតក្រុមសន្សំ និងកម្ចីខ្នាតតូចរបស់ស្ត្រី ដែលស្ត្រីជាអ្នកគ្រប់គ្រងដោយខ្លួនឯង និងបង្កើតនូវការបណ្តុះបណ្តាលជំនាញកសិកម្មទៅតាមតម្រូវការរបស់ស្ត្រី ជម្រើសរកប្រាក់ចំណូលគោលវិធីដែលមានការចូលរួម និងការធ្វើសេចក្តីសម្រេចចិត្ត ។ លើសពីនេះការបណ្តុះបណ្តាលអំពីគោលវិធីអភិវឌ្ឍន៍សហគមន៍ដោយ មានការចូលរួមនឹងបង្កើនសមត្ថភាពរបស់ទីភ្នាក់ងាររដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន ក្នុងការផ្តល់ការគាំទ្រ និងផ្តល់ភាពអង់អាចដល់ស្ត្រីក្រីក្រ ។

ប្រភព : ADB. 2009. *Grant to the People's Republic of China for the Women's Economic Empowerment Pilot Project.* Manila.

**គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ ប្រទេសកម្ពុជា** (គោលវិធីចូលរួម : ភាពជាដៃគូ, ភាពស៊ីជម្រៅ : មធ្យម)

គម្រោងនេះផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាឃុំគោលដៅ ដើម្បីឱ្យពួកគេអាចបំពេញតួនាទីរបស់ពួកគេក្នុងការផ្តល់សេវាសាធារណៈឱ្យបានកាន់តែប្រសើរ ជាងមុន ។ សកម្មភាពនានា រួមមានការពង្រឹងការយល់ដឹងជាសាធារណៈអំពីសិទ្ធិប្រជាធិបតេយ្យ និងគណនេយ្យភាព និងលទ្ធភាពទទួលបានយុត្តិធម៌ បង្កើនប្រសិទ្ធភាពរបស់សមាជិកក្រុមប្រឹក្សាជាស្ត្រីដែលជាប់ឆ្នោត និងរៀបចំវេទិកាបណ្តាញស្ត្រីនៅថ្នាក់ស្រុក និងថ្នាក់ឃុំ ។

ប្រភព : ADB. 2006. *Grant to Cambodia for Phase II of the Commune Council Development Project.* Manila.

## ឧបករណ៍ដែលពាក់ព័ន្ធយេនឌ័រ និងការចូលរួម

ADB មានឧបករណ៍ ដើម្បីគាំទ្រដល់ការបញ្ជ្រាបយេនឌ័រ ដែលផ្តោតផងដែរលើបញ្ហានៃការចូលរួម ។ ក្រៅពីឧបករណ៍ដែល ADB មាន មានធនធានខាងក្រៅជាច្រើន ដែលផ្តល់ការគាំទ្រដល់ការបញ្ជ្រាបយេនឌ័រ និងលើកទឹកចិត្តឱ្យមានកម្លាំងផ្លាស់ប្តូរវាងយេនឌ័រ និងការចូលរួម ។ បញ្ជីធនធាននៃមគ្គុទេសក៍នេះ បង្ហាញពីឧបករណ៍ដែលមានភាព ពាក់ព័ន្ធច្រើនបំផុតជាមួយនឹង ADB ។ ឧបករណ៍ទាំងនេះគ្របដណ្តប់លើជំនាញជាច្រើនដូចជាការបង្កើតសូចនាករឆ្លើយតបចំពោះយេនឌ័រ ការវាយតម្លៃយេនឌ័រដែលមានការចូលរួម និងការវិភាគថវិកាឆ្លើយតបចំពោះយេនឌ័រ ។

### ឧបករណ៍ដែលពាក់ព័ន្ធយេនឌ័រ និងការចូលរួមរបស់ ADB

| ឧបករណ៍ | សេចក្ដីពិពណ៌នា |
|---|---|
| កញ្ចប់ឧបករណ៍ស្ដីពីយេនឌ័រ ច្បាប់ និងគោលនយោបាយនៅក្នុង ប្រតិបត្តិការការងាររបស់ ADB[ក] | កញ្ចប់ឧបករណ៍នេះរៀបរាប់ពីបញ្ហាយេនឌ័រ នៅក្នុងការតាក់តែងច្បាប់ និងគោលនយោបាយ និងពីសនិទានភាពសម្រាប់ការចាត់វិធានការពិសេស ដើម្បីកាត់បន្ថយគម្លាត និងការរើសអើងយេនឌ័រ។ កញ្ចប់ឧបករណ៍នេះពិនិត្យលើយេនឌ័រ នៅក្នុងយុទ្ធសាស្ត្រស្ដីពីភាពជាដៃគូប្រចាំប្រទេស (ការដាក់ ពិន្ទុយេនឌ័រ សម្រាប់ការវាយតម្លៃលើលទ្ធផលការងារប្រចាំប្រទេស ការវាយតម្លៃយេនឌ័រប្រចាំ ប្រទេស យុទ្ធសាស្ត្រយេនឌ័រប្រចាំប្រទេស និងផែនទីបង្ហាញផ្លូវតាមវិស័យ) និងនៅក្នុងប្រតិបត្តិការ ការងាររបស់ ADB ។ |
| សៀវភៅណែនាំអំពីការវិភាគសង្គម (HSA)[ខ] | សៀវភៅណែនាំអំពីការវិភាគសង្គម មានដាក់បញ្ចូលបញ្ជីត្រួតពិនិត្យយេនឌ័រ សម្រាប់ការវិភាគបឋម លើភាពក្រីក្រ និងសង្គមការរៀបចំគម្រោង ការស្វែងរកការពិត ឬការវាយតម្លៃគម្រោង និងការ ណែនាំអំពីការបង្កើតផែនការយេនឌ័រ។ បញ្ជីត្រួតពិនិត្យទាំងនេះពាក់ព័ន្ធជាមួយនឹងការចូលរួម ហើយគួរយកមកប្រើប្រាស់ រួមជាមួយនឹងបញ្ជីត្រួតពិនិត្យតាមវិស័យដែលមាន ដើម្បីធានាឱ្យមានការចូល រួមឱ្យបានគ្រប់គ្រាន់ នៅក្នុងការរៀបចំ និងការអនុវត្តគម្រោង។ |
| បញ្ជីត្រួតពិនិត្យយេនឌ័រតាមវិស័យ[គ] | បញ្ជីត្រួតពិនិត្យទាំងនេះ រួមមាន កត្តានានាដែលពាក់ព័ន្ធជាមួយនឹងយេនឌ័រ (ដូចជា ការចូលរួមរបស់ស្ត្រី) នៅក្នុងគម្រោងកសិកម្ម អប់រំសុខភាព ការតាំងទីលំនៅការអភិវឌ្ឍទីក្រុង និងលំនៅដ្ឋាន និងការផ្គត់ផ្គង់ទឹក និងអនាម័យ។ សំណួរនានា រួមមាន : តើយុទ្ធសាស្ត្រ និងចំណុចដៅដែលពាក់ព័ន្ធនឹងការចូលរួមរបស់ស្ត្រី ត្រូវបានដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដានរបស់គម្រោង (DMF) ដែរឬទេ? តើមានគោលនយោបាយ និងកម្មវិធី (របស់ក្រសួងរដ្ឋាភិបាល ទីភ្នាក់ងារប្រតិបត្តិអង្គការក្រៅរដ្ឋាភិបាល ។ល។) ដែលមានគោលបំណងធានាឱ្យមានការចូលរួមរបស់ស្ត្រីអ្វីខ្លះ ដែលអាចមានផលប៉ះពាល់ដល់គម្រោង? |
| កំណត់ហេតុសង្ខេបៈ ផែនការសកម្មភាពយេនឌ័ររបស់គម្រោង (GAPs)[ឃ] | កំណត់ហេតុសង្ខេបនេះបង្ហាញថា GAPs របស់គម្រោងគួរត្រូវបានរៀបចំឡើង នៅក្នុងកំឡុងពេល រៀបចំគ្រប់គម្រោងទាំងអស់ដែលផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់សហគមន៍ និងផ្តល់នូវមេរៀន សម្រាប់បង្កើត GAPs របស់គម្រោងប្រកបដោយប្រសិទ្ធភាព។ កំណត់ហេតុនេះផ្តល់ការណែនាំអំពី ការដាក់បញ្ចូលការបង្កើត GAP ទៅក្នុងការរៀបចំគម្រោង និងនៅក្នុងរបាយការណ៍ និងអនុសាសន៍ របស់ប្រធានធនាគារ (នេះរាប់បញ្ចូលការធានាយ៉ាងណាឱ្យចំណុចដៅ និងកូតា ដែលពាក់ព័ន្ធនឹងការ ចូលរួមរបស់ស្ត្រី និងប្រយោជន៍ដែលទទួលបានពីគម្រោងរបស់ GAP នៅក្នុង DMF) ទៅក្នុងការ ចាប់ផ្តើមកម្ចី (ប្រែក្លាយ GAP នៃការរៀបចំគម្រោង ឱ្យក្លាយជាការអនុវត្តលំអិតនៃ GAP) និង ការអនុវត្ត ការពិនិត្យតាមដាន និងការពិនិត្យឡើងវិញលើកម្ចី (តាមដានបន្តដើម្បីធានាយ៉ាងណា ឱ្យមានការអនុវត្ត GAP និងដោះស្រាយបញ្ហានានា ដែលកើតមានឡើង) ។ |

[ក] ADB. 2006. *Gender, Law and Policy in ADB Operations: A Tool Kit.* Manila. www.adb.org/Documents/Manuals/Gender-Toolkit/Gender-Law-Policy-Toolkit.asp

[ខ] ADB. 2007. *Handbook on Social Analysis.* Manila. pp. 123–127 (Appendix 6. Gender and Development).

[គ] ADB. Sector Gender Checklists (agriculture, education, health, resettlement, urban development and housing, and water supply and sanitation): http://beta.adb.org/themes/gender/checklists-toolkits

[ឃ] ADB. 2009. *Briefing Note. Project Gender Action Plans.* Manila. www.adb.org/Documents/Brochures/Project-Gender-Action-Plans/gender-briefing-note.pdf

## ៣. អភិបាលកិច្ចល្អ និងការអភិវឌ្ឍសមត្ថភាព

### អភិបាលកិច្ចល្អ និងការចូលរួម

អភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍សមត្ថភាព គឺជាកម្លាំងចលករជម្រុញឱ្យមានការផ្លាស់ប្តូរមួយ នៅក្នុងយុទ្ធសាស្ត្រ ២០២០ និងមានទំនាក់ទំនងយ៉ាងជិតស្និទជាមួយនឹងការចូលរួម ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងមគ្គុទេសក៍ នេះ (លេខយោងទី ២)។ ការចូលរួម គឺជាសកម្មភាពគាំទ្រឱ្យគ្នាទៅវិញទៅមកមួយក្នុងចំណោមសកម្មភាពទាំង ៤ នៅក្នុងគោលនយោបាយអភិបាលកិច្ចរបស់ ADB ។[៦៨] គោលនយោបាយនេះលើកឡើងថា ការចូលរួមកើតឡើងពីការ ទទួលស្គាល់ថា មនុស្ស គឺជាស្នូលនៃការអភិវឌ្ឍ។ ពួកគេមិនមែនត្រឹមតែអ្នកទទួលផលចុងក្រោយប៉ុណ្ណោះទេ ប៉ុន្តែគឺជាភ្នាក់ងារនៃការអភិវឌ្ឍ។ ការចូលរួម រួមមានការចូលរួមរបស់អ្នកទទួលផល និងក្រុមដែលទទួលរងផលប៉ះពាល់ការជួបប្រសព្វគ្នារវាងវិស័យសាធារណៈ/វិស័យឯកជន ការធ្វើវិមជ្ឈការមុខងារសាធារណៈ និងមុខងារផ្តល់សេវា (ការផ្តល់ភាពអង់អាចដល់រដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន) និងការសហការជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលនានា។

ផែនការសកម្មភាពស្តីពីអភិបាលកិច្ច និងការប្រឆាំងនឹងអំពើពុករលួយទី ២ (GACAP II) រៀបរាប់ពីការងារ ជាអាទិភាពចំនួន៣ សម្រាប់ ADB ដែលសុទ្ធតែជាវិស័យដែលមានសារៈសំខាន់ មិនថាចំពោះវិស័យណានោះទេ ដូចជាការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ លទ្ធកម្ម និងភាពងាយរងគ្រោះចំពោះអំពើពុករលួយ។[៦៩] នៅក្នុងការអនុវត្តផែនការសកម្មភាពនេះ ADB ធ្វើការវាយតម្លៃលើហានិភ័យផ្នែកអភិបាលកិច្ច និងផែនការគ្រប់គ្រងហានិភ័យ (RAMPs) នៅ ៣ កម្រិត ដូចជានៅកម្រិតជាតិ កម្រិតវិស័យ និងកម្រិតកម្មវិធី/គម្រោង។ ការវាយតម្លៃទាំងនេះ ពិនិត្យលើចំណុចខ្លាំងរបស់ស្ថាប័នផ្លូវការ (រដ្ឋាភិបាល) និងស្ថាប័នក្រៅផ្លូវការដំណើរការ និងទំនាក់ទំនងរបស់អ្នកពាក់ព័ន្ធនៅក្នុងការងារទាំង ៣ ខាងលើនេះ និងធ្វើការវាយតម្លៃពីវិសាលភាពនៃហានិភ័យ ដែលអាចកើតមានសម្រាប់ ADB ។

> ផែនការសកម្មភាពស្តីពីអភិបាលកិច្ច និងការប្រឆាំងនឹងអំពើពុករលួយទី ២ (GACAP II) ផ្តោតជាសំខាន់លើការជម្រុញឱ្យមានការចូលរួមពីអង្គការសង្គមស៊ីវិល ដើម្បីលើកកម្ពស់ឱ្យមានទំនាក់ទំនងរវាងរដ្ឋាភិបាលរបស់ប្រទេស កំពុងអភិវឌ្ឍជាសមាជិក និងប្រជាពលរដ្ឋ ដើម្បីពង្រឹងការចូលរួម និងបង្កើនគណនេយ្យភាព។ ផែនការនេះលើកទឹកចិត្ត ឱ្យមានការចូលរួមពីសង្គមស៊ីវិល។
>
> ប្រភព៖ ADB. 2006. *Second Governance and Anticorruption Action Plan (GACAP II)*. Manila.

ចាំបាច់ត្រូវមានការយល់ដឹងស៊ីជម្រៅអំពីរចនាសម្ព័ន្ធលើកទឹកចិត្ត នៅក្នុងប្រទេស និង/ឬវិស័យ ដើម្បីកំណត់ ពីសកម្មភាពកាត់បន្ថយហានិភ័យសំដៅធ្វើការផ្លាស់ប្តូរឥរិយាបថរបស់អ្នកពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព។[៧០] នៅក្នុងការកាត់បន្ថយហានិភ័យ ADB ធ្វើការងារនៅខាងផ្នែកផ្គត់ផ្គង់ នៃអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋាភិបាល។ នៅខាងផ្នែកតម្រូវការ ADB ដាក់ឱ្យអនុវត្តនូវការចូលរួមរបស់អង្គការសង្គមស៊ីវិល និងគណនេយ្យភាពសង្គម។

## ជំហានដើម្បីបង្កើនការចូលរួមឱ្យដល់កម្រិតអតិបរមា នៅក្នុងការវាយតម្លៃ និងដោះស្រាយបញ្ហាអភិបាលកិច្ច

### ការវាយតម្លៃលើហានិភ័យផ្នែកអភិបាលកិច្ច

- **ធានាយ៉ាងណាឱ្យការវាយតម្លៃនានា ធ្វើឡើងដោយមានការចូលរួម និងពិនិត្យលើរចនាសម្ព័ន្ធក្រៅផ្លូវការផងនិងផ្លូវការផង :** ការវិភាគអ្នកពាក់ព័ន្ធ ពិនិត្យលើទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធនានា (ឧ. អង្គការក្រៅរដ្ឋាភិបាល សហជីព សមាគមឧស្សាហកម្ម និង ប្រព័ន្ធផ្សព្វផ្សាយ)។ នេះត្រូវមានការចូលរួមពីអ្នកពាក់ព័ន្ធនានា តាមរយៈការសម្ភាស ការពិភាក្សាក្រុមគោលដៅ ការពិភាក្សា ឬ កិច្ចប្រជុំប្រមូលគំនិត ដើម្បីកំណត់ឱ្យបានពេញលេញអំពីកន្លែងដែលមានហានិភ័យ និងឱកាសសម្រាប់បង្កើនការចូលរួម (សូម មើលឧបករណ៍ទី ១ : ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ទំព័រទី ២៥)។ ការវិភាគអ្នកពាក់ព័ន្ធលើកកម្ពស់ឱ្យមាន (i) ការទាមទារគណនេយ្យភាពពីអ្នកពាក់ព័ន្ធ និង (ii) ការផ្តល់នូវអភិបាលកិច្ច (ដែលអ្នកដែលមានតួនាទីកាន់អំណាចចែករំលែកនូវ ព័ត៌មាន ចាត់វិធានការក្នុងក្របខ័ណ្ឌនិយ័តកម្មដែលមានការកំណត់ច្បាស់លាស់ បែងចែកធនធានប្រកបដោយតម្លាភាព ផ្តល់ឱកាសដើម្បីឱ្យមានការចូលរួម និងមានគណនេយ្យភាពចំពោះសកម្មភាពរបស់ពួកគេ)។[ក]
- **ធ្វើការងារក្នុងភាពជាដៃគូជាមួយនឹងអង្គការសង្គមស៊ីវិល (CSOs) ដែលមានបទពិសោធន៍ :** អង្គការសង្គមស៊ីវិលដែលមានឯកទេសវាយតម្លៃហានិភ័យដោយមានការចូលរួម ធ្វើឱ្យដំណើរការនេះកាន់តែមានភាពស៊ីជម្រៅ និងផ្តល់លទ្ធភាពឱ្យមានការយល់ដឹងយ៉ាងច្រើនអំពីរចនាសម្ព័ន្ធនៃការផ្តល់ការលើកទឹកចិត្ត និងទំនាក់ទំនងរបស់អ្នកពាក់ព័ន្ធ។នេះគឺជាអ្វីដែលបានរកឃើញនៅក្នុង ប្រទេសម៉ុងហ្គោលី ដែលADBធ្វើការងារជាដៃគូជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិដែលមានមូលដ្ឋានរឹងមាំមួយ ដើម្បីធ្វើការវាយតម្លៃលើហានីភ័យផ្នែកអភិបាលកិច្ច និងរៀបចំផែនការគ្រប់គ្រងហានិភ័យ។[ខ]

### ការដោះស្រាយបញ្ហាអភិបាលកិច្ច

- ដាក់បញ្ចូលការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋាភិបាល ជាមួយនឹងការលើកកម្ពស់យន្តការគណនេយ្យភាពសង្គម : ការបង្កើតយន្តការជាក់លាក់ ដើម្បីធានាយ៉ាងណាឱ្យមានការធ្វើសេចក្តីសម្រេចចិត្តដែលមានការចូលរួម និងផ្តល់លទ្ធភាពឱ្យមានការត្រួតពិនិត្យឱ្យបានច្រើនពីសង្គមស៊ីវិល គឺជាការបំពេញបន្ថែមលើការបណ្តុះបណ្តាលរបស់រដ្ឋាភិបាល។ នេះអាចមានផលប៉ះពាល់លើរចនាសម្ព័ន្ធក្រៅផ្លូវការផង និងផ្លូវការផង (សូមមើលឧបករណ៍ស្តីពីអភិបាលកិច្ចល្អ និងការចូលរួម)។

[ក] ADB. Sector Risk Assessment Guidance Notes: Education Guidance Note: www.adb.org/Documents/Guidelines/Education-Sector-Risk-Assessment/Guidance-Note-Education-Sector-Risk-Assessment.pdf; Road Transport: www.adb.org/Documents/Guidelines/Road-Transport-Subsector-Risk-Assessment/default.asp; Urban Water: www.adb.org/Documents/Guidelines/Urban-Water-Sector-Risk-Assessment/Guidance-Note-Urban-Water-Supply-Sector-Risk-Assessment.pdf: Electricity: www.adb.org/Documents/Guidelines/Electricity-Sector-Risk-Assessment/Guidance-Note-Electricity-Sector-Risk-Assessment.pdf

[ខ] ADB. 2009. *The Governance Brief. Risk-Based Governance Assessment: An Approach to Assist in Mainstreaming Governance.* Manila.

ខាងក្រោមនេះ គឺជាឧទាហរណ៍បង្ហាញពីអន្តរាគមន៍គ្រប់គ្រងហានិភ័យរបស់ ADB ដែលបានដាក់បញ្ចូលគណនេយ្យភាពសង្គម និងការចូលរួមរបស់សង្គមស៊ីវិល ។

## យន្តការពិនិត្យតាមដានគណនេយ្យភាពសង្គម

**ប្រទេសនេប៉ាល់ :** ការវាយតម្លៃហានិភ័យនៅក្នុងវិស័យអភិវឌ្ឍន៍ទីក្រុង បានកំណត់នូវហានិភ័យធំៗ នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លទ្ធកម្ម និងអំពើពុករលួយ ។ ផែនការកាត់បន្ថយ និងគ្រប់គ្រងហានិភ័យរបស់ ADB ដាក់បញ្ចូលការអភិវឌ្ឍសមត្ថភាព របស់រដ្ឋាភិបាលរួមជាមួយនឹងការគាំទ្រដល់គណៈកម្មការស៊ើបអង្កេត លើករណីប្រើអំណាចដោយបំពាន និងការគាំទ្រដល់អង្គការ និងក្រុមសង្គមស៊ីវិល ។

**ប៉ាស៊ីហ្វិច :** ការវាយតម្លៃហានិភ័យរបស់ប្រទេសបានបង្ហាញឱ្យឃើញថា មានយន្តការតែមួយចំនួនតូចតែប៉ុណ្ណោះ ដើម្បីលើកទឹកចិត្ត ឱ្យមានការចូលរួមពីសង្គមស៊ីវិល នៅក្នុងដំណើរការនៃការបែងចែកធនធាន តាមរយៈការរៀបចំថវិកាប្រចាំឆ្នាំ ។ ជាធម្មតាមិនមានទំនាក់ទំនងដែលមានលក្ខណៈស្ថាបនានោះឡើយ ។ ដូច្នេះហើយជំនួយបច្ចេកទេសថ្នាក់តំបន់មួយត្រូវបានបង្កើតឡើងដើម្បីលើកទឹកចិត្តឱ្យអ្នកពាក់ព័ន្ធចូលរួម នៅក្នុងការជជែកវែកញែកវិភាគដាក់អាទិភាពនិងពិនិត្យតាមដានការសម្រេចចិត្តអំពីចំណាយ និងការវិនិយោគសាធារណៈ ។

ប្រភព Philippine ref; ADB. 2009. *Nepal: Sector Level Risk Assessment and Risk Management Plan to Assess Public Financial Management, Procurement and Corruption Risks in the Urban Sector.* Consultant's report. Manila; ADB. 2003. *Technical Assistance for Civil Society Participation in Budget Formulation in the Pacific.* Manila.

ក៏មានទំនាក់ទំនងសំខាន់ៗផងដែររវាងការចូលរួម នៅក្នុងវិស័យអភិបាលកិច្ច និងយេនឌ័រ ។ ឧទាហរណ៍ នៅក្នុងប្រទេសប៉ាគីស្ថាន ជំនួយបច្ចេកទេសរបស់ ADB បានគាំទ្រដល់ការពង្រឹងការអនុវត្តការប្តេជ្ញាចិត្ត ដែលមានក្នុង គោលនយោបាយស្តីពីយេនឌ័រ នៅក្នុងកម្មវិធីកាត់បន្ថយភាពក្រីក្រ និងកំណែទម្រង់អភិបាលកិច្ច ។ សកម្មភាពនានា រួមមានកិច្ចពិគ្រោះយោបល់កម្រិត គោលនយោបាយជាមួយអ្នកពាក់ព័ន្ធនានា ការលើកកម្ពស់ឱ្យមានការចូលរួមរបស់ ស្ត្រី នៅក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចកម្រិតនយោបាយ និងកម្រិតរដ្ឋបាល និងការផ្តល់មូលនិធិដល់រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលក្នុងការអនុវត្តសមាសភាគផ្សេងៗ នៃផែនការសកម្មភាពស្តីពីកំណែទម្រង់យេនឌ័រ ។[៧១]

### ឧបករណ៍ដែលពាក់ព័ន្ធនឹងអភិបាលកិច្ចល្អ និងការចូលរួម

ADB គាំទ្រដល់ការឧបករណ៍នានា ដើម្បីលើកកម្ពស់ឱ្យមានការចូលរួមនៅក្នុងអភិបាលកិច្ចល្អ ។

| ឧបករណ៍ | សេចក្តីពិពណ៌នា |
| --- | --- |
| **កញ្ចប់ឧបករណ៍ស្តីពីប័ណ្ណរាយការណ៍របស់ ប្រជាពលរដ្ឋ (CRC)** [ក] | កញ្ចប់ឧបករណ៍ CRC ផ្តល់ការណែនាំដល់អ្នកប្រើប្រាស់ តាមជំហានសំខាន់ៗខាងក្រោម នៅក្នុង ដំណើរការ CRC :<br>• **ជំហានទី ១ វាយតម្លៃលើស្ថានភាពក្នុងមូលដ្ឋាន :** កំណត់ថាស្ថានភាពមានភាពសមស្រប សម្រាប់អនុវត្ត CRC ដែរឬទេ<br>• **ជំហានទី ២ ធានាឱ្យមានការរៀបចំមុនពេលធ្វើការអង្កេត :** កំណត់ពីវិសាលភាពនៃ CRC និង រៀបចំផែនការអនុវត្ត<br>• **ជំហានទី ៣ ធ្វើការអង្កេត :** បណ្តុះបណ្តាលអ្នកស្រាវជ្រាវ សម្ភាសជាមួយអ្នកឆ្លើយតប និងធ្វើការកត់ត្រាទិន្នន័យ<br>• **ជំហានទី ៤ វិភាគក្រោយការអង្កេត :** កំណត់ពីលទ្ធផលរកឃើញសំខាន់ៗអំពីការមានសេវា ការប្រើប្រាស់សេវាការពេញចិត្តនឹងសេវា ។ល។<br>• **ជំហានទី ៥ ផ្សព្វផ្សាយលទ្ធផលរកឃើញ :** ចែករំលែកជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ (សារព័ត៌មានប្រជាពលរដ្ឋ និងអ្នកផ្តល់សេវា)<br>• **ជំហានទី ៦ កែលំអសេវា :** ប្រើប្រាស់លទ្ធផលរកឃើញរបស់ CRCដើម្បីកែលំអសេវា (ឧ.សិក្ខាសាលាជាមួយអ្នកផ្តល់សេវាដើម្បីធ្វើការចែករំលែកការអនុវត្តល្អៗ វេទិកាសាធារណៈ សាកល្បងកំណែទម្រង់ថ្មីៗ) |
| **កំណត់សម្គាល់ផ្តល់ការណែនាំអំពីការវាយតម្លៃហានិភ័យតាមវិស័យ** [ខ] | កំណត់សម្គាល់ណែនាំតាមវិស័យនេះត្រូវបានព្រាងឡើង សម្រាប់វិស័យជាអាទិភាពដូចជាវិស័យថាមពលការផ្គត់ផ្គង់ទឹកនៅទីក្រុង អប់រំ និងផ្លូវថ្នាក់ ។ កំណត់សម្គាល់ទាំងនេះផ្តល់ការបញ្ជាក់ពីលក្ខណៈដោយឡែកៗពីគ្នា នៃវិស័យនីមួយៗ និងរំលេចឱ្យឃើញពីឱកាសចូលរួមនៅក្នុងដំណើរការវាយតម្លៃហានិភ័យ ។ កំណត់សម្គាល់ទាំងនេះមានដាក់បញ្ចូលការវិភាគអ្នកពាក់ព័ន្ធ ដែលពិនិត្យលើទំនាក់ទំនងផ្លូវការ និងក្រៅផ្លូវការរវាងអ្នកពាក់ព័ន្ធនានា ដើម្បីជួយកំណត់កន្លែង ដែលអាចមានហានិភ័យ និងឱកាសបង្កើនការចូលរួម ។<br>• នៅក្នុងវិស័យអប់រំ កំណត់សម្គាល់ណែនាំនេះទទួលស្គាល់ថា "កង្វះការចូលរួមរបស់បុគ្គលិកសិក្សា សិស្ស មាតាបិតា និងតំណាងសង្គមស៊ីវិលផ្សេងទៀត អាចធ្វើឱ្យចុះខ្សោយដល់គណនេយ្យភាព និងនាំឱ្យមានការប្រើប្រាស់ថវិកាដោយបំពាន" ។<br>• នៅក្នុងវិស័យផ្គត់ផ្គង់ទឹក និងអគ្គិសនីក្នុងទីក្រុង មានការកំណត់ស្រដៀងគ្នាថា "សមត្ថភាពនៅមានកម្រិត ដើម្បីឱ្យមានការចូលរួមពីក្រុមអតិថិជនសមាគមឧស្សាហកម្ម និងសមាគមវិជ្ជាជីវៈ និងអង្គការសង្គមស៊ីវិល នៅក្នុងដំណើរការរៀបចំផែនការតាមវិស័យ អាចធ្វើឱ្យចុះខ្សោយនូវ ភាពឆ្លើយតបរបស់ផែនការ" ។ |
| **មគ្គុទេសក៍ស្តីពីការវាយតម្លៃសមត្ថភាពលទ្ធកម្មរបស់ទីភ្នាក់ងារប្រតិបត្តិ (EA)** [គ] | **ឧបករណ៍នេះផ្តល់ការគាំទ្រដល់ការកំណត់ពីហានិភ័យនៃការអនុវត្ត ដែលពាក់ព័ន្ធនឹងធនធានលទ្ធកម្ម និងរចនាសម្ព័ន្ធ និងដំណើរការនានារបស់ទីភ្នាក់ងារប្រតិបត្តិ ។ ឧបករណ៍នេះក៏ស្នើផងដែរ នូវវិធានការកាត់បន្ថយហានិភ័យ ដើម្បី ADB និងអ្នកខ្ចីរបស់ខ្លួនយកទៅធ្វើការពិចារណា ។** |
| **ការពិនិត្យឡើងវិញលើលទ្ធកម្ម ដើម្បីធានាឱ្យមាន ការអនុវត្តប្រកបដោយប្រសិទ្ធភាព(PREI)** [ឃ] | **PREI គឺជាវិធីសាស្ត្រមួយរបស់ ADB ដែលប្រើប្រាស់សូចនាករ ដើម្បីវាយតម្លៃ និងពិនិត្យ តាមដានការងារលទ្ធកម្ម សកម្មភាពប្រព័ន្ធ និងការរៀបចំស្ថាប័នរបស់ទីភ្នាក់ងារប្រតិបត្តិ ឬរបស់ទីភ្នាក់ងារអនុវត្ត ។ វិធីសាស្ត្រនេះគាំទ្រដល់ការកំណត់ និងការដោះស្រាយហានិភ័យ និងភាពងាយរងគ្រោះ ដែលពាក់ព័ន្ធជាមួយនឹងលទ្ធកម្ម ក្នុងគោលបំណងពង្រឹងការអនុវត្តគម្រោង ។** |

[ក] The Citizen Report Card Toolkit. www.citizenreportcard.com/index.html

[ខ] ADB. Sector Risk Assessment Guidance Notes: Education Guidance Note: www.adb.org/Documents/Guidelines/Education-Sector-Risk-Assessment/Guidance-Note-Education-Sector-Risk-Assessment.pdf; Road Transport: www.adb.org/Documents/Guidelines/Road-Transport-Subsector-Risk-Assessment/default.asp; Urban Water: www.adb.org/Documents/Guidelines/Urban-Water-Sector-Risk-Assessment/Guidance-Note-Urban-Water-Supply-Sector-Risk-Assessment.pdf: Electricity: www.adb.org/Documents/Guidelines/Electricity-Sector-Risk-Assessment/Guidance-Note-Electricity-Sector-Risk-Assessment.pdf

[គ] ADB. Guide to ADB Procurement Capacity Assessment. Manila (accessible via My ADB cosopedia).

[ឃ] ADB. Procurement Review for Effective Implementation User's Guide and Manual. Manila.

បញ្ជីធនធាននៃមគ្គុទេសក៏នេះ បង្ហាញពីធនធានដែលមានប្រយោជន៏នានា ដែលបង្កើតឡើងដោយអង្គការខាងក្រៅ សម្រាប់លើកកម្ពស់នូវគណនេយ្យភាពសង្គម នៅក្នុងប្រតិបត្តិការនានារបស់ ADB ។ មានការងារត្រួតគ្នាជាច្រើន ជាមួយនឹងវិធីសាស្ត្រ ដែលរៀបរាប់ក្នុងឧបករណ៏វដ្តគម្រោង នៅក្នុងមគ្គុទេសក៏នេះ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីទំនាក់ ទំនងយ៉ាងជិតស្និទ្ធរវាងអភិបាលកិច្ច និងការចូលរួម ។

ឧទាហរណ៏ល្អ១ ដែលបង្ហាញពីអង្គការ ដែលធ្វើការងារផ្នែកការចូលរួមរបស់សង្គមស៊ីវិល និងអភិបាលកិច្ច នៅ ក្នុងតំបន់នេះ រួមមានបណ្តាញគណនេយ្យភាពសង្គមនៅអាស៊ីខាងកើត និងប៉ាស៊ីហ្វិច (ANSA-EAP) ដែលជាបណ្តាញ ថ្នាក់តំបន់ ធ្វើការងារលើកកម្ពស់គណនេយ្យភាពសង្គម និងបណ្តាញគណនេយ្យភាពសង្គមនៅអាស៊ីខាងត្បូង ដែលជាគំនិតផ្តួចផ្តើមរបស់ធនាគារពិភពលោក ដើម្បីបង្កើតឱ្យមានការយល់ដឹងឱ្យបានទូលំទូលាយរវាងរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល អំពីការប្រើប្រាស់ឧបករណ៏គណនេយ្យភាពសង្គម ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ ។[៧២]

## ៤. ហេដ្ឋារចនាសម្ព័ន្ធ-ការបង្ការមេរោគ និងជំងឺអេដស៍

### ការបង្ការមេរោគ និងជំងឺអេដស៍ និងការចូលរួម

ហេដ្ឋារចនាសម្ព័ន្ធ គឺជាវិស័យដ៏សំខាន់មួយសម្រាប់ ADB ។ ខណៈពេលដែលមានការបង្ហាញចេញឱ្យឃើញ យ៉ាងច្បាស់អំពីអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច មានការទទួលស្គាល់កាន់ច្រើនឡើងអំពីភាពចាំបាច់ ដើម្បីកាត់បន្ថយផលបះពាល់ជាអវិជ្ជមាន ដែលគេមិនចង់ឱ្យមាន និងគ្រោះថ្នាក់នានា។ នៅក្នុងឆ្នាំ ២០០៥ ADB បានដាក់ចេញនូវ *ការឆ្លើយតបជាយុទ្ធសាស្ត្ររបស់ខ្លួន ចំពោះការឆ្លងរាលដាលមេរោគ និងជំងឺអេដស៍* ហើយផែនការនេះទទួលបានការគាំទ្រដោយផែនការប្រតិបត្តិសុខាភិបាលឆ្នាំ២០០៨ ក្រោមយុទ្ធសាស្ត្រ២០២០។ លើសពីនេះគំនិតផ្តួចផ្តើមគមនាគមន៍/ដឹកជញ្ជូនប្រកបដោយនិរន្តរភាព ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ ២០១០ ក៏ទទួលស្គាល់ផងដែរ អំពីភាពចាំបាច់ ដើម្បីកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននានា ដែលពាក់ព័ន្ធជាមួយនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងមេរោគ និងជំងឺអេដស៍។ ផែនការប្រតិបត្តិនេះផ្តល់អាទិភាព ដល់ការគាំទ្រដល់ការសម្រេចលទ្ធផលផ្នែកសុខភាព តាមរយៈប្រតិបត្តិការផ្នែកហេដ្ឋារចនាសម្ព័ន្ធ ហើយបានផ្តល់ជា អនុសាសន៍ដាក់លាក់ឱ្យមានការបញ្ជ្រាបការបង្ការមេរោគអេដស៍ ទៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធនានា ជាពិសេសគម្រោងផ្លូវថ្នល់។[៧៣]

> *នៅក្នុងឆ្នាំ ២០០៦ ADB បានចុះហត្ថលេខាលើគំនិតផ្តួចផ្តើមរួមមួយរបស់ទីភ្នាក់ងារអភិវឌ្ឍន៍នានា សម្រាប់ វិស័យហេដ្ឋារចនាសម្ព័ន្ធ ដើម្បីកាត់បន្ថយការឆ្លងរាលដាលមេរោគ/ជំងឺអេដស៍* ។ADB អនុវត្តគំនិតផ្តួចផ្តើមនេះ នៅកម្រិតប្រទេស និងតំបន់ដោយធ្វើការងារក្នុងភាពជាដៃគូជាមួយនឹងដៃគូអភិវឌ្ឍន៍ដទៃទៀតដែលជាហត្ថលេខីរដ្ឋាភិបាល និងវិស័យឯកជន។
>
> ប្រភព: ADB, African Development Bank, Department for International Development, World Bank, Japan Bank for International Cooperation, and KfW. 2006. *Joint Initiative by Development Agencies for the Infrastructure Sectors to Mitigate the Spread of HIV/AIDS*. Toronto.

ADB ប្តេជ្ញាចិត្ត ក្នុងការបង្កើតនូវភាពជាដៃគូ ដែលមានលក្ខណៈច្នៃប្រឌិត។ នេះរួមមានការប្រើប្រាស់ គោលវិធីតាមបែបចូលរួម និងការសហការជាមួយនឹងអង្គការសង្គមស៊ីវិលនិងសហគមន៍ដើម្បីផ្តល់ការគាំទ្រដល់យន្តការមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាពជាងមុនសំដៅផ្តល់ជំនួយដល់ក្រុមដែលងាយរងគ្រោះ និងក្រុមដែលជួបប្រទះការលំបាក។[៧៤]

## ជំហ្វូនាន ដើម្បីបង្កើនការចូលរួមក្នុងការអនុវត្តគម្រោងបង្ការមេរោគអេដស៍ឱ្យបានជាអតិបរមា

- **ធានាយ៉ាងណាឱ្យមានការចូលរួមពីសហគមន៍ នៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃវដ្តគម្រោង[ក] :**
  - **ការតស៊ូមតិនិងការកសាងសមត្ថភាព :** ធានាយ៉ាងណាឱ្យមានការចូលរួមប្រកបដោយអត្ថន័យពីសំណាក់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ដូចជាស្ត្រីជនចំណាកស្រុកប្រជាពលរដ្ឋចល័ត និងអ្នកដែលរស់នៅជាមួយឬរងផលប៉ះពាល់ដោយសារមេរោគ និងជំងឺអេដស៍នៅក្នុងការរៀបចំអន្តរាគមន៍នានា និងនៅក្នុងការផ្តល់ការអប់រំអំពីមេរោគអេដស៍ ។
  - **សេវាមេរោគ និងជំងឺអេដស៍សំខាន់ៗ :** ធានាយ៉ាងណាឱ្យសម្ភារព័ត៌មានអប់រំ និងប្រាស្រ័យទាក់ទងនានា ត្រូវបានបង្កើតឡើង និងធ្វើតេស្តសាកល្បង ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ ហើយសកម្មភាពអប់រំផ្សព្វផ្សាយអំពីការផ្លាស់ប្តូរឥរិយាបថត្រូវបានអនុវត្ត ឡើង ដោយប្រើប្រាស់គោលវិធី ដែលមានការចូលរួមពីសហគមន៍ ។
  - **ការស្រាវជ្រាវការពិនិត្យតាមដាន និងការវាយតម្លៃ :** បង្កើតគណៈកម្មាធិការដឹកនាំការពិនិត្យតាមដាន និងវាយតម្លៃដែលមានការចូលរួមពីអ្នកដឹកនាំសហគមន៍នៅមូលដ្ឋាន ។ បណ្តុះបណ្តាលអ្នកដឹកនាំសហគមន៍និងមន្ត្រីរដ្ឋាភិបាលនៅមូលដ្ឋានអំពីជំនាញសិក្សា រៀនសូត្រ និងធ្វើសកម្មភាព ។ រៀបចំសិក្ខាសាលាពាក់កណ្តាល និងបញ្ចប់គម្រោងដោយមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ ។

- **ប្រើប្រាស់ជំនាញ និងឯកទេសរបស់អង្គការសង្គមស៊ីវិល (រាប់បញ្ចូលទាំងអង្គការក្រៅរដ្ឋាភិបាលផង) :** សង្គមស៊ីវិលបំពេញតួនាទី យ៉ាងសំខាន់ នៅក្នុងការឆ្លើយតបចំពោះការរាលដាលជំងឺអេដស៍ នៅទូទាំងពិភពលោក ។ នៅតាមបណ្តាប្រទេសជាច្រើន អង្គការសង្គមស៊ីវិល គឺជាអ្នកផ្តល់សេវាសំខាន់ៗជាងគេ ។ ជំនាញឯកទេសទូលំទូលាយរបស់ពួកគេធ្វើឱ្យពួកគេក្លាយជាដៃគូដ៏សំខាន់មួយ ។ ការដឹងពីវត្តមានរបស់ពួកគេចំណុចខ្លាំង និងទីតាំងភូមិសាស្ត្រ ដែលពួកគេបំពេញការងារ គឺជាលក្ខខណ្ឌដ៏ចាំបាច់មួយ ដើម្បីឱ្យមានការចូលរួមប្រកបដោយអត្ថន័យ ។[ខ]

- **បញ្ហាបយេនឌ័រ និងការចូលរួមនៅក្នុងការបង្ការមេរោគអេដស៍ :** មនុស្សដែលងាយឆ្លងមេរោគអេដស៍បំផុតនៅក្នុងពេលកំពុង មានការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ គឺកម្មករបុរសដែលមានជំនាញ និងដែលមិនសូវមានជំនាញ និងស្ត្រីវ័យក្មេងនៅជនបទ ដែលទទួលបានការអប់រំតិចតួច ហើយធ្វើដំណើរទៅការដ្ឋានសាងសង់ដើម្បីបម្រើសេវាផ្លូវភេទ ។ ការយល់ និងឆ្លើយតបចំពោះទិដ្ឋភាពយេនឌ័រ និងការធានាយ៉ាងណាឱ្យក្រុមដែលមានហានិភ័យខ្ពស់អាចចូលរួមនៅក្នុងការរៀបចំ និងការអនុវត្តគម្រោងមានសារៈសំខាន់យ៉ាងខ្លាំង ។[គ]

[ក] ADB. 2010. *Practice Guidelines for Harmonizing HIV Prevention Initiatives in the Infrastructure sector.* Manila. p. 42. Appendix 3. www.adb.org/documents/guidelines/harmonizing-hiv-prevention-gms/harmonizing-hiv-prevention-gms.pdf

[ខ] UNAIDS. Civil society partnerships. www.unaids.org/en/Partnerships/Civil+society/default.asp

[គ] ADB. 2009. *Intersections. Gender, HIV, and Infrastructure Operations. Lessons from Selected ADB-Financed Transport Projects.* Manila.

ឧទាហរណ៍ ដែលបង្ហាញពីការងារតាមបែបចូលរួមរបស់ ADB នៅក្នុងការដោះស្រាយបញ្ហាមេរោគ និងជំងឺ អេដស៍ មានដូចខាងក្រោម :

**ឧទាហរណ៍ ដែលបង្ហាញពីការងារដែល ADB ធ្វើជាមួយនឹងអង្គការសង្គមស៊ីវិល ដើម្បីដោះស្រាយបញ្ហា មេរោគ និងជំងឺអេដស៍**

| តួនាទី | ឧទាហរណ៍ |
|---|---|
| ការស្រាវជ្រាវ | នៅក្នុងប្រទេសវៀតណាម វិទ្យាស្ថានស្រាវជ្រាវឯកជនដែលទទួលបានថវិកាពី ADB មួយបានធ្វើការអង្កេតអំពីចំណេះដឹងអាកប្បកិរិយា និងការប្រព្រឹត្តដែលពាក់ព័ន្ធជាមួយនឹងមេរោគអេដស៍ និងជំងឺកាមរោគរបស់កម្មករកំពង់ផែអ្នកដើរកប៉ាល់ និងកម្មករសាងសង់ផ្លូវថ្នល់ និងស្ពាន។ ការអង្កេតនេះផ្តល់ជាព័ត៌មាន សម្រាប់ការរៀបចំផែនការសកម្មភាព ស្តីពីមេរោគអេដស៍របស់ក្រសួងគមនាគមន៍។[ក] |
| ការបណ្តុះបណ្តាល និងការផ្តល់សេវាដែលពាក់ព័ន្ធជាមួយមេរោគ និងជំងឺអេដស៍ | នៅក្នុងប្រទេសម៉ុងហ្គោលី ADB បានសហការជាមួយនឹងមូលនិធិអេដស៍ជាតិ ដែលជាអង្គការក្រៅ រដ្ឋាភិបាលមួយ ដើម្បីរៀបចំ និងអនុវត្តសកម្មភាពបណ្តុះបណ្តាល ហើយទទឹមគ្នានេះមានអង្គការ អន្តរជាតិធំមួយដែលមានឈ្មោះថា ម៉ារីស្តុបអន្តរជាតិ ផ្តល់សេវាផ្សព្វផ្សាយសង្គមអំពីស្រោមអនាម័យ នៅក្នុងខេត្តមួយ។[ខ] |
| ការបង្កើនការយល់ដឹង និងការក្បៀងគរ | នៅក្នុងខេត្តយូណាន សាធារណរដ្ឋប្រជាមានិតចិន អង្គការអន្តរជាតិមួយដែលមានឈ្មោះថា **humana People-to-People (hPP)** បានផ្តល់ការបណ្តុះបណ្តាលមន្ត្រីនៅតាមមូលដ្ឋានដែលជាយុវជន អំពីរបៀបផ្តល់ការអប់រំ និងការប្រឹក្សាយោបល់ដោយផ្ទាល់បង្កើនការយល់ដឹង និងក្បៀងគរអ្នកដែលមានភាពលេចធ្លោរនៅនឹងមូលដ្ឋាន និងនៅក្នុងសហគមន៍ទាំងមូល ដើម្បីប្រយុទ្ធប្រឆាំងនឹងវីរុសនៅ នៅតំបន់ដែលមានករណីមេរោគអេដស៍ខ្ពស់។[គ] |

[ក] ADB. 2008. *Regional Technical Assistance for the HIV Prevention and Infrastructure in Mekong Project.* Manila.

[ខ] ADB. 2004. *Loan to Mongolia for the Regional Road Development Project.* Manila.

[គ] ADB. 2006. *Fighting HIV/AIDS in Asia and the Pacific Subproject Sustainable Networks for Local HIV/AIDS Prevention in the People's Republic of China*. Manila.

## មេរោគ និងជំងឺអេដស៍ និងឧបករណ៍ស្តីពីការចូលរួម

ADB បានបង្កើតនូវឧបករណ៍ជាច្រើន រួមជាមួយនឹងដៃគូគម្រោងរបស់ខ្លួន។ ឧបករណ៍ដែលមានភាពពាក់ព័ន្ធជាងគេ ត្រូវបានលើកយកមកបង្ហាញនៅទីនេះ ហើយសុទ្ធតែអាចរកបានតាមអនទ្បាញ :

- គេហទំព័ររបស់ ADB
  www.adb.org/gms/hIv-Prevention-Infrastructure-Sector/default.asp
- គេហទំព័រស្តីពីមេរោគអេដស៍ និងហេដ្ឋារចនាសម្ព័ន្ធ របស់មហាអនុតំបន់ទន្លេមេគង្គ (ADB និង IoM)

  www.hivinfrastructure.info/index.php
- មូលដ្ឋានទិន្នន័យស្តីពីមេរោគ និងជំងឺអេដស៍ សម្រាប់អាស៊ីប៉ាស៊ីហ្វិច (UNAIDS, UNICEF, who, និង ADB)

  www.aidsdatahub.org/
- UNAIDS (ដែល ADB សហការយ៉ាងជិតស្និទជាមួយ តាមរយៈ MoU)

  www.unaids.org and http://unaidstoday.org/?tag=civil-soc

អង្គការផ្សេងទៀត ដែលបានបង្កើតនូវឧបករណ៍ដទៃទៀតជាច្រើន គឺមានឈ្មោះនៅក្នុងបញ្ជីធនធានរបស់មគ្គុទេសក៍នេះ។

## ឧបករណ៍របស់ ADB ដែលពាក់ព័ន្ធជាមួយនឹងមេរោគ និងជំងឺអេដស៍ និងការចូលរួម

| ឧបករណ៍ | សេចក្តីពិពណ៌នា |
|---|---|
| គោលការណ៍ណែនាំអំពីការធ្វើសុខដុមនីយកម្មគំនិតផ្តួចផ្តើមបង្ការមេរោគអេដស៍នៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ[ក] | គោលការណ៍ណែនាំនេះ រៀបរាប់ពីគោលវិធីជារួមមួយ សម្រាប់ធ្វើការងារខាងផ្នែកបង្ការ មេរោគអេដស៍ និងហេដ្ឋារចនាសម្ព័ន្ធ ដែលបង្កើតឡើង ដោយដៃគូអភិវឌ្ឍន៍សំខាន់ៗ។ គោលការណ៍ណែនាំនេះមានដាក់បញ្ចូលនូវគោលការណ៍សំខាន់ៗ រួមមាន : "ធានាឱ្យមាន ការចូលរួមរបស់ស្ត្រី ជនចំណាកស្រុក ប្រជាពលរដ្ឋចល័ត និងអ្នករស់នៅជាមួយមេរោគ អេដស៍ (នៅពេលដែលសមស្រប) នៅក្នុងគ្រប់ដំណាក់កាលទាំងអស់របស់គម្រោង (ការ រៀបចំ ការអនុវត្ត ការពិនិត្យតាមដាន និងវាយតម្លៃ និងក្រោយពេលសាងសង់)"។ គោលការណ៍ណែនាំនេះក៏រៀបរាប់ផងដែរអំពីសមាសធាតុជាមូលដ្ឋាននៃកញ្ចប់បង្ការមេរោគអេដស៍ ដោយប្រើប្រាស់គោលវិធីដែលមានការចូលរួម។ |
| សម្រាប់ជីវិត ដែលពោរពេញដោយសេចក្តីស្រឡាញ់ : ឧបករណ៍បណ្តុះបណ្តាលអំពីការបង្ការមេរោគអេដស៍ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅតាមការដ្ឋានសំណង់ផ្លូវថ្នល់ និងសហគមន៍ដែលទទួលរងផលប៉ះពាល់[ខ] | ឧបករណ៍នេះមានដាក់បញ្ចូលនូវម៉ូឌុលបណ្តុះបណ្តាលតាមលក្ខណៈអន្តរកម្មចំនួន ៥ ដោយ មានសកម្មភាពសម្រាប់ក្រុមគោលដៅនីមួយៗ ដូចជាកម្មករសំណង សហគមន៍មូលដ្ឋាន និងកន្លែងកម្សាន្តសប្បាយ។ ប្រធានបទដែលគ្របដណ្តប់ រួមមាន ព័ត៌មានជាមូលដ្ឋានអំពី សុខភាពបន្តពូជ ព័ត៌មានអំពីជំងឺកាមរោគ រួមទាំងមេរោគ និងជំងឺអេដស៍ផង ការប្រាស្រ័យទាក់ទង និងការប្រតិបត្តិនៅក្នុងទំនាក់ទំនង ដើម្បីកាត់បន្ថយឥរិយាបថប្រកប ដោយហានិភ័យ និងនៅក្នុងការរស់នៅជាមួយនឹងអ្នកដែលកំពុងរស់នៅជាមួយនឹងមេរោគអេដស៍។ ឧបករណ៍នេះក៏មានដាក់បញ្ចូលផងដែរនូវឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃសម្រាប់វគ្គបណ្តុះបណ្តាល។ |
| ADB ផ្លូវថ្នល់ និងមេរោគ/ជំងឺអេដស៍ : សៀវភៅធនធានសម្រាប់វិស័យគមនាគមន៍[គ] | ធនធាននេះជួយដល់បុគ្គលិក ADB និងមនុស្សផ្សេងទៀត ឱ្យអាចរៀបចំកម្មវិធីអេដស៍ ឱ្យកាន់តែមានប្រសិទ្ធភាព នៅក្នុងវិស័យគមនាគមន៍។ ឧបករណ៍នេះមានរៀបរាប់ពី ទិដ្ឋភាពរួមអំពីបញ្ហាសំខាន់ៗការណែនាំអំពីការដាក់បញ្ចូលបញ្ហាមេរោគ និងជំងឺអេដស៍ ទៅក្នុងវដ្តគម្រោងរបស់ ADB (ឧ. ដាក់បញ្ចូលការស្វែងរកឱកាស ដើម្បីសហការជាមួយ នឹងសង្គមស៊ីវិល) និងមានលើកឡើងជាឧទាហរណ៍អំពីក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដាន និងសមាសធាតុនានានៃគម្រោងរបស់ ADB។ |
| សុវត្ថិភាពបន្ថែមទៀត : សៀវភៅធនធានអំពីសុខភាព និងសុវត្ថិភាព នៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធ[ឃ] | សៀវភៅណែនាំនេះបង្ហាញពីឧបករណ៍ និងជំនាញបង្ការមេរោគអេដស៍ សម្រាប់អ្នកគ្រប់ គ្រងគម្រោងមន្ត្រីទទួលបន្ទុកសុខភាព និងសុវត្ថិភាពការងារភ្នាក់ងារសុខភាពនៅតាមការដ្ឋានការងារ និងអ្នកគ្រប់គ្រងការដ្ឋានផ្សេងទៀត ដែលទទួលខុសត្រូវលើសុខភាព និងសុខមាលភាពរបស់កម្មករ។ សៀវភៅណែនាំនេះមានដាក់បញ្ចូលនូវព័ត៌មានជាមូលដ្ឋាន អំពីមេរោគអេដស៍ និងជំហានដើម្បីផ្តល់ការណែនាំអំពីការបង្ការមេរោគ និងជំងឺអេដស៍នៅកន្លែងធ្វើការ (បង្កើតក្រុមការងារធ្វើការវាយតម្លៃតាមបែបរហ័ស និងបង្កើតផែនការសកម្មភាពនៅកន្លែងធ្វើការ ដើម្បីបង្ការមេរោគអេដស៍ និងពិនិត្យតាមដាន និងវាយតម្លៃ)។ |
| ឧបករណ៍ដំណើរការសមត្ថភាពជីវិតរបស់សហគមន៍ – បណ្តាញអ្នកជំនាញដែលធ្វើការងារពាក់ព័ន្ធជាមួយ នឹងជំងឺអេដស៍[ង] | បណ្តាញអ្នកជំនាញនេះ គឺជាក្រុមអ្នកសម្របសម្រួលមួយក្រុម ដែលជម្រុញឱ្យសហគមន៍ ធ្វើសកម្មភាព តាមរយៈគោលវិធីមួយ ដែលប្រើប្រាស់ចំណុចខ្លាំងរបស់ពួកគេ និងជម្រុញ ឱ្យមានភាពជាម្ចាស់នៅមូលដ្ឋាន។ គោលវិធីនេះត្រូវបានគេយកមកប្រើប្រាស់នៅក្នុងផ្នែក នៃវដ្តមួយដែលគេហៅថាដំណើរការសមត្ថភាពជីវិតរបស់សហគមន៍។ នៅតាមជំហាននីមួយៗ ក្រុមអ្នកសម្របសម្រួលផ្តល់ការគាំទ្រដល់សហគមន៍អំពីរបៀបប្រើ ប្រាស់ឧបករណ៍។ ជំហានទាំង ៥ រួមមាន :<br>១. តើយើងចង់ទៅដល់ណា? (ឧបករណ៍ : ក្តីសុបិន្ត)<br>២. តើយើងនៅត្រង់ណានាពេលនេះ? (ឧបករណ៍ : ស្វ័យវាយតម្លៃ)<br>៣. តើយើងនឹងទៅដល់ទីនោះ ដោយរបៀបណា? (ឧបករណ៍ : ការរៀបចំផែនការ សកម្មភាព)<br>៤. តើយើងសម្រេចបាននូវវឌ្ឍនភាពអ្វីដែរឬទេ? (ឧបករណ៍ : ការវាស់វែងដោយខ្លួនឯង លើការផ្លាស់ប្តូរ)<br>៥. យើងរៀនសូត្រ និងធ្វើការចែករំលែក (ឧបករណ៍ : ការជួយគ្នាពិពណ៌ចំណេះដឹង ។ល ។)។ ជាមួយនឹងការឧបត្ថម្ភពី ADB បណ្តាញអ្នកជំនាញនេះ បានធ្វើការងារជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល នៅក្នុងប្រទេសកម្ពុជា ឥណ្ឌា ឥណ្ឌូនេស៊ី ហ្វីលីពីន ប៉ាពួញូហ្គីនី និងថៃ។ ពួកគេបានបង្រៀនបុគ្គលិកអំពីដំណើរការសមត្ថភាពដែល ពាក់ព័ន្ធជាមួយនឹងជំងឺអេដស៍ និងរបៀបកែសម្រួលដំណើរការនេះ និងយកទៅអនុវត្តនៅក្នុងការងាររបស់ពួកគេជាមួយនឹងសហគមន៍។ |

| ឧបករណ៍ | សេចក្ដីពិពណ៌នា |
|---|---|
| អន្តរវិស័យ - យេនឌ័រ មេរោគអេដស៍ និងហេដ្ឋារចនាសម្ព័ន្ធ មេរៀនដែលទទួលបានពីគម្រោងគមនាគមន៍មួយចំនួនដែលទទួលបានហិរញ្ញប្បទានពី ADB[ច] | ឯកសារបោះពុម្ពផ្សាយនេះផ្ដល់ការណែនាំអំពីការបញ្ជ្រាបយេនឌ័រ ទៅក្នុងការរៀបចំ គម្រោង វិសាលភាពរបស់គម្រោងដែលផ្ដោតលើការបង្កើតភាពជាដៃគូ និងអន្តរាគមន៍ដែលមានគុណភាព និងការកែលំអការពិនិត្យតាមដាន និងវាយតម្លៃ។ ឯកសារនេះផ្ដល់នូវអនុសាសន៍មុនពេលសាងសង់ ក្នុងកំឡុងពេលសាងសង់ និងក្រោយពេលសាងសង់។ |

[ក] ADB. 2010. *Practice Guidelines for Harmonizing HIV Prevention Initiatives in the Infrastructure Sector.* Manila (developed in collaboration with AusAID, FHI, ILO, IOM, JICA, JUNIMA, Sida, UNESCO, USAID, and the World Bank).

[ខ] ADB and International Organization for Migration (IOM). 2009. *For Life, With Love: A Training Tool for HIV Prevention and Safe Migration in Road Construction Settings and Affected Communities.* Manila.

[គ] ADB. 2008. *ADB, Roads, and HIV/AIDS. A Resource Book for the Transport Sector.* Manila.

[ឃ] ADB, MSI, and Baalong Health & Safe Action Project. 2008. *More Safety. A Resource Manual for Health and Safety in Infrastructure.* Manila.

[ង] Constellation for AIDS Competence. www.communitylifecompetence.org/en/94-resources

[ច] ADB. 2009. *Intersections. Gender, HIV, and Infrastructure Operations. Lessons from Selected ADB-Financed Transport Projects.* Manila.

# ៥. ហេដ្ឋារចនាសម្ព័ន្ធ-ទឹក និងអនាម័យ

## ទឹក និងអនាម័យ និងការចូលរួម

ទឹក និងអនាម័យ ស្ថិតនៅក្រោមហេដ្ឋារចនាសម្ព័ន្ធ ដែលជាផ្នែកប្រតិបត្តិការដ៏សំខាន់មួយនៅក្នុងយុទ្ធសាស្ត្រ ២០២០។ "គោលនយោបាយទឹកសម្រាប់ទាំងអស់គ្នា" (២០១១) របស់ ADB ជម្រុញយ៉ាងសកម្មឱ្យមានការចូលរួម នៅក្នុងការគ្រប់គ្រងធនធានទឹក និងផ្តល់សេវាទឹកនៅគ្រប់កម្រិតទាំងអស់ និងជម្រុញឱ្យមានការបង្កើតភាពជាដៃគូ រវាងរដ្ឋាភិបាល ទីភ្នាក់ងារឯកជន អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍។[៧៥] ការប្តេជ្ញានេះត្រូវបានគាំទ្រដោយ *ផែនការប្រតិបត្តិ ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានសេវាសុខភាព និងសម្រេចបានលទ្ធផលក្រោមយុទ្ធសាស្ត្រ២០២០* ដែលផ្តល់អាទិភាពដល់ភាពជាដៃគូ និងគាំទ្រឱ្យមានការសម្រេចនូវលទ្ធផលដែលពាក់ព័ន្ធជាមួយនឹងសុខភាព តាមរយៈ ប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធ ជាពិសេស ទឹក និងអនាម័យ។[៧៦] ជំហានខាងក្រោមនេះ អាចយកទៅអនុវត្តបាន សម្រាប់តំបន់ជនបទផង និងតំបន់ទីក្រុងផង ប៉ុន្តែផ្នែកនេះផ្តោតដោយឡែកលើការចូលរួម នៅក្នុងការងារផ្គត់ផ្គង់ទឹក នៅតំបន់ជនបទ និងទីក្រុងពោលគឺមិនសូវលើអនាម័យនោះទេ ដោយសារតែមានការប្រើប្រាស់នូវគោលវិធីផ្សេងៗពី គ្នា នៅក្នុងបរិបទនីមួយៗ។

### ជំហានដើម្បីបង្កើនការចូលរួមនៅក្នុងគម្រោងផ្គត់ផ្គង់ទឹក និងអនាម័យនៅជនបទ និងទីក្រុង

#### ការរៀបចំគម្រោង

- **ធ្វើការពិគ្រោះយោបល់ និងវាយតម្លៃ ដោយមានការចូលរួម ៖** ការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ជាមួយនឹងគ្រប់អ្នកពាក់ព័ន្ធទាំងអស់ក្នុងសហគមន៍ និងការប្រើប្រាស់បច្ចេកទេសវាយតម្លៃ ដោយមានការចូលរួម លើកទឹកចិត្តឱ្យមានការចូលរួម នៅក្នុងការអនុវត្ត និងធានាយ៉ាងណាឱ្យអន្តរាគមន៍នានា អាចបំពេញបានទៅតាមសេចក្តីត្រូវការរបស់អ្នកទទួលផល (សូមមើលឧបករណ៍ទី ១ និងទី ៣)។ សម្រាប់តំបន់ទីក្រុង ADB បានបង្កើតនូវលក្ខខណ្ឌប្រតិបត្តិគំរូមួយ សម្រាប់ធ្វើការវាយតម្លៃវិភាគលើការផ្គត់ផ្គង់ទឹក ក្នុងទីក្រុងដោយមានការចូលរួម។ វិធីសាស្ត្រវាយតម្លៃដោយមានការចូលរួម (MPA) គឺជាឧបករណ៍ដ៏មានប្រយោជន៍មួយសម្រាប់តំបន់ជនបទ និងតំបន់ទីក្រុង (សូមមើលការផ្តល់សេវាផ្គត់ផ្គង់ទឹក និងសុខភាពនៅសហគមន៍ ប្រទេសឥណ្ឌូនេស៊ី)។

#### ការអនុវត្តគម្រោង

- **បង្កើត និងគាំទ្រដល់អង្គការនៅតាមសហគមន៍មូលដ្ឋាន(CBOs)ដូចជាក្រុមអ្នកប្រើប្រាស់ទឹកជាដើម ៖** ជម្រុញឱ្យមានការចូលរួមពីអង្គការសហគមន៍ ដើម្បីឱ្យសហគមន៍មានភាពជាម្ចាស់ និងចូលរួម។ អង្គការទាំងនេះបំពេញតួនាទីជាច្រើន ដូចជាតំណាងឱ្យសហគមន៍ ក្នុងការបង្ហាញពីសេចក្តីត្រូវការរបស់សហគមន៍ចំពោះអ្នកផ្តល់សេវា ការពិនិត្យតាមដានគុណភាព នៃការផ្តល់សេវាឬការគ្រប់គ្រង និងផ្តល់សេវាដោយខ្លួនឯងតែម្តង។
- **ដាក់បញ្ចូលសកម្មភាពដែលពាក់ព័ន្ធជាមួយនឹងអនាម័យ ការកៀងគរសហគមន៍ និងការអប់រំ ៖** ដាក់បញ្ចូល "ផ្នែករឹង"ដូចជាបង្គន់អនាម័យនិងប្រព័ន្ធអនាម័យជាមួយនឹងសមាសធាតុ "ផ្នែកទន់" ដែលផ្តោតលើការអប់រំ និងការជម្រុញឱ្យមានតម្រូវការ ដើម្បីបង្កើនផលរយៈពេលវែងឱ្យដល់កម្រិតអតិបរមា។ សហគមន៍ចាំបាច់ត្រូវយល់ពីគោលបំណងរបស់ប្រព័ន្ធទាំងនេះ ដឹងពីរបៀប ប្រើប្រាស់ និងពីសារៈសំខាន់នៃឥរិយាបថអនាម័យផ្ទាល់ខ្លួន ដូចជាលាងដៃទុកដាក់ទឹកឱ្យបានត្រឹមត្រូវ និងចោលទឹកសំណល់ឱ្យបានត្រឹមត្រូវ។ សកម្មភាពនានា អាចរួមមាន កម្មវិធីបណ្តុះបណ្តាលក្នុងសាលារៀន សិក្ខាសាលាក្នុងភូមិសម្រាប់ស្ត្រី បុរស និងកុមារ និង ការបង្កើតជាផ្ទាំងរូបភាព និងឯកសារដទៃទៀត។ ការផ្លាស់ប្តូរទម្លាប់អនាម័យដោយមានការចូលរួម (PhAST) គឺជាវិធីសាស្ត្រដ៏មានប្រយោជន៍មួយ (សូមមើលការផ្តល់សេវាផ្គត់ផ្គង់ទឹក និងសុខភាពនៅសហគមន៍ ប្រទេសឥណ្ឌូនេស៊ី)។

ប្រភព ៖ ADB. Model TOR. Diagnostic City Water Assessments. www.adb.org/Water/tools/City-Water-Assessments.asp

## - ទឹក (និងអនាម័យ) ជនបទ

ADB បានបង្កើតនូវគោលវិធីផ្គត់ផ្គង់ទឹក និងអនាម័យជនបទ ផ្តោតលើសហគមន៍ប្រកបដោយជោគជ័យមួយ ។ គោលវិធីនេះតម្រង់ទិសទៅតាមតម្រូវការ និងផ្អែកលើតម្រូវការដែលកំណត់ដោយអ្នកទទួលផល ។ គោលវិធីជម្រុញឱ្យមានការចូលរួមពីអ្នកទទួលផលនៅក្នុងដំណាក់កាលផ្សេងៗរបស់គម្រោង ចាប់ពីការរៀបចំគម្រោង រហូតដល់ការ អនុវត្ត និងការវាយតម្លៃគម្រោង ។ ខុសពីតំបន់ទីក្រុងដែលជាធម្មតា មានអ្នកផ្តល់សេវាជាផ្លូវការសហគមន៍នៅតំបន់ជនបទ គឺជាអ្នកដំណើរការ និងថែទាំប្រព័ន្ធ ។ ការចូលរួមរបស់សហគមន៍ ត្រូវបានធ្វើឱ្យក្លាយជាផ្លូវការតាមរយៈការបង្កើតអង្គការសហគមន៍ (ដែលជារឿយៗ ត្រូវបានគេហៅថាសមាគមអ្នកទទួលផល ក្រុមការងារជនបទ និងសមាគមអនាម័យ ឬក្រុមអ្នកប្រើប្រាស់ទឹក) នៃក្រុមមនុស្ស ដែលជាតំណាងឱ្យគ្រួសារទទួលផលនីមួយៗ ។[៧៧]

គឺតាមរយៈ CBO នេះហើយ ដែលអ្នកទទួលផល

- ជ្រើសរើសប្រភេទបច្ចេកវិទ្យាផ្គត់ផ្គង់ទឹក និងអនាម័យដែលពួកគេចង់បាន (ការភ្ជាប់បណ្តាញតាមផ្ទះការដាក់ក្បាលរ៉ូប៊ីណេសម្រាប់ប្រើប្រាស់រួមស្នប់ទឹកដែលប្រើដោយដៃ ។ល ។)
- ផ្សព្វផ្សាយពីកម្រិតសេវា ដែលពួកគេមានឆន្ទៈ និងមានលទ្ធភាពបង់បាន
- បំពេញតួនាទីយ៉ាងសកម្ម នៅក្នុងការរៀបចំផែនការ និងការរៀបចំគម្រោង
- ចូលរួមចំណែកជាពេលវេលា កម្លាំងពលកម្ម និងសម្ភារសម្រាប់គម្រោង
- ដំណើរការ និងថែទាំប្រព័ន្ធ ដើម្បីធានាឱ្យមាននិរន្តរភាព និង
- បង្កើតនូវអន្តរាគមន៍ផ្លាស់ប្តូរឥរិយាបថ ដែលពាក់ព័ន្ធនឹងអនាម័យផ្ទាល់ខ្លួន និងអនាម័យបរិស្ថាន

**គោលវិធីផ្គត់ផ្គង់ទឹក និងអនាម័យជនបទ ដែលផ្តោតលើសហគមន៍ ប្រទេសស្រីលង្កា**
(គោលវិធីចូលរួម : ភាពជាដៃគូ កម្រិតស៊ីជម្រៅ : ខ្ពស់)

នៅក្នុងប្រទេសស្រីលង្កា គម្រោងផ្គត់ផ្គង់ទឹករបស់ ADB ទ្រង់ទ្រាយធំដែលផ្តោតលើផ្នែកផ្គត់ផ្គង់បាន និងកំពុងបន្តអនុវត្តចាប់តាំងពីទសវត្សរ៍ ១៩៨០ មកម្ល៉េះ ដោយមានជោគជ័យតិចតួចតែប៉ុណ្ណោះ ។ គម្រោងទី ៣ ដែលបានចាប់ផ្តើម នៅក្នុងឆ្នាំ ១៩៩៩ បានដាក់ឱ្យអនុវត្តនូវគោលវិធីផ្តោតលើសហគមន៍ថ្មីមួយ ។ គោលវិធីនេះផ្តោត លើការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងលើចំណេះដឹងដើម្បីចៀសវាងអនុវត្តអន្តរាគមន៍ដែលមិនសមស្រប និងដើម្បីបង្កើនភាពជាម្ចាស់ និងនិរន្តរភាព ។ រដ្ឋាភិបាលបានផ្លាស់ពីអ្នកអនុវត្ត ទៅជាអ្នកសម្របសម្រួល ហើយតួនាទីរបស់សហគមន៍បានផ្លាស់ពី អ្នកចាំតែទទួលផលទៅជាអ្នកចូលរួមដែលសកម្ម ។ ក្រុមអ្នកប្រើប្រាស់ទឹក(WUGs)ត្រូវបានបង្កើតឡើងដោយមានការជួយពីអង្គការសង្គមស៊ីវិលជាដៃគូ ។ ក្រុមទាំងនេះបានរៀបចំការពិគ្រោះយោបល់ដើម្បីកំណត់ពីតម្លៃប្រើប្រាស់ និងពីប្រភេទសេវាដែលសហគមន៍ចង់បាន និងធ្វើការគ្រប់គ្រងការសាងសង់ និងដំណើរការដូចជាជួល និងត្រួតពិនិត្យអ្នកម៉ៅការជាដើម ។ រដ្ឋាភិបាលនៅថ្នាក់មូលដ្ឋានជាអ្នកផ្តល់ការគាំទ្របច្ចេកទេស ។ WUGs ក៏បានរៀបចំការរួមបដិភាគរបស់សហគមន៍ផងដែរ (២០% នៃចំណាយថ្លៃដើមជាសាច់ប្រាកនិងជាកម្លាំងពលកម្ម) និងធ្វើការគ្រប់គ្រងមូលនិធិតូចមួយសម្រាប់សកម្មភាពរកចំណូលដើម្បីឱ្យប្រជាពលរដ្ឋក្រីក្រអាចរកចំណូល សម្រាប់ភ្ជាប់បណ្តាញប្រើប្រាស់ ។ ដោយសារតែការដងទឹកភាគច្រើនគឺជាការងាររបស់ស្ត្រីការចូលរួម និងការសម្រេចចិត្តរបស់ស្ត្រី មានសារៈសំខាន់យ៉ាងខ្លាំងចំពោះជោគជ័យរបស់គម្រោង ។ ស្ត្រីបានផ្តល់ការគាំទ្រជា

ពិសេសលើការអប់រំអំពីអនាម័យ និងដោយមានការជួយជ្រុមជ្រែងពីអ្នកសម្របសម្រួល មានការរៀបចំវគ្គអប់រំសម្រាប់កុមារដែលរៀននៅសាលាមត្តេយ្យ និងសាលាបឋមសិក្សា។ បង្គន់ដែលទទួលបានការឧបត្ថម្ភ ក៏លើទឹកចិត្តឱ្យសហគមន៍ធ្វើការងារសាងសង់ផងដែរ។ ជារឿយៗ ស្ត្រីគឺជាអ្នកដឹកនាំការងារនេះ។

ប្រភព៖ ADB. 1999. *Loan to Sri Lanka for the Third Water Supply and Sanitation Sector Project.* Manila; http://www.adb.org/water/actions/SRI/third-water-supply.asp and http://www.adb.org/participation/toolkit-water-sanitation-project.asp

## ការផ្តល់សេវាផ្គត់ផ្គង់ទឹក និងថែទាំសុខភាពដល់សហគមន៍ ប្រទេសឥណ្ឌូនេស៊ី
## (គោលវិធីចូលរួម ៖ ភាពជាដៃគូ កម្រិតស៊ីជម្រៅ ៖ ខ្ពស់)

គោលវិធីដែលផ្តោតលើសហគមន៍ នៅក្នុងប្រទេសឥណ្ឌូនេស៊ីបានកែសម្រួលក្របខ័ណ្ឌលើកកម្ពស់អនាម័យដើម្បីធ្វើការអភិវឌ្ឍ និង កែលំអហេដ្ឋារចនាសម្ព័ន្ធទឹក និងអនាម័យទៅតាមតម្រូវការរបស់សហគមន៍ នៅតាមតំបន់គម្រោងដែលស្ថិតនៅទីជនបទ។ គោលវិធីជារួម បានដាក់បញ្ចូលនូវការពង្រីកលទ្ធភាពទទួលបានឧបករណ៍សម្ភារ ជាមួយនឹងការអប់រំផ្សព្វផ្សាយអំពីអនាម័យ និងការគាំទ្រឱ្យមានការបង្កើតក្របខ័ណ្ឌស្ថាប័នអន្តរគ្រោះមួយ ដើម្បីកាត់បន្ថយករណីជំងឺរាក។ គម្រោងនេះក៏បានរៀបចំឱ្យមានជាយុទ្ធនាការសុខភាពផងដែរ ដើម្បីធ្វើការផ្លាស់ប្តូរឥរិយាបថដែលពាក់ព័ន្ធជាមួយនឹងអនាម័យ និងកាត់បន្ថយករណីជំងឺដែលពាក់ព័ន្ធនឹងទឹក។ គម្រោងនេះបានប្រើប្រាស់វិធីសាស្ត្រវាយតម្លៃដោយមានការចូលរួម (MPA)ដែលត្រូវបានបង្កើតឡើងដោយកម្មវិធីទឹក និងអនាម័យ និងបច្ចេកទេសផ្លាស់ប្តូរទម្លាប់អនាម័យដោយមានការចូលរួម(PhAST)និងប្រើប្រាស់កញ្ចប់អនាម័យជាមូលដ្ឋាន របស់អង្គការយូនីសេហ្វ (សូមមើលឧបករណ៍ចូលរួមដែលពាក់ព័ន្ធជាមួយនឹងទឹក និងអនាម័យ)។ សកម្មភាពផ្លាស់ប្តូរឥរិយាបថ រួមមាន កម្មវិធីសុខភាព និងអនាម័យតាមសាលារៀន ការលើកកម្ពស់អនាម័យនៅតាមកន្លែងប្រារព្ធពិធីសាសនា កម្មវិធីអនាម័យសហគមន៍ និងកម្មវិធីសំអាតទឹក និងស្តុកទឹកតាមផ្ទះ។ សកម្មភាពនានាបានពិចារណាផងដែរលើបញ្ហាយេនឌ័រ និងវប្បធម៌ និងភាសារបស់ ជនជាតិដើមភាគតិច។

ប្រភព៖ ADB. 2005. *Loan and Grant Assistance to Indonesia for the Community Water Services and Health Project.* Manila.

គោលវិធីផ្តោតលើសហគមន៍ បង្ហាញថាគេចាំបាច់ត្រូវចំណាយពេលវេលាបន្ថែម ដើម្បីជម្រុញឱ្យមានការចូលរួមប្រកបដោយអត្ថន័យ ដើម្បីធ្វើឱ្យមាននិរន្តរភាព និងផលរយៈពេលវែង។ សហគមន៍មានមោទនភាព ចំពោះការចាត់ចែងគម្រោងរបស់ខ្លួនប្រកបដោយជោគជ័យ ហើយលទ្ធភាពទទួលបានទឹក និងសេវាអនាម័យ ធ្វើឱ្យសុខភាពមានភាពប្រសើរជាងមុន និងមានពេលទំនេរ សម្រាប់រកចំណូលចិញ្ចឹមកូន និងធ្វើសកម្មភាពផ្សេងទៀត។ សហគមន៍មួយចំនួនថែមទាំងបានកែលំអប្រព័ន្ធទឹករបស់ខ្លួនថែមទៀតផង។

## -ទឹក (និងអនាម័យ) ទីក្រុង

ជាធម្មតានៅតំបន់ទីក្រុង តែងមានក្រុមហ៊ុនផ្គត់ផ្គង់ទឹកផ្លូវការ។ ឧទាហរណ៍នៃក្រុមហ៊ុនផ្គត់ផ្គង់ទឹកទាំងនេះ រួមមានក្រុមហ៊ុនទឹកទីក្រុងម៉ានីល នៅប្រទេសហ្វីលីពីន និងគណៈកម្មាធិការផ្គត់ផ្គង់ទឹក និងលូបង់ហ្គាល័រ (BWSSB) នៅក្នុងឥណ្ឌា។ ប៉ុន្តែបើទោះបីជានេះគឺជាសេវាផ្តាច់មុខក៏ដោយ ក៏សង្គមស៊ីវិលនៅតែមានឱកាសចូលរួម។ ការចូលរួមចាប់ផ្តើមជាមួយនឹងការវាយតម្លៃ។ លក្ខខណ្ឌប្រតិបត្តិគំរូរបស់ ADB សម្រាប់ធ្វើការវាយតម្លៃវិភាគលើការផ្គត់ផ្គង់ទឹក ក្នុងទីក្រុង ប្រើប្រាស់គោលវិធីត្រួតពិនិត្យទីផ្សារផ្លូវការ (ការផ្គត់ផ្គង់ទឹក អ្នកភ្ជាប់បំពង់តាមគ្រួសារតូចៗ

អតិថិជន) និងទីផ្សារក្រៅផ្លូវការ (អ្នកលក់ទឹក អ្នកផ្គត់ផ្គង់ទឹកដបអតិថិជន) ដោយមានការចូលរួម ដើម្បីផ្តល់នូវព័ត៌មានអំពីសក្តានុពលនៃការវិនិយោគលើសេវានេះ ។[៧៨] ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធមានសារៈសំខាន់យ៉ាងខ្លាំង ហើយគោលវិធីនេះពិនិត្យយ៉ាងជាក់លាក់លើការរំលេចឱ្យឃើញពីតម្រូវការរបស់ប្រជាពលរដ្ឋក្រីក្រនៅទីក្រុង និងលើរបៀបដែលគម្រោងមួយអាចផ្តល់ការគាំទ្រ ដល់អ្នកមិនបានទទួលសេវា និងដែលជួបប្រទះការលំបាកជាងគេ ។

ឧទាហរណ៍ គោលវិធីនេះអាចរួមមាន :

- ការឧបត្ថម្ភធនគោលដៅ (ឧ. គោលនយោបាយផ្តល់ឧបត្ថម្ភធនរវាងអ្នកមាន និងអ្នកក្រ) និង
- កិច្ចសន្យាបញ្ចេញពីសេវាសាធារណៈ ដែលចាំបាច់ត្រូវតែមាននៅតំបន់ដែលមានចំណូលទាបមួយចំនួន

អ្នកពាក់ព័ន្ធក៏មានសារៈសំខាន់ផងដែរ នៅក្នុងការបង្កើតនូវស្ថាប័ននិយ័តកម្មមួយ សម្រាប់ធ្វើការកំណត់ពីតម្លៃប្រើប្រាស់ និងកែសម្រួលតម្លៃប្រើប្រាស់ និងនៅក្នុងការពិនិត្យតាមដានការផ្តល់សេវាផ្គត់ផ្គង់ទឹកជាលក្ខណៈផ្ទាច់មុខ ។ លើសពីនេះ មានការលើកទឹកចិត្តឱ្យមានភាពជាដៃគូប្រកបដោយផលិតភាពរវាងអតិថិជននិង/ឬសង្គមស៊ីវិល និងអ្នកផ្តល់សេវាតាមរយៈការពិភាក្សាគ្នា និងការបង្កើតកិច្ចព្រមព្រៀងអំពីសូចនាករលទ្ធផលការងារសំខាន់ៗ ។ ការធ្វើបែបនេះផ្តល់លទ្ធភាពឱ្យមានការយល់ដឹងកាន់តែច្រើនជាងមុន អំពីកាតព្វកិច្ចបំពេញការងារសម្រាប់ សេវាសាធារណៈ (ឧ. លទ្ធភាពប្រើប្រាស់លទ្ធភាពចំណាយ) និងអតិថិជន និង/ឬសង្គមស៊ីវិល (ឧ. បង់ថ្លៃប្រើប្រាស់ ដែលបានឯកភាពគ្នា បង់ឱ្យបានទាន់ពេលវេលា ការពិនិត្យតាមដានសេវាកម្ម) ។

នៅពេលដែលសហគមន៍ក្រីក្រក្នុងទីក្រុង ពុំមានលទ្ធភាពតទឹកពីបណ្តាញចែកចាយបានគេមានបង្កើតនូវគម្រោងភ្ជាប់បណ្តាញទឹកខ្នាតតូច(SPWNs) សម្រាប់ភ្ជាប់ទឹកតាមគ្រួសារទាំងនេះ ។ ពេលខ្លះគម្រោងទាំងនេះក៏ត្រូវបានអនុវត្តនៅតាមតំបន់ជនបទផងដែរ ប៉ុន្តែជាធម្មតានៅតាមកន្លែងដែលពុំមានអ្នកផ្តល់សេវា ហើយដង់ស៊ីតេខ្ពងផ្ទះទាប (មានន័យថាការភ្ជាប់បណ្តាញតាមផ្ទះមិនអាចធ្វើទៅបាន បើគិតតាមន័យសេដ្ឋកិច្ច) ធ្វើឱ្យគោលវិធីផ្តោតលើសហគមន៍ ដូចដែលរៀបរាប់ខាងលើកាន់តែមានលក្ខណៈសមស្រប ។ ឱកាសចូលរួមមាននៅក្នុងគ្រប់ដំណាក់កាល សំខាន់ៗទាំងអស់នៃ SPWN ដូចដែលបង្ហាញខាងក្រោម ហើយ ADB មានឧបករណ៍មួយ ដើម្បីគាំទ្រដល់ការអនុវត្ត គម្រោងទាំងនេះ នោះគឺ*នៅក្នុងបំពង់ទឹក : ទឹកសម្រាប់ប្រជាពលរដ្ឋក្រីក្រ (In the Pipeline: Water for the Poor)* ដែលអាចបានលើគេហទំព័ររបស់ ADB ។[៧៩]

១. *ដំណាក់កាលដំបូង :* នេះរួមមានការកំណត់ពីក្រុមអ្នកទទួលផលគោលដៅ និងធ្វើការកំណត់ពីឆន្ទៈរបស់ពួកគេក្នុងការទទួលយកការទទួលខុសត្រូវ និងផ្តល់ការគាំទ្រដល់គម្រោង ។ រដ្ឋាភិបាល ឬសហគមន៍អាចផ្តួចផ្តើមឱ្យមានការកំណត់បែបនេះ ។ រដ្ឋាភិបាល ឬសហគមន៍ គួរស្វាគមន៍ឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់រួមទាំងសង្គមស៊ីវិលផងដែរ ។ ចាំបាច់ត្រូវមានការយល់ព្រមពីគ្រប់អ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់មុនពេលចាប់ផ្តើមការសិក្សាពីលទ្ធភាព អនុវត្ត ។

២. *គំរូធុរកិច្ច និងឧបករណ៍ :* អង្គការសង្គមស៊ីវិលអាចចូលរួមនៅក្នុងគំរូធុរកិច្ចជាច្រើន។ ក្រុមហ៊ុនផ្តល់សេវាសាធារណៈចម្បង អាចបង្កើតកិច្ចព្រមព្រៀងជាមួយនឹងអង្គការសហគមន៍ ដែលនៅក្នុងកិច្ចព្រមព្រៀងនេះ អង្គការសហគមន៍ទទួលរ៉ាប់រងលើការចែកវិក្កយបត្រ និងប្រមូលប្រាក់តាមគ្រួសារ ឬអង្គការក្រៅរដ្ឋាភិបាល ឬអង្គការសហគមន៍ (ឧ. សហករទឹក ឬសមាគមអ្នកប្រើប្រាស់ទឹក) អាចធ្វើជាអ្នកផ្គត់ផ្គង់ទឹកខ្នាតតូចដោយខ្លួនឯង។

៣. *ការផ្តល់ហិរញ្ញប្បទាន :* គម្រោង ដែលត្រូវបានសាកល្បងនៅក្នុងប្រទេសហ្វីលីពីន ឥណ្ឌា និងឥណ្ឌូនេស៊ី បានបង្ហាញ ថាសហគមន៍ក្រីក្រមានលទ្ធភាព និងឆន្ទៈខ្លះៗ ក្នុងការបង់ប្រាក់សម្រាប់ប្រើប្រាស់សេវាទឹកពីបណ្តាញ។

៤. *វិធានការធានានិរន្តរភាព និងភាពអាចទទួលយកបាន :* គម្រោងដែលមានប្រសិទ្ធភាព និងនិរន្តរភាពប្រកបដោយជោគជ័យ កើតចេញពីភាពជាដៃគូប្រកបដោយប្រសិទ្ធភាពរវាងរដ្ឋាភិបាល និងសង្គមស៊ីវិល។ អង្គការសហគមន៍អាចធ្វើ ការកៀងគរ និងជួយសហគមន៍មូលដ្ឋានធ្វើការចងក្រងគ្នា ដើម្បីចូលរួមនៅតាមគម្រោងនានាបានដោយធានាយ៉ាងណា ឱ្យប្រជាពលរដ្ឋក្រីក្រទទួលបានសេវា ហើយសេវាទាំងនេះមាននិរន្តរភាព។ ពួកគេក៏អាចចូលរួមនៅក្នុងប្រតិបត្តិការបច្ចេកទេសការថែទាំ និងប្រតិបត្តិការជាលក្ខណៈពាណិជ្ជកម្មផងដែរ។ តួនាទីពិតប្រាកដរបស់ពួកគេ គឺអាស្រ័យលើការអនុវត្តការរៀបចំ ឬគំរូធុរកិច្ច។

៥. *វិធានការនិយ័តកម្ម :* ចាំបាច់ត្រូវមានយន្តការគណនេយ្យភាពផងដែរ ដើម្បីធានាយ៉ាងណាឱ្យមានការសម្រេចនូវ គ្រប់លក្ខខណ្ឌតម្រូវផ្នែកសុខភាព និងប្រតិបត្តិការ ដែលកំណត់ដោយច្បាប់ទាំងអស់។ ក្នុងនាមជាតំណាងសហគមន៍ អង្គការសហគមន៍អាចបំពេញតួនាទីជាអ្នកឃ្លាំមើល។

## ការចូលរួមនៅក្នុងបណ្តាញផ្គត់ផ្គង់ទឹកខ្នាតតូច ទីក្រុងម៉ានីល ប្រទេសហ្វីលីពីន (គោលវិធីចូលរួម : ភាពជាដៃគូ, ភាពស៊ីជម្រៅ : ខ្ពស់)

ADB បានសាកល្បងគម្រោងភ្ជាប់បណ្តាញទឹកខ្នាតតូច (SPWNs) នៅក្នុងប្រទេសហ្វីលីពីន វៀតណាម និងឥណ្ឌា នៅក្នុងឆ្នាំ ២០០៥-២០០៨។ គម្រោងសាកល្បងចំនួន ២ ត្រូវបានអនុវត្តនៅក្នុងទីក្រុងម៉ានីល។ នៅតំបន់ភាគខាងលិចសមាគមម្ចាស់ផ្ទះចំនួន ៦ គឺជាអ្នកទទួលផល។ សមាគមនីមួយៗបានបង្កើតអង្គការសហគមន៍រៀងៗខ្លួន ហើយអង្គការសហគមន៍ចំនួន ៦ បានបង្កើតនូវអង្គការ សហគមន៍សមាជិកភាពមួយដើម្បីធ្វើជាតំណាងឱ្យពួកគេ។ គឺអង្គការសហគមន៍នេះហើយដែលផ្តល់ជាអនុសាសន៍អំពីអង្គការក្រៅរដ្ឋាភិបាល ដែលបានក្លាយជាអ្នកដំណើរការ SPWN។ នៅតំបន់ភាគខាងកើតក្រុមហ៊ុនផ្តល់សេវាសាធារណៈ គឺជាប្រតិបត្តិករនៃគម្រោងSPWN ខណៈពេលដែលសមាគមម្ចាស់ផ្ទះបានបង្កើតនូវអង្គការសហគមន៍មួយដើម្បីធ្វើការចែកវិក្កយបត្រ និងប្រមូលថ្លៃសេវាប្រើប្រាស់តាមផ្ទះ។ នៅក្នុងករណីទាំងពីរនេះ អង្គការសហគមន៍ត្រូវបានប្រើប្រាស់ដើម្បីប្រមូលចងក្រងសហគមន៍ឱ្យធ្វើសកម្មភាព ហើយបានជ្រើសរើសនូវអ្នកដឹកនាំ ដែលអាចនិយាយតំណាងឱ្យសហគមន៍ និងនិយាយជាមួយនឹងសហគមន៍ នៅក្នុងគ្រប់ការចរចាទាំងអស់ដែលធ្វើឡើងជាមួយអ្នកទទួលផលក្រុមហ៊ុនផ្តល់សេវាសាធារណៈធនាគារ និងការិយាល័យនិយ័តកម្មសេដ្ឋកិច្ច។

ប្រភព : ADB. 2005. *Regional Technical Assistance to implement Pilot Projects for Small Piped Water Networks.* Manila.

## ទឹក និងអនាម័យ និងឧបករណ៍ចូលរួម

គម្រោងរបស់ ADB បានបង្កើតនូវឧបករណ៍ដ៏មានប្រយោជន៍ ដើម្បីគាំទ្រឱ្យមានការចូលរួមក្នុងការងារផ្គត់ផ្គង់ទឹក និងអនាម័យ។

**ឧបករណ៍របស់ ADB ដែលពាក់ព័ន្ធជាមួយនឹងទឹក និងអនាម័យ និងឧបករណ៍ចូលរួម**

| ឧបករណ៍ | សេចក្តីពិពណ៌នា |
|---|---|
| នៅក្នុងបំពង់ទឹក ទឹកសម្រាប់អ្នកក្រ (**In the Pipeline. Water for the Poor**) ការវិនិយោគលើ បណ្តាញផ្គត់ផ្គង់ទឹកខ្នាតតូច[ក] | កញ្ចប់ឧបករណ៍នេះ ត្រូវបានបង្កើតឡើងសម្រាប់ប្រើប្រាស់ដោយរដ្ឋាភិបាល ទីភ្នាក់ងារអភិវឌ្ឍន៍ ក្រុមហ៊ុនផ្តល់សេវាសាធារណៈ និងសង្គមស៊ីវិលដែលអនុវត្តគម្រោងផ្គត់ផ្គត់ទឹកតាម បណ្តាញខ្នាតតូច។ ឧបករណ៍នេះផ្តល់នូវម៉ូឌុល ដែលគ្របដណ្តប់លើសមាសភាគសំខាន់ៗរបស់ គម្រោង (ការសិក្សាពីគម្រោង គំរូធុរកិច្ច ការផ្តល់ហិរញ្ញប្បទាន និរន្តរភាព និងវិធានការដែល ពាក់ព័ន្ធនឹងភាពអាចទទួលយកបាន និងវិធានការនិយ័តកម្ម) ក៏ដូចជាមានជាករណីសិក្សា និងលក្ខខណ្ឌប្រតិបត្តិគំរូ (ToR)កិច្ចសន្យា និងគោលការណ៍ណែនាំអំពីបទបញ្ជានានា។ ឧបករណ៍ នេះរំលេចឱ្យឃើញពីសារៈសំខាន់នៃការចូលរួមរបស់សហគមន៍ និងសង្គមស៊ីវិល និងឱកាសជាក់លាក់ ដើម្បីធានាឱ្យមានការចូលរួមបែបនេះ។ |
| លក្ខខណ្ឌប្រតិបត្តិគំរូ សម្រាប់ធ្វើការវាយតម្លៃវិភាគលើការ ផ្គត់ផ្គង់ទឹកក្នុងទីក្រុង[ខ] | លក្ខខណ្ឌប្រតិបត្តិនេះដាក់ចេញនូវក្របខ័ណ្ឌមួយ សម្រាប់ការវាយតម្លៃជាគំរូនៅតំបន់ទីក្រុង។ លក្ខខណ្ឌប្រតិបត្តិនេះលើកទឹកចិត្តឱ្យមានការចូលរួមរបស់សង្គមស៊ីវិល និងផ្តល់ការណែនាំអំពីការពិគ្រោះយោបល់ និងការចូលរួមសំខាន់ៗរបស់អ្នកពាក់ព័ន្ធ។ |
| លក្ខខណ្ឌប្រតិបត្តិគំរូ-ការសម្រួលដល់អ្នកផ្គត់ផ្គង់ទឹកតាមបណ្តាញជាលក្ខណៈឯកជន[គ] | លក្ខខណ្ឌប្រតិបត្តិនេះដាក់ចេញនូវក្របខ័ណ្ឌមួយ សម្រាប់ជម្រុញឱ្យមានការចូលរួមរបស់អ្នក ផ្តល់សេវាខ្នាតតូច (រួមទាំងអង្គការសហគមន៍ផង) នៅក្នុងការរៀបចំកម្មវិធីរបស់វិស័យសាធារណៈ និងឯកជន។ មានជំហានចំនួន ៥ សម្រាប់ធ្វើការជ្រើសរើសប្រតិបត្តិករសម្រាប់ បណ្តាញណាមួយ។ ជំហានទាំងនេះ រួមមាន ការចូលរួមតតាមរយៈការអង្កេតវិភាគតាមបែប រហ័សលើអតិថិជន និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ នៅតាមសហគមន៍គោលដៅ ជាមួយក្រុមហ៊ុនផ្តល់សេវាសាធារណៈ អ្នកផ្តល់សេវាអាជ្ញាធរដែនដី អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នដទៃទៀត។ |
| ក្រុមសិក្សារៀនសូត្រ – មគ្គុទេសក៍សម្រាប់អ្នកសម្របសម្រួល ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព នៅតំបន់ទន្លេសាប[ឃ] | ក្រុមសិក្សារៀនសូត្រ គឺជាមនុស្សមួយក្រុម ដែលជួបប្រជុំគ្នាជាទៀងទាត់ ដើម្បីធ្វើការពិភាក្សា និងរៀនសូត្រពីបញ្ហានានា ដែលជាការព្រួយបារម្ភរបស់ពួកគេសហគមន៍ពួកគេ ឬសង្គមទាំងមូល។ នេះគឺជាវិធីសាស្ត្រប្រមូលផ្តុំសហគមន៍មួយ ដើម្បីជម្រុញឱ្យមានការធ្វើសកម្មភាព ដើម្បីដោះស្រាយបញ្ហាដែលបានពិភាក្សាគ្នា។ មគ្គុទេសក៍នេះ គឺជាធនធានទូទៅមួយ សម្រាប់ ប្រើប្រាស់ជាមួយនឹងក្រុមសិក្សារៀនសូត្រណាក៏បាន ហើយងាយស្រួល យកទៅអនុវត្តចំពោះបញ្ហាទឹក និងអនាម័យ និងបញ្ហាអនាម័យផ្ទាល់ខ្លួន និងសុខភាពដែលពាក់ព័ន្ធ។ |

[ក] ADB. 2008. *In the Pipeline. Water for the Poor. Investing in Small Piped Water Networks.* Manila. www.adb.org/Documents/Books/Water-Pipeline/default.asp

[ខ] ADB. Model TOR. Diagnostic City Water Assessments. www.adb.org/Water/tools/City-Water-Assessments.asp

[គ] ADB. Model TOR. Mainstreaming Small Scale Private Water Piped Network Providers. www.adb.org/Water/tools/TOR-SSPWP.asp

[ឃ] Live & Learn Environmental Education. 2004. (Prepared for ADB as part of TA-6123. Promoting Effective Water Management Policies and Practice). *Learning Circle Facilitators' Guide to Promote Sustainable Development in the Tonle Sap.* Phnom Penh. www.livelearn.org/resources/manuals/LC%20Facilitators%20Guide%20Tonle%20Sap.pdf

អង្គការនានាបានបង្កើតនូវធនធានជាច្រើន ដើម្បីគាំទ្រដល់ការចូលរួម នៅក្នុងវិស័យផ្គត់ផ្គង់ទឹក និងអនាម័យ។ បញ្ជីធនធាននៃមគ្គុទេសក៍នេះ មានរៀបរាប់ពីធនធានមួយចំនួន។ ធនធានដែលមានប្រយោជន៍ជាពិសេស គឺគេហទំព័ររបស់កម្មវិធីទឹក និងអនាម័យ (WSP) ដែលជាកម្មវិធីភាពជាដៃគូរបស់អ្នកផ្តល់ជំនួយចម្រុះ។ ធនាគារពិភពលោក គឺជាអ្នកចាត់ចែងដើម្បីជួយឱ្យប្រជាពលរដ្ឋក្រីក្រទទួលបានសេវាផ្គត់ផ្គង់ទឹក និងអនាម័យដែលមានតម្លៃសមរម្យមានសុវត្ថិភាព និងមាននិរន្តរភាព។[៨០]

# ឧបសម្ព័ន្ធ

## ១. ភារកិច្ចរបស់ ADB ពាក់ព័ន្ធនឹងការចូលរួម

### សេចក្តីផ្តើម

ភារកិច្ច ដែលពាក់ព័ន្ធជាមួយនឹងការចូលរួមក្នុងប្រតិបត្តិការរបស់ ADB ត្រូវបានបង្ហាញយ៉ាងច្បាស់។ យុទ្ធសាស្ត្រ ២០២០ រៀបរាប់ពីវិស័យស្នូលចំនួន៥ ដែល ADB ត្រូវផ្តោតការយកចិត្តទុកដាក់។ វិស័យទាំង ៥ នេះត្រូវបំពេញបន្ថែមដោយកម្លាំងចលករដែលធ្វើឱ្យមានការផ្លាស់ប្តូរចំនួន៥។ កម្លាំងចលករនីមួយៗផ្តល់លទ្ធភាពឱ្យ ADB បំពេញការងារក្នុងនាមជាទីភ្នាក់ងារដែលធ្វើឱ្យមានការផ្លាស់ប្តូរ តាមរយៈការជម្រុញឱ្យមានកំណើន និងការធ្វើការងារ រួមជាមួយនឹងជំនួយអភិវឌ្ឍន៍ទូលំទូលាយផ្សេងទៀត។ ឥឡូវនេះមានការស្វែងចេញឱ្យឃើញយ៉ាងច្បាស់ថា អ្វីដែលសំខាន់គឺល្បឿន និងនិន្នាការនៃកំណើន។ ការចូលរួម និងការធ្វើការងារជាមួយនឹងសង្គមស៊ីវិលត្រូវបានគេទទួលស្គាល់ ថាជាផ្នែកមួយដ៏សំខាន់នៃភាពជាដៃគូ (លេខយោងចុងក្រោយទី ២)។

**យុទ្ធសាស្ត្រ ២០២០ របស់ ADB**

**វិស័យសំខាន់ៗ**

- ហេដ្ឋារចនាសម្ព័ន្ធ
- បរិស្ថាន(រាប់បញ្ចូលទាំងការប្រែប្រួលអាកាសធាតុ)
- សហប្រតិបត្តិការប្រចាំតំបន់ និងសមាហរណកម្ម
- ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ
- ការអប់រំ

**វិស័យដទៃទៀត**

- សុខាភិបាល
- កសិកម្ម
- គ្រោះមហន្តរាយ និងជំនួយគ្រាអាសន្ន

**កម្លាំងចលករនៃការផ្លាស់ប្តូរ**

- ការអភិវឌ្ឍវិស័យឯកជន និងប្រតិបត្តិការវិស័យឯកជន
- អភិបាលកិច្ចល្អ និងការអភិវឌ្ឍសមត្ថភាព
- សមធម៌យេនឌ័រ
- ដំណោះស្រាយចំណេះដឹង
- ភាពជាដៃគូ

ប្រភព៖ ADB. 2008. *Strategy 2020: The Long-Term Strategic Framework of the Asian Development Bank 2008–2020.* Manila.

យុទ្ធសាស្ត្រ ២០២០ ត្រូវបានបំពេញបន្ថែមដោយយុទ្ធសាស្ត្រពន្លឿនការកាត់បន្ថយភាពក្រីក្ររបស់ ADB (២០០៤) ដែលបានចែងថា "ការផ្តល់សេវា និងនិរន្តរភាពនៃការអភិវឌ្ឍសង្គមកាន់តែមានភាពប្រសើរឡើង នៅពេលដែលមនុស្សគ្រប់រូប ជាពិសេសប្រជាពលរដ្ឋក្រីក្រ និងអ្នកដែលត្រូវបានគេផាត់ចេញ មានឱកាសចូលរួម នៅក្នុងការ កំណត់ពីគោលនយោបាយ និងកម្មវិធីសាធារណៈ"។

កាន់តែទូលំទូលាយជាងនេះទៅទៀត គោលវិធីដែលមានការចូលរួម ដែលរួមមានការធ្វើការងារប្រកបដោយ អត្ថន័យជាមួយនឹងសង្គមស៊ីវិលទទួលបានការគាំទ្រពីគោលនយោបាយដទៃទៀតជាច្រើនរបស់ ADB ពីដំណើរការ ធុរកិច្ច និងពីគោលការណ៍ណែនាំ និងការណែនាំដល់បុគ្គលិក។

"ADB ចាត់ទុកការលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យសាធារណៈ វិស័យឯកជន និងសង្គមស៊ីវិលនៅក្នុងគ្រប់ប្រតិបត្តិការទាំងអស់ថាមានសារៈសំខាន់យ៉ាងខ្លាំង" ។

ប្រភព ៖ ADB. 2003. Promotion of Cooperation with NGOs. *Operations Manual.* OM E4/BP. Manila.

ADB បានលើកទឹកចិត្តឱ្យមានការសហការជាមួយនឹងសង្គមស៊ីវិល ចាប់តាំងពីឆ្នាំ ១៩៨៧ មកម្ល៉េះ ហើយ សហប្រតិបត្តិការនេះត្រូវបានពង្រឹងបន្ថែមទៀត នៅក្នុងគោលនយោបាយសហការជាមួយអង្គការក្រៅរដ្ឋាភិបាលឆ្នាំ ១៩៩៨ ដែលត្រូវបានធ្វើបច្ចុប្បន្នកម្ម ។[៩១] គោលនយោបាយនេះទទួលស្គាល់បទពិសោធន៍ចំណេះដឹង និងជំនាញរបស់សង្គមស៊ីវិល ថាជាទ្រព្យដ៏មានតម្លៃ ដើម្បីឱ្យ ADB អាចបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅអាស៊ី និងប៉ាស៊ីហ្វិច ។ ក្របខ័ណ្ឌសម្រាប់សម្រួលដល់ដំណើរការអភិវឌ្ឍន៍ដោយមានការចូលរួម នៅក្នុងប្រតិបត្តិការនានារបស់ ADB ត្រូវបានរៀបចំឡើងនៅក្នុងឆ្នាំ ១៩៩៦ ជាផ្នែកមួយនៃការផ្តល់ការណែនាំដល់បុគ្គលិក ។ ក្របខ័ណ្ឌនេះរៀបរាប់ពីរបៀបដែលដំណើរការអភិវឌ្ឍន៍ដែលមានការចូលរួមមានភាពសមស្របទៅនឹងប្រតិបត្តិការធុរកិច្ចរបស់ ADB ។

PCP និង SPS របស់ ADB ក៏មានទំនាក់ទំនងយ៉ាងជិតស្និទជាមួយនឹងការចូលរួម និងផ្តល់ការគាំទ្រដល់ការចូលរួមផងដែរ ។

**គោលនយោបាយប្រាស្រ័យទាក់ទងសាធារណៈ (២០១១)** មានគោលបំណងបង្កើនការជឿទុកចិត្ត និង សមត្ថភាពរបស់អ្នកពាក់ព័ន្ធដើម្បីចូលរួមជាមួយនឹង ADB ។ គោលនយោបាយនេះទទួលស្គាល់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការស្វែងរក និងទទួលបានព័ត៌មានអំពីប្រតិបត្តិការនានារបស់ ADB ។ គោលនយោបាយនេះគាំទ្រដល់ការចែករំលែក ចំណេះដឹង និងផ្តល់លទ្ធភាពឱ្យមានការអភិវឌ្ឍដែលមានការចូលរួម ឬការប្រាស្រ័យទាក់ទងទ្វេទិសជាមួយអ្នកដែលរងផលប៉ះពាល់ ។

**គោលនយោបាយស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាន (២០០៩)** តម្រូវឱ្យអ្នកខ្ចី/អតិថិជនចូលរួមជាមួយនឹងសហគមន៍ ក្រុម ឬអ្នកដែលរងផលប៉ះពាល់ដោយសារគម្រោងនានាដែលស្នើឡើង និងជាមួយនឹងសង្គមស៊ីវិលតាមរយៈការបង្ហាញព័ត៌មានជាចំហការពិគ្រោះយោបល់ និងការចូលរួមត្រឹមត្រូវសមស្របទៅនឹងហានិភ័យ និងផលប៉ះពាល់ដែលមានមកលើសហគមន៍ដែលរងផលប៉ះពាល់ (សម្រាប់ព័ត៌មានបន្ថែម សូមមើលផ្នែកស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាន ទំព័រទី ៦៣) ។

ប្រភព៖ ADB. 2011. *Public Communications Policy 2011.* Manila; ADB. 2009. *Safeguard Policy Statement.* Manila.

ការចូលរួមក៏ទទួលបានការគាំទ្រផងដែរ នៅក្នុងគោលនយោបាយយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិតាមវិស័យរបស់ ADB ។ ខាងក្រោមនេះគឺជាព័ត៌មានអំពីគោលនយោបាយសំខាន់ៗ ៖

## គោលនយោបាយរបស់ ADB ដែលពាក់ព័ន្ធជាមួយនឹងការចូលរួម

**ផែនការប្រតិបត្តិនៃគំនិតផ្តួចផ្តើមដឹកជញ្ជូនប្រកបដោយនិរន្តរភាព (២០១០)** ទទួលស្គាល់ថា ចាំបាច់ត្រូវមានគោលវិធីដែលមាន ប្រសិទ្ធភាពជាងមុន ដើម្បីធ្វើការគ្រប់គ្រងទិដ្ឋភាពសង្គមនៃវិស័យគមនាគមន៍/ដឹកជញ្ជូន ។ គោលវិធីទាំងនេះ រួមមានការប្រើប្រាស់គោលវិធីដែលមានការចូលរួមច្រើនជាងមុន សម្រាប់ការរៀបចំផែនការគម្រោង និងយុទ្ធសាស្រ្តគម្រោង ដើម្បីការពារហានិភ័យផ្នែកមេរោគ/ជំងឺអេដស៍ និងការជួញដូរមនុស្សការដាក់បញ្ចូលការថែទាំនៅតាមសហគមន៍ និងការប្រើប្រាស់ជម្រើសថ្លៃប្រើប្រាស់ និងជម្រើសឧបត្ថម្ភធន ដើម្បីបង្កើនការផ្តល់សេវាដល់ក្រុមដែលងាយរងគ្រោះ ។

**ផែនការប្រតិបត្តិ សម្រាប់ធានានិរន្តរភាពសន្តិសុខស្បៀងនៅអាស៊ី និងប៉ាស៊ីហ្វិច (២០០៩)** លើកឡើងថាអភិបាលកិច្ចល្អ និងការកសាងសមត្ថភាព នឹងទទួលបានការគាំទ្រតាមរយៈការដកចេញនូវឧបសគ្គនានា ដែលរារាំងដល់ការចូលរួមរបស់ប្រជាពលរដ្ឋក្រីក្រ និងក្រុមដែលងាយរងគ្រោះ ។ ផែនការនេះមានដាក់បញ្ចូលនូវការផ្តោតការយកចិត្តទុកដាក់លើអ្នកដែលនៅតែត្រូវបានគេផាត់ចេញ មិនឱ្យចូលរួមនៅក្នុងសកម្មភាពសេដ្ឋកិច្ច ដើម្បីផ្តល់ឱ្យអ្នកផលិតតូចៗនូវលទ្ធភាពគ្រប់គ្រាន់ ដើម្បីទទួលបានទីផ្សារ បច្ចេកវិទ្យា និង ព័ត៌មាន និងផ្តល់នូវឱកាសរកចំណូល និងឱកាសការងារចម្រុះដល់ពួកគេ ។

**ការសម្រេចបាននូវប្រសិទ្ធភាពនៃការអភិវឌ្ឍ នៅក្នុងតាមប្រទេសដែលមានលទ្ធផលការងារនៅខ្សោយ (គោលវិធីជម្រុញឱ្យមាន ការចូលរួមនៅក្នុងប្រទេសដែលមានលទ្ធផលការងារនៅខ្សោយរបស់ ADB ២០០៧)** ចែងថា ADB នឹងបង្កើនការប្រើប្រាស់ វិធីសាស្រ្តរៀបចំគម្រោង និងកម្មវិធី ដែលលើកកម្ពស់តួនាទីរបស់អ្នកទទួលផលគោលដៅ នៅក្នុងករណីមិនមានរដ្ឋាភិបាល ដែលអាចបំពេញការងារក្នុងកម្រិតគ្រប់គ្រាន់ ។

**ការអភិវឌ្ឍភាពក្រីក្រ និងមេរោគ/ជំងឺអេដស៍ : ការឆ្លើយតបជាយុទ្ធសាស្រ្តរបស់ ADB ចំពោះការកើនឡើងនូវការរាលដាលជំងឺ (២០០៥)** ចែងថារដ្ឋាភិបាលមិនស្ថិតនៅក្នុងស្ថានភាពមួយល្អដើម្បីធ្វើគ្រប់ការងារទាំងអស់ ដែលចាំបាច់ត្រូវធ្វើដើម្បីដោះស្រាយបញ្ហាមេរោគ និងជំងឺអេដស៍នោះទេ ជាពិសេសនៅក្នុងការផ្តោតគោលដៅ និងការធ្វើការងារជាមួយនឹងក្រុមដែលនៅឯកោពីគេក្នុងសង្គម និងក្រុមដែលទទួលរងការមាក់ងាយ ។ អង្គការក្រៅរដ្ឋាភិបាល និងអង្គការសហគមន៍បានបង្ហាញពីសមត្ថភាពរបស់ពួកគេ ដើម្បីបំពេញតួនាទីបន្ថែមដ៏សំខាន់ ក្នុងការកៀងគរធនធាន និងផ្តល់នូវការបង្ការ និងការថែទាំ ។

**គោលនយោបាយស្តីពីការផ្តល់ជំនួយសម្រាប់គ្រោះមហន្តរាយ និងគ្រោះអាសន្ន (២០០៤)** ចែងថា ADB ចាត់ទុកការលើកទឹកចិត្ត ឱ្យមានការចូលរួមពីវិស័យសាធារណៈវិស័យឯកជន និងសង្គមស៊ីវិល នៅក្នុងគ្រប់ប្រតិបត្តិការទាំងអស់ ថាមានសារៈសំខាន់ ហើយពុំមានផ្នែកណាដែលសំខាន់ជាងការត្រៀមបង្ការគ្រាអាសន្ន និងការឆ្លើយតបចំពោះវិបត្តិនោះឡើយ ។ សង្គមស៊ីវិល និងទីភ្នាក់ងារផ្តល់ជំនួយសង្គ្រោះ និងមនុស្សធម៌គឺជាដៃគូដ៏សំខាន់ ។ ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធចម្រុះរបស់ ADB ការចូលរួមរបស់ប្រជាពលរដ្ឋ និងភាពជាម្ចាស់នៅមូលដ្ឋានលើដំណើរការស្តារបនាឡើងវិញ និងដំណើរការអភិវឌ្ឍន៍មានសារៈសំខាន់យ៉ាងខ្លាំង ។

**យន្តការគណនេយ្យភាព (២០០៣)** រួមមាន ដំណាក់កាលពិគ្រោះយោបល់ ដើម្បីឆ្លើយតបចំពោះបញ្ហាជាក់លាក់របស់ប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់នៅក្នុងគម្រោងដែលទទួលបានជំនួយពី ADB តាមរយៈវិធីសាស្រ្តដែលផ្អែកលើការឯកភាពគ្នាក្រៅផ្លូវការ ដោយមានការចូលរួមពីគ្រប់ភាគីដែលពាក់ព័ន្ធទាំងអស់ និងដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម ដើម្បីធ្វើការស្រាវជ្រាវអំពីការប្រព្រឹត្តល្មើសទៅនឹងគោលនយោបាយ និងនីតិវិធីប្រតិបត្តិការរបស់ ADB ។ ដំណាក់កាលទាំង ២ នេះមានទំនាក់ទំនងជាមួយ នឹងគោលបំណងបង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍ និងគុណភាពគម្រោងរបស់ ADB ។

**គោលនយោបាយស្តីពីយេនឌ័រ និងការអភិវឌ្ឍ (១៩៩៨)** ចាត់ទុកការបញ្ជ្រាបយេនឌ័រ ថាជាយុទ្ធសាស្រ្តដ៏សំខាន់មួយ ហើយការ បញ្ជ្រាបនេះត្រូវបានឱ្យនិយមន័យថាជា "ការពិចារណាលើបញ្ហាយេនឌ័រ នៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់របស់ ADB អមដោយកិច្ចខិតខំប្រឹងប្រែងដើម្បីលើកទឹកចិត្ត ឱ្យមានការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការសម្រេចចិត្តនៃសកម្មភាពអភិវឌ្ឍន៍នានា" ។

**គោលនយោបាយស្តីពីការអប់រំ (២០០២)** ទទួលស្គាល់ថាចាំបាច់ត្រូវតែមានការចូលរួមឱ្យបានកាន់តែសកម្មពីអង្គការក្រៅរដ្ឋាភិបាល ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់សហគមន៍ នៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការអភិវឌ្ឍន៍វិស័យអប់រំ ។ គោលនយោបាយនេះក៏មានចែងផងដែរថា សហគមន៍មូលដ្ឋានគួរចូលរួមឱ្យបានកាន់តែសកម្មជាងមុន នៅក្នុងការរៀបចំ និងការអនុវត្តការងារអប់រំ ដែល ទទួលបានជោគជ័យ និងមាននិរន្តរភាព ។

**គោលនយោបាយទឹកសម្រាប់ទាំងអស់គ្នា (២០០១)** លើកឡើងថា ADB នឹងលើកកម្ពស់ឱ្យមានការចូលរួម នៅក្នុងការគ្រប់គ្រងធនធានទឹក នៅគ្រប់កម្រិតទាំងអស់ហើយនឹងជម្រុញឱ្យមានការសហការគ្នា ក្នុងភាពជាដៃគូរវាងរដ្ឋាភិបាល ទីភ្នាក់ងារឯកជនអង្គការក្រៅរដ្ឋាភិបាល និងសហគមន៍ ។ ការចូលរួមគឺជាការចាំបាច់ដើម្បីធានាយ៉ាងណាឱ្យមានធ្វើសុខុដុមនីយកម្មលើចំណុចដែល ដែលមានភាពប្រទាំងប្រទើសគ្នា និងដកចេញនូវបញ្ហាអសមធម៌ ។

**អភិបាលកិច្ច : ការគ្រប់គ្រងការអភិវឌ្ឍដែលមានភាពល្អប្រសើរ (១៩៩៥)** ចែងថាប្រជាពលរដ្ឋ គឺជាអ្នកទទួលផលចុងក្រោយ និងជាទីភ្នាក់ងារនៃការអភិវឌ្ឍ។ ការចូលរួម គឺជាសកម្មភាពដ៏សំខាន់មួយ ក្នុងចំណោមសកម្មភាពសំខាន់ៗទាំង ៤ ហើយតម្រូវឱ្យរចនាសម្ព័ន្ធរបស់រដ្ឋាភិបាលមានភាពបត់បែនគ្រាន់គ្រាន់ដើម្បីឱកាសឱ្យអ្នកទទួលផល និងអ្នកដែលរងផលប៉ះពាល់ដទៃទៀត ចូលរួមធ្វើការកែលំអការរៀបចំ និងការអនុវត្តគោលនយោបាយសាធារណៈកម្មវិធី និងគម្រោងនានា។ នៅកម្រិតសង្គម ការស្រាវជ្រាវបានបង្ហាញថា រដ្ឋាភិបាលមានប្រសិទ្ធភាពបំផុត នៅពេលធ្វើការងារជាមួយសង្គមស៊ីវិលដែលមានភាពរឹងមាំ។ រដ្ឋាភិបាលអាចបង្កើនសម្ព័ន្ធភាពជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល ដើម្បីបង្កើនការចូលរួមនៅកម្រិតសហគមន៍ និងលើកកម្ពស់ ឱ្យមានការប្រើប្រាស់គោលវិធីពីក្រោមឡើងលើសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

សៀវភៅណែនាំអំពីប្រតិបត្តិការរបស់ ADB មានដាក់បញ្ចូលនូវព័ត៌មានយោងសំខាន់ៗអំពីការចូលរួម (សូមមើលផ្នែកទី២ នៃឧបសម្ព័ន្ធ)។ ផ្នែកដែលនិយាយអំពីការលើកកម្ពស់ ឱ្យមានការសហការជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល (២០០៣) ចាត់ទុកអង្គការក្រៅរដ្ឋាភិបាលថាជាដៃគូដ៏មានប្រយោជន៍ ឬជាទីប្រឹក្សាគម្រោង នៅក្នុងការកំណត់ ការរៀបចំ ការអនុវត្ត ការពិនិត្យតាមដាន និងវាយតម្លៃគម្រោង។ ចុងក្រោយមានសៀវភៅណែនាំ និងគោលការណ៍ណែនាំជាក់ស្តែងជាច្រើន ដែលផ្តល់ការគាំទ្រដល់ការចូលរួម ហើយបំពេញបន្ថែមឱ្យមគ្គុទេសក៍នេះ។ នៅក្នុង *សៀវភៅណែនាំអំពីការវិភាគសង្គម* (២០០៧) ការចូលរួមត្រូវបាន រំលេចជាទិដ្ឋភាពសំខាន់មួយ ក្នុងចំណោមទិដ្ឋភាពសង្គមសំខាន់ៗ ចំនួន ៤ នៅក្នុងគោលនយោបាយ និងប្រតិបត្តិការនានា របស់ ADB ក៏ដូចជានៅក្នុងគោលនយោបាយស្តីពីយេនឌ័រ និងការអភិវឌ្ឍ គោលនយោបាយស្តីពីការការពារផលប៉ះពាល់សង្គម និងការគ្រប់គ្រងហានិភ័យ និងភាពងាយរងគ្រោះដទៃទៀត។ *គោលការណ៍ណែនាំបុគ្គលិកស្តីពីការរៀបចំយុទ្ធសាស្ត្រស្តីពីភាពជាដៃគូប្រចាំប្រទេស (CPS) និងក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដាន (DMF)* ក៏រំលេចឱ្យឃើញផងដែរពីឱកាសសម្រាប់ចូលរួម ហើយ *សៀវភៅធនធានសម្រាប់សង្គមស៊ីវិល* គឺជាឯកសារយោងដ៏មានប្រយោជន៍មួយសម្រាប់ធ្វើការងារជាមួយនឹងអង្គការសង្គមស៊ីវិលជាដៃគូ។[៨២]

"ADB ទទួលស្គាល់ពីសារៈសំខាន់នៃការផ្សព្វផ្សាយព័ត៌មាន និងការលើកទឹកចិត្តឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធនានា នៅក្នុងការបង្កើតកម្មវិធីប្រចាំប្រទេស និងការរៀបចំ និងការអនុវត្តគម្រោងជាក់លាក់។ កត្តាទាំងនេះអាច បង្កើនប្រសិទ្ធភាពភាពពាក់ព័ន្ធ និងនិរន្តរភាពនៃសកម្មភាពអភិវឌ្ឍន៍ និងអាចរួមចំណែកចំពោះអភិបាលកិច្ចល្អ និងការចូលរួម និងការផ្តល់ភាពអង់អាចដល់ក្រុមដែលជួបប្រទះការលំបាក"។

ប្រភព : ADB. 2007. *Handbook on Social Analysis. A Working Document.* Manila.

## ២. សៀវភៅណែនាំអំពីការចូលរួមនៅក្នុងប្រតិបត្តិការរបស់ ADB

សម្រាប់ព័ត៌មានបន្ថែមអំពីគោលនយោបាយនីមួយៗ ក្នុងចំណោមគោលនយោបាយទាំងនេះ និងការអនុវត្ត គោលនយោបាយទាំងនេះសូមចូលមើលគេហទំព័រ www.abd.org ។ សូមកត់សម្គាល់ថា ព័ត៌មានយោងបង្ហាញជា កថាខណ្ឌខាងក្រោម គឺសំដៅលើផ្នែកដែលត្រូវបានដកស្រង់ចេញពីសៀវភៅណែនាំអំពីប្រតិបត្តិការរបស់ ADB ។

### យន្តការគណនេយ្យភាព សៀវភៅណែនាំប្រតិបត្តិការផ្នែក L1/BP

១. ដំណាក់កាលពិគ្រោះយោបល់ មានគោលបំណងជួយដល់អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង ក្នុងការដោះស្រាយបញ្ហាជាក់លាក់ដែលបង្កឡើងដោយសារគម្រោងដែលទទួលបានជំនួយពី ADB តាមរយៈវិធីសាស្ត្រក្រៅ ផ្លូវការផ្អែកទៅតាមការឯកភាពគ្នា និងការចូលរួមពីសំណាក់គ្រប់ភាគីទាំងអស់ឱ្យ ។ ឧ. អ្នកសម្របសម្រួលគម្រោងពិសេស (SPF) អាចស្នើឱ្យមានការប្រើប្រាស់គោលវិធីផ្សេងៗពីគ្នា ដូចជាការរៀបចំកិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធការរៀបចំ និងសម្របសម្រួលដំណើរការពិគ្រោះយោបល់ ឬការចូលរួមនៅក្នុងការស្វែងរកការពិតអំពីស្ថានភាពអ្វីមួយ ។ [...]

២. សកម្មភាពជាក់លាក់របស់ការិយាល័យ SPF រួមមានដូចខាងក្រោម : [...]

iii. អនុវត្តកម្មវិធីផ្សព្វផ្សាយព័ត៌មានដល់សាធារណជនទូទៅ

iv. ពិនិត្យ និងវាយតម្លៃលើពាក្យបណ្តឹងនានា [...]

vi. សម្របសម្រួលការពិគ្រោះយោបល់ ប្រើប្រាស់ការិយាល័យរបស់គណៈកម្មាធិការនេះ និង/ឬសម្របសម្រួលឱ្យមានការបង្កើតនូវយន្តការសម្រុះសម្រួលមួយ

vii. ផ្តល់ព័ត៌មានដល់ក្រុមប្រឹក្សាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀតអំពីសកម្មភាពពិគ្រោះយោបល់ជាក់លាក់ [...]

៣. មុខងាររបស់ OCRP (ដំណាក់កាលការិយាល័យពិនិត្យឡើងវិញលើភាពអនុលោម) រួមមាន (i) ការធ្វើការផ្សព្វផ្សាយព័ត៌មាន និងធ្វើការពិគ្រោះយោបល់ជាមួយសាធារណជន ពាក់ព័ន្ធជាមួយនឹងយន្តការគណនេយ្យភាពរបស់ ADB [...][៨៣]

៤. OCRP ធ្វើការសម្របសម្រួលជាមួយនឹងនាយកដ្ឋានប្រតិបត្តិការអង្គការក្រៅរដ្ឋាភិបាល និងមជ្ឈមណ្ឌលសង្គមស៊ីវិល និងនាយកដ្ឋានទំនាក់ទំនងសាធារណៈ ដើម្បីធានាឱ្យមានការដាក់បញ្ចូលការផ្សព្វផ្សាយព័ត៌មាន និងការពិគ្រោះយោបល់ជាសាធារណៈ ទៅក្នុងសកម្មភាពនានារបស់ ADB ដែលត្រូវបានរៀបចំឡើង ដើម្បីលើកកម្ពស់ឱ្យមានទំនាក់ទំនងជាមួយអ្នកទទួលផលរបស់គម្រោង ឬអ្នកពាក់ព័ន្ធនានា រាប់បញ្ចូលទាំងក្រុមសង្គមស៊ីវិលផងដែរ ។

## កិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល សៀវភៅណែនាំប្រតិបត្តិការផ្នែក E4/OP

៥. ការពិគ្រោះយោបល់ជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលបានក្លាយជាផ្នែកស្តង់ដាមួយនៃសកម្មភាពកំណត់ និងរៀបចំគម្រោងរបស់ADB ។ ក្នុងនាមជាប្រភពព័ត៌មានដៃគូ ឬទីប្រឹក្សាគម្រោងអង្គការក្រៅរដ្ឋាភិបាល អាចផ្តល់នូវទស្សនវិស័យផ្សេងៗពីគ្នា អំពីបញ្ហានៃការអភិវឌ្ឍ, ទស្សនៈថ្មីៗអំពីតម្រូវការ បំណងប្រាថ្នា និងទស្សនវិស័យរបស់សហគមន៍ ដែលជាអ្នកទទួលផលគោលដៅ និងធាតុចូលអំពីការអនុវត្តទម្រង់ការនានាសម្រាប់កម្ចី និងសកម្មភាពជំនួយបច្ចេកទេស ដែលទទួលបានថវិកាពី ADB ។

៦. នៅក្នុងកំឡុងពេលអនុវត្តគម្រោង ឬជំនួយបច្ចេកទេសគេអាចជម្រុញឱ្យមានការចូលរួមពីអង្គការក្រៅរដ្ឋាភិបាលដែលមានសមត្ថភាពគ្រប់គ្រាន់នៅពេលដែលសមស្រប ជាទីភ្នាក់ងារងារប្រតិបត្តិ ឬអនុវត្ត ទៅតាមការ យល់ព្រមពីរដ្ឋាភិបាល ឬគេអាចជួលអង្គការក្រៅរដ្ឋាភិបាលឱ្យអនុវត្តសមាសភាគណាមួយរបស់គម្រោង ឬផ្តល់នូវសេវាជាក់លាក់ដូចជាការកៀងគរសហគមន៍ការបណ្តុះបណ្តាលឬការផ្តល់សេវារបស់គម្រោងទៅឱ្យសហគមន៍ ឬប្រជាពលរដ្ឋ ដែលត្រូវបានជ្រើសរើស ។ អង្គការក្រៅរដ្ឋាភិបាលក៏អាចមានតួនាទី នៅក្នុងការពិនិត្យតាមដានកម្មវិធី / គម្រោង និងជំនួយបច្ចេកទេស និងជួយដោះស្រាយបញ្ហានិរន្តរភាពគម្រោងដូចជានៅក្នុងការបន្តដំណើរការ និងថែទាំហេដ្ឋារចនាសម្ព័ន្ធសហគមន៍ជាដើម ។ [...]

## យុទ្ធសាស្ត្រស្ដីពីភាពជាដៃគូប្រចាំប្រទេស សៀវភៅណែនាំប្រតិបត្តិការផ្នែក A2/OP

៧. ក្រុមការងារដែលចុះបេសកកម្មរៀបចំយុទ្ធសាស្ត្រ ធ្វើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធក្នុងប្រទេស កំពុងអភិវឌ្ឍជាសមាជិក[៨៤] អំពីសេចក្តីព្រាង CPS និងផែនការធុរកិច្ចនៃប្រតិបត្តិការប្រចាំប្រទេស (COBP) ជាធម្មតាសម្រាប់រយៈពេល ៣ ឆ្នាំម្តងនៃ CPS ។ បេសកកម្មនេះបញ្ចប់ជាមួយនឹង ការបង្កើតអនុស្សរណៈនៃការយោគយល់គ្នា ជាមួយនឹងប្រទេសកំពុងអភិវឌ្ឍជាសមាជិក ។ ក្រុមការងារដែលចុះបេសកកម្មរៀបចំ CPS ក៏ធ្វើការសម្របសម្រួល ជាមួយនឹងដៃគូអភិវឌ្ឍន៍ដទៃទៀតដែរ ។

## ជំនួយសម្រាប់គ្រោះមហន្តរាយ និងគ្រោះអាសន្ន សៀវភៅណែនាំប្រតិបត្តិការផ្នែក D7/OP

៨. ដំណើរការដែលមានការចូលរួម គឺជាផ្នែកមួយដ៏សំខាន់នៃការងាររបស់ ADB ដោយផ្តោតគោលដៅជាពិសេស លើការលើកកម្ពស់ការកាត់បន្ថយភាពក្រីក្រតាមរយៈធាតុចូល និងភាពជាម្ចាស់របស់អ្នកដែលមានភាគហ៊ុន ។ ADB ចាត់ទុកការលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យសាធារណៈវិស័យឯកជន និងសង្គមស៊ីវិល នៅក្នុងគ្រប់ប្រតិបត្តិការទាំងអស់ ថាមានសារៈសំខាន់យ៉ាងខ្លាំងហើយពុំមានការចូលរួមណាដែលសំខាន់ជាងការត្រៀមបង្ការគ្រោះអាសន្ន និងការឆ្លើយតបចំពោះវិបត្តិឡើយ ។ បើទោះបីជាក្របខ័ណ្ឌពេលវេលាអាចមានលក្ខណៈបន្ទាន់ជាងកាលៈទេសៈធម្មតាក៏ដោយ ដោយសារតែលក្ខណៈបន្ទាន់នៃជំនួយសម្រាប់គ្រាអាសន្ន ADB នឹងបន្តប្រើប្រាស់ដំណើរការពិគ្រោះយោបល់ និងដំណើរការដែលមានការចូលរួម នៅក្នុងការរៀបចំគម្រោងឱ្យបានច្រើន តាមលទ្ធភាពដែលអាចធ្វើទៅបាន ។ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ជួយសម្របសម្រួលដល់ដំណើរការនេះ ។

## យេនឌ័រ និងការអភិវឌ្ឍ សៀវភៅណែនាំប្រតិបត្តិការផ្នែក C2/OP

៩. យុទ្ធសាស្ត្រយេនឌ័រ អាចមានដាក់បញ្ចូលការពិគ្រោះយោបល់កម្រិតគោលនយោបាយ, ការសិក្សាពិសេស។, ការវិនិយោគឱ្យចំគោលដៅដើម្បីកែតម្រូវបញ្ហាគម្លាតយេនឌ័រ, យុទ្ធសាស្ត្រសម្រាប់បង្កើនការចូលរួមរបស់ស្ត្រី នៅក្នុងដំណើរការនៃការអភិវឌ្ឍ, ការផ្តល់ការគាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី ។ [...]

១០. GAP របស់គម្រោងមួយ [...] រួមមាន (ii) លក្ខណៈរៀបចំ យន្តការ ចំណុចដៅ និងសូចនាករពិនិត្យតាមដាន ដែលមានការចូលរួមពីគ្រប់យេនឌ័រ ត្រូវបានដាក់បញ្ចូលទៅក្នុងការរៀបចំគម្រោង ដើម្បីសម្របសម្រួល និងលើកកម្ពស់ឱ្យមានការចូលរួមរបស់ស្ត្រី និង / ឬប្រយោជន៍រូបីពីគម្រោង ។ [...]

### Appendix 1
### Gender and Development Section of IPSA

បញ្ហាយេនឌ័រ គួរទទួលបានការឆ្លើយតប នៅពេលដែល :

- មានគម្លាត និងវិសមភាពយ៉ាងធំធេងរវាងលទ្ធភាពរបស់បុរស និងស្ត្រីក្នុងការទទួលបាន និងប្រើប្រាស់សេវាធនធានទ្រព្យសម្បត្តិ ឱកាស និងការចូលរួមនៅក្នុងការដំណើរការធ្វើសេចក្តីសម្រេចចិត្ត [...] ឧទាហរណ៍ អំពីការចូលរួមនៅក្នុងសៀវភៅណែនាំ អំពីប្រតិបត្តិការរបស់ ADB[៩១]

# ឧបសម្ព័ន្ធទី ២

# ការពិចារណាសំខាន់ៗពាក់ព័ន្ធនឹងយេនឌ័រ នៅក្នុងការរៀបចំគម្រោង

## ការវិភាគយេនឌ័រ

- [...] តើទាំងស្ត្រី ទាំងបុរស ត្រូវបានគេពិគ្រោះយោបល់ជាមួយ និងចូលរួមនៅក្នុងការរៀបចំគម្រោងដែរឬទេ?
- តើឧបសគ្គផ្នែកវប្បធម៌សង្គម ច្បាប់ សេដ្ឋកិច្ច និងឧបសគ្គដទៃទៀត ដែលរារាំងមិនឱ្យស្ត្រីអាចចូលរួម និងមិន ឱ្យមានអត្ថប្រយោជន៍ស្មើភាពគ្នាសម្រាប់គ្រប់យេនឌ័រទាំងអស់ត្រូវបានកំណត់ដែរឬទេ?
- តើមានការរៀបចំបង្កើតយុទ្ធសាស្ត្រ ដើម្បីដោះស្រាយឧបសគ្គទាំងនេះដែរឬទេ?
- តើអង្គការស្ត្រីនៅមូលដ្ឋានត្រូវបានគេពិគ្រោះយោបល់ ហើយតើសមត្ថភាពរបស់ពួកគេក្នុងនាមជាអ្នកផ្តល់សេវា ត្រូវបានគេវាយតម្លៃដែរឬទេ? [...]
- តើទិន្នន័យគោលបែងចែកតាមយេនឌ័រសំខាន់ៗ (ឧ. %នៃស្ត្រី ដែលបានចូលរួមក្នុងការបណ្តុះបណ្តាល តំណាងរបស់ស្ត្រី នៅក្នុងស្ថាប័នដែលធ្វើសេចក្តីសម្រេចចិត្ត) ត្រូវបានប្រមូលដើម្បីផ្តល់ព័ត៌មានអំពីចំណុចដៅយេនឌ័រ និងផែនការសកម្មភាពយេនឌ័រ និងក្នុងក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដានគម្រោងដែរឬទេ?

## ការរៀបចំគម្រោង

- [...] តើការរៀបចំគម្រោងមានដាក់បញ្ចូលនូវធាតុចេញយុទ្ធសាស្ត្រលក្ខណៈនៃការរៀបចំ ឬចំណុចដៅដើម្បីលើកកម្ពស់ និងសម្របសម្រួលឱ្យមានការចូលរួមយ៉ាងសកម្មភាពរបស់ស្ត្រី នៅក្នុងគម្រោង ដែរឬទេ? [...]
- តើមានការកំណត់នូវថវិកាដោយឡែក សម្រាប់សម្របសម្រួលការចូលរួមរបស់ស្ត្រី ដែរឬទេ?
- តើយុទ្ធសាស្ត្រ និងចំណុចដៅពាក់ព័ន្ធនឹងការចូលរួមរបស់ស្ត្រី ត្រូវបានដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដានរបស់គម្រោងនេះដែរឬទេ? [...]

# ឧបសម្ព័ន្ធទី ៣

## ទម្រង់នៃផែនការសកម្មភាពយេនឌ័ររបស់គម្រោង

ការរៀបចំគម្រោង ។ [...] ផែនការសកម្មភាពយេនឌ័រ ចាំបាច់ត្រូវដាក់បញ្ចូលនូវលក្ខណៈរៀបចំគម្រោងជាក់លាក់ នៅក្នុងធាតុចេញគម្រោងភាគច្រើន ដើម្បីសម្របសម្រួល និងធានាឱ្យស្ត្រីចូលរួម និងមានលទ្ធភាពទទួលបានប្រយោជន៍ ពីគម្រោង ដោយធាតុចេញភាគច្រើនក្នុងចំណោមធាតុចេញទាំងនេះមានលក្ខណៈ ឬយន្តការរៀបចំយេនឌ័រយ៉ាងហោចណាស់ ៣។ [...] ចំណុចដៅទាំងឡាយ ដែលត្រូវបានកំណត់សម្រាប់ការចូលរួមរបស់ស្ត្រី ឬលទ្ធភាពរបស់ស្ត្រី ដើម្បីទទួលបានប្រយោជន៍ពីគម្រោង ឧ. ចំនួនស្ត្រីដែលត្រូវទទួលបានការបណ្តុះបណ្តាល កៅអីបម្រុងសម្រាប់ស្ត្រី នៅក្នុងស្ថាប័នធ្វើសេចក្តីសម្រេចចិត្តដូចជា ក្រុមអ្នកប្រើប្រាស់ទឹក ចំនួនអាហារូបករណ៍សម្រាប់ក្មេងស្រី ការចូលរួមរបស់ស្ត្រីនៅក្នុងការប្រតិបត្តិការ និងការថែទាំ ការពិនិត្យតាមដាន និងការវាយតម្លៃ ។ល។ គួរត្រូវបានលើកឡើង និងរំលេច ឱ្យឃើញនៅទីនេះ។

១. ការអនុវត្ត ។ [...] ផ្នែកនេះគួររៀបរាប់អំពី [...] (ii) ការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល ដើម្បីសម្របសម្រួលការចូលរួមរបស់ស្ត្រី។ [...]

២. ការពិនិត្យតាមដាន និងវាយតម្លៃ [...] ខ ចែងទាំងឡាយដើម្បីជម្រុញឱ្យមានការចូលរួមរបស់ស្ត្រី នៅក្នុងការពិនិត្យតាមដាន និងវាយតម្លៃគម្រោង ក៏គួរលើកយកមកធ្វើការពិពណ៌នាផងដែរ។

### អភិបាលកិច្ច សៀវភៅណែនាំប្រតិបត្តិការផ្ទៃក C4/BP

១១. គោលការណ៍នៃការចូលរួមកើតចេញពីការទទួលស្គាល់ថាមនុស្ស គឺជាស្នូលនៃការអភិវឌ្ឍ។ ពួកគេគឺជាអ្នកទទួលផលចុងក្រោយ និងជាភ្នាក់ងារនៃការអភិវឌ្ឍដែលធ្វើការងារតាមរយៈក្រុម ឬសមាគម និងក្នុងនាមជាបុគ្គលម្នាក់ៗ។ ការចូលរួមមានន័យថា រចនាសម្ព័ន្ធរបស់រដ្ឋាភិបាលមានភាពបត់បែនគ្រប់គ្រាន់ ដើម្បីផ្តល់ឱកាសឱ្យអ្នកទទួលផល និងអ្នកដែលរងផលប៉ះពាល់ដទៃទៀតអាចធ្វើការកែលំអការរៀបចំ និងការអនុវត្តគោលនយោបាយសាធារណៈកម្មវិធី និងគម្រោងនានាបាន។

១២. ការចូលរួម នៅក្នុងជីវិតសេដ្ឋកិច្ច ដោយទីភ្នាក់ងារផ្សេងក្រៅពីរដ្ឋ រួមមាន តួនាទីរបស់វិស័យឯកជន ក្នុងការ បំពេញការងារជាមួយនឹងរដ្ឋាភិបាល និងសកម្មភាពរបស់សង្គមស៊ីវិល ដូចជាអង្គការក្រៅរដ្ឋាភិបាលជាដើម។ អង្គការ ក្រៅរដ្ឋាភិបាលផ្តល់នូវមធ្យោបាយបំពេញបន្ថែម សម្រាប់ទាញយកថាមពលពីប្រជាពលរដ្ឋ។ អង្គការក្រៅរដ្ឋាភិបាលអាចមានប្រយោជន៍ នៅក្នុងការកំណត់ពីប្រយោជន៍របស់ប្រជាពលរដ្ឋប្រមូលផ្តុំគំនិតរបស់សាធារណជនទូទៅ ដើម្បីគាំទ្រដល់ប្រយោជន៍ទាំងនេះ និងរៀបចំសកម្មភាព។ អង្គការទាំងនេះគឺជាសម្ព័ន្ធមិត្តដ៏មានប្រយោជន៍របស់រដ្ឋាភិបាល នៅក្នុងការលើកកម្ពស់ឱ្យមានការចូលរួមនៅកម្រិតសហគមន៍ និងជម្រុញឱ្យមានការប្រើប្រាស់គោលវិធីអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច "ពីក្រោមឡើងលើ"។

## អភិបាលកិច្ច សៀវភៅណែនាំប្រតិបត្តិការផ្នែក C4/OP

១៣. **ដំណើរការពិគ្រោះយោបល់**-គម្រោងអភិបាលកិច្ច និងទិដ្ឋភាពអភិបាលកិច្ចនៃគម្រោងតាមវិស័យ នឹងត្រូវបានកំណត់ តាមរយៈដំណើរការពិគ្រោះយោបល់ ដូចជាវេទិកា ដែលរៀបចំឡើង ដើម្បីប្រមូលគំនិត ឬដើម្បីពិភាក្សាពីលទ្ធផលរកឃើញនៃការវាយតម្លៃលើហានិភ័យអភិបាលកិច្ចពីអ្នកពាក់ព័ន្ធនានា ដូចជា រដ្ឋាភិបាល និងអង្គការ សង្គមស៊ីវិល ជាដើម ។

១៤. **ការចូលរួមរបស់សង្គមស៊ីវិល**- GACAP II គូសបញ្ជាក់ពីភាពចាំបាច់ ដើម្បីជម្រុញឱ្យមានការចូលរួមពី អង្គការសង្គមស៊ីវិលនៅក្នុងការត្រួតពិនិត្យ និងលើកកម្ពស់ទំនាក់ទំនងរវាងរដ្ឋាភិបាលរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក និងប្រជាពលរដ្ឋ។ ការធ្វើបែបនេះនឹងពង្រឹងការចូលរួម និងបង្កើនគណនេយ្យភាព។ សង្គមស៊ីវិលគួរត្រូវបាន គេពិគ្រោះយោបល់ជាមួយ នៅពេលរៀបចំធ្វើការវាយតម្លៃហានិភ័យ និងបង្កើតផែនការគ្រប់គ្រងហានិភ័យ ក្នុងកំឡុងពេលរៀបចំ CPS ។ នៅពេលដែលអាចធ្វើទៅបាន និងផ្អែកទៅតាមការវាយតម្លៃលើសមត្ថភាពរបស់សង្គមស៊ីវិល (ដែលត្រូវបានធ្វើឡើងរួមគ្នា ជាមួយនឹងរដ្ឋាភិបាលរបស់ប្រទេសកំពុងអភិវឌ្ឍ ជាសមាជិក) គួរមានការខិតខំប្រឹងប្រែង ផ្តល់លទ្ធភាពឱ្យអង្គការសង្គមស៊ីវិលនៅមូលដ្ឋាន ពិនិត្យតាមដានលទ្ធផលនៃគម្រោងអភិបាលកិច្ច ក្នុងកំឡុងពេល អនុវត្ត។

## ការដាក់បញ្ចូលទិដ្ឋភាពសង្គម នៅក្នុងប្រតិបត្តិការរបស់ ADB សៀវភៅណែនាំប្រតិបត្តិការផ្នែក C3/BP

១៥. គ្រប់ប្រតិបត្តិការទាំងអស់របស់ ADB សុទ្ធតែមានទិដ្ឋភាពសង្គម ដែលចាំបាច់ត្រូវយកមកធ្វើការពិចារណា ចាប់ពីដំណាក់កាលរៀបចំកម្មវិធីប្រចាំប្រទេស និងដំណាក់កាលដំណើរការគម្រោងតទៅ។ ទិដ្ឋភាពសង្គមសំខាន់ៗ ដែលគាំទ្រដោយគោលនយោបាយ ឬយុទ្ធសាស្ត្រជាក់លាក់របស់ ADB រួមមាន (i) ការចូលរួម (ii) យេនឌ័រ និងការអភិវឌ្ឍ (iii) ការការពារផលប៉ះពាល់សង្គម និងការគ្រប់គ្រងហានិភ័យសង្គម ជាពិសេស (iv) ក្នុងចំណោមក្រុមដែលងាយរង គ្រោះ។

១៦. ប្រតិបត្តិការរបស់ ADB មានដាក់បញ្ចូលទិដ្ឋភាពសង្គម ដើម្បីធានាយ៉ាងណាឱ្យមានការសម្រេចបាននូវ លទ្ធផលផ្នែកការអភិវឌ្ឍសង្គមខាងក្រោម ជាពិសេសសម្រាប់ប្រជាពលរដ្ឋក្រីក្រ អ្នកដែលងាយរងគ្រោះ និងអ្នកដែលត្រូវបានគេផាត់ចេញ ៖

i. គោលនយោបាយ និងស្ថាប័នដែលទទួលស្គាល់ និងលើកកម្ពស់ការចូលរួម និងសមធម៌ នៅក្នុងការទទួលបានសេវាធនធាន និងឱកាសនានា

ii. ការបង្កើនភាពអង់អាច ដើម្បីចូលរួមនៅក្នុងជីវភាពសង្គម សេដ្ឋកិច្ច និងនយោបាយ និង

iii. ការបង្កើនសន្តិសុខ និងលទ្ធភាពគ្រប់គ្រងហានិភ័យ

១៧. នៅក្នុងការសម្រេចនូវលទ្ធផលផ្នែកការអភិវឌ្ឍសង្គមទាំងនេះ ADB

i. លើកទឹកចិត្តឱ្យមានការពិគ្រោះយោបល់ និងការចូលរួមដោយអ្នកពាក់ព័ន្ធនានា (ដូចជា រដ្ឋាភិបាល ទីភ្នាក់ងារ ប្រតិបត្តិ និងទីភ្នាក់ងារអនុវត្ត អតិថិជន និង/ឬអ្នកទទួលផលអ្នកដែលរងផលប៉ះពាល់ដោយសារគម្រោងដែលគាំទ្រដោយADB) ផ្តល់ឱ្យពួកគេនូវឱកាសដើម្បីចូលរួមនៅក្នុងដំណាក់កាលសំខាន់ៗនៃការរៀបចំកម្មវិធីប្រចាំប្រទេស និងវដ្តគម្រោងនានា និងស្វែងរកការសហការពីអង្គការក្រៅរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិលដទៃទៀតនៅពេលដែលសមស្របនៅក្នុងការបង្កើតការរៀបចំ ការអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃគម្រោងនានា [...]

## ប្រព័ន្ធគ្រប់គ្រងលទ្ធផលការងាររបស់គម្រោង (PPMS), សៀវភៅណែនាំប្រតិបត្តិការផ្ទៃក J1/BP

១៨. PPMS របស់ ADB គឺជាគោលវិធីរៀបចំផែនការគម្រោងពិនិត្យតាមដានការអនុវត្តគម្រោង និងវាយតម្លៃលទ្ធផល ផ្អែកទៅតាមលទ្ធផលជាក់ស្តែង។ នៅក្នុងដំណាក់កាលរៀបចំ PPMS ផ្តោតសំខាន់លើការចូលរួមរបស់អ្នក ពាក់ព័ន្ធ [...]

## ប្រព័ន្ធគ្រប់គ្រងលទ្ធផលការងាររបស់គម្រោង (PPMS), សៀវភៅណែនាំប្រតិបត្តិការផ្ទៃក J1/OP

១៩. ក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដាន គឺជាឧបករណ៍ផ្អែកលើលទ្ធផលជាក់ស្តែង ដែលផ្តល់នូវវចនាសម្ព័ន្ធ សម្រាប់ដំណើរការរៀបចំផែនការគម្រោងដែលរួមចំណែកចំពោះការរៀបចំគម្រោង និងការជ្រើសរើសគម្រោងឱ្យបានល្អហើយក្នុងពេលជាមួយគ្នា បង្កើតនូវមូលដ្ឋានសម្រាប់ធ្វើការពិនិត្យតាមដាន និងវាយតម្លៃគម្រោង។ ដោយរៀបចំឡើង ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដាននេះជួយបង្កើនការយល់ដឹង និងភាពជា ម្ចាស់របស់អ្នកពាក់ព័ន្ធលើគម្រោង។

## ការប្រាស្រ័យទាក់ទងសាធារណៈ សៀវភៅណែនាំប្រតិបត្តិការផ្ទៃក L3/OP

២០. ដើម្បីសម្របសម្រួលការពិគ្រោះយោបល់ជាមួយនឹងអ្នកដែលរងផលប៉ះពាល់ និងជាមួយបុគ្គល និងអង្គការដទៃទៀត ព័ត៌មានអំពីគម្រោងវិស័យសាធារណៈ ឬវិស័យឯកជនដែលកំពុងរៀបចំ (រួមទាំងបញ្ហាសង្គម និងបរិស្ថានផង) ត្រូវតែផ្តល់ដល់អ្នកដែលផលប៉ះពាល់។ ADB ត្រូវធ្វើការងារឱ្យបានជិតស្និទជាមួយនឹងអ្នកខ្ចី ឬអ្នកគាំទ្រគម្រោង ដើម្បីធានាឱ្យមានការផ្តល់ព័ត៌មាន និងការស្វែងរកព័ត៌មានត្រឡប់អំពីការរៀបចំគម្រោងដែលបានស្នើឡើង ហើយត្រូវមានការតែងតាំងជនបង្គោលម្នាក់ ដើម្បីទំនាក់ទំនងជាប្រចាំជាមួយនឹងអ្នកដែលរងផលប៉ះពាល់។ ការធ្វើបែបនេះគួរ ចាប់ផ្តើមឱ្យបានឆាប់នៅក្នុងការរៀបចំគម្រោង ដើម្បីឱ្យទស្សនៈយល់ឃើញរបស់អ្នកដែលរងផលប៉ះពាល់ អាចត្រូវបានយកមកធ្វើការពិចារណាឱ្យបានគ្រប់គ្រាន់ នៅក្នុងការរៀបចំគម្រោង និងបន្តមាននៅតាមដំណាក់កាលនីមួយៗនៃការរៀបចំដំណើរការ និងការអនុវត្តគម្រោង។ ADB ត្រូវធានាយ៉ាងណាឱ្យការរៀបចំគម្រោងផ្តល់លទ្ធភាពឱ្យអ្នកពាក់ព័ន្ធអាចផ្តល់នូវព័ត៌មានត្រឡប់ ក្នុងកំឡុងពេលអនុវត្ត។ ADB ត្រូវធានាយ៉ាងណាឱ្យព័ត៌មានដែលពាក់ព័ន្ធអំពីការផ្លាស់ប្តូរសំខាន់ៗចំពោះវិសាលភាពរបស់គម្រោង ក៏ត្រូវបានចែករំលែកជាមួយនឹងអ្នកដែលរងផលប៉ះពាល់ផងដែរ។

២១. ដើម្បីគាំទ្រដល់លក្ខខណ្ឌតម្រូវនៅក្នុងកថាខណ្ឌទី ១៦ រដ្ឋាភិបាលរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក និង ADB អាចរួមគ្នារៀបចំផែនការប្រាស្រ័យទាក់ទងសម្រាប់គម្រោង និងកម្មវិធីមួយចំនួនជាពិសេសគម្រោង និងកម្មវិធី ដែលមានលទ្ធភាពទាក់ទាញចំណាប់អារម្មណ៍ខ្ពស់ពីសាធារណជនទូទៅ។ ឧទាហរណ៍ ផែនការទាំងនេះអាចលើកឡើងជា អនុសាសន៍អំពីរបៀបជម្រុញឱ្យមានការចូលរួមក្នុងការពិគ្រោះយោបល់ជាមួយនឹងអ្នកដែលរងផលប៉ះពាល់ ពង្រីកលទ្ធភាពរបស់សាធារណជនទូទៅក្នុងការទទួលបានព័ត៌មានអំពីកំណែទម្រង់សេដ្ឋកិច្ច និងច្បាប់ ជួយដល់រដ្ឋាភិបាល និងអ្នកឧបត្ថម្ភគម្រោង ក្នុងការជម្រុញឱ្យមានការចូលរួមពីអ្នកដែលរងផលប៉ះពាល់នៅក្នុងការរៀបចំ និងការអនុវត្តសកម្មភាព ដែលទទួលបានជំនួយពី ADB និងបង្កើនការចូលរួមពីប្រជាពលរដ្ឋនៅមូលដ្ឋាន និងអង្គការសង្គមស៊ីវិលនៅក្នុងដំណើរការនៃការអភិវឌ្ឍ។

## គោលនយោបាយស្ដីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាន សៀវភៅណែនាំប្រតិបត្តិការផ្នែក F1/OP

២២. ក្រុមការងារគម្រោងផ្ដល់ដំបូន្មានដល់អ្នកទទួល/អតិថិជនថាការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ជាមួយនឹងអ្នកដែលរងផលប៉ះពាល់ នឹងត្រូវបានធ្វើឡើង ហើយដំណើរការពិគ្រោះយោបល់ទាំងនេះ នឹងត្រូវចងក្រងទុកជាឯកសារយ៉ាងត្រឹមត្រូវនៅក្នុង EIA (ការប៉ាន់ប្រមាណពីហេតុប៉ះពាល់បរិស្ថាន), IEE (ការវាយតម្លៃបរិស្ថានជាបឋម) ផែនការតាំងទីលំនៅ និង/ឬ IPP (ផែនការស្ដីពីជនជាតិដើមភាគតិច)។ នាយកដ្ឋានប្រតិបត្តិការ តាមរយៈការពិនិត្យលើភាពត្រឹមត្រូវ និងការពិនិត្យឡើងវិញ ធ្វើការកំណត់ថាតើអ្នកទទួល/អតិថិជនបានបំពេញ ឬនឹងបំពេញទៅ តាមលក្ខខណ្ឌតម្រូវផ្នែកការពិគ្រោះយោបល់ និងការចូលរួម ដូចដែលបានដាក់ចេញនៅក្នុងលក្ខខណ្ឌស្ដីពីការការពារ ផលប៉ះពាល់សង្គម និងបរិស្ថាន ១–៤ ដែរឬទេ។ ក្រុមការងារគម្រោងផ្ដោតការយកចិត្តទុកដាក់ជាពិសេស ដើម្បីធានាយ៉ាងណាឱ្យក្រុមដែលងាយរងគ្រោះមានឱកាសគ្រប់គ្រាន់ដើម្បីចូលរួមនៅក្នុងការពិគ្រោះយោបល់នានា។ សម្រាប់ គម្រោង ដែលត្រូវបានបែងចែកថាជាគម្រោងប្រភេទ ក សម្រាប់បរិស្ថាន ការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត ឬជនជាតិដើមភាគតិចក្រុមគម្រោងចូលរួម នៅក្នុងការពិគ្រោះយោបល់ ដើម្បីស្វែងយល់ពីការព្រួយបារម្ភធំៗរបស់អ្នកដែល ទទួលរងផលប៉ះពាល់ដោយសារគម្រោង ដើម្បីឱ្យមានការឆ្លើយតបឱ្យបានគ្រប់គ្រាន់ទៅនឹងការព្រួយបារម្ភ និងអនុសាសន៍ទាំងនេះ នៅក្នុងការរៀបចំគម្រោង និងនៅក្នុងផែនការស្ដីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាន។

២៣. លក្ខខណ្ឌតម្រូវផ្នែកការការពារផលប៉ះពាល់សង្គម និងបរិស្ថានទី ៣ តម្រូវឱ្យអ្នកទទួលកម្ចី/អតិថិជន និង ADB ធ្វើការបញ្ជាក់ថាថាតើមានការគាំទ្រពីយ៉ាងទូលំទូលាយ ពីសហគមន៍ជនជាតិដើមភាគតិច ដែលទទួលរងផលប៉ះពាល់ ក្រោមកាលៈទេសៈចំនួន ៣ ដែរឬទេ។ នៅក្នុងករណីទាំងនេះ ADB តម្រូវឱ្យអ្នកទទួលកម្ចី/អតិថិជនចងក្រង ទុកជាឯកសារនូវដំណើរការ និងលទ្ធផលនានានៃការពិគ្រោះយោបល់ និងការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិច ដែលទទួលរងផលប៉ះពាល់។ ឯកសារទាំងនេះត្រូវបានផ្ញើទៅកាន់ ADB ដើម្បីធ្វើការពិនិត្យឡើងវិញ។ នាយកដ្ឋានប្រតិបត្តិការពិនិត្យឡើងវិញលើឯកសារស្ដីពីដំណើរការពិគ្រោះយោបល់ដែលត្រូវបានចងក្រងដោយអ្នកទទួលកម្ចី/ អតិថិជន និងធ្វើការផ្ទៀងផ្ទាត់ថាពិតជាមានការបង្ហាញពីការគាំទ្រទូលំទូលាយរបស់សហគមន៍ចំពោះសកម្មភាពគម្រោងដែរឬទេ តាមរយៈការធ្វើការស្រាវជ្រាវដោយខ្លួនឯង។ ADB មិនបន្តដំណើរការគម្រោងឡើយ ប្រសិនបើខ្លួនមិនអាចកំណត់ថាពិតជាមានការគាំទ្រយ៉ាងទូលំទូលាយបែបនេះពីសហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់នោះ។

## ៣ : សំណួរដែលគេតែងសួរញឹកញាប់

**សំណួរទី ១ :** *តើប្រយោជន៍ដែលទទួលបានពីការចូលរួមត្រូវបានវាស់វែងយ៉ាងដូចម្តេច?*

**ចម្លើយទី ១ :** ការសិក្សាជាច្រើនបានកំណត់ពីប្រយោជន៍ ដែលទទួលបានពីការចូលរួម។ ការសិក្សាអន្តរវិស័យមួយ ដែលធ្វើឡើងលើគម្រោងចំនួន ៦៨ របស់ធនាគារពិភពលោក បង្ហាញថាគម្រោងនានា ដែលឆ្លើយតបចំពោះលក្ខខណ្ឌសង្គម វប្បធម៌បានល្អមានប្រយោជន៍សេដ្ឋកិច្ចក្នុងកម្រិតមធ្យម ពីរដងច្រើនជាងគម្រោង ដែលមិនបានបំពេញទៅតាមលក្ខខណ្ឌសង្គម និងដែលមានការវិភាគមិនបានល្អ ឬគម្រោងដែលមានការចូលរួមក្នុងកម្រិតទាប។[៨៥] ការវិភាគស្ថិតិរបស់ទីភ្នាក់ងារជាច្រើន ដែលបានមកពីគម្រោងផ្គត់ផ្គង់ទឹកជនបទចំនួន ១២១ បានរកឃើញថា "ការចូលរួមរបស់អ្នកទទួលផល" គឺជាកត្តាដ៏សំខាន់ជាងគេបំផុតមួយ នៅក្នុងការកំណត់ពីគុណភាពជារួមរបស់ការអនុវត្ត។ ក្នុងចំណោម គម្រោងចំនួន ៤៩ ដែលមានការចូលរួមក្នុងកម្រិតទាបមានគម្រោងត្រឹមតែ ៨% ប៉ុណ្ណោះដែលទទួលបានជោគជ័យ ហើយក្នុងចំណោមគម្រោង ៤២ ដែលមានការចូលរួមក្នុងកម្រិតខ្ពស់ មានគម្រោងចំនួន ៦៤% ដែលទទួលបាន ជោគជ័យ។[៨៦]

**សំណួរទី ២ :** *តើការចូលរួមមានចំណាយអ្វីខ្លះ?*

**ចម្លើយទី ២ :** ការចំណាយលើពេលវេលា និងការវិនិយោគមានការប្រែប្រួល។ ការសិក្សាមួយរបស់ធនាគារពិភពលោក លើគម្រោងដែលមានការចូលរួមបានរកឃើញថា ការចំណាយមានការកើនឡើងពី ១០% ទៅ ១៥% សម្រាប់ថវិការៀបចំ និងការចុះអភិបាល ដែលភាគច្រើនត្រូវទូទាត់ដោយប្រើប្រាស់មូលនិធិត្រាស់ហ្វាន់។[៨៧] សៀវភៅធនធានស្តីពីការ ចូលរួមរបស់ធនាគារពិភពលោក បង្ហាញពីករណីសិក្សាជាច្រើន ថាការចំណាយបន្ថែមសម្រាប់ការចូលរួមគឺមានពី ១០០០០ ដុល្លារ ទៅ ៣០០០០ ដុល្លារ ដោយរដ្ឋាភិបាល និងធនាគារពិភពលោកជាអ្នកចែករំលែកការចំណាយនេះ។ ការសិក្សាផ្សេងទៀតរបស់ធនាគារពិភពលោកបង្ហាញថា បើទោះបីជាគេត្រូវការពេលវេលាយូរ ដើម្បីរៀបចំគម្រោងដែលមានការចូលរួមក៏ដោយ ពុំមានការចំណាយពេលបន្ថែម ដើម្បីធ្វើការបង្ហាញទៅកាន់ក្រុមប្រឹក្សាភិបាល ឬដើម្បីចូលជាធរមាននោះឡើយ។[៨៨] គម្រោងដែលមានផែនការចូលរួមក្នុងកម្រិតទាប ត្រូវការពេលវេលា ឬចំណាយបន្ថែមតិចតួចតែប៉ុណ្ណោះ។ គម្រោងដទៃទៀត ដូចជាគម្រោងសាងសង់ទំនប់ធំៗ ជាដើម អាចតម្រូវឱ្យមានការរៀបចំផែនការ ចូលរួមបន្ថែម ដែលមានលក្ខណៈស្មុគស្មាញ ដែលត្រូវការពេលវេលាជាង ១ ឆ្នាំ និងចំណាយលុយរាប់សែនដុល្លារ។ ការ ចូលរួមក៏មានចំណាយឱកាស សម្រាប់ក្រុមដែលចូលរួមផងដែរ។

បើទោះបីជាចំណាយ និងពេលវេលាបន្ថែមហាក់បីដូចជាច្រើនលើសលុបក៏ដោយមន្ត្រីគម្រោងគួរធ្វើការពិចារណាអំពីអ្វីដែលអាចខាតបង់ដោយសារការមិនដាក់បញ្ចូលការចូលរួម។ ការចំណាយលើការដោះស្រាយបញ្ហានៅពេលក្រោយ ដោយសារការមិនបានឱ្យគ្រប់អ្នកពាក់ព័ន្ធទាំងអស់ចូលរួមនឹងធ្វើឱ្យមានការវិនិយោគចុងក្រោយខ្ពស់ជាងកម្រិតវិនិយោគ ដែលគួរមានពីដំបូង។ នៅក្នុងករណីធ្ងន់ធ្ងរចំណាយទាំងនេះអាចរួមមានការផ្លាស់ប្តូរការរៀបចំគម្រោង។ ដូចគ្នានេះដែរ ពេលវេលា ដែលចំណាយសម្រាប់ការដោះស្រាយបញ្ហា ទំនងជាវែងជាងពេលវេលាដែលចាំបាច់សម្រាប់ការពិគ្រោះយោបល់ នៅដំណាក់កាលដំបូងៗរបស់គម្រោង។

**សំណួរទី ៣ :** *តើប្រភេទគម្រោងអ្វីខ្លះ ដែលសមស្របឱ្យមានការចូលរួម?*

**ចម្លើយទី ៣ :** វិធីសាស្ត្រដែលមានការចូលរួម អាចប្រើប្រាស់បាននៅក្នុងគម្រោងគ្រប់ប្រភេទទាំងអស់ ដូចជា សកម្មភាពផ្តល់កម្ចីផ្អែកតាមគោលនយោបាយ និងហេដ្ឋារចនាសម្ព័ន្ធធំៗ ជាដើមមិនត្រឹមតែគម្រោងកាត់បន្ថយភាពក្រីក្រ និងគម្រោងសង្គមនោះទេ។ លក្ខខណ្ឌតម្រូវអប្បបរមា គឺថា ADB រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធសំខាន់ៗយល់ព្រម អនុវត្តដំណើរការដែលមានការចូលរួម។ មគ្គុទេសក៏នេះផ្តល់ការណែនាំអំពីការចូលរួមក្នុងវដ្តគម្រោង (សូមមើលផ្នែកទី ៣ ទំព័រទី ១៥) និងផ្តល់នូវការណែនាំតាមវិស័យ/ប្រធានបទមួយចំនួនទៀត (សូមមើលផ្នែកទី៤ ទំព័រទី៦១)។

**សំណួរទី ៤ :** *តើមានកន្លែងណា ដែលការចូលរួមអាចមានដំណើរការទៅបានល្អជាពិសេសដែរឬទេ?*

**ចម្លើយទី ៤ :** មាន-នៅកន្លែងដែលអ្នកពាក់ព័ន្ធមានបំណងចូលរួម និងនៅកន្លែងដែលបង្ហាញពីអត្ថប្រយោជន៍ច្បាស់លាស់ ពុំមានភាពប្រទាំងប្រទើសផ្អែកគោលបំណងជាមូលដ្ឋាន និងធ្លាប់មានបទពិសោធន៍ល្អពីមុនមកជាមួយនឹងការចូលរួម។ នៅក្នុងមគ្គុទេសក៏ទាំងមូល មានឧទាហរណ៍អំពីការអនុវត្តល្អ ដែលអាចយកទៅអនុវត្តកន្លែងផ្សេងទៀត នៅក្នុងគម្រោងដែលគាំទ្រដោយ ADB ។

**សំណួរទី ៥ :** *តើមានស្ថានភាពណា ដែលការចូលរួមមិនមានលក្ខណៈសមស្រប ដែរឬទេ?*

**ចម្លើយទី ៥ :** មានតិចតួចបំផុត-អាចមានការចូលរួមតិចតួច នៅដំណាក់កាលដំបូងបំផុតនៃការឆ្លើយតបចំពោះ ស្ថានភាពអាសន្ន នៅក្នុងស្ថានភាពក្រោយពេលមានវិវាទកើតមានឡើង និងនៅកន្លែងដែលរដ្ឋាភិបាលជំទាស់យ៉ាងខ្លាំងក្លាចំពោះការចូលរួម។ គន្លឹះសំខាន់ គឺត្រូវរៀបចំគោលវិធីចូលរួម ឱ្យសមស្របតាមឱកាស និងឧបសគ្គសម្រាប់ស្ថានភាពជាក់លាក់។

**សំណួរទី ៦ :** *តើការចូលរួមប៉ុណ្ណាទើបគ្រប់គ្រាន់?*

**ចម្លើយទី ៦ :** ការបង្កើតនូវផែនការស្តីពីការចូលរួមមួយដែលមានភាពរឹងមាំ (បំពេញទៅតាមលក្ខណៈវិនិច្ឆ័យ នៃបញ្ជីត្រួតពិនិត្យសម្រាប់ឧបករណ៍ទី ៤) វាយតម្លៃលើភាពគ្រប់គ្រាន់។ នៅកម្រិតអប្បបរមា ប្រសិនបើគោលនយោបាយ ឬគម្រោងមួយ នឹងមានផលប៉ះពាល់មកលើជីវិតរបស់មនុស្ស ឬរបស់សមាជិករបស់ក្រុមណាមួយ អ្នកទាំងនោះត្រូវមានសិទ្ធិចែករំលែកនូវទស្សនៈយល់ឃើញរបស់ខ្លួនចំពោះគោលនយោបាយ ឬគម្រោងនេះ។ ភាពគ្រប់គ្រាន់នៃការចូលរួមមិនមែនកើតឡើងដោយឯកឯងនោះទេ។ វាអាស្រ័យលើវិសាលភាព និងគោលដៅរបស់សកម្មភាព ភាពស្មុគស្មាញនៃប្រយោជន៍របស់អ្នកពាក់ព័ន្ធ និងកត្តាសង្គម និងនយោបាយដទៃទៀតនៅក្នុងបរិបទនេះ។ សកម្មភាពដែលពាក់ព័ន្ធនឹងហានិភ័យសង្គមសេដ្ឋកិច្ច ឬបរិស្ថានក្នុងកម្រិតមួយខ្ពស់ ឬគោលដៅចម្បងដែលលើកកម្ពស់ដល់ការចូលរួម និងការផ្តល់ភាពអង់អាចត្រូវការការចូលរួមបន្ថែម និងកាន់តែស៊ីជម្រៅ នៅក្នុងវដ្តគម្រោងទាំងមូល។ គម្រោងដែលមិនសូវមាន ប្រយោជន៍ខ្វែងគ្នាត្រូវការការចូលរួមតិចតួច។ ការចូលរួមនៅក្នុងបរិយាកាសដែលមានអរិភាពផ្នែកនយោបាយអាចជាការលំបាក ប៉ុន្តែមិនមែនថាមិនអាចធ្វើបាននោះទេ។ នៅក្នុងស្ថានភាពបែបនេះមួយចំនួន ADB អាចសម្រេចចិត្តវិនិយោគធនធានជាច្រើនលើការចូលរួម ដើម្បីលើកទឹកចិត្តឱ្យមានកំណែទម្រង់ និងកសាងសមត្ថភាពនៅមូលដ្ឋាន។

**សំណួរទី ៧ :** *ប្រសិនបើមនុស្សមួយក្រុមបដិសេធមិនចូលរួម តើយើងកំពុងស្ថិតនៅក្នុងភាពទ័លច្រកឬ?*

**ចម្លើយទី ៧ :** ទីមួយ ការប្រើប្រាស់ការចរចា និងការបញ្ចុះបញ្ចូលប្រកបដោយសន្តិវិធី អាចលើកទឹកចិត្តក្រុមឱ្យត្រឡប់ មករកតុចរចាវិញ។ អន្តរការីដែលជាភាគីទី ៣ អាចជាដៃគូដ៏មានប្រយោជន៍មួយ ដើម្បីលើកទឹកចិត្តឱ្យមានការយោគ យល់ពីភាគីទាំងសងខាង។ ចុងក្រោយប្រសិនបើក្រុមនេះមានសារៈសំខាន់ចំពោះគម្រោង ហើយបដិសេធមិនព្រមសហការ សូម្បីតែមានការព្យាយាមច្រើនលើកច្រើនសារនៅក្នុងការពិភាក្សា នោះចាំបាច់ត្រូវមានការពិចារណាប្រើ ប្រាស់ការសម្រុះសម្រួលជាផ្លូវការបន្ថែមទៀត ត្រូវមានការផ្លាស់ប្តូរដ៏ធំមួយចំពោះការរៀបចំគម្រោង ឬជម្រើសចុងក្រោយត្រូវបោះបង់គម្រោងចោលតែម្តង។

**សំណួរទី ៨ :** *តើអ្នកដែលជាអ្នកទទួលខុសត្រូវលើការចូលរួម នៅក្នុងគម្រោងរដ្ឋ ដែលទទួលបានមូលនិធិពី ADB?*

**ចម្លើយទី ៨ :** ADB និងប្រទេសកំពុងអភិវឌ្ឍជាសមាជិក ចែករំលែកការទទួលខុសត្រូវជាមួយគ្នា ដើម្បីធានាឱ្យមានការចូលរួម នៅក្នុងគម្រោងដែលទទួលបានមូលនិធិពី ADB។ នៅក្នុងការរៀបចំគម្រោង ADB សហការជាមួយនឹង មន្ត្រីរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ដើម្បីធ្វើការពិគ្រោះយោបល់ នៅក្នុងការរៀបចំ និងបង្កើតផែនការស្តីពីការ ចូលរួម នៅក្នុងការអនុវត្ត។ ជាធម្មតាតែងមានការជួលទីប្រឹក្សាដើម្បីគាំទ្រដល់ដំណើរការនេះ។ បន្ទាប់មកទីភ្នាក់ងារ ប្រតិបត្តិរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ត្រូវទទួលខុសត្រូវអនុវត្តផែនការ និងផ្ញើរបាយការណ៍វឌ្ឍនភាពទៅ ADB ហើយក្នុងពេលជាមួយគ្នា ADB ត្រូវធ្វើការពិនិត្យឡើងវិញ និងវាយតម្លៃលើវឌ្ឍនភាព ដើម្បីធានាឱ្យមានការសម្រេចគោលដៅរបស់គម្រោង។

**សំណួរទី ៩ :** *ចុះការចូលរួមសម្រាប់គម្រោងវិស័យឯកជន ដែលអតិថិជនវិស័យឯកជនបានបញ្ចប់ការសិក្សាអំពីលទ្ធភាពអនុវត្ត និងការវាយតម្លៃលើបរិស្ថាន និងសង្គមដែលពាក់ព័ន្ធហើយ មុនពេលមានការចូលរួមពី ADB វិញ?*

**ចម្លើយទី ៩ :** សម្រាប់ការចូលរួម ដែលពាក់ព័ន្ធជាមួយនឹងបញ្ហាការពារផលប៉ះពាល់បរិស្ថាន និងសង្គមអ្នកទទួលកម្ចី និង/ឬអតិថិជនទទួលខុសត្រូវក្នុងការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយនឹងអ្នកដែលរងផលប៉ះពាល់។ ADB ពិនិត្យលើភាពត្រឹមត្រូវនៅពេលពិនិត្យឡើងវិញលើប្រតិបត្តិការ ដើម្បីកំណត់ពីភាពគ្រប់គ្រាន់នៃសកម្មភាព ពិគ្រោះយោបល់ដែលអតិថិជនបានធ្វើ មុនពេលមានការចូលរួមពី ADB។ ប្រសិនបើការពិនិត្យលើភាពត្រឹមត្រូវរកឃើញនូវគម្លាតមួយចំនួន ទៅតាមអ្វីដែលតម្រូវដោយគោលនយោបាយរបស់ ADB ត្រូវកំណត់ពីវិធានការកែតម្រូវ និងដាក់បញ្ចូលវិធានការទាំងនេះ ទៅក្នុងផ្នែកស្តីពីការចូលរួម នៅក្នុងផែនការស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាន និងផែនការស្តីពីសកម្មភាពកែតម្រូវ។

ឥឡូវនេះក្រុមហ៊ុនបើកចំហជាងមុនច្រើនអំពីការអនុវត្តរបស់ពួកគេ ពាក់ព័ន្ធជាមួយនឹងបញ្ហាសង្គម និងបរិស្ថាន។ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានបោះពុម្ពផ្សាយនូវសៀវភៅណែនាំមួយសម្រាប់អតិថិជនរបស់ IFC ដែលមានឈ្មោះថា *បំពេញធុរកិច្ចប្រសើរជាងមុនតាមរយៈការពិគ្រោះយោបល់ជាសាធារណៈប្រកបដោយប្រសិទ្ធភាព* ស្តីពីការគ្រប់គ្រងការរំពឹងទុករបស់សហគមន៍ ការរៀបចំការពិគ្រោះយោបល់ឱ្យស្របទៅតាមបរិបទរបស់វិស័យឯកជន និងការលើកទឹកចិត្តឱ្យមានការពិគ្រោះយោបល់រវាងក្រុមហ៊ុន និងអ្នកពាក់ព័ន្ធនៅមូលដ្ឋានរបស់ក្រុមហ៊ុនទាំង

នេះនៅក្នុងពេញមួយវដ្តរបស់គម្រោង។[៨៩] ផ្នែកទី ៣ : ការចូលរួមនៅក្នុងវដ្តគម្រោងរបស់ ADB មានដាក់បញ្ចូលនូវផ្នែក ដោយឡែកមួយស្តីពីការចូលរួម នៅក្នុងប្រតិបត្តិការរបស់វិស័យឯកជន។

**សំណួរទី ១០ :** *តើមានកាលៈទេសៈណា ដែលមិនគួរបន្តអនុវត្តគម្រោង ប្រសិនបើមិនមានការចូលរួមឱ្យបានគ្រប់គ្រាន់ដែរឬទេ?*

**ចម្លើយទី ១០ :** ប្រសិនបើការចូលរួមមានសារៈសំខាន់ ដើម្បីធានាឱ្យមានការរៀបចំគម្រោង និងការអនុវត្តគម្រោងឱ្យបានសមស្របហើយមានការបញ្ជាក់ថាការចូលរួមមិនអាចធ្វើទៅបាននោះប្រហែលជាចាំបាច់ត្រូវពន្យារពេល ដំណើរការគម្រោង ឬលុបចោលគម្រោង។ បរិយាកាសដែលមិនមានភាពអំណោយផលចំពោះគោលវិធីដែលមានការចូលរួម អាចកាត់បន្ថយឱកាសអនុវត្តគម្រោង ដែលស្ថិតក្នុងប្រភេទមួយចំនួន។ តែទោះជាយ៉ាងណាក៏ដោយ ADB មានតួនាទីលើកទឹកចិត្តឱ្យប្រទេសកំពុងអភិវឌ្ឍជាសមាជិក បង្កើនការចូលរួមរបស់សង្គមស៊ីវិល និងផ្តល់ការគាំទ្រដល់អង្គការទាំងនេះ ជាជាងគ្រាន់តែបញ្ចៀសមិនឱ្យមានការប្រឈមមុខគ្នា។

**សំណួរទី ១១ :** *តើខ្ញុំអាចទទួលបានការបណ្តុះបណ្តាលនៅកន្លែងណា?*

**ចម្លើយទី ១១ :** ADB រៀបចំសិក្ខាសាលាសម្រាប់បុគ្គលិកស្តីពីការចូលរួម ដែលពាក់ព័ន្ធជាមួយនឹងអង្គការសង្គមស៊ីវិល ការបង្កើតក្របខ័ណ្ឌរៀបចំ និងពិនិត្យតាមដាន និងគោលនយោបាយស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាន។ លើសពីនេះក៏មានកម្មវិធីបណ្តុះបណ្តាលថ្នាក់តំបន់ជាច្រើន និងមានវិទ្យាស្ថានជាច្រើន ដែលមានឯកទេសផ្នែកវិធីសាស្ត្រ ដែលមានការចូលរួមដូចជា វិទ្យាស្ថានអន្តរជាតិផ្នែកស្តារតំបន់ជនបទឡើងវិញនៅក្នុងប្រទេសហ្វីលីពីន និងវិទ្យាស្ថាន ផ្នែកការអនុវត្តដែលមានការចូលរួម (PRAXIS) នៅក្នុងប្រទេសឥណ្ឌាជាដើម។

| ការវិភាគអ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ (ឧបករណ៍ទី១) | | |
|---|---|---|
| **ការវិភាគអ្នកពាក់ព័ន្ធ** | ជាការណែនាំអំពីការវិភាគអ្នកពាក់ព័ន្ធធនធាននេះរៀបរាប់ពីដំណើរការដែលមាន៤ ដំណាក់កាល : កំណត់អ្នកពាក់ព័ន្ធសំខាន់ៗ កំណត់ពីប្រយោជន៍របស់អ្នកពាក់ព័ន្ធ កំណត់ពីអំណាច និងឥទ្ធិពលរបស់អ្នកពាក់ព័ន្ធ និងបង្កើតយុទ្ធសាស្ត្រស្តីពីការចូលរួមរបស់អ្នកពាក់ព័ន្ធ ។ | World Bank. Website content: Social Analysis-Tools and Methods Stakeholder Analysis. Washington, DC. http://go.worldbank.org/ZVIkD48760 |
| ការពិគ្រោះយោបល់ជាមួយនឹងអង្គការសង្គមស៊ីវិល : គោលការណ៍ណែនាំទូទៅអំពីបុគ្គលិករបស់ធនាគារពិភពលោក | គោលការណ៍ណែនាំនេះបង្ហាញពីសង្គមស៊ីវិល (មុខងារ និងប្រភេទ) ការពិគ្រោះយោបល់ និង គោលដៅនៃការពិគ្រោះយោបល់ ។ គោលការណ៍ ណែនាំនេះផ្តល់ដំបូន្មានអំពីការរៀបចំផែនការ និង ការរៀបចំការពិគ្រោះយោបល់ ការដោះស្រាយបញ្ហាដែលអាចកើតមានឡើង ការផ្តល់ព័ត៌មានត្រឡប់ និងការតាមដានបន្ត និងផ្តល់នូវគន្លឹះអំពី ការពិគ្រោះយោបល់ដែលមានប្រសិទ្ធភាព ។ | World Bank. 2000. Consultations with Civil Society Organizations. General Guidelines for World Bank Staff. Washington, DC. http://siteresources.worldbank.org/INTRANET SOCIALDEVELOPMENT/873204-1111663470099/ 20489515/ConsultationsWithCSOsGuidelines.pdf |
| **ការពិគ្រោះយោបល់ជាមួយនឹង សង្គមស៊ីវិល : សៀវភៅធនធាន** | សៀវភៅធនធាននេះបំពេញបន្ថែម ឱ្យគោលការណ៍ណែនាំខាងលើដោយផ្តល់នូវ ព័ត៌មានអំពីមូលហេតុដែលត្រូវធ្វើការពិគ្រោះយោបល់ (និយមន័យអង្គការសង្គមស៊ីវិល [CSOs] ប្រភេទនៃការពិគ្រោះយោបល់ និងអ្នក ពាក់ព័ន្ធ) និងរបៀបធ្វើការពិគ្រោះយោបល់ ។ នេះរួមមានការរៀបចំការពិគ្រោះយោបល់ ការបង្កើតនូវព័ត៌មានសង្ខេប/ការជ្រើសរើសអ្នកចូលរួមការជួយដល់អ្នកជំនាញការផ្តល់ការបណ្តុះបណ្តាល/ការស្នើសុំព័ត៌មានត្រឡប់ការផ្តល់ ព័ត៌មានជាសាធារណៈ ការសម្ភាសក្រុមគោលដៅការរៀបចំសិក្ខាសាលា/ការពិភាក្សាតុមូល/ការ ផ្តល់ព័ត៌មានត្រឡប់ជាសាធារណៈ ការពិភាក្សា តាមប្រព័ន្ធអេឡិចត្រូនិចការជួបជុំ/សវនាការជាសាធារណៈ ការកត់ត្រាការផ្តល់ព័ត៌មានត្រឡប់ និងការវាយតម្លៃដំណើរការ ។ ឧបសម្ព័ន្ធមានបង្ហាញពីករណីសិក្សាផ្សេងៗ ។ | World Bank. 2007. Consultations with Civil Society. A Sourcebook. Washington, DC. http://siteresources.worldbank.org/ INTRANETSOCIALDEVELOPMENT/ 873204-1111663470099/20489462/ ConsultationsSourcebook.pdf |
| ប្រជាពលរដ្ឋ គឺជាដៃគូ : សៀវភៅ ណែនាំរបស់ OECD អំពីព័ត៌មានការពិគ្រោះយោបល់ និងការចូលរួមរបស់សាធារណជននៅក្នុងការតាក់តែងគោលនយោបាយ | សៀវភៅណែនាំនេះជួយដល់មន្ត្រីរដ្ឋាភិបាលនៅក្នុងការពង្រឹងទំនាក់ទំនងរវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ ។ សៀវភៅណែនាំនេះពិនិត្យលើការបង្កើតក្របខ័ណ្ឌមួយសម្រាប់ពង្រឹងទំនាក់ទំនងនេះ និងសមាសភាគសំខាន់ៗនានា ដូចជាការពិគ្រោះយោបល់ការចូលរួមយ៉ាងសកម្មការវាយតម្លៃការជ្រើសរើសឧបករណ៍ និងសកម្មភាព និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ។ សៀវភៅណែនាំនេះបញ្ចប់ដោយផ្តល់នូវដំបូន្មានចំនួន ១០ ស្តីពីសកម្មភាព (ធ្វើការពិចារណាឱ្យបានល្អិតល្អន់ ចាប់ផ្តើមចេញ ពីទស្សនវិស័យរបស់ប្រជាពលរដ្ឋផ្តល់នូវអ្វីដែល អ្នកបានសន្យាពិនិត្យមើលពេលវេលាត្រូវមានភាពច្នៃប្រឌិតធ្វើឱ្យមានតុល្យភាពរវាង ប្រយោជន៍នានា ត្រៀមទទួលការរិះគន់ជម្រុញឱ្យមានការចូលរួមពីបុគ្គលិករបស់អ្នកបង្កើតនូវយុទ្ធសាស្ត្រដែលមានលក្ខណៈត្រង់ត្រសងគ្នា និងធ្វើសកម្មភាពឥឡូវនេះ) ។ | OECD. 2001. Citizens as Partners. OECD Handbook on Information, Consultation and Public Participation in Policy-Making. Paris. www.oecdbookshop.org/oecd/display.asp?lang= EN&sf1=identifiers&st1=422001141p1 |

តទៅទំព័របន្ទាប់

| | | |
|---|---|---|
| ឆ្ពោះទៅបង្កើតវប្បធម៌ពិគ្រោះយោបល់ និងសន្ទនា-គោលការណ៍ទូទៅ និងស្តង់ដារអប្បបរមាសម្រាប់ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដែលកំណត់ដោយគណៈកម្មការ | កិច្ចព្រមព្រៀងនេះមានដាក់បញ្ចូលនូវគោលការណ៍ទូទៅ (ការចូលរួម ការបើកចំហ និងគណនេយ្យភាពប្រសិទ្ធភាព និងភាពស៊ីសង្វាក់គ្នា) និងស្តង់ដារអប្បបរមាសម្រាប់ការពិគ្រោះ យោបល់របស់គណៈកម្មការ ។ ទាំងនេះត្រូវអនុវត្ត នៅដំណាក់កាលរៀបចំគោលនយោបាយមុនពេលធ្វើសេចក្តីសម្រេចចិត្ត : (១)ខ្លឹមសាររបស់ការពិគ្រោះយោបល់មានភាពច្បាស់លាស់, (២) ភាគីពាក់ព័ន្ធអាចបញ្ចេញគំនិតយោបល់របស់ពួកគេ, (៣) គណៈកម្មការផ្សព្វផ្សាយការពិគ្រោះយោបល់នានាយ៉ាងទូលំទូលាយ ដើម្បីឱ្យបាន ជ្រួតជ្រាបដល់គ្រប់ក្រុមគោលដៅទាំងអស់, (៤) អ្នកចូលរួមមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការឆ្លើយតប និង (៥) មានការផ្តល់នូវការទទួលស្គាល់ និងព័ត៌មានត្រឡប់គ្រប់គ្រាន់ ។ | Commission of the European Communities. 2002. Towards a reinforced culture of consultation and dialogue – General principles and minimum standards for consultation of interested parties by the Commission. Brussels. http://ec.europa.eu/civil_society/consultation _standards/index_en.htm |
| សមាគមអន្តរជាតិផ្នែកប្រអប់ឧបករណ៍ស្តីពីការចូលរួម ជាសាធារណៈ (IAP2) | ប្រអប់ឧបករណ៍នេះ គឺជាបញ្ជីបច្ចេកទេសសម្រាប់ចែករំលែកព័ត៌មាន (ឧ. ការផ្តល់ព័ត៌មានដោយសង្ខេបគណៈកម្មាធិការជំនាញ មណ្ឌលព័ត៌មាន) បច្ចេកទេសសម្រាប់ចងក្រង និងផ្តល់ព័ត៌មានត្រឡប់ (ឧ. អ្នកសម្របសម្រួល សហគមន៍ ការអង្កេតតាមអ៊ីនធឺណិត និងការអង្កេតដោយផ្ទាល់) និងបច្ចេកទេសដើម្បីនាំមនុស្សឱ្យមកជួបជុំគ្នា (ឧ. គណៈវិនិច្ឆ័យរបស់ប្រជាពលរដ្ឋពិពណ៌ និងព្រឹត្តិការណ៍នានា ក្រុមផ្តល់ប្រឹក្សា) ។ | International Association for Public Participation. (IAP2). IAP2's Toolbox. http://iap2.affiniscape.com/associations/4748/files/06Dec_Toolbox.pdf |
| មគ្គុទេសក៍ស្តីពីការចូលរួមតាមអនឡាញ | មគ្គុទេសក៍នេះផ្តល់ការគាំទ្រដល់ការចូលរួមរបស់ ប្រជាពលរដ្ឋតាមរយៈមធ្យោបាយកុំព្យូទ័រ និង អ៊ីនធឺណិត ។ មគ្គុទេសក៍នេះមានដាក់បញ្ចូលនូវសមត្ថភាពអ្នកសម្របសម្រួលរបស់សមាគមអ្នក សម្របសម្រួលអន្តរជាតិ (IAF) និងក្រមសីលធម៌សម្រាប់ការសម្របសម្រួលក្រុមរបស់ **IAF** ។ | New Zealand Government. 2007. Guide to Online Participation. Auckland. www.e.govt.nz/library/guide-to-online-participation-2007.pdf?bcsi_scan_7823DFCE46415F3E=0&bcsi _scan_filename=guide-to-online-participation-2007.pdf |
| **ការរៀបចំគម្រោង និងការបង្កើត DMF (ឧបករណ៍ទី ២)** | | |
| ឧបករណ៍ សម្រាប់សម្រេចនូវផលរយៈពេលវែងរបស់គោលនយោបាយ : សៀវភៅណែនាំសម្រាប់អ្នកស្រាវជ្រាវ | សៀវភៅណែនាំនេះផ្តល់នូវឧបករណ៍ ដើម្បីភ្ជាប់ ទំនាក់ទំនងរវាងការស្រាវជ្រាវ និងគោលនយោបាយ ។ ឧបករណ៍វាយតម្លៃបរិបទក៏អាច យកមកអនុវត្ត នៅក្នុងការរៀបចំគម្រោងផងដែរ ហើយមានដាក់បញ្ចូលនូវវិធីសម្រាប់ការរៀបចំ ផែនការការវិភាគមូលដ្ឋាន ការវិភាគដើមឈើ បញ្ហា ការវិភាគអ្នកពាក់ព័ន្ធការវិភាគឥទ្ធិពល ការបង្កើតផែនទីបង្ហាញពីឥទ្ធិពលការវិភាគ **SWOT** (ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង) និងការវិភាគត្រីកោណ ។ | Overseas Development Institute. 2004. Tools for Policy Impact. A Handbook for Researchers. London. www.odi.org.uk/Rapid/Tools/Toolkits/Policy_Impact/ |
| សៀវភៅណែនាំស្តីពីការពិគ្រោះយោបល់ និងការចូលរួមនៅក្នុង ប្រតិបត្តិការនានារបស់ធនាគារអភិវឌ្ឍន៍អាហ្វ្រិច | សៀវភៅណែនាំនេះពិនិត្យលើគោលការណ៍ស្តីពី ការចូលរួមសំខាន់ៗ និងចំណុចផ្តើមសំខាន់ៗ ស្តីពី ការចូលរួមនៅក្នុងវដ្តគម្រោង ។ សៀវភៅណែនាំ នេះក៏ផ្តល់នូវការណែនាំផងដែរអំពីវិធីសាស្ត្រ និង ឧបករណ៍នានា ដូចជា ការវិភាគអ្នកពាក់ព័ន្ធដោយមានការចូលរួម កិច្ចប្រជុំ សិក្ខាសាលា ដែលមានការចូលរួមការស្រាវជ្រាវ និងការប្រមូល ទិន្នន័យដោយមានការចូលរួម និងការរៀបចំ ផែនការដោយមានការចូលរួម ។ | African Development Bank (AfDB). 2001. Handbook on stakeholder consultation and participation in AfDB operations. www.afdb.org/fileadmin/uploads/afdb/Documents/Policy-Documents/Handbook%20on %20Stakeholder%20Consultaion.pdf |

| | | |
|---|---|---|
| **បង្កើនការចូលរួមរបស់អ្នកពាក់ព័ន្ធនៅក្នុងកម្មវិធីព្រៃឈើជាតិ : ឧបករណ៍សម្រាប់អ្នកអនុវត្ត ការងារ** | ធនធាននេះពិនិត្យលើការចូលរួមរបស់អ្នកពាក់ព័ន្ធ នៅក្នុងកម្មវិធីព្រៃឈើ ប៉ុន្តែឧបករណ៍ទាំងនេះ អាចយកទៅអនុវត្ត នៅក្នុងវិស័យដទៃទៀត ហើយមានភាពពាក់ព័ន្ធជាពិសេសចំពោះការរៀបចំគម្រោង ។ ឧបករណ៍នានា រួមមានការវិភាគអ្នកពាក់ព័ន្ធការបង្កើតចក្ខុវិស័យ ការបង្កើតផែនទីដោយមានការចូលរួម ការបង្កើតផែនទីបង្ហាញពីទំនាក់ទំនង ការវិភាគបញ្ហា ការវិភាគដំណោះស្រាយការវិភាគ SWOT ឧបករណ៍កូនកាត់ (ឧបករណ៍កូនកាត់នេះដាក់បញ្ចូលកត្តានានានៃការវិភាគ SWOT រួមជាមួយនឹងកត្តានានានៃលំហាត់ដាក់ពិន្ទុ ដើម្បីគ្របដណ្តប់លើការវាយតម្លៃបែបគុណវិស័យផង និងបរិមាណវិស័យផង) និងការបង្កើតនូវប្រអប់ឧបករណ៍ និងផែនការសកម្មភាព ។ | FAO. 2009. Enhancing stakeholder participation in national forest programmes. Tools for practitioners. Rome. ftp://ftp.fao.org/docrep/fao/012/i1037e/i1037e00.pdf |
| **ឧបករណ៍រៀបចំផែនការអភិវឌ្ឍន៍ ដែលមានការចូលរួម** | ធនធាននេះបង្ហាញពីឧបករណ៍ជាច្រើន សម្រាប់រៀបចំផែនការអភិវឌ្ឍន៍ ដោយមានការចូលរួម ។ ឧបករណ៍មួយចំនួន ដែលគេនិយមប្រើប្រាស់រួមមាន : ឧបករណ៍ចែករំលែកព័ត៌មាន(ឧ. កាសែត កិច្ចប្រជុំគេហទំព័រ) ឧបករណ៍ពិគ្រោះយោបល់ (ឧ. ការជជែកវែកញែកក្នុងសហគមន៍ ការពិភាក្សាក្រុមគោលដៅ ការអង្កេតគំនិតយោបល់) និងឧបករណ៍រៀបចំផែនការដោយ មានការសហការ (ឧ. ការស្រាវជ្រាវ និងការរៀបចំផែនការដោយមានការចូលរួម) ។ | CIVICUS & PG Exchange. Participatory Development Planning Tools. www.pgexchange.org/images/toolkits/PGX_F_Participatory%20Development%20Planning.pdf |
| **ការវាយតម្លៃដោយមានការចូលរួម** (ឧបករណ៍ទី ៣) | | |
| **ការវាយតម្លៃអ្នកទទួលផល** | ធនធាននេះបង្ហាញពីរបៀបធ្វើការវាយតម្លៃអ្នកទទួលផល **(BA)** ។ **BA** គឺជាឧបករណ៍ស្រាវជ្រាវគុណវិស័យ ដែលត្រូវបានប្រើប្រាស់ដើម្បីបង្កើនផលរយៈពេលវែងនៃប្រតិបត្តិការអភិវឌ្ឍន៍ តាមរយៈការស្នើសុំទស្សនៈយល់ឃើញរបស់អ្នក ទទួលផលអំពីកំណែទម្រង់ដែលកំពុងមានក្នុងផែនការ ឬកំណែទម្រង់ដែលកំពុងបន្តអនុវត្ត ។ ធនធាននេះខិតខំផ្តល់នូវព័ត៌មានស៊ីជម្រៅបែប គុណវិស័យដែលអាចជឿទុកចិត្តស្តីពីលក្ខខណ្ឌសង្គមវប្បធម៌ និងការយល់ឃើញរបស់ក្រុមគោលដៅ ។ គោលវិធីនេះពឹងផ្អែកសំខាន់លើការសម្ភាសការពិភាក្សាក្រុមគោលដៅ និងការសង្កេតមើលអ្នកចូលរួមដោយផ្ទាល់ ។ | World Bank. 2002. Beneficiary Assessment. Washington, DC. http://siteresources.worldbank.org/INTPSIA/Resources/490023-1121114603600/beneficiary_assessment.pdf |
| **ការចូលរួម និងការវាយតម្លៃសង្គម : ឧបករណ៍ និងបច្ចេកទេស** | ម៉ូឌុលទី ១ របស់មគ្គុទេសក៍នេះ ផ្តល់ព័ត៌មានអំពីការវាយតម្លៃសង្គម ដែលជាដំណើរការមួយ ដើម្បីធានាយ៉ាងណាឱ្យប្រតិបត្តិការអភិវឌ្ឍន៍នានាទទួល បានព័ត៌មានអំពីបញ្ហាសង្គមសំខាន់ៗ និងធ្វើការ ពិចារណាលើបញ្ហាទាំងនោះ និងដាក់បញ្ចូល យុទ្ធសាស្ត្រស្តីពីការចូលរួម ដើម្បីជម្រុញឱ្យមាន ការចូលរួមពីអ្នកពាក់ព័ន្ធនានា ។ នេះគឺជា ដំណើរការ ដែលធ្វើឡើងជាវដ្ត ។ ម៉ូឌុលបន្តបន្ទាប់ពន្យល់ពីឧបករណ៍ផ្សេងៗ ។ ម៉ូឌុលទី ២ ពិនិត្យលើ ការវិភាគអ្នកពាក់ព័ន្ធ ម៉ូឌុលទី ៣ ការវាយតម្លៃ ជនបទដោយមានការចូលរួម ម៉ូឌុលទី ៤ ការ ពិនិត្យតាមដាន និងការវាយតម្លៃដោយមានការ ចូលរួម ម៉ូឌុលទី ៥ ការវាយតម្លៃអ្នកទទួលផល និងម៉ូឌុលទី ៦ SARAR (ការផ្តល់តម្លៃឱ្យខ្លួនឯង ចំណុចខ្លាំង ភាពមានធនធាន ការរៀបចំផែនការ សកម្មភាព និងការទទួលខុសត្រូវ) ។ | World Bank. 1998. Participation and Social Assessment: Tools and Techniques. Washington, DC. http://gametlibrary.worldbank.org/FILES/216_Guidelines%20for%20participation%20&%20social%20assessment%20-%20World%20Bank.pdf |

| | | |
|---|---|---|
| **មគ្គុទេសក៍ស្តីពីការវាយតម្លៃភាព ក្រីក្រដោយមានការចូលរួមការ ណែនាំអំពីទ្រឹស្តី និងការអនុវត្ត** | ការវាយតម្លៃភាពក្រីក្រ ដោយមានការចូលរួម (PPA) គឺឧបករណ៍មួយ ដើម្បីដាក់បញ្ចូលទស្សនៈ យល់ឃើញរបស់ប្រជាពលរដ្ឋក្រីក្រទៅក្នុងការ វិភាគភាពក្រីក្រ ការបង្កើតនូវអន្តរាគមន៍សម្រាប់កាត់បន្ថយភាពក្រីក្រ ការវាយតម្លៃលើផលប៉ះ ពាល់របស់គម្រោង និងគោលនយោបាយ និងនៅក្នុងការបង្កើតយុទ្ធសាស្រ្តដើម្បីកាត់បន្ថយភាពក្រីក្រ តាមរយៈគោលនយោបាយសាធារណៈ ។ មគ្គុទេសក៏នេះជួយធ្វើការវាយតម្លៃពេលដែល **PPA** នឹងមានប្រយោជន៍កន្លែងដែលត្រូវធ្វើការ វាយតម្លៃបែបនេះ របៀបរៀបចំដំណើរការ របៀបធ្វើឱ្យមានគុណភាពនៅក្នុងការងារនៅមូលដ្ឋាន និងការវិភាគនានា និងរបៀបធានា ឱ្យមានឥទ្ធិពលលើគោលនយោបាយ ។ | Overseas Development Institute. 2001. A Rough Guide to PPAs: Participatory Poverty Assessment – An Introduction to Theory and Practice. London. www.odi.org.uk/resources/details.asp?id=1747&title=rough-guide-ppas-participatory-poverty-assessment-introduction-theory-practice |
| **ឧបករណ៍ស្តីពីការវាយតម្លៃដោយ មានការចូលរួមនៅក្នុង ប្រតិបត្តិការ** | ឧបករណ៍នេះរៀបរាប់ពីជំហាននានា ដើម្បីផ្តល់ការណែនាំអំពីការវាយតម្លៃ ដោយមានការចូលរួម : ការពិនិត្យឡើងវិញលើព័តិមានដែលមានស្រាប់ ការរៀបចំផែនទីបង្ហាញពីចម្រុះភាព ការប្រើប្រាស់វិធីសាស្រ្តស្រាវជ្រាវ (ឧ. ការសង្កេតដោយមានការចូលរួម ការពិភាក្សា ដោយមានការរៀបចំខ្លះ ការពិភាក្សាក្រុមគោលដៅ ការជ្រើសរើសប្រធានបទ ការសម្របសម្រួលការពិភាក្សា ការធ្វើឱ្យព័តិមានដែល ប្រមូលបានមានលក្ខណៈជាប្រព័ន្ធ ការប្រើប្រាស់ សកម្មភាពតាមដានបន្ត ការប្រើប្រាស់ការវិភាគ គ្រប់ជ្រុងជ្រោយ និងការដាក់អាទិភាព ការកត់ កំណត់ហេតុកិច្ចប្រជុំ និងការរៀបចំសិក្ខាសាលា រៀបចំផែនការ ដោយមានការចូលរួម ។ | UNHCR. 2006. Tool for Participatory Assessment in Operations. http://www.unhcr.org/450e963f2.html |
| **ប្រអប់ឧបករណ៏របស់សហគមន៏ : គំនិតវិធីសាស្រ្ត និងឧបករណ៏សម្រាប់ធ្វើការប៉ាន់ប្រមាណ ពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួមនៅក្នុងសហគមន៏ព្រៃឈើ** | ប្រអប់ឧបករណ៏នេះចងក្រងគ្រប់ជ្រុងជ្រោយអំពី វិធីសាស្រ្ត និងឧបករណ៏ប៉ាន់ប្រមាណ និងពិនិត្យ តាមដាន និងវាយតម្លៃ ដោយមានការចូលរួម (ដែលរៀបចំឡើង សម្រាប់គម្រោងសហគមន៏ព្រៃឈើប៉ុន្តែអាចអនុវត្តបាន នៅក្នុងគ្រប់វិស័យទាំងអស់) ។ ប្រអប់ឧបករណ៏នេះរៀបរាប់ពី ដំណើរការជាជំហាន១ សម្រាប់ការប៉ាន់ប្រមាណ និងពិនិត្យតាមដាន និងវាយតម្លៃ ដោយមានការ ចូលរួម និងមានរំលេចពីឧបករណ៏ដែលមានប្រយោជន៏ចំនួន ២៣ ដូចជា: កិច្ចប្រជុំក្រុម, ការគូសរូប និងការពិភាក្សា, ការបង្កើតផែនទីបង្ហាញពីប្រវត្តិកន្លងមក, ការដាក់ចំណាត់ថ្នាក់ ការដាក់ពិន្ទុ និងការរៀបតាមលំដាប់លំដោយ, ការវាយតម្លៃបរិស្ថាននៅសហគមន៏ និងការស្រាវជ្រាវដោយមានការចូលរួម ។ | FAO. 1990. The Community's toolbox: The idea, methods and tools for participatory assessment, monitoring and evaluation in community forestry. Rome. www.fao.org/docrep/x5307e/x5307e00.htm |
| **មគ្គុទេសក៏ស្តីពីសកម្មភាព PISA : ឧបករណ៏ជម្រុញដោយសហគមន៏ សម្រាប់ធ្វើការប្រមូល ទិន្នន័យ និងធ្វើសេចក្តីសម្រេចចិត្ត** | មគ្គុទេសក៏នេះបង្ហាញ និងពន្យល់ពីគោលគំនិត និងយុទ្ធសាស្រ្តសម្រាប់ធ្វើការសម្រេចចិត្ត ផ្អែកតាមព័តិមាន និងទិន្នន័យត្រឹមត្រូវហើយក្នុងពេលជាមួយគ្នា ផ្តល់ភាពអង់អាចដល់អ្នកពាក់ព័ន្ធសំខាន់ៗ នៅក្នុងដំណើរការនេះ ។ មគ្គុទេសក៏នេះ រៀបរាប់ពីគោលវិធីវាយតម្លៃលើប្រព័ន្ធព័តិមាន ដោយមានការចូលរួម **(PISA)** ដែលប្រើ ប្រាស់ឧបករណ៏វាយតម្លៃជនបទដោយមានការចូលរួម **(PRA)** និងប្រើប្រាស់បច្ចេកវិទ្យាព័តិមាន និងទំនាក់ទំនងដែលមានស្រាប់ ។ | PACT. 2004. The PISA Action Guide: Community-Driven Tools for Data Collection and Decision Making. Washington, DC. http://pactworld.org/galleries/resource-center/pisa_action_guide.pdf |

| | | |
|---|---|---|
| **កញ្ចប់ឧបករណ៍ស្ដីពីវិធីសាស្ត្រ ដែលមានការចូលរួម : សៀវភៅណែនាំសម្រាប់អ្នកអនុវត្តការងារ** | សៀវភៅណែនាំនេះ គឺជាឧបករណ៍អនុវត្តផ្ទាល់មួយ សម្រាប់ចាប់ផ្ដើម និងគ្រប់គ្រងគម្រោង ដោយមានការចូលរួម ។ សៀវភៅណែនាំនេះមាន វិធីសាស្ត្រដែលមានការចូលរួមស៊ីជម្រៅចំនួន ១៣ និងមានរៀបរាប់ពីវិធីសាស្ត្រចំនួន ៥០ ផ្សេងទៀត ។ | King Baudouin Foundation and Flemish Institute for Science and Technology Assessment. 2005. Participatory Methods Toolkit. A Practitioner's Manual. www.kbs-frb.be/uploadedFiles/KBS-FRB/Files/EN/PUB_1540_Participatoty_toolkit_New_edition.pdf |

## ការបង្កើតផែនការស្ដីពីការចូលរួម (ឧបករណ៍ទី ៤)

**សូមមើលឧបករណ៍ខាងលើ :**

